ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ បាត់ដំបង

# កិច្ចតែងការបង្រៀន

# សីលធម៌ - ពលរដ្ឋវិជ្ជា

## ថ្នាក់ទី ៧

រៀបរៀងដោយ គរុសិស្សជំនាន់ទី២៤ ឆ្នាំសិក្សា ២០១២ - ២០១៤

ស្របតាមកម្មវិធីសិក្សាថ្មី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ បាត់ដំបង

# កិច្ចតែងការបង្រៀន

# សីលធម៌ - ពលរដ្ឋវិជ្ជា

## ថ្នាក់ទី ៧

រៀបរៀងដោយ គរុសិស្សជំនាន់ទី២៥ ឆ្នាំសិក្សា ២០១២ - ២០១៤

*ស្របតាមកម្មវិធីសិក្សាថ្មី*

# មាតិកា


**ជំពូក ១ : យេនឌ័រ និងសិទ្ធិមនុស្ស**

1. ភេទ និង យេនឌ័រ
2. ផ្នត់គំនិត
3. យេនឌ័រ និងផ្នត់គំនិត
4. ការរើសអើង និងបញ្ហាផ្លូវចិត្ត
5. ការបំបាត់ចោលការរើសអើងចំពោះស្ត្រី
6. វិធានការធានាសមភាពយេនឌ័រ

**ជំពូក ២ : មិត្តភាព**

1. លក្ខណៈមិត្តភាព
2. ការរក្សាមិត្តភាព
3. សារៈសំខាន់នៃមិត្តភាពល្អ

**ជំពូក ៣ : គ្រួសារ**

1. ប្រភេទគ្រួសារ
2. សុភមង្គលគ្រួសារ
3. វិធីកសាងសុភមង្គលគ្រួសារ

**ជំពូក ៤ : ការរស់នៅជាមួយសហគមន៍**

1. ការបោះឆ្នោត
2. តួនាទីនិងភារកិច្ចរបស់តំណាងសិស្ស
3. ដំណើរការនៃការបោះឆ្នោត
4. លក្ខខណ្ឌនៃការឈរឈ្មោះជាបេក្ខជន
5. ការចូលរួមបោះឆ្នោត
6. លក្ខណៈសម្បត្តិនៃអ្នកជាប់ឆ្នោត

**ជំពូក ៥ : ការកំណត់គោលដៅជីវិត**

1. ការជ្រើសរើសអាជីព
2. សារៈសំខាន់នៃការជ្រើរើសអាជីព
3. ព័ត៌មានអំពីអាជីព

# កិច្ចតែងការបង្រៀន

- កាលបរិច្ឆេទ : ថ្ងៃ ទី ខែ ឆ្នាំ
- មុខវិជ្ជា : សីលធម៌-ពលរដ្ឋវិជ្ជា
- **ជំពូកទី១ : យេនឌ័រ និង សិទ្ធិមនុស្ស**
- **មេរៀនទី១ : ភេទ និង យេនឌ័រ**
- ថ្នាក់ទី : ៧
- វិធីសាស្ត្របង្រៀន : គោលវិធីសិស្សមជ្ឈមណ្ឌល (ពិភាក្សាក្រុម)
- រយៈពេល : ១ម៉ោងសិក្សា

## I. **វត្ថុបំណង**

- ចំណេះដឹង : ពណ៌នាពីភេទ និងយេនឌ័រ បានត្រឹមត្រូវតាមរយៈការសិក្សាអត្ថបទ
- បំណិន : ប្រៀបធៀបពីភេទ និងយេនឌ័រ បានយ៉ាងត្រឹមត្រូវតាមរយៈការពិភាក្សាក្រុម
- ឥរិយាបថ : បណ្តុះស្មារតីសិស្សឱ្យយល់ច្បាស់ពីភេទ និងយេនឌ័រដើម្បីសម្រាប់ការរស់នៅក្នុងសង្គម

## II. **ខ្លឹមសារមេរៀន**

1. **ភេទ**
2. **យេនឌ័រ**

## III. **សម្ភារឧបទេស**

- សៀវភៅសិក្សាសង្គមថ្នាក់ទី៧ ថ្មី (សិស្ស) ទំព័រ ១៥១-១៥៣ បោះពុម្ពឆ្នាំ ២០១១
- ប័ណ្ណសំណួរ
- ផ្ទាំងមេរៀនសង្ខេប

## IV. ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
| --- | --- | --- |
| – សណ្តាប់ធ្នាប់ អនាម័យ<br>អវត្តមាន | **ជំហានទី១**<br>(រដ្ឋបាលថ្នាក់)<br>• សណ្តាប់ធ្នាប់<br>• អនាម័យ<br>• អវត្តមាន<br>• ពង្រឹងវិន័យ | –ប្រធានថ្នាក់ឡើងរាយការណ៍។ |
| - តើប្អូនមានភេទអ្វី?<br><br><br>–តើប្អូនមានបងប្អូនប៉ុន្មាននាក់?<br>–ប្រុសប៉ុន្មានស្រីប៉ុន្មាន?<br>–តើប្អូនសម្គាល់ពួកគេជាប្រុសឬជាស្រីត្រង់ចំណុចណា?<br>–តើពួកគេមានភារកិច្ចដូចគ្នាឬខុសគ្នា? | **ជំហានទី២**<br>(រំឭកមេរៀនចាស់)<br>- ប្រុស ឬ ស្រី<br><br><u>ទំនាក់ទំនងមេរៀនថ្មី</u><br>–2 3 4 5 នាក់<br>–ប្រុស2 ស្រី2 ស្រី1 ប្រុស3<br>–សក់វែង ឬខ្លី សំឡេង ភេទ ភិនភាគ...។<br>–ដូចគ្នា / ខុសគ្នា។ | –ប្រុស ស្រី<br><br><br>–2 3 4 5 នាក់<br>–ប្រុស2 ស្រី2 ស្រី1 ប្រុស3<br>–សក់វែង ឬខ្លី សំឡេង ភេទ ភិនភាគ ខ្ពស់ ឬទាប...។<br>–ដូចគ្នា / ខុសគ្នា។ |
| –ឱ្យសិស្សបើកសៀវភៅទំព័រ ១៥១<br>–តើចំណងជើងនេះមានន័យដូចម្តេច?<br><br>–តើប្អូនឃើញមានអ្វីខ្លះនៅក្នុងរូបភាពនេះ?<br>–តើរូបភាពនេះចង់បង្ហាញពីអ្វី?<br><br>–តើរូបភាពនិងចំណងជើងមានទំនាក់ទំនងគ្នាដែរឬទេ?ព្រោះអ្វី? | **ជំហានទី៣**<br>(មេរៀនប្រចាំថ្ងៃ)<br>**ជំពូកទី១:**<br>**យេនឌ័រ និង សិទ្ធិមនុស្ស**<br><br>–ភេទ និងតួនាទី និងអ្វីៗដែលមនុស្សអាចធ្វើបាន។<br><br>–គ្រូពេទ្យ គ្រូបង្រៀន ជាងឈើ សិស្ស...។<br>– ពីតួនាទី និងសេរីភាពដែល បុគ្គលម្នាក់ៗមាន<br>–មានទំនាក់ទំនង ព្រោះរូបភាពបង្ហាញពីសិទ្ធិសេរីភាពក្នុងការប្រកបមុខរបរត្រូវជាមួយចំណងជើង | <br><br><br><br><br>–ចំណងជើងនេះមានន័យថា ភេទ និងតួនាទី និងអ្វីៗដែលមនុស្សអាចធ្វើបាន។<br>–គ្រូពេទ្យ គ្រូបង្រៀន ជាងឈើ សិស្ស...។<br>–បង្ហាញពីតួនាទី និងសេរីភាពដែលបុគ្គលម្នាក់ៗមាន។<br>–មានទំនាក់ទំនង ព្រោះរូបភាពបង្ហាញពីសិទ្ធិសេរីភាពក្នុងការប្រកបមុខរបរត្រូវជាមួយចំណងជើង" |

| | | |
|---|---|---|
| | ”យេនឌ័រ និងសិទ្ធិមនុស្ស” | យេនឌ័រ និងសិទ្ធិមនុស្ស” |
| -ឱ្យសិស្សអានខ្លឹមសារជំពូក ទំព័រទី ១៥១ | **មេរៀនទី ១** :<br>**ភេទ និង យេនឌ័រ** | -សិស្សអានតាមការណែនាំ |
| -ឱ្យសិស្សបើកសៀវភៅទំព័រ ១៥២ អានចំណងជើងមេរៀន រួចគ្រូសរសេរដាក់លើក្ដារខៀន | | -សិស្សសរសេរចំណងជើងមេរៀនដាក់ក្នុងសៀវភៅ |
| -តើចំណងជើងមេរៀនមានន័យដូចម្ដេច? | -មានន័យថាតួនាទី ភេទ និងភារកិច្ចរបស់មនុស្សយើងម្នាក់ៗ ។ | - ចំណងជើងមេរៀនមានន័យថាតួនាទី ភេទ និងភារកិច្ចរបស់មនុស្សយើងម្នាក់ៗ។ |
| -តើប្អូនឃើញមានអ្វីខ្លះនៅក្នុងរូបភាពនេះ? | -ឃើញយុវជនម្នាក់ យុវនារីម្នាក់កំពុងប្រើប្រាស់កុំព្យូទ័រ។ | -ឃើញយុវជនម្នាក់ យុវនារីម្នាក់កំពុងប្រើប្រាស់កុំព្យូទ័រ។ |
| -តើចំណងជើងនិងរូបភាពមានទំនាក់ទំនងគ្នាដែរឬទេ?ព្រោះអ្វី? | -មានទំនាក់ទំនងគ្នា ព្រោះរូបភាពបង្ហាញពីយុវជន យុវនារីធ្វើការងារបានដូចគ្នា ឯចំណងជើង "ភេទ និង យេនឌ័រ”។ | -មានទំនាក់ទំនងគ្នាព្រោះរូបភាពបង្ហាញពីយុវជន យុវនារីធ្វើការងារបានដូចគ្នា ឯចំណងជើង "ភេទ និង យេនឌ័រ” ។<br>-សិស្សអានបណ្ដាក់គ្នា |
| -ឱ្យសិស្សអានខ្លឹមសារមេរៀនទំព័រ ១៥២-១៥៣បណ្ដាក់គ្នា<br>-គ្រូសរសេរពាក្យពិបាកដាក់លើក្ដារខៀន | **ពន្យល់ពាក្យ** | |
| | -បញ្ញា : ការចេះដឹង ឬចំណេះដឹងដែលទទួលបានពីការរៀន<br>-វប្បធម៌ : ការសាបព្រោះនូវចំណេះដឹង<br>-ភារកិច្ច : កិច្ចការដែលត្រូវធ្វើ | -សិស្សឡើងពន្យល់ន័យ<br>-បញ្ញា : ការចេះដឹង ឬចំណេះដឹងដែលទទួលបានពីការរៀន។<br>-វប្បធម៌ : ការសាបព្រោះនូវចំណេះដឹង។<br>-ភារកិច្ច : កិច្ចការដែលត្រូវធ្វើ |
| -គ្រូកែសម្រួលឱ្យសិស្សកត់ | -ឥរិយាបថ : ដំណើរដេកដើរឈរអង្គុយ | -ឥរិយាបថ : ដំណើរដេកដើរឈរអង្គុយ។<br>-សិស្សកត់ចូលសៀវភៅ |
| -គ្រូបែងចែកសិស្សជា៤ក្រុមៈ | **ពិភាក្សាក្រុម** | -សិស្សចូលតាមក្រុមពិភាក្សា |

| | | |
|---|---|---|
| –**ក្រុមទី១+២**:តើភេទសំដៅទៅលើអ្វី?<br><br>–**ក្រុមទី៣+៤**:យេនឌ័រជាអ្វី? តើយើងអាចផ្លាស់ប្តូរបានដែរឬទេ?<br><br>–គ្រូសំយោគចម្លើយឱ្យសិស្សកត់ចូលសៀវភៅ<br>–គ្រូឱ្យសិស្សទាញមេរៀនសង្ខេប<br><br>–គ្រូឱ្យសិស្សកត់ | –ភេទសំដៅទៅលើភាពខុសគ្នាតាមធម្មជាតិខាងជីវសាស្ត្រដែលគេអាចសម្គាល់មនុស្សណាម្នាក់ជាប្រុស ឬស្រីហើយភេទសំដៅយកលក្ខណៈរូបរាងកាយរបស់មនុស្សម្នាក់ៗ សរីរាង្គបន្តពូជ មុខមាត់។<br><br>-ជាការកំណត់របស់គ្រួសារ សហគមន៍ និងសង្គម<br>-ការបែងចែកការងារ អប់រំ សិទ្ធិ អំណាច ឋានៈ  និងតួនាទីដល់បុរស ស្ត្រី ។<br>-អាចផ្លាស់ប្តូរបាន ព្រោះវាមានលក្ខណៈសង្គម មិនមែនពីកំណើត<br><br>**មេរៀនសង្ខេប**<br><br>ភេទ និងយេនឌ័រមិនដូចគ្នាទេ ។ យេន ឌ័រ ជាអ្នកបែងចែកឋានៈ ការងារតួនាទី ដល់បុរសនិងស្ត្រី។ យេនឌ័រ អាចផ្លាស់ ប្តូរបាន ព្រោះវាមានលក្ខណៈសង្គម មិនមែនពីកំណើត។ | –ភេទសំដៅទៅលើភាពខុសគ្នាតាមធម្មជាតិខាងជីវសាស្ត្រដែលគេអាចសម្គាល់មនុស្សណាម្នាក់ជាប្រុស<br>ឬស្រីហើយភេទសំដៅយកលក្ខណៈរូបរាងកាយរបស់មនុស្សម្នាក់ៗ សរីរាង្គបន្តពូជ មុខមាត់។<br><br>–យេនឌ័រជាការកំណត់របស់គ្រួសារ សហគមន៍ និងសង្គម ពាក់ព័ន្ធនិងការបែងចែកការងារ ការអប់រំសិទ្ធិអំណាច ឋានៈ និងតួនាទីដល់កូនប្រុសស្រី និងបុរសស្ត្រី។ យេនឌ័រអាចផ្លាស់ប្តូរបាន ព្រោះវានមានលក្ខណៈសង្គម និងមិនមែនពីកំណើត ។<br>–សិស្សកត់ចូលសៀវភៅ<br><br>–សិស្សទាញមេរៀនសង្ខេប<br><br>–សិស្សកត់ចូលសៀវភៅ |
| –តើភេទសំដៅលើអ្វី? | **ជំហានទី៤**<br>(ពង្រឹងពុទ្ធិ)<br>––ភេទសំដៅលើលក្ខណៈរូបរាងកាយ និងសរីរាង្គបន្តពូជ ភិនភាគ និងមុខមាត់។ | –ភេទសំដៅលើលក្ខណៈរូបរាងកាយ និងសរីរាង្គបន្តពូជ ភិនភាគ និងមុខមាត់។ |

| | | |
|---|---|---|
| –តើភេទ និងយេនឌ័រខុសគ្នាដែរឬទេ? ព្រោះអ្វី? | –ភេទ និងយេនឌ័រខុសគ្នាព្រោះ ភេទសំដៅលើលក្ខណៈរូបរាងកាយ និងសរីរាង្គ ឯយេនឌ័រសំដៅលើតួនាទី ភារកិច្ច និងទំនួលខុសត្រូវរបស់បុរសស្ត្រីដោយឡែកពីគ្នា។ | –ភេទ និងយេនឌ័រខុសគ្នាព្រោះ ភេទសំដៅលើលក្ខណៈរូបរាងកាយ និងសរីរាង្គ ឯយេនឌ័រសំដៅលើតួនាទី ភារកិច្ច និងទំនួលខុសត្រូវរបស់បុរសស្ត្រីដោយឡែកពីគ្នា។ |
| –ចូរប្អូនពន្យល់ពាក្យ៖ វិចារណញាណ លក្ខខណ្ឌ បុរេនិច្ឆ័យ។<br>–មេរៀនយើងចប់ហើយទៅផ្ទះវិញកុំភ្លេចមើលមេរៀនឡើងវិញផង និងជួយធ្វើកិច្ចការផ្ទះផង។ | **ជំហានទី៥**<br>(បណ្តាំផ្ញើ)<br>ពន្យល់ពាក្យ<br>– វិចារណញាណ លក្ខខណ្ឌ និង បុរេនិច្ឆ័យ ។ | –សិស្សស្តាប់តាមការណែនាំរបស់គ្រូដោយយកចិត្តទុកដាក់ និងត្រៀមអនុវត្តតាម។ |

# កិច្ចតែងការបង្រៀន

- កាលបរិច្ឆេទ : ថ្ងៃ ទី ខែ ឆ្នាំ
- មុខវិជ្ជា : សីលធម៌-ពលរដ្ឋវិជ្ជា
- ថ្នាក់ទី : ៧
- **ជំពូក ១** : **យេនឌ័រ និង សិទ្ធិមនុស្ស**
- **មេរៀនទី២** : **ផ្លូវគំនិត**
- វិធីសាស្ត្របង្រៀន : គោលវិធីសិស្សមជ្ឈមណ្ឌល (វិធីចោទឆ្លើយ)
- រយៈពេល : ១ម៉ោងសិក្សា

## I. វត្ថុបំណង

- ចំណេះដឹង : រៀបរាប់ពីសុខភាព ចិត្តគំនិត និងផ្លូវគំនិត ត្រឹមត្រូវតាមរយៈការសិក្សាអត្ថបទ
- បំណិន : វែកញែកពីសុខភាព ចិត្តគំនិត និងផ្លូវគំនិត ត្រឹមត្រូវតាមរយៈសំណួរចោទឆ្លើយ
- ឥរិយាបថ : បណ្តុះស្មារតីសិស្សឱ្យកែប្រែផ្លូវគំនិត

## II. ខ្លឹមសារមេរៀន

1. **សុខភាព និងចិត្តគំនិត**
2. **ផ្លូវគំនិត**

## III. សម្ភារឧបទេស

- សៀវភៅសិក្សាសង្គមថ្នាក់ទី៧ ថ្មី (សៀវភៅសិស្ស) ទំព័រ ១៥៤-១៥៥ បោះពុម្ពឆ្នាំ ២០១១
- ប័ណ្ណសំណួរ
- ផ្ទាំងមេរៀនសង្ខេប

IV. **ដំណើរការបង្រៀន**

| **សកម្មភាពគ្រូ** | **ខ្លឹមសារមេរៀន** | **សកម្មភាពសិស្ស** |
|---|---|---|
| -ពិនិត្យលើៈ សណ្តាប់ធ្នាប់ អនាម័យ អវត្តមាន។ | **ជំហានទី១**<br>(រដ្ឋបាលថ្នាក់)<br>• សណ្តាប់ធ្នាប់<br>• អនាម័យ<br>• អវត្តមាន<br>• ពង្រឹងវិន័យ | -ប្រធានថ្នាក់ឡើងរាយការណ៍។ |
| -តើយេនឌ័រជាអ្វី?<br><br><br><br><br>-តើភេទ និងយេនឌ័រខុសគ្នាដែរឬទេ?<br><br><br><br><br><br><br>-តើប្អូនធ្លាប់ដឹងពីផ្នត់គំនិតដែរឬទេ?<br>-តើមនុស្សគ្រប់រូបមានផ្នត់គំនិតដូចគ្នាដែរឬទេ? | **ជំហានទី២**<br>(រំឭកមេរៀនចាស់)<br>-យេនឌ័រជាការកំណត់របស់គ្រួសារ សហគមន៍ពាក់ព័ន្ធព្រមទាំងការបែងចែកការងារអប់រំសិទ្ធិអំណាច ឋានៈ និងតួនាទីបុរសស្ត្រី ។<br><br>-ខុសគ្នា ព្រោះភេទសំដៅលើ លក្ខណៈរូបរាងកាយ មុខមាត់សរីរាង្គ ឯយេនឌ័រ សំដៅ លើតួនាទីភារកិច្ចនិងទំនួលខុសត្រូវ របស់បុរសស្ត្រីដោយឡែកពីគ្នា។<br><br>**<u>ទំនាក់ទំនងមេរៀនថ្មី</u>**<br>-ធ្លាប់ / មិនធ្លាប់<br><br>-ដូច / មិនដូច | -យេនឌ័រជាការកំណត់របស់ គ្រួសារ សហគមន៍ពាក់ព័ន្ធព្រម ទាំងការបែងចែកការងារអប់រំសិទ្ធិអំណាច ឋានៈ និងតួនាទីបុរសស្ត្រី ។<br>-ខុសគ្នា ព្រោះភេទសំដៅលើលក្ខណៈរូបរាងកាយ មុខមាត់សរីរាង្គ ឯយេនឌ័រ សំដៅលើតួនាទីភារកិច្ច និងទំនួលខុសត្រូវរបស់បុរសស្ត្រី ដោយឡែកពីគ្នា ។<br><br><br>-ធ្លាប់ / មិនធ្លាប់<br><br>-ដូច / មិនដូច |
| -ឱ្យសិស្សបើកសៀវភៅទំព័រ ១៥៤ អានចំណងជើងមេរៀន រួចគ្រូសរសេរដាក់លើក្តារខៀន<br>-តើចំណងជើងមេរៀននេះមានន័យដូចម្តេច? | **ជំហានទី៣**<br>(មេរៀនប្រចាំថ្ងៃ)<br>**មេរៀនទី២ : ផ្នត់គំនិត**<br>1. សុខភាព និងចិត្តគំនិត<br>2. ផ្នត់គំនិត<br><br>-គំនិតលម្អៀង ឬទម្រង់នៃការគិតយល់ ឃើញណាមួយដែលជិតជាប់ | -សិស្សសរសេរចំណងជើងមេរៀន ដាក់ក្នុងសៀវភៅ<br><br>-ចំណងជើងមេរៀននេះមានន័យថា គំនិតលម្អៀង ឬទម្រង់នៃការគិត |

| | | |
|---|---|---|
| | អារម្មណ៍របស់មនុស្ស | យល់ឃើញណាមួយដែលជិតជាប់អារម្មណ៍របស់មនុស្ស ។ |
| –ឱ្យសិស្សអានខ្លឹមសារមេរៀន ទំព័រ ១៥៤-១៥៥ | -ទំព័រ ១៥៤-១៥៥ | –សិស្សអានខ្លឹមសារមេរៀន |
| | **ពន្យល់ពាក្យ** | |
| –គ្រូសរសេរពាក្យពិបាកដាក់លើក្តារខៀន រួចឱ្យសិស្សឡើងពន្យល់ | –បុរេនិច្ឆ័យ : ការយល់ឃើញដោយមិនបានពិចារណា ។<br>–វិវត្ត : ប្រែប្រួល។<br>–សមត្ថភាព : ភាពដែលអាចធ្វើទៅបាន។ | –សិស្សឡើងពន្យល់ន័យ<br>–បុរេនិច្ឆ័យ : ការយល់ឃើញដោយមិនបានពិចារណា។<br>–វិវត្ត : ប្រែប្រួល។<br>–សមត្ថភាព : ភាពដែលអាចធ្វើទៅបាន។ |
| –គ្រូសម្រួលឱ្យសិស្សកត់ | | –សិស្សកត់ចូលសៀវភៅ |
| | **សកម្មភាពចោទឆ្លើយ** | |
| –តើសុខភាពជាអ្វី? | –ជាភាពមានសេចក្តីសុខពេញលេញ ( កាយ ចិត្ត សង្គម ) មិនពិការ ។ | –សុខភាពគឺជាភាពមានសេចក្តីសុខពេញលេញផ្នែកសម្បទា ផ្លូវកាយ ចិត្ត និងផ្នែកសង្គមមិនមែនគ្រាន់ តែគ្មានជំងឺ ឬពិការឡើយ ។ |
| –ដូចម្តេចដែលហៅថាសុខភាពផ្លូវចិត្ត? | – គឺការធ្វើឱ្យមនុស្សមានអារម្មណ៍ស្រស់ថ្លា មានអាកប្បកិរិយា និងទំនាក់ទំនងល្អជាមួយអ្នកនៅជុំវិញខ្លួន ។ | –ដែលហៅថាសុខភាពផ្លូវចិត្តគឺការធ្វើឱ្យមនុស្សមានអារម្មណ៍ស្រស់ថ្លា មានអាកប្បកិរិយានិងទំនាក់ទំនងល្អជាមួយអ្នកនៅជុំវិញខ្លួន ។ |
| –តើផ្នត់គំនិតជាអ្វី? | –ផ្នត់គំនិតជាបុរេនិច្ឆ័យ ឬជំនឿតៗគ្នាការពូជដែលៗ និងការយល់ឃើញដែលបានបង្កើតឡើងដោយសង្គមធម៌របស់ខ្លួន ។ | – ផ្នត់គំនិតជាបុរេនិច្ឆ័យឬជំនឿតៗគ្នាការពូជដែលៗ និងការយល់ឃើញដែលបានបង្កើតឡើងដោយសង្គមធម៌របស់ខ្លួន ។ |
| –គ្រូសំយោគចម្លើយឱ្យសិស្សកត់ចូលសៀវភៅ | | –សិស្សកត់ចូលសៀវភៅ |
| | **មេរៀនសង្ខេប** | |

| | | |
|---|---|---|
| –ដឹកនាំសិស្សសាកល្បងសង្ខេបមេរៀន<br><br>–ឱ្យសិស្សកត់ចូលសៀវភៅ | សុខភាពផ្លូវចិត្តល្អធ្វើឱ្យមនុស្សមានអារម្មណ៍ល្អ ប្រាជ្ញាល្អមានសេចក្តីសុខ មានសមត្ថភាពបំពេញការងារផ្សេងៗ។ ផ្នត់គំនិតជាទម្រង់នៃការយល់ ឃើញ ដែលជិតដាមនៅក្នុងអារម្មណ៍មនុស្ស តាមការកំណត់របស់សង្គមវប្បធម៌។ វាមានតម្លៃវិជ្ជមាន ឬអវិជ្ជមានតាមកាលៈទេសៈសង្គម ។ | –សិស្សសាកល្បងសង្ខេបមេរៀន<br><br>–សិស្សកត់ចូលសៀវភៅ |
| –តើអ្វីទៅជាសុខភាពផ្នែកផ្លូវចិត្ត?<br><br>–តើផ្នត់គំនិតអាចផ្លាស់ប្តូរ ឬកែប្រែបានដែរឬទេ? | **ជំហានទី៤**<br>(ពង្រឹងពុទ្ធិ)<br>–សុខភាពផ្លូវចិត្តល្អធ្វើឱ្យមនុស្សមានអារម្មណ៍ល្អ ប្រាជ្ញាល្អមានសេចក្តីសុខ មានសមត្ថភាពបំពេញការងារផ្សេងៗ ។<br><br>–ផ្នត់គំនិតអាចផ្លាស់ប្តូរបានទៅតាមអារម្មណ៍ ឬការគិតរបស់បុគ្គលម្នាក់ៗនិងសង្គមវប្បធម៌។ | –សុខភាពផ្លូវចិត្តល្អធ្វើឱ្យមនុស្សមានអារម្មណ៍ល្អ ប្រាជ្ញាល្អមានសេចក្តីសុខ មានសមត្ថភាព បំពេញការងារផ្សេងៗ ។<br><br>–ផ្នត់គំនិតអាចផ្លាស់ប្តូរបានទៅតាមអារម្មណ៍ ឬការគិតរបស់បុគ្គលម្នាក់ៗនិងសង្គមវប្បធម៌។ |
| –ចូរប្អូនពន្យល់ពាក្យៈ ឧត្តម សេដ្ឋកិច្ច សង្គមកិច្ច។<br>–មេរៀនយើងចប់ហើយទៅផ្ទះវិញកុំភ្លេចមើលមេរៀនឡើងវិញផង និងជួយធ្វើកិច្ចការផ្ទះផង។ | **ជំហានទី៥**<br>(កិច្ចការផ្ទះ ឬបណ្តាំផ្ញើ)<br>–ឧត្តម<br>សេដ្ឋកិច្ច<br>សង្គមកិច្ច | –សិស្សកត់កិច្ចការយកទៅធ្វើនៅផ្ទះ។<br>–សិស្សស្តាប់តាមការណែនាំរបស់គ្រូដោយយកចិត្តទុកដាក់ និងត្រៀមអនុវត្តតាម ។ |

# កិច្ចតែងការបង្រៀន

- ❖ កាលបរិច្ឆេទ : ថ្ងៃ ទី ខែ ឆ្នាំ
- ❖ មុខវិជ្ជា : សីលធម៌ ពលរដ្ឋវិជ្ជា
- ❖ ថ្នាក់ទី : ៧
- ❖ **ជំពូកទី១ : យេនឌ័រ និងសិទ្ធិមនុស្ស**
- ❖ **មេរៀនទី៣ : យេនឌ័រ និងផ្នត់គំនិត**
- ❖ វិធីសាស្រ្ត : គោលវិធីសិស្សមជ្ឈមណ្ឌល
- ❖ រយៈពេល : ១ ម៉ោងសិក្សា ( សម្រាប់ម៉ោងទី១ )

## I. **វត្ថុបំណង**

- ចំណេះដឹង : ប្រាប់ពីផ្នត់គំនិតរបស់សង្គមទាក់ទងទៅនិងយេនឌ័របានត្រឹមត្រូវ តាមរយៈការសិក្សាអត្ថបទ
- បំណិន : វិភាគអំពីផ្នត់គំនិតមនុស្សបច្ចុប្បន្ន ទាក់ទងទៅ និងយេនឌ័របានត្រឹមត្រូវតាមរយៈការពិភាក្សាក្រុម។
- ឥរិយាបថ : ស្រឡាញ់ចូលរួមគាំទ្រទៅលើសមភាព យេនឌ័រនៅក្នុងសង្គម ។

## II. **ខ្លឹមសារមេរៀន**

1. **ផ្នត់គំនិតសង្គមទាក់ទងយេនឌ័រ**

## III. **សម្ភារឧបទេស**

-សៀវភៅសិក្សាសង្គមថ្នាក់ទី៧ ថ្មី (សៀវភៅសិស្ស) ទំព័រ ១៥៦,១៥៧ បោះពុម្ពឆ្នាំ២០០៩

-ប័ណ្ណសំណួរ, ផ្ទាំងរូបភាព

IV. **ដំណើរការបង្រៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ពិនិត្យ អវត្តមាន សណ្តាប់ធ្នាប់ អនាម័យ វិន័យ | **ជំហានទី១**<br>(រដ្ឋបាលថ្នាក់) | -ប្រធានថ្នាក់ឡើងរាយការណ៍ |
| -តើផ្នត់គំនិតគឺជាអ្វី?<br><br>-តើគេអាចចែកផ្នត់គំនិតជាប៉ុន្មាន?<br><br>-តើភាពស្មើគ្នារវាងបុរស និងស្ត្រីក្នុងសង្គមគេហៅថាអ្វី? | **ជំហានទី២**<br>(រំលឹកមេរៀនចាស់)<br>**មេរៀនទី២: ផ្នត់គំនិត**<br><br>-ផ្នត់គំនិតគឺជាទម្រង់នៃការយល់ឃើញ ដែលជិតដាមនៅក្នុងអារម្មណ៍មនុស្សម្នាក់ៗទៅតាមការកំណត់របស់សង្គម និង វប្បធម៌ ។<br><br>-គេបែងចែកផ្នត់គំនិតជា ២គឺ៖<br>• ផ្នត់គំនិតវិជ្ជមាន<br>• ផ្នត់គំនិតអវិជ្ជមាន<br><br><u>ទំនាក់ទំនងមេរៀន</u><br>- យេនឌ័រ | - ផ្នត់គំនិតគឺជាទម្រង់នៃការយល់ឃើញ ដែលជិតដាមនៅក្នុងអារម្មណ៍ មនុស្សម្នាក់ៗទៅតាមការកំណត់របស់សង្គម និង វប្បធម៌ ។<br><br>-គេបែងចែកផ្នត់គំនិតជា ២គឺ៖<br>• ផ្នត់គំនិតវិជ្ជមាន<br>• ផ្នត់គំនិតអវិជ្ជមាន<br><br>- ហៅថា យេនឌ័រ |
| -ឱ្យសិស្សបើកសៀវភៅទំព័រ ១៥៦ អានចំណងជើងមេរៀន<br><br>-តើចំណងជើងរបស់យើងមានន័យដូចម្តេច?<br><br>-តើប្អូនឃើញអ្វីខ្លះនៅក្នុងរូបភាព? | **ជំហានទី៣**<br>(មេរៀនប្រចាំថ្ងៃ)<br>**មេរៀនទី៣:**<br>**យេនឌ័រ និងផ្នត់គំនិត**<br><br>**សិក្សាចំណងជើង**<br>-ភាពស្មើគ្នារវាង បុរស និងស្រីនៅក្នុងសង្គម។<br><br>**សិក្សារូបភាព**<br>- ពាងទឹក ធុងទឹក សត្វ ឆ្កែ សត្វឆ្មា កុមារាកំពុងរៀន កុមារីម្នាក់ កំពុង | -សិស្សធ្វើតាមការណែនាំ<br><br>-ចំណងជើងនេះចងនិយាយអំពីភាពស្មើគ្នារវាងបុរសនិងស្រីនៅក្នុងសង្គម។<br><br>-ឃើញមានពាងទឹកធុងទឹកសត្វឆ្កែ សត្វឆ្មា កុមារាកំពុងរៀនកុមារី |

| | | |
|---|---|---|
| | បំពេញ កិច្ចការផ្ទះ។ | ម្នាក់កំពុងបំពេញកិច្ចការផ្ទះ។ |
| -តើរូបភាពនេះចងបង្ហាញអំពីអ្វី? | **-ភាពមិនស្មើគ្នារវាងកុមារា និងកមារី ២នាក់ក្នុងគ្រួសារមួយដែលទទួលបាននូវឱកាសរៀនសូត្រ ធ្វើការងាររកស៊ី** | -រូបភាពនេះចង់បង្ហាញពីភាពមិនស្មើគ្នារវាងកុមារានិងកុមារីពីនាក់នៅក្នុងសង្គមគ្រួសារមួយ ដែលកុមារាទទួលបាននូវឱកាសក្នុងការរៀនសូត្ររីឯក្មេងស្រីបែរជាជំនួសវិញដោយការងារផ្ទះពុំបានសិក្សារៀនសូត្រ។ |
| -តើរូបភាពនិងចំណងជើងមានទំនាក់ទំនងគ្នាដែររឺទេ? ព្រោះអ្វី? | **ទំនាក់ទំនងរូបភាពនិងចំណងជើង**<br>-មានទំនាក់ទំនងគ្នាព្រោះចំណងជើងនិយាយពីយេនឌ័រនិងផ្ទត់គំនិត ឯរូបភាពវិញឆ្លុះបញ្ចាំងពីផ្នត់គំនិតមួយដែលទាក់ទងទៅ នឹងយេនឌ័រនៅក្នុងសង្គមគ្រួសារមួយ។ | -មានទំនាក់ទំនងគ្នាព្រោះ ចំណងជើងនិយាយពីយេនឌ័រ និងផ្នត់គំនិត ឯរូបភាពវិញឆ្លុះបញ្ចាំងពីផ្នត់គំនិតមួយដែលទាក់ទងទៅនឹងយេនឌ័រនៅក្នុងសង្គមគ្រួសារមួយ។ |
| -ឱ្យសិស្សអានខ្លឹមសារមេរៀនទំព័រទី១៥៦-១៥៧ | **ពន្យល់ពាក្យ**<br>-សមភាព (ន)<br>-សន្តិសុខស្បៀង (ន)<br><br>-ព័ត៌មាន(ន) | -សិស្សអានខ្លឹមសារមេរៀន<br>=ភាពស្មើគ្នា ។<br>=ការបំពេញបាននូវតម្រូវការផ្នែកស្បៀងអាហារឱ្យបានគ្រប់គ្រាន់មិនមានភាពខ្វះខាត។<br>=ដំណឹង ។ |
| -គ្រូកត់ពន្យល់ពាក្យដាក់នៅលើក្តារខៀន<br>- ពន្យល់នូវខ្លឹមសារមេរៀនដល់សិស្ស | | |
| -បែងចែកសិស្សជា៤ក្រុមពិភាក្សាៈ | **ពិភាក្សាក្រុម** | -ចូលតាមក្រុមពិភាក្សា |
| **-ក្រុមទី១:** តើនៅក្នុងគ្រួសារសហគមន៍ក្មេងប្រុសទទួលបាន | • ឱកាសរៀនសូត្រជ្រៅជ្រះ ការបំប៉នចំណីអាហារ | -នៅក្នុងគ្រួសារនិងសហគមន៍ក្មេងប្រុសទទួលបានឱកាស |

| | | |
|---|---|---|
| ឱកាសក្នុងការធ្វើអ្វីខ្លះ? | • ការទទួលដំណឹងឬព័ត៌មានផ្សេងៗបានយ៉ាងទូលំទូលាយ<br>• សេរីភាពនិងការរាប់អានមិត្ត<br>• ឱកាសក្នុងការក្លាយជាអ្នកដឹនាំនៅក្នុងគ្រួសារនិងសហគមន៍។ | ដូចជា៖<br>• ឱកាសរៀនសូត្រជ្រៅជ្រះ ការបំប៉នចំណីអាហារ<br>• កាទទួលដំណឹងឬព័ត៌មានផ្សេងៗបានយ៉ាងទូលំទូលាយ<br>• សេរីភាពនិងការរាប់អានមិត្ត ឱកាសក្នុងការក្លាយជាអ្នកដឹកនាំនៅក្នុងគ្រួសារនិងសហគមន៍។ |
| **-ក្រុមទី២:** ចូរឱ្យឧទាហរណ៍ពីផ្នត់គំនិតដែលទាក់ទងនិងយេនឌ័រ ។ | -ឧទាហរណ៍ពីផ្នត់គំនិត៖<br>• ជាទូទៅ ម្តាយតែងតែផ្ទេរបន្ទុកការងារពិសេសការងារផ្ទះឱ្យកូនស្រី។<br>• បុរសដែលធ្វើការងារផ្ទះត្រូវសង្គមចាត់ទុកថាបុរសទន់ខ្សោយឬមានចរិកស្រី ។<br>• រាល់កិច្ចការដែលត្រូវស្រីធ្វើមិនសូវទទួលបានការវាយតម្លៃឱ្យត្រឹមត្រូវពីសង្គមព្រោះកិច្ចការទាំងនោះសង្គមចាត់ទុកថាការងារធម្មតារបស់ស្ត្រី។ | -ឧទាហរណ៍ពីផ្នត់គំនិត៖<br>• ជាទូទៅ ម្តាយតែងតែផ្ទេរបន្ទុកការងារពិសេសការងារផ្ទះឱ្យកូន ស្រី។<br>• បុរសដែលធ្វើការងារផ្ទះត្រូវសង្គមចាត់ទុកថាបុរសទន់ខ្សោយឬមានចរិកស្រី។<br>• រាល់កិច្ចការដែលត្រូវស្រីធ្វើមិនសូវទទួលបានការវាយតម្លៃឱ្យត្រឹមត្រូវពីសង្គមព្រោះកិច្ចការទាំងនោះសង្គមចាត់ទុកថាការងារធម្មតារបស់ស្ត្រី។ |
| **-ក្រុមទី៣:** តើនៅក្នុងសង្គមគ្រួសារ ស្ត្រីត្រូវទទួលរ៉ាប់រងនូវការទទួលខុសត្រូវអ្វីខ្លះ? | -ថែរក្សាផ្ទះ<br>-ចិញ្ចឹមបីបាច់ថែរក្សាកូន<br>-រកប្រាក់ចំណូល (ចិញ្ចឹមមាន់ ទា ធ្វើកសិកម្ម...) | -នៅក្នុងសង្គមគ្រួសារស្ត្រីត្រូវ ទទួលរ៉ាប់រងនូវការទទួលខុសត្រូវជាច្រើនរាប់តាំង ពីការថែរក្សាផ្ទះសម្បែង ការចិញ្ចឹមបីបាច់កូន ការរកប្រាក់ចំណូលសម្រាប់គ្រួសារ។ តាមរយៈការប្រកបកិច្ចការ ដូចជា ចិញ្ចឹមជ្រូក មាន់ ទា គោនិងការធ្វើ កសិកម្ម ដើម្បីធានាដល់សន្តិសុខស្បៀងក្នុងគ្រួសារ ។ |
| **-ក្រុមទី៤:** ហេតុអ្វី បានជាបុគ្គល គ្រួសារនិង សហគមន៍ត្រូវធ្វើការកែប្រែឥរិយាបថ | -ធានាសមភាពយេនឌ័ររវាងបុរសនិងស្ត្រីក្នុងសង្គម<br>-ផ្តល់សិទ្ធិ (បុរស ស្ត្រី) ពេញលេញ | -បានជាបុគ្គល គ្រួសារ និង សហគមន៍ ត្រូវធ្វើការកែប្រែឥរិយាបថផ្នត់គំនិតអវិជ្ជមាន |

| | | |
|---|---|---|
| ផ្នត់គំនិត អវិជ្ជមានទៅលើ យេនឌ័រ?<br><br><br><br><br><br>-កែសម្រួលឱ្យសិស្សកត់ចូល សៀវភៅ<br><br>-ឱ្យសិស្សសង្ខេបមេរៀន ឡើងវិញ<br><br><br><br><br><br><br><br><br><br><br>-កែសម្រួលឱ្យសិស្សកត់ចូល សៀវភៅ | ក្នុងការទទួលបានឱកាស អំណាច ការបែងចែក និងទទួលផល ។<br><br><br><br><br><br><br><br><br><br>**មេរៀនសង្ខេប**<br>ផ្នត់គត់គំនិត អវិជ្ជមានរបស់ គ្រួសារ និងសង្គមធ្វើឱ្យកើតមាននូវ ការរើសអើង និងផ្តល់ផលប៉ះពាល់ ទៅដល់ក្មេងស្រី និងស្ត្រី ធ្វើឱ្យពួក គេមិនទទួលបានការអប់រំ និង ត្រូវ ធ្វើការយ៉ាងច្រើនក្នុងគ្រួសារ ដែល ជាហេតុនាំឱ្យបាត់បង់សមភាព យេនឌ័រ ។ ដូចនេះ បុគ្គលគ្រួសារ និងសហគមន៍ត្រូវតែកែប្រែ នូវឥរិយា បថ និងផ្នត់គំនិតអវិជ្ជមាន នេះ ដើម្បី ធានាឱ្យសមភាព យេនឌ័រឡើងវិញ។ | ទៅលើយេនឌ័រព្រោះដើម្បី ធានាឱ្យមានសមភាពយេនឌ័រ ផ្តល់ឱ្យស្ត្រី និងបុរសឱ្យទទួល បាន សិទ្ធិពេញលេញមាន ឱកាសអំណាចការបែងចែក ទទួលខុសត្រូវនិងការទទួលផលដូច គ្នា។<br>-សិស្សកត់ចូលសៀវភៅ<br><br><br>-សិស្សសង្ខេបមេរៀន<br><br><br><br><br><br><br><br><br><br><br><br>-សិស្សកត់ចូលសៀវភៅ |
| <br><br>-តើនៅក្នុងគ្រួសារសហគមន៍ ក្មេងប្រុសទទួលបានឱកាសក្នុង ការធ្វើអ្វីខ្លះ? | **ជំហានទី៤**<br>(ពង្រឹងពុទ្ធិ)<br>• ឱកាសរៀនសូត្រជ្រៅជ្រះ ការបំប៉នចំណីអាហារ<br>• កាទទួលដំណឹងឬព័ត៌មាន ផ្សេងៗបានយ៉ាងទូលំទូលាយ<br>• សេរីភាពនិងការរាប់អានមិត្ត<br>• ឱកាសក្នុងការក្លាយជាអ្នក ដឹកនាំនៅក្នុងគ្រួសារនិង សហគមន៍។ | <br><br>-នៅក្នុងគ្រួសារនិងសហគមន៍ ក្មេងប្រុសទទួលបានឱកាស ដូចជា៖<br>• ឱកាសរៀនសូត្រជ្រៅជ្រះ ការបំប៉នចំណីអាហារ<br>• កាទទួលដំណឹងឬព័ត៌មាន ផ្សេងៗបានយ៉ាងទូលំទូលាយ<br>• សេរីភាពនិងការរាប់អានមិត្ត<br>• ឱកាសក្នុងការក្លាយជាអ្នក |

| | | |
|---|---|---|
| | | ដឹកនាំនៅក្នុងគ្រួសារនិង សហគមន៍។ |
| -ពេលត្រលប់ទៅផ្ទះវិញមើលមេរៀនបន្ត និងជួយធ្វើកិច្ចការផ្ទះផង ។ | **ជំហានទី៥**<br>(បណ្តាំផ្ញើ)<br>-ទំព័រ 158-159 | -សិស្សស្តាប់តាមការណែនាំ |

# កិច្ចតែងការបង្រៀន

- កាលបរិច្ឆេទ : ថ្ងៃ ទី ខែ ឆ្នាំ
- មុខវិជ្ជា : សីលធម៌ ពលរដ្ឋវិជ្ជា
- ថ្នាក់ទី : ៧
- **ជំពូកទី១ : យេនឌ័រ និងសិទ្ធិមនុស្ស**
- **មេរៀនទី៣ : យេនឌ័រ និងផ្នត់គំនិត**
- វិធីសាស្រ្ត : សិស្សមជ្ឈមណ្ឌល
- រយៈពេល : ១ម៉ោងសិក្សា(សម្រាប់ម៉ោងទី២)

## I. វត្ថុបំណង

- ចំណេះដឹង : ប្រាប់ពីសារៈប្រយោជន៍នៃសមភាពយេនឌ័រ ចំពោះក្មេងស្រី និងស្រ្តីតាមរយៈ រយៈការសិក្សាអត្ថបទ ។
- បំណិន : វិភាគពីមធ្យោបាយក្នុងការកែលម្អផ្នត់គំនិតនិងការប្រព្រឹត្តរបស់បុគ្គល គ្រួសារ និងសហគមន៍ ទាក់ទងទៅនឹងយេនឌ័របានត្រឹមត្រូវតាមរយៈការពិភាក្សាក្រុម។
- ឥរិយាបថ : ទទួលស្គាល់ និងធ្វើការកែលម្អផ្នត់គំនិតអវិជ្ជមានទាក់ទងទៅយេនឌ័រនៅក្នុង សង្គមរបស់ខ្លួន ។

## II. ខ្លឹមសារមេរៀន

2. **ការផ្លាស់ប្តូរផ្នត់គំនិត និងការប្រព្រឹត្ត របស់គ្រួសារ និងសង្គម**

## III. សម្ភារឧបទេស

- សៀវភៅសិក្សាសង្គមថ្នាក់ទី៧ (សិស្ស) ទំព័រទី ១៥៨, ១៥៩ បោះពុម្ពឆ្នាំ២០០៩
- ប័ណ្ណសំណួរ
- ផ្ទាំងមេរៀនសង្ខេប

IV. **ដំណើរការបង្រៀន**

| **សកម្មភាពគ្រូ** | **ខ្លឹមសារមេរៀន** | **សកម្មភាពសិស្ស** |
|---|---|---|
| -គ្រូតពិនិត្យលើ អវត្តមាន អនាម័យ សណ្តាប់ធ្នាប់ វិន័យ | **ជំហានទី១**<br>(រដ្ឋបាលថ្នាក់)<br>-អវត្តមាន វិន័យ អនាម័យ ពង្រឹងវិន័យ | -ប្រធានថ្នាក់ឡើងរាយការណ៍ |
| -ចូរប្អូនរកឧទាហរណ៍ពីផ្នត់គំនិតដែលទាក់ទងយេនឌ័រ ។<br><br>-ថ្ងៃនេះយើសិក្សាចំណុចបន្តគឺចំណុចអ្វី? | **ជំហានទី២**<br>(រំលឹកមេរៀនចាស់)<br>**មេរៀនទី៣** :<br>**ផ្នត់គំនិត និងយេនឌ័រ**<br><br>• ជាទូទៅ ម្តាយតែងតែផ្ទេរបន្ទុកការងារពិសេសការងារផ្ទះឱ្យកូនស្រី។<br>• បុរសដែលធ្វើការងារផ្ទះត្រូវសង្គមចាត់ទុកថាបុរសទន់ខ្សោយឬមានចរិកស្រី។<br>• រាល់កិច្ចការដែលត្រូវស្រីធ្វើមិនសូវទទួលបានការវាយតម្លៃឱ្យត្រឹមត្រូវពីសង្គមព្រោះកិច្ចការទាំងនោះសង្គមចាត់ទុកថាការងារធម្មតារបស់ស្ត្រី។<br><br><u>**ទំនាក់ទងមេរៀនថ្មី**</u><br>2.ការផ្លាស់ប្តូរផ្នត់គំនិត និងការប្រព្រឹត្ត របស់គ្រួសារ និងសង្គម | -ឧទាហរណ៍ពីផ្នត់គំនិតៈ<br>• ជាទូទៅ ម្តាយតែងតែផ្ទេរបន្ទុកការងារពិសេសការងារផ្ទះឱ្យកូន ស្រី។<br>• បុរសដែលធ្វើការងារផ្ទះត្រូវសង្គមចាត់ទុកថាបុរសទន់ខ្សោយឬមានចរិកស្រី។<br>• រាល់កិច្ចការដែលត្រូវស្រីធ្វើមិនសូវទទួលបានការវាយតម្លៃឱ្យត្រឹមត្រូវពីសង្គមព្រោះកិច្ចការទាំងនោះសង្គមចាត់ទុកថាការងារធម្មតារបស់ស្ត្រី។<br><br>2.ការផ្លាស់ប្តូរផ្នត់គំនិត និងការប្រព្រឹត្ត របស់គ្រួសារ និងសង្គម |
| - ឱ្យសិស្សបើកសៀវភៅទំព័រទី ១៥៨<br><br>-ឱ្យសិស្សអានចំណងជើង | **ជំហានទី៣**<br>(មេរៀនប្រចាំថ្ងៃ)<br>**មេរៀនទី៣**:<br>**យេនឌ័រ និងផ្នត់គំនិត**<br><br>**២.ការផ្លាស់ប្តូរផ្នត់គំនិត និងការ** | - សិស្សធ្វើតាមការណែនាំ<br><br>- អាន |

| | | |
|---|---|---|
| តូចសរសេរចំណងជើងលើក្ដាខៀន<br><br>-តើចំណងជើងមានន័យដូចម្ដេច?<br><br><br><br><br>-តើប្អូនឃើញអ្វីខ្លះនៅក្នុងរូបភាព?<br><br><br><br><br>-តើរូបភាពនេះចង់បង្ហាញអំពីអ្វី?<br><br><br><br>-តើរូបភាពជាមួយចំណងជើងមានទំនាក់ទំនងគ្នាឬទេ?<br><br><br><br><br><br>- ឱ្យសិស្សអានខ្លឹមសារមេរៀនរួចសរសេរពាក្យពិបាកលើក្ដាខៀន<br><br><br><br><br>-ឱ្យសិស្សកត់ចូលសៀវភៅ | **ប្រព្រឹត្ត របស់គ្រួសារ និងសង្គម**<br><br>**សិក្សាចំណងជើង**<br>- ការធ្វើការផ្លាស់ប្ដូរ នូវឥរិយាបថ និងការគិតបែបអវិជ្ជមានរបស់គ្រួសារនិងសង្គមទៅលើយេនឌ័រ។<br><br><br>**សិក្សារូបភាព**<br>-ឃើញមានកុមារីនិងមនុស្សជាច្រើន និង អ្នកគ្រូម្នាក់កំពុងបង្រៀនសិស្សបីនាក់និង ស្រីម្នាក់កំពុងអង្គុយលើកៅអី ប្រអប់ និងមានឯកសារផ្សេងៗ...។<br><br><br>-រូបភាពនេះចង់បង្ហាញអំពីការចូលមរបស់កុមារី និងស្រីនៅក្នុងសង្គម។<br><br>**ទំនាក់នងរូបភាពនិងចំណងជើង**<br>-ពីការកែប្រែនិងផ្លាស់ប្ដូរនូវ ផ្នត់គំនិតក៏ដូចជាឥរិយាបថរបស់សង្គម និងគ្រួសារ។ រីឯរូបភាពបានបង្ហាញពីការចូលរួមរបស់កុមារី និងស្ត្រីនៅក្នុងសង្គម ។<br><br><br>**ពន្យល់ពាក្យ**<br>-សេវា (ន)<br>-លទ្ធភាព (ន)<br>-ឥរិយាបថ<br>-អភិវឌ្ឍន៍(ន)<br><br><br>**ពិភាក្សាក្រុម** | <br><br><br><br><br><br><br><br><br>-ឃើញមានកុមារីនិងមនុស្សជាច្រើន និង អ្នកគ្រូម្នាក់កំពុងបង្រៀនសិស្សបីនាក់និងស្រីម្នាក់កំពុងអង្គុយលើកៅអី ប្រអប់ និងមានឯកសារផ្សេងៗ...។<br><br>-រូបភាពនេះចង់បង្ហាញអំពីការចូលមរបស់កុមារី និងស្រីនៅក្នុងសង្គម។<br><br><br>-មានទំនាក់ទំនងព្រោះ ចំណងជើងនិយាយពីការកែប្រែនិងផ្លាស់ប្ដូរនូវផ្នត់គំនិងក៏ដូចជាឥរិយាបថរបស់សង្គមនិងគ្រួសារ។ រីឯរូបភាពបានបង្ហាញពីការចូលរួមរបស់កុមារី និងស្ត្រីនៅក្នុងសង្គម។<br>-សិស្សអាន<br>=ការបម្រើនូវផ្នែកអ្វីមួយ។<br>=ភាពដែលអាចធ្វើទៅបាន។<br>=អាកប្បកិរិយានៃការប្រព្រឹត្ត។<br>=ការរីចម្រើន។<br><br><br>-កត់ចូលសៀវភៅ |

| | | |
|---|---|---|
| -បែងសិស្សជា៤ក្រុម៖ | | -សិស្សចូលក្រុមពិភាក្សា |
| **-ក្រុមទី១:** តើគេត្រូវធ្វើដូចម្តេចដើម្បីផ្លាស់ប្តូរផ្នត់គំនិត និងការរើសអើងរបស់សហគមន៍ និងសង្គមទាក់ទងយេនឌ័រ? | - ធ្វើការផ្សព្វផ្សាយ អប់រំអំពីយេនឌ័រទៅកាន់គ្រួសារនិងសហគមន៍ទាំងមូលឱ្យបានដឹងនិងធ្វើការបង្កើត និងអនុវត្តច្បាប់ផ្សេងៗ។ | -ដើម្បីផ្លាស់ប្តូរផ្នត់គំនិត និងការប្រព្រឹត្តរបស់សហគមន៍ និងសង្គមទាំងមូលទាក់ទងទៅនិងយេនឌ័រយើងត្រូវ ធ្វើការផ្សព្វផ្សាយ អប់រំអំពីយេនឌ័រទៅកាន់គ្រួសារនិងសហគមន៍ទាំងមូលឱ្យបានដឹង និងធ្វើការបង្កើតនិងអនុវត្ត ច្បាប់ផ្សេងៗ |
| **-ក្រុមទី២:** តើមានវិធីមធ្យោបាយអ្វីខ្លះ ដើម្បីផ្លាស់ប្តូរគំនិត និងការ ប្រព្រឹត្ត របស់គ្រួសារទាក់ទងទៅនិងយេនឌ័រ? | -ប្រើវិធីឬមធ្យោបាយដូចជា៖<br>• ផ្សព្វផ្សាយ ឬអប់រំបណ្តុះបណ្តាលមនុស្សគ្រប់វ័យអំពីយេនឌ័រ<br>• ជំរុញឱ្យក្មេងស្រីមានឱកាសទទួលបានការសិក្សាតាំងពីបឋមសិក្សាដល់ឧត្តមសិក្សាដូចក្មេងប្រុស។<br>• ការផ្សព្វផ្សាយនៃជោគជ័យស្នាដៃរបស់កុមារីនិងស្ត្រីដើម្បីប្រឆាំងនឹងគំនិតដែលយល់ឃើញថាមានតែកុមារានិងបុរសទេដែលមានសមត្ថភាពអាចធ្វើបាន<br>• ជំរុញឱ្យកុមារានិងបុរសចូលរួមធ្វើការងារផ្ទះ<br>• គាំទ្រស្ត្រីជាបេក្ខនារីនៅពេលឈរឈ្មោះបោះឆ្នោត<br>• ជំរុញឱ្យស្ត្រីមានចំនួនច្រើនក្នុងការ គ្រប់គ្រងគ្រប់លំដាប់ថ្នាក់និងបំបាត់អំពើហិង្សាលើស្ត្រីនិងកុមារី<br>• ជំរុញនិងផ្តល់ឱកាសឱ្យក្មេងស្រី ក្មេងប្រុស បុរស នារីទទួលបានឱកាសស្មើគ្នាក្នុងការអប់រំ ការថែទាំទំនុកបម្រុង កិច្ចការពារនិងសេវាផ្សេងៗ ។<br>• លើកទឹកចិត្តក្មេងស្រី ស្ត្រីដើម្បីឱ្យគេមានភាពក្លាហាននិងមាន | -ប្រើវិធីឬមធ្យោបាយដូចជា៖<br>• ផ្សព្វផ្សាយ ឬអប់រំបណ្តុះបណ្តាលមនុស្សគ្រប់វ័យអំពីយេនឌ័រ<br>• ជំរុញឱ្យក្មេងស្រីមានឱកាសទទួល បានការសិក្សាតាំងពីបឋមសិក្សា ដល់ឧត្តមសិក្សាដូច ក្មេងប្រុស។<br>• ការផ្សព្វផ្សាយនៃជោគជ័យស្នាដៃរបស់កុមារីនិងស្ត្រីដើម្បីប្រឆាំង នឹងគំនិតដែលយល់ឃើញ ថាមានតែកុមារា និងបុរសទេដែលមាន សមត្ថភាពអាចធ្វើបាន<br>• ជំរុញឱ្យកុមារានិងបុរសចូលរួមធ្វើ ការងារផ្ទះ<br>• គាំទ្រស្ត្រីជាបេក្ខនារីនៅពេលឈរឈ្មោះបោះឆ្នោត<br>• ជំរុញឱ្យស្ត្រីមានចំនួនច្រើនក្នុងការ គ្រប់គ្រងគ្រប់លំដាប់ថ្នាក់និងបំបាត់អំពើហិង្សាលើស្ត្រីនិងកុមារី<br>• ជំរុញនិងផ្តល់ឱកាសឱ្យក្មេងស្រីក្មេងប្រុស បុរស នារីទទួលបានឱកាសស្មើគ្នាក្នុងការអប់រំ ការថែទាំទំនុកបម្រុង |

| | | |
|---|---|---|
| -**ក្រុមទី៣:** ហេតុអ្វីបានជាគេទាមទារឱ្យមានការកែប្រែគំនិតសង្គមដើម្បីធានាឱ្យមានសមភាពយេនឌ័រ ?<br><br>-**ក្រុមទី៤:** តើការមានសមភាពយេនឌ័រមានប្រយោជន៍អ្វីខ្លះចំពោះក្មេងស្រី និង ស្ត្រី?<br><br>-សំយោគចម្លើយ | សមត្ថភាពគ្រប់គ្រាន់ក្នុងការចូលរួមការងារអភិវឌ្ឍន៍និងសេដ្ឋកិច្ចសង្គមជាតិ និងការធ្វើការសំរេចចិត្តក្នុងគ្រួសារសហគមន៍និងសង្គម ។<br><br>- ស្ត្រីចូលរួមចំណែកអភិវឌ្ឍ<br>- ជាកម្លាំងចលករ ជម្រុញបុរសឱ្យប្រសើរ<br><br>• ក្មេងស្រីនិងស្ត្រីទទួលបានការអប់រំស្មើនឹងបុរស ក្មេងប្រុស។<br>• ទទួលបានការយកចិត្តទុកដាក់ពីសង្គមគ្រួសារ និងសហគមន៍។<br>• ទទួលបានកិច្ចការពារថែទាំទំនុកបំរុងដូចក្មេងប្រុស និងបុរស់ដែរ។<br>• មានលទ្ធភាពនិង សមត្ថភាពក្នុងការធ្វើសេចក្តី សំរេចចិត្តនៅក្នុងគ្រួសារ និងសង្គម។<br>• ទទួលបានការឱ្យតម្លៃ និងផ្តល់សិទ្ធិស្មើ និងបុរស និងក្មេងប្រុស។<br><br>**មេរៀនសង្ខេប** | កិច្ចការពារនិងសេវា ផ្សេងៗ ។<br>• លើកទឹកចិត្តក្មេងស្រី ស្ត្រីដើម្បីឱ្យគេមានភាពក្លាហាននិងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការចូល រួមការងារអភិវឌ្ឍន៍ និងសេដ្ឋកិច្ច សង្គមជាតិ និងការធ្វើការសំរេច ចិត្តក្នុងគ្រួសារសហគមន៍ និង សង្គម ។<br><br>-ពីព្រោះថានៅក្នុងសង្គមស្ត្រីក៏ដូចជាចំណែកមួយដែរក្នុងការចូលរួមអភិវឌ្ឍ សហគមន៍ និងសង្គមស្ត្រីគឺជាកំលាំងចលកររុញច្រានឲ្យបុរសធ្វើការកាន់តែល្អ ប្រសើរ ។ និយាយរួមព្រោះថាមនុស្សទាំងអស់មានសិទ្ធិ និងតម្លៃស្មើៗគ្នា។<br><br>-ការមានសមភាពយេនឌ័រមានប្រយោជ៍ចំពោះក្មេងស្រីនិង ស្ត្រីមានដូចជា៖<br>• ក្មេងស្រីនិងស្ត្រីទទួលបានការអប់រំស្មើនឹងបុរស ក្មេងប្រុស។<br>• ទទួលបានការយកចិត្តទុកដាក់ពីសង្គមគ្រួសារនិងសហគមន៍។<br>• ទទួលបានកិច្ចការពារថែទាំទំនុកបំរុងដូចក្មេងប្រុស និងបុរស់ដែរ។<br>• មានលទ្ធភាពនិងសមត្ថភាពក្នុងការធ្វើសេចក្តី សំរេចចិត្តនៅក្នុងគ្រួសារ និងសង្គម។<br>• ទទួលបានការឱ្យតម្លៃ និងផ្តល់សិទ្ធិស្មើនិងបុរសនិងក្មេងប្រុស។<br>-សិស្សចម្លង |

| | | |
|---|---|---|
| -ឱ្យសិស្សសង្ខេបមេរៀនឡើងវិញ | គ្រួសារសង្គមត្រូវតែកែប្រែ ឥរិយាបថ និងផ្នត់គំនិតដែលទាក់ទងនិងយេនឌ័រ តាមរយៈ ការជំរុញ និងផ្តល់ឱកាសឱ្យក្មេងស្រី និងក្មេងប្រុស និងបុរស ស្ត្រី ទទួលបានឱកាសស្មើគ្នាក្នុងការរស់នៅការអប់រំការថែទាំទំនុកបម្រុងកិច្ចការពារ និងសេវាផ្សេងៗ និងលើកកម្ពស់ភាពអង់អាចក្លាហាន ដល់ស្ត្រី ដើម្បីឱ្យពួកគេមានសមត្ថភាព និងលទ្ធភាពគ្រប់គ្រាន់ក្នុងការចូលរួមអភិវឌ្ឍគ្រួសារ និងសង្គមជាតិឱ្យមានការរីកចម្រើន។ | -សិស្សសង្ខេបមេរៀន |
| -តើការមានសមភាពយេនឌ័រមានប្រយោជ៍អ្វីខ្លះចំពោះក្មេងស្រី និង ស្ត្រី? | **ជំហានទី៤**<br>(ពង្រឹងពុទ្ធិ)<br>-ការមានសមភាពយេនឌ័រមានប្រយោជន៍ចំពោះក្មេងស្រី និងស្ត្រីមានដូចជាៈ<br>• ក្មេងស្រីនិងស្ត្រីទទួលបានការអប់រំស្មើនឹងបុរស ក្មេងប្រុស។<br>• ទទួលបានការយកចិត្តទុកដាក់ពីសង្គមគ្រួសារ និងសហគមន៍។<br>• ទទួលបានកិច្ចការពារថែទាំទំនុកបំរុងដូចក្មេងប្រុស និងបុរស់ដែរ។<br>• មានលទ្ធភាពនិង សមត្ថភាពក្នុងការធ្វើសេចក្តី សំរេចចិត្តនៅក្នុងគ្រួសារ និងសង្គម។<br>• ទទួលបានការឱ្យតម្លៃ និងផ្តល់សិទ្ធិស្មើ និងបុរស និងក្មេងប្រុស។ | -ការមានសមភាពយេនឌ័រមានប្រយោជ៍ចំពោះក្មេងស្រីនិងស្ត្រីមានដូចជាៈ<br>• ក្មេងស្រីនិងស្ត្រីទទួលបានការអប់រំស្មើនឹងបុរស ក្មេងប្រុស។<br>• ទទួលបានការយកចិត្តទុកដាក់ពីសង្គមគ្រួសារនិងសហគមន៍។<br>• ទទួលបានកិច្ចការពារថែទាំទំនុកបំរុងដូចក្មេងប្រុសនិងបុរស់ដែរ។<br>• មានលទ្ធភាពនិងសមត្ថភាពក្នុងការធ្វើសេចក្តីសំរេចចិត្តនៅក្នុងគ្រួសារ និងសង្គម។<br>• ទទួលបានការឱ្យតម្លៃ និងផ្តល់សិទ្ធិស្មើ និងបុរស និងក្មេងប្រុស។ |
| -ពេលប្អូនត្រលប់ទៅផ្ទះវិញ | **ជំហានទី៥**<br>(បណ្តាំផ្ញើ) | -សិស្សស្តាប់យ៉ាងយកចិត្តទុក ដាក់ |

| | | |
|---|---|---|
| មើលមេរៀនបន្តផង ជួយកិច្ចការឪពុកម្តាយ។ | | |

# កិច្ចតែងការបង្រៀន

- កាលបរិច្ឆេទ : ថ្ងៃ ទី ខែ ឆ្នាំ
- មុខវិជ្ជា : សីលធម៌-ពលរដ្ឋវិជ្ជា
- ថ្នាក់ទី : ៧
- **ជំពូកទី១** : **យេនឌ័រ និង សិទ្ធិមនុស្ស**
- **មេរៀនទី៤** : **ការរើសអើង និង បញ្ហាផ្លូវចិត្ត**
- វិធីសាស្ត្របង្រៀន : គោលវិធីសិស្សមជ្ឈមណ្ឌល (ពិភាក្សាក្រុម)
- រយៈពេល : ២ ម៉ោងសិក្សា (សម្រាប់ម៉ោងទី១)

## I. **វត្ថុបំណង**

- ចំណេះដឹង : ឱ្យនិយមន័យពីការរើសអើងចំពោះកុមារី និងស្ត្រី បានត្រឹមត្រូវតាមរយៈការសិក្សាអត្ថបទ
- បំណិន : វិភាគពីផលប៉ះពាល់អវិជ្ជមាននៃការរើសអើងយេនឌ័របានត្រឹមត្រូវតាមរយៈការពិភាក្សាក្រុម។
- ឥរិយាបថ : បណ្ដុះស្មារតីឱ្យស្អប់ខ្ពើម និងបញ្ឈប់រាល់អំពើរើសអើងភេទទាំងឡាយដើម្បីចូលរួមអភិវឌ្ឍប្រទេសជាតិ។

## II. **ខ្លឹមសារមេរៀន**

1. **ការរើសអើងភេទ**
2. **ការរើសអើងចំពោះកុមារី និងស្ត្រី**
3. **ផលប៉ះពាល់អវិជ្ជមាននៃការរើសអើងយេនឌ័រ**

## III. **សម្ភារឧបទេស**

- សៀវភៅសិស្សសិក្សាសង្គមថ្នាក់ទី៧ ថ្មី ទំព័រ ១៦០-១៦៣ បោះពុម្ពឆ្នាំ ២០១១
- ប័ណ្ណសំណួរ
- ផ្ទាំងរូបភាព
- ផ្ទាំងមេរៀនសង្ខេប

## IV. **បញ្ញត្តបញ្ច្រាប**

- ចូលរួមលើកកម្ពស់សមភាពយេនឌ័រ និងលុបបំបាត់ការរើសអើងភេទ

## V. ដំណើរការមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ពិនិត្យលើ: អវត្តមាន អនាម័យ វិន័យ សណ្តាប់ធ្នាប់។ | **ជំហានទី១**<br>(រដ្ឋបាលថ្នាក់) | -ប្រធានថ្នាក់ឡើងរាយការណ៍។ |
| -តើកាលពីម៉ោងមុនយើងបានសិក្សាពីមេរៀនអ្វី?<br>- តើមានវិធីឬ មធ្យោបាយអ្វីខ្លះ ដើម្បីផ្លាស់ប្តូរផ្នត់គំនិត និងការប្រព្រឹត្តរបស់គ្រួសារ ទាក់ទង និង យេនឌ័រ?<br><br><br><br><br><br><br><br>-តើប្អូនធ្លាប់ទទួលការរើសអើងពីនរណាម្នាក់ដែរឬទេ?<br>-តើប្អូនមានអារម្មណ៍ដូចម្តេចដែរ? | **ជំហានទី២**<br>(រំឭកមេរៀនចាស់)<br>**មេរៀនទី៣**:<br>**យេនឌ័រ និង ផ្នត់គំនិត**<br>-មានដូចជា៖<br>• ផ្សព្វផ្សាយពីយេនឌ័រ<br>• ជំរុញឱ្យក្មេងប្រុសក្មេងស្រីទទួលការសិក្សាបានខ្ពស់<br>• ផ្សព្វផ្សាយស្នាដៃជោគជ័យរបស់កុមារី ស្ត្រី<br>• ជំរុញកុមារា បុរសចូលរួមធ្វើការងារផ្ទះ<br>• គាំទ្រស្ត្រី<br>• លើកទឹកចិត្តក្មេងស្រី និងស្ត្រីដើម្បីមានភាពក្លាហាន។<br><br>**ទំនាក់ទំនងមេរៀនថ្មី**<br>-ធ្លាប់ ឬ មិនធ្លាប់<br><br>-មិនសប្បាយ<br>-មានអារម្មណ៍កោ... | មេរៀនទី៣:<br>យេនឌ័រ និង ផ្នត់គំនិត<br>-មានដូចជា៖<br>• ផ្សព្វផ្សាយពីយេនឌ័រ<br>• ជំរុញឱ្យក្មេងប្រុសក្មេងស្រីទទួលការសិក្សាបានខ្ពស់<br>• ផ្សព្វផ្សាយស្នាដៃជោគជ័យរបស់កុមារី ស្ត្រី<br>• ជំរុញកុមារា បុរសចូលរួមធ្វើការងារផ្ទះ<br>• គាំទ្រស្ត្រី<br>• លើកទឹកចិត្តក្មេងស្រី និងស្ត្រីដើម្បីមានភាពក្លាហាន។<br><br><br>-ធ្លាប់ ឬ មិនធ្លាប់<br><br>-មិនសប្បាយចិត្តឯកកោ...។ |
| -ឱ្យសិស្សបើសៀវភៅទំព័រ ១៦០ អានចំណងជើង រួចគ្រូសរសេរដាក់លើក្តារខៀន | **ជំហានទី៣**<br>(ដំណើរការមេរៀនថ្មី)<br>**មេរៀនទី៤**:<br>**ការរើសអើង និង បញ្ហាផ្លូវចិត្ត** | -សិស្សធ្វើតាមការណែនាំរបស់គ្រូ |

| | | |
|---|---|---|
| -ឱ្យសិស្សអានខ្លឹមសារមេរៀន ទំព័រ ១៦០-១៦១<br><br>-គ្រូសរសេរពាក្យពិបាកដាក់លើក្ដារខៀន<br><br><br><br><br><br>-កែលម្អរួចឱ្យសិស្សកត់<br><br>-គ្រូបែងចែកសិស្សជា៥ក្រុម៖<br><br>**-ក្រុមទី១:** តើអ្វីទៅជាការរើសអើង?<br><br><br><br><br><br><br>**-ក្រុមទី២:** តើកុមារី និងស្ត្រីទទួលការរើសអើងអ្វីខ្លះ? | **ពន្យល់ពាក្យ**<br><br>-ផ្ទត់គំនិត (ន): ការប្រកាន់យកទស្សនៈដដែលៗ។<br>-រើសអើង (កិ): ស្អប់ប្រកាន់មិនចូលចិត្ត។<br>-វិនិច្ឆ័យ (កិ): ត្រិះរិះពិចារណា។<br>-បុគ្គលិកលក្ខណៈ (ន): លក្ខណៈជាគ្រឿងសម្គាល់ចំពោះមនុស្ស ឬ សត្វ។<br><br>**ពិភាក្សាក្រុម**<br><br>**- ការប្រកាន់ពូជសាសន៍ អាយុ ភេទ សមត្ថភាព វណ្ណៈ**<br>**- លម្អៀង បុរេនិច្ឆ័យ**<br><br><br><br><br><br>-ទទួលរងការរើសអើងដូចជា៖<br>+កុមារី<br>• មិនឱ្យទៅរៀន<br>• ទុកឱ្យធ្វើការងារផ្ទះ<br>• ទទួលរងការគាបសង្កត់<br>• ជួញដូរ<br>• បង្ខំឱ្យគោរពប្រពៃណី ទំនៀមទម្លាប់។<br>+ស្ត្រី<br>• បង្វិលចង្កានមិនជុំ<br>• គ្មានសមត្ថភាព<br>• មិនចេះសម្រេចចិត្តចេះតែ | -អានខ្លឹមសារមេរៀន<br><br>-សាកល្បងពន្យល់ន័យ<br><br><br><br><br><br><br>-សិស្សកត់ចូលសៀវភៅ<br><br>-សិស្សចូលតាមក្រុមពិភាក្សា<br><br>-ជាអំពើដែលបង្ហាញពីការប្រកាន់ ការបែងចែកការវិនិច្ឆ័យទៅលើអ្នកណាម្នាក់ដោយមិនផ្អែកលើការវាយតម្លៃខាងក្រៅដោយលម្អៀងលើអាយុ សមត្ថភាព ផ្លូវកាយ ភេទ សាសនា...។<br><br>-ទទួលរងការរើសអើងដូចជា៖<br>+កុមារី<br>• មិនឱ្យទៅរៀន<br>• ទុកឱ្យធ្វើការងារផ្ទះ<br>• ទទួលរងការគាបសង្កត់<br>• ជួញដូរ<br>• បង្ខំឱ្យគោរពប្រពៃណី ទំនៀមទម្លាប់។<br>+ស្ត្រី<br>• បង្វិលចង្កានមិនជុំ<br>• គ្មានសមត្ថភាព<br>• មិនចេះសម្រេចចិត្តចេះតែ |

| | | |
|---|---|---|
| | ការងារផ្ទះ។ | ការងារផ្ទះ។ |
| **-ក្រុមទី៣:** តើយើងត្រូវធ្វើដូចម្ដេចដើម្បីលប់បំបាត់ការរើសអើងចំពោះ កុមារី និង ស្ត្រី? | -យើងត្រូវ៖<br>• លើកកម្ពស់គុណភាពអប់រំ<br>• លើកកម្ពស់សិទ្ធិឱ្យស្មើគ្នាគ្រប់ផ្នែកគ្រប់កាលៈទេសៈ<br>• ផ្ដល់ឱ្យកុមារីទៅសាលារៀន<br>• ឱ្យស្ត្រីធ្វើការសម្រេចចិត្តជាអាទិភាព។ | -យើងត្រូវ៖<br>• លើកកម្ពស់គុណភាពអប់រំ<br>• លើកកម្ពស់សិទ្ធិឱ្យស្មើគ្នាគ្រប់ផ្នែកគ្រប់កាលៈទេសៈ<br>• ផ្ដល់ឱ្យកុមារីទៅសាលារៀន<br>• ឱ្យស្ត្រីធ្វើការសម្រេចចិត្តជាអាទិភាព។ |
| **-ក្រុមទី៤:** តើការរើសអើងភេទផ្ដល់ផលប៉ះពាល់អវិជ្ជមានអ្វីខ្លះដល់ស្ត្រី កុមារី និង ប្រទេសជាតិ? | -មានផលប៉ះពាល់ដូចជា៖<br>+ចំពោះកុមារី និង ស្ត្រី<br>• បាត់បង់ឱកាសក្នុងការអភិវឌ្ឍខ្លួន និងគ្រួសារ សហគម<br>• ទទួលបានការសិក្សាតិចតួច<br>• មិនអាចឱ្យកុមារី និងស្ត្រីរកការងារធ្វើបាន<br>• មិនមានតួនាទីផ្សេងៗក្នុងសង្គម។<br>+ចំពោះប្រទេសជាតិ<br>• បាត់បង់សណ្ដាប់ធ្នាប់<br>• ភាពក្រីក្រកើនឡើង។ | -មានផលប៉ះពាល់ដូចជា៖<br>+ចំពោះកុមារី និង ស្ត្រី<br>• បាត់បង់ឱកាសក្នុងការអភិវឌ្ឍខ្លួន និងគ្រួសារ សហគម<br>• ទទួលបានការសិក្សាតិចតួច<br>• មិនអាចឱ្យកុមារី និងស្ត្រីរកការងារធ្វើបាន<br>• មិនមានតួនាទីផ្សេងៗក្នុងសង្គម។<br>+ចំពោះប្រទេសជាតិ<br>• បាត់បង់សណ្ដាប់ធ្នាប់<br>• ភាពក្រីក្រកើនឡើង។ |
| -កែលម្អឱ្យសិស្សកត់<br>- ឱ្យសិស្សទាញមេរៀនសង្ខេប | **មេរៀនសង្ខេប**<br>ការរើសអើងគឺជាការប្រកាន់បែងចែក ការវិនិច្ឆ័យមិនល្អលើនរណាម្នាក់ ឬការប្រកាន់បក្សពួកនិយម។ ការរើសអើងនេះផ្ដល់ផលប៉ះពាល់អវិជ្ជមានដល់កុមារី និង ស្ត្រីពុំមានឱកាសអភិវឌ្ឍខ្លួន គ្រួសារ សហគម ហើយទទួលការអប់រំតិចជាដើម ។ ចំណែកប្រទេសជាតិវិញគ្មានសន្តិសុខពុំអាចកាត់បន្ថយភាពក្រីក្របានឡើយ។ | -សិស្សកត់ចូលសៀវភៅ<br>-សិស្សទាញមេរៀនសង្ខេប |

| | | |
|---|---|---|
| -ឱ្យសិស្សកត់ចូលសៀវភៅ | | -សិស្សកត់ចូលសៀវភៅ |
| -តើយើងត្រូវធ្វើដូចម្តេចដើម្បីលប់បំបាត់ការរើសអើងចំពោះកុមារី និង ស្ត្រី?<br><br>-តើការរើសអើងភេទផ្តល់ផលប៉ះពាល់អវិជ្ជមានអ្វីខ្លះដល់ស្ត្រី កុមារី និង ប្រទេសជាតិ? | **ជំហានទី៤**<br>(ពង្រឹងពុទ្ធិ)<br>-យើងត្រូវ៖<br>• លើកកម្ពស់គុណភាពអប់រំ<br>• លើកកម្ពស់សិទ្ធិឱ្យស្មើគ្នាគ្រប់ផ្នែកគ្រប់កាលៈទេសៈ<br>• ផ្តល់ឱ្យកុមារីទៅសាលារៀន<br>• ឱ្យស្ត្រីធ្វើការសម្រេចចិត្តជាអាទិភាព។<br><br>-មានផលប៉ះពាល់ដូចជា៖<br>+ចំពោះកុមារី និង ស្ត្រី<br>• បាត់បង់ឱកាសក្នុងការអភិវឌ្ឍខ្លួន និងគ្រួសារ សហគម<br>• ទទួលបានការសិក្សាតិចតួច<br>• មិនអាចឱ្យកុមារី និងស្ត្រីរកការងារធ្វើបាន<br>• មិនមានតួនាទីផ្សេងៗក្នុងសង្គម។<br>+ចំពោះប្រទេសជាតិ<br>• បាត់បង់សណ្តាប់ធ្នាប់<br>• ភាពក្រីក្រកើនឡើង។ | -យើងត្រូវ៖<br>• លើកកម្ពស់គុណភាពអប់រំ<br>• លើកកម្ពស់សិទ្ធិឱ្យស្មើគ្នាគ្រប់ផ្នែកគ្រប់កាលៈទេសៈ<br>• ផ្តល់ឱ្យកុមារីទៅសាលារៀន<br>• ឱ្យស្ត្រីធ្វើការសម្រេចចិត្តជាអាទិភាព។<br><br>-មានផលប៉ះពាល់ដូចជា៖<br>+ចំពោះកុមារី និង ស្ត្រី<br>• បាត់បង់ឱកាសក្នុងការអភិវឌ្ឍខ្លួន និងគ្រួសារ សហគម<br>• ទទួលបានការសិក្សាតិចតួច<br>• មិនអាចឱ្យកុមារី និងស្ត្រីរកការងារធ្វើបាន<br>• មិនមានតួនាទីផ្សេងៗក្នុងសង្គម។<br>+ចំពោះប្រទេសជាតិ<br>• បាត់បង់សណ្តាប់ធ្នាប់ ភាពក្រីក្រកើនឡើង។ |
| -ពេលត្រឡប់ទៅផ្ទះវិញត្រូវខិតខំរៀនសូត្របន្ថែម ជាពិសេសធ្វើដំណើរត្រូវប្រយ័ត្នផង។ | **ជំហានទី៥**<br>(បណ្តាំផ្ញើ) | -អនុវត្តតាមការណែនាំ។ |

# កិច្ចតែងការបង្រៀន

- កាលបរិច្ឆេទ : ថ្ងៃ ទី ខែ ឆ្នាំ
- មុខវិជ្ជា : សីលធម៌-ពលរដ្ឋវិជ្ជា
- ថ្នាក់ទី : ៧
- **ជំពូកទី១** : **យេនឌ័រ និង សិទ្ធិមនុស្ស**
- **មេរៀនទី៤** : **ការរើសអើង និងបញ្ហាផ្លូវចិត្ត**
- វិធីសាស្ត្រ : គោលវិធីសិស្សមជ្ឈមណ្ឌល (វិធីចោទឆ្លើយ)
- រយៈពេល : ២ ម៉ោងសិក្សា (សម្រាប់ម៉ោងទី២)

## I. វត្ថុបំណង

- ចំណេះដឹង : ពណ៌នាពីមូលហេតុដែលនាំឱ្យមានបញ្ហាផ្លូវចិត្ត ការតានតឹង ជំងឺផ្លូវចិត្ត ការធ្លាក់ទឹកចិត្ត និងការថែទាំសុខភាពផ្លូវចិត្ត បានត្រឹមត្រូវតាមរយៈ ការអានខ្លឹមសារមេរៀន។
- បំណិន : វិភាគពីបញ្ហាតានតឹងក្នុងចិត្ត ការធ្លាក់ទឹកចិត្ត និងវិធីបំបាត់ការ តានតឹង ព្រម ទាំងការធ្លាក់ទឹកចិត្ត បានត្រឹមត្រូវតាមរយៈការចោទឆ្លើយ។
- ឥរិយាបថ : ស្រឡាញ់ថែទាំសុខភាពផ្លូវចិត្ត ដើម្បីកាត់បន្ថយបញ្ហាផ្លូវចិត្តក្នុងការរស់នៅ ប្រចាំថ្ងៃ ។

## II. ខ្លឹមសារមេរៀន

4. **បញ្ហាផ្លូវចិត្ត**

## III. សម្ភារឧបទេស

- សៀវភៅសិក្សាសង្គមថ្នាក់ទី៧ ទំព័រ ១៦២-១៦៣ បោះពុម្ពឆ្នាំ ២០១១
- ប័ណ្ណសំណួរ
- ផ្ទាំងមេរៀនសង្ខេប

## IV. បញ្ញត្តបង្រាប

V. រស់នៅប្រកបដោយសេរីភាព និងបើកចិត្តឱ្យទូលាយដើម្បីបញ្ចៀសបញ្ហាកើតឡើងខាងលើ។

## VI. **ដំណើរការបង្រៀន**

| **សកម្មភាពគ្រូ** | **ខ្លឹមសារមេរៀន** | **សកម្មភាពសិស្ស** |
|---|---|---|
| -ពិនិត្យលើ: អនាម័យ អវត្តមាន វិន័យ សណ្តាប់ធ្នាប់។ | **ជំហានទី១**<br>(រដ្ឋបាលថ្នាក់) | -ប្រធានថ្នាក់ឡើងរាយការណ៍។ |
| -តើកាលពីម៉ោងមុនយើងបានសិក្សាពីមេរៀនអ្វី?<br><br>-តើយើងត្រូវធ្វើដូចម្តេចដើម្បីលុបបំបាត់អំពើរើសអើងចំពោះកុមារ និងស្ត្រី?<br><br>-តើអ្វីទៅជាការរើសអើង?<br><br>-នៅពេលប្អូនធ្វើអ្វីមួយបរាជ័យ តើប្អូនមានអារម្មណ៍ដូចម្តេច? | **ជំហានទី២**<br>(រំឭកមេរៀនចាស់)<br>**មេរៀនទី៤**:<br>**ការរើសអើង និងបញ្ហាផ្លូវចិត្ត**<br><br>-ដើម្បីលុបបំបាត់ត្រូវៈ<br>• លើកកម្ពស់គុណភាពអប់រំ<br>• លើកតម្កើងសិទ្ធិឱ្យស្មើគ្នាគ្រប់ផ្នែកគ្រប់កាលៈទេសៈ<br>• ឱ្យស្ត្រីធ្វើការសម្រេចចិត្តជាអាទិភាព<br>• ផ្តល់ឱ្យកុមារទៅសាលារៀន។<br><br>-ជាអំពើដែលបង្ហាញពីការប្រកាន់ ការបែងចែក ការវិនិច្ឆ័យទៅលើអ្នកណាម្នាក់ដោយមិនផ្អែកលើការវាយតម្លៃខាងក្រៅដោយលម្អៀងលើអាយុ សមត្ថភាព ផ្លូវកាយ ភេទ សាសនា...។<br><br><u>**ទំនាក់ទំនងមេរៀនថ្មី**</u><br>-អារម្មណ៍ធុញថប់ ខឹង...។ | មេរៀនទី៤:<br>ការរើសអើង និងបញ្ហាផ្លូវចិត្ត<br><br>-ដើម្បីលុបបំបាត់ត្រូវៈ<br>• លើកកម្ពស់គុណភាពអប់រំ<br>• លើកតម្កើងសិទ្ធិឱ្យស្មើគ្នាគ្រប់ផ្នែកគ្រប់កាលៈទេសៈ<br>• ផ្តល់ឱ្យកុមារទៅសាលារៀន<br>• ឱ្យស្ត្រីធ្វើការសម្រេចចិត្តជាអាទិភាព។<br>-ជាអំពើដែលបង្ហាញពីការប្រកាន់ ការបែងចែកការវិនិច្ឆ័យទៅលើអ្នកណាម្នាក់ដោយមិនផ្អែកលើការវាយតម្លៃខាងក្រៅដោយលម្អៀងលើ អាយុ សមត្ថភាព ផ្លូវកាយ ភេទសាសនា...។<br><br>-អារម្មណ៍ធុញថប់ ខឹង...។ |
| -ឱ្យសិស្សបើកសៀវភៅទំព័រ ១៦២ អានចំណងជើងមេរៀន រួចគ្រូសរសេរដាក់លើក្តារខៀន | **ជំហានទី៣**<br>(មេរៀនប្រចាំថ្ងៃ)<br>**មេរៀនទី៤**: **ការរើសអើង និងបញ្ហាផ្លូវចិត្ត** | -ធ្វើតាមការណែនាំរបស់គ្រូ |

| | | |
|---|---|---|
| -ឱ្យសិស្សអានខ្លឹមសារមេរៀន<br><br>-គ្រូសរសេរពាក្យពិបាកដាក់លើក្ដារខៀនឱ្យសិស្សឡើងពន្យល់<br><br><br><br><br><br><br><br>-ពន្យល់បន្ថែម និង ឱ្យសិស្សចម្លង<br>-សួរ និងឱ្យសិស្សឡើងសរសេរលើ ក្ដាខៀន | 4. **បញ្ហាផ្លូវចិត្ត**<br><br>**ពន្យល់ពាក្យ**<br>-អសកម្ម (កិ): គ្មានអំពើ នៅស្ងៀម។<br>-ប្រតិកម្ម (កិ): អំពើប្រឆាំង អំពើតទល់។<br>-ឥទ្ធិពល (ន): កម្លាំងនៃឫទ្ធិ អនុភាព អំណាច។<br>-ឱវាទ (ន): ដំបូន្មាន អនុសាសន៍។<br><br>**សកម្មភាពចោទឆ្លើយ** | -សិស្សអានខ្លឹមសារមេរៀន<br><br>-សិស្សសាកល្បងពន្យល់ន័យ<br>-<br><br><br><br><br><br><br>- សិស្សកត់ចូលសៀវភៅ<br>-សិស្សឆ្លើយសំណួរះ |
| ១. តើការតានតឹងចិត្តជាអ្វី? ហើយមនុស្សដែលមានការតានតឹងចិត្តមានអាការៈដូចម្ដេច? | -ការតានតឹងចិត្តជាការប្រែប្រួល ឬប្រតិកម្មនៃអារម្មណ៍ដែលកើតមាននៅពេលបុគ្គលជួបប្រទះហេតុការណ៍ ឬបញ្ហាលំបាកផ្សេងៗ។<br>- អាការៈ ឈឺក្បាល អស់កម្លាំង...។ | -ការតានតឹងចិត្តជាការប្រែប្រួល ឬប្រតិកម្មនៃអារម្មណ៍ដែលកើតមាននៅពេលបុគ្គលជួបប្រទះហេតុការណ៍ ឬបញ្ហាលំបាកផ្សេងៗ។ ហើយមានអាការៈឈឺក្បាល អស់កម្លាំង។ |
| ២. តើការធ្លាក់ទឹកចិត្តជាអ្វី? | -ការធ្លាក់ទឹកចិត្តជាការធ្លាក់ចុះនៃអារម្មណ៍ដែលនាំឱ្យមានភាពក្រៀមក្រំ បាត់បង់ភាពសប្បាយ និងបាត់បង់ចំណាប់អារម្មណ៍ទៅលើអ្វីដែលនៅជុំវិញខ្លួន។ | -ការធ្លាក់ទឹកចិត្តជាការធ្លាក់ចុះនៃអារម្មណ៍ដែលនាំឱ្យមានភាពក្រៀមក្រំ បាត់បង់ភាពសប្បាយនិងបាត់បង់ចំណាប់អារម្មណ៍ទៅលើអ្វីដែលនៅជុំវិញខ្លួន។ |
| ៣. តើមានវិធីអ្វីខ្លះ ដើម្បីព្យាបាលជំងឺផ្លូវចិត្ត? | -វិធីព្យាបាលមានះ<br>• បណ្ដុះស្មារតីសុទិដ្ឋិនិយម និង មានក្ដីសង្ឃឹម។<br>• ទទួលទានអាហារឱ្យទៀងទាត់ សម្រាកឱ្យគ្រប់គ្រាន់។ | -វិធីព្យាបាលមានះ<br>• បណ្ដុះស្មារតីសុទិដ្ឋិនិយម និង មានក្ដីសង្ឃឹម។<br>• ទទួលទានអាហារឱ្យទៀងទាត់ សម្រាកឱ្យគ្រប់គ្រាន់។ |

| | | |
|---|---|---|
| -គ្រូសំយោគឱ្យសិស្សកត់<br>-គ្រូឱ្យសិស្សសង្ខេបមេរៀនឡើងវិញ។<br><br>-ឱ្យសិស្សកត់ចូលសៀវភៅ | • ជជែកលេងជាមួយមិត្តភក្តិជិតស្និត។<br>• ស្តាប់បង្គាប់ឪពុកម្តាយចាស់ទុំ<br>• លេងកីឡា ស្តាប់ភ្លេង ដើរកម្សាន្ត។<br>• ធ្វើលំហាត់ប្រាណ<br>• ពិគ្រោះយោបល់ជាមួយអ្នកទុកចិត្ត ដើម្បីផ្តល់កម្លាំងចិត្ត។<br><br>**មេរៀនសង្ខេប**<br>ការតានតឹងចិត្ត ជាការប្រែប្រួលផ្នែកអារម្មណ៍។មនុស្សដែលមានការតានតឹងចិត្តតែងឆាប់ ឆេវឆាវ មួម៉ៅ ឆាប់ខឹង។ ការធ្លាក់ ទឹកចិត្ត ជាការធ្លាក់ចុះនៃអារម្មណ៍ ឬ ក្តីសង្ឃឹម ។ នេះបបណ្តាលមកពីបាត់បង់នូវមនុស្សជាទីស្រឡាញ់ កិត្តិយស ការងារ ទ្រព្យសម្បត្តិ ឬ ការបរាជ័យ។ | • ជជែកលេងជាមួយមិត្តភក្តិជិតស្និត។<br>• ស្តាប់បង្គាប់ឪពុកម្តាយចាស់ទុំ<br>• លេងកីឡា ស្តាប់ភ្លេង ដើរកម្សាន្ត។<br>• ធ្វើលំហាត់ប្រាណ<br>• ពិគ្រោះយោបល់ជាមួយអ្នកទុកចិត្ត ដើម្បីផ្តល់កម្លាំងចិត្ត។<br>-សិស្សកត់ចូលសៀវភៅ<br>-សិស្សសាកល្បងសង្ខេបមេរៀន<br><br>-សិស្សកត់ចូលសៀវភៅ |
| -តើការធ្លាក់ទឹកចិត្តបណ្តាលមកពីអ្វី?<br><br>-តើមានវិធីអ្វីខ្លះ ដើម្បីព្យាបាលជំងឺផ្លូវចិត្ត ? | **ជំហានទី៤**<br>(ពង្រឹងពុទ្ធិ)<br>-បណ្តាលមកពីបាត់បង់នូវមនុស្សជាទីស្រឡាញ់ កិត្តិយស ការងារ ទ្រព្យសម្បត្តិ ការប្រឡងធ្លាក់ ឬ ការបរាជ័យ។<br>-វិធីព្យាបាលមាន៖<br>• បណ្តុះស្មារតីសុទិដ្ឋិនិយម និង មានក្តីសង្ឃឹម។<br>• ទទួលទានអាហារឱ្យទៀងទាត់ សម្រាកឱ្យគ្រប់គ្រាន់។<br>• ជជែកលេងជាមួយមិត្តភក្តិជិតស្និត។<br>• ស្តាប់បង្គាប់ឪពុកម្តាយចាស់ទុំ | -បណ្តាលមកពីបាត់បង់នូវមនុស្សជាទីស្រឡាញ់ កិត្តិយស ការងារ ទ្រព្យសម្បត្តិ ការប្រឡងធ្លាក់ ឬការបរាជ័យ។<br>-វិធីព្យាបាលមាន៖<br>• បណ្តុះស្មារតីសុទិដ្ឋិនិយម និង មានក្តីសង្ឃឹម។<br>• ទទួលទានអាហារឱ្យទៀងទាត់ សម្រាកឱ្យគ្រប់គ្រាន់។<br>• ជជែកលេងជាមួយមិត្តភក្តិជិតស្និត។<br>• ស្តាប់បង្គាប់ឪពុកម្តាយចា |

| | | |
|---|---|---|
| | • លេងកីឡា ស្តាប់ភ្លេង ដើរកម្សាន្ត។<br>• ធ្វើលំហាត់ប្រាណ<br>• ពិគ្រោះយោបល់ជាមួយអ្នកទុកចិត្ត ដើម្បីផ្តល់កម្លាំងចិត្ត។ | ស់ទុំ<br>• លេងកីឡា ស្តាប់ភ្លេង ដើរកម្សាន្ត។<br>• ធ្វើលំហាត់ប្រាណ<br>• ពិគ្រោះយោបល់ជាមួយអ្នកទុកចិត្ត ដើម្បីផ្តល់កម្លាំងចិត្ត។ |
| -គ្រូដាក់សំណួរឱ្យសិស្សធ្វើនៅផ្ទះ។ | **ជំហានទី៥**<br>(កិច្ចការផ្ទះ)<br>- សំណួរៈ<br>១. តើការរើសអើងយេនឌ័រទាក់ទងនឹងការរំលោភសិទ្ធិមនុស្សអ្វីខ្លះ?<br>២. តើគេត្រូវធ្វើដូចម្តេច ដើម្បីលុបបំបាត់ចោលការរើសអើងទាំងនេះ? | -កត់សំណួរយកទៅធ្វើនៅផ្ទះ |

# កិច្ចតែងការបង្រៀន

- ❖ កាលបរិច្ឆេទ : ថ្ងៃ ទី ខែ ឆ្នាំ
- ❖ មុខវិជ្ជា : សីលធម៌-ពលរដ្ឋវិជ្ជា
- ❖ ថ្នាក់ទី : ៧
- ❖ **ជំពូកទី១** : **យេនឌ័រ និង សិទ្ធិមនុស្ស**
- ❖ **មេរៀនទី៥** : **ការលុបបំបាត់ការរើសអើងចំពោះស្ត្រី**
- ❖ វិធីសាស្ត្រ : គោលវិធីសិស្សមជ្ឈមណ្ឌល (វិធីពិភាក្សាក្រុម)
- ❖ រយៈពេល : ២ ម៉ោងសិក្សា (សម្រាប់ម៉ោងទី១)

## I. **វត្ថុបំណង**

- ➢ ចំណេះដឹង : រៀបរាប់ពីការលុបបំបាត់ចោលរាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទបានត្រឹមត្រូវតាមរយៈរូបភាព សិក្សាអត្ថបទ និង ការពន្យល់របស់គ្រូ ។
- ➢ បំណិន : កំណត់ពីសិទ្ធិរបស់ស្ត្រីក្នុងវិស័យនយោបាយ និង វិស័យអប់រំបានត្រឹមត្រូវតាមរយៈការពិភាក្សាក្រុម ។
- ➢ ឥរិយាបថ : ការពារ និងចូលរួមលុបបំបាត់ការរើសអើងចំពោះស្ត្រី ព្រមទាំងឱ្យតម្លៃលើតួនាទីរបស់ស្ត្រីក្នុងសង្គមបច្ចុប្បន្ន ។

## II. **ខ្លឹមសារមេរៀន**

1. **វិស័យនយោបាយ**
2. **វិស័យអប់រំ**

## III. **សម្ភារឧបទេស**

- សៀវភៅសិក្សាសង្គមថ្នាក់ទី៧ ទំព័រ ១៦៤-១៦៥បោះពុម្ពឆ្នាំ ២០១១
- ប័ណ្ណសំណួរ
- ផ្ទាំងរូបភាព
- ផ្ទាំងមេរៀនសង្ខេប

## IV. ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូពិនិត្យលើ: សណ្តាប់ធ្នាប់ អនាម័យ អវត្តមាន | **ជំហានទី១**<br>(រដ្ឋបាលថ្នាក់)<br>• សណ្តាប់ធ្នាប់<br>• អនាម័យ<br>• អវត្តមាន<br>• ពង្រឹងវិន័យ | -ប្រធានថ្នាក់ឡើងរាយការណ៍ |
| -តើកាលពីថ្ងៃមុនយើងបានសិក្សាមេរៀនអ្វី?<br><br>-ដូចម្តេចដែលហៅថាការរើសអើង?<br><br><br><br><br><br><br><br>-ដើម្បីឱ្យស្ត្រីមានសិទ្ធិស្មើនឹងបុរស តើយើងត្រូវធ្វើដូចម្តេច? | **ជំហានទី២**<br>(រំលឹកមេរៀនចាស់)<br>**មេរៀនទី៤**:<br>**ការរើសអើង និង បញ្ហាផ្លូវភេទ**<br><br>-ជាអំពើដែលបង្ហាញពីការប្រកាន់ ការបែងចែក ការវិនិច្ឆ័យទៅលើអ្នកណាម្នាក់ដោយមិនផ្អែកលើបុគ្គលិកលក្ខណៈរបស់គេ។<br><br><br><br>**ទំនាក់ទំនងមេរៀនថ្មី**<br>-លុបបំបាត់ការរើសអើងចំពោះស្ត្រី ។ | មេរៀនទី៤:<br>ការរើសអើង និង បញ្ហាផ្លូវភេទ<br><br>-ជាអំពើដែលបង្ហាញពីការប្រកាន់ ការបែងចែក ការវិនិច្ឆ័យទៅលើអ្នកណាម្នាក់ដោយមិនផ្អែកលើបុគ្គលិកលក្ខណៈផ្ទាល់ខ្លួន របស់គេ និង ជាអំពើដែលមានភាពលម្អៀងទៅលើអាយុ សមត្ថភាព ពូជសាសន៍ ភេទ និង សាសនាជាដើម។<br><br>-ដើម្បីឱ្យស្ត្រីមានសិទ្ធិស្មើនឹងបុរស យើងត្រូវលុបបំបាត់ការរើសអើងចំពោះស្ត្រី។ |
| -ឱ្យសិស្សបើកសៀវភៅទំព័រ ១៦៤ រួចអានចំណងជើងមេរៀន<br><br><br><br>-សរសេរចំណងជើងមេរៀនដាក់លើក្តារខៀន | **ជំហានទី៣**<br>(មេរៀនប្រចាំថ្ងៃ)<br>**មេរៀនទី៥**:<br>**ការលុបបំបាត់ការរើសអើងចំពោះស្ត្រី**<br><br>សិក្សាចំណងលើជើង<br>-ការលុបបំបាត់ចោលនូវការបែងចែកប្រកាន់ ភាពលំអៀងចំពោះ | -អានចំណងជើងមេរៀន<br><br><br><br>-មានន័យថាការលុបបំបាត់ចោលនូវការបែងចែកបក្សពួកការប្រកាន់ |

| | | |
|---|---|---|
| –តើចំណងជើងមេរៀននេះមាន ន័យដូចម្តេច? | ស្ត្រី។ | ពូជសាសន៍ ភេទ សាសនាជាដើម។ |
| | **សិក្សាលើរូបភាព** | |
| –តើនៅក្នុងរូបភាពនេះប្អូនអ្វីខ្លះ? (ទំព័រ១៦៥) | –ឃើញ និស្សិតប្រុស-ស្រីពីរនាក់ ក្មេងប្រុសដាំបាយ ក្មេងស្រីជូតផ្ទះ និង ស្ត្រីម្នាក់កាប់សាច់។ | –ឃើញ និស្សិត ក្មេងប្រុស-ស្រី ស្ត្រីម្នាក់ កំសៀវ និង អុស។ |
| –តើរូបភាពនេះបង្ហាញពីអ្វី? | –ការចេះជួយការងារគ្នាក្នុងផ្ទះ ដោយមិនប្រកាន់តួនាទី ប្រុស ឬ ស្រី។ | –រូបភាពនេះបង្ហាញពីការចេះជួយគ្នាដោយមិនប្រកាន់ការងារ ប្រុស-ស្រី និង មានសិទ្ធិស្មើគ្នារវាងបុរស និង ស្ត្រី។ |
| | **ទំនាក់ទំនងរូបភាព និង ចំណងជើង** | |
| –តើរូបភាពនិងចំណងជើងមានទំនាក់ទំនងនឹងគ្នាដែរឬទេ? | –ព្រោះរូបភាព និង ចំណងជើងសុទ្ធតែបង្ហាញពីសិទ្ធិស្មើគ្នារវាងបុរសនិង ស្ត្រី។ | –មានទំនាក់ទំនងនឹងគ្នាព្រោះ រូបភាព និង ចំណងជើងសុទ្ធតែ បង្ហាញពីសិទ្ធិស្មើគ្នារវាងបុរស និង ស្ត្រី។ |
| –ឱ្យសិស្សអានខ្លឹមសារមេរៀន ទំព័រ ១៦៤-១៦៥ | | –អានខ្លឹមសារមេរៀនបណ្តាក់គ្នា |
| –សរសេរពាក្យពិបាកលើក្តារខៀន រួចឱ្យសិស្សឡើងពន្យល់ | **ពន្យល់ពាក្យ** | –ឡើងពន្យល់ន័យនៃពាក្យ |
| | –សិទ្ធិ (ន): អ្វីៗដែលយើងអាចធ្វើ បាន តែស្ថិតនៅក្រោមច្បាប់។<br>–អនុសញ្ញា (ន) : កិច្ចព្រមព្រៀងដែលគ្មានថ្ងៃកំណត់របស់ ប្រទេសនានា។<br>–អនុម័ត (ន) : ការយល់ព្រម ។ | –ចូលតាមក្រុមពិភាក្សា |
| –បែងចែកសិស្សជា៤ក្រុម៖ | សកម្មភាពក្រុម | |
| –**ក្រុមទី១**: តើនៅថ្ងៃទី 18 ខែធ្នូ ឆ្នាំ 1979 មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តអនុសញ្ញាស្តីពីអ្វី? | –ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ។ | –អនុម័តអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ។ |
| –**ក្រុមទី២**: តើខ្លឹមសារអនុសញ្ញានេះមានអ្វីខ្លះ? | –គឺទាមទារឱ្យបំបាត់ចោលការកេងប្រវ័ញ្ច ការរើសអើងនារីភេទ ដើម្បី | –អនុសញ្ញានេះគឺទាមទារឱ្យបំបាត់ចោលការកេងប្រវ័ញ្ច ការ |

| | | |
|---|---|---|
| | លើកកំពស់ស្ថានភាព និង គោរពសិទ្ធិស្ត្រីដែលធានានូវឱកាសស្មើគ្នាលើគ្រប់វិស័យ។ | រើសអើងនារីភេទ ដើម្បីលើកកំពស់ស្ថានភាព និង គោរពសិទ្ធិស្ត្រីដើម្បីលើកកំពស់សិទ្ធិស្ត្រី។ |
| -**ក្រុមទី៣**: តើនៅក្នុងវិស័យនយោបាយស្ត្រីទទួលបានសិទ្ធិអ្វីខ្លះ? | • សិទ្ធិបោះឆ្នោត និង ឈរឈ្មោះឱ្យគេបោះឆ្នោត។<br>• ចូលរួមចាត់ចែង និង អនុវត្តគោលនយោបាយរបស់រដ្ឋ។<br>• ចូលរួមក្នុងអង្គការ និង សមាគមមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធនិងជីវភាពសាធារណៈ។<br>• ធ្វើជាតំណាងរដ្ឋាភិបាលនៅថ្នាក់អន្តរជាតិ និង ចូលរួមក្នុងកិច្ចការរបស់អង្គការអន្តរជាតិ | -ស្ត្រីទទួលបានសិទ្ធិដូចជា៖<br>• សិទ្ធិបោះឆ្នោត និង ឈរឈ្មោះឱ្យគេបោះឆ្នោត។<br>• ចូលរួមចាត់ចែង និង អនុវត្តគោលនយោបាយរបស់រដ្ឋ។<br>• ចូលរួមក្នុងអង្គការ និង សមាគមមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធនិងជីវភាពសាធារណៈ។<br>• ធ្វើជាតំណាងរដ្ឋាភិបាលនៅថ្នាក់អន្តរជាតិ និង ចូលរួមក្នុងកិច្ចការរបស់អង្គការអន្តរជាតិ។ |
| -**ក្រុមទី៤**: តើក្នុងវិស័យអប់រំស្ត្រីមានសមត្ថភាពជាមួយបុរសដូចម្តេចខ្លះ? | -ស្ត្រីមានសមត្ថភាពដូចជា៖<br>• ការទទួលការសិក្សាសញ្ញាប័ត្រក្នុងគ្រឹះស្ថានអប់រំគ្រប់ប្រភេទទាំងនៅជនបទ ទីក្រុង ការអប់រំចំណេះដឹងទូទៅ និង ការអប់រំបណ្តុះបណ្តាលគ្រប់ប្រភេទ។<br>• ឱកាសចូលរួមសកម្មភាពកំសាន្ត កីឡា និង ជីវភាពវប្បធម៌។<br>• ឱកាសដូចគ្នាក្នុងការទទួលអាហាររូបករណ៍ និង ប្រាក់សម្រាប់ការសិក្សា។<br>• ការទទួលព័ត៌មានពិសេសជាក់លាក់ដើម្បីជួយធានាសុខភាព និង សុខុមាលភាព | -ស្ត្រីមានសមត្ថភាពដូចជា៖<br>• ការទទួលការសិក្សាសញ្ញាប័ត្រក្នុងគ្រឹះស្ថានអប់រំគ្រប់ប្រភេទទាំងនៅជនបទ ទីក្រុង ការអប់រំចំណេះដឹងទូទៅ និង ការអប់រំបណ្តុះបណ្តាលគ្រប់ប្រភេទ។<br>• ឱកាសចូលរួមសកម្មភាពកំសាន្ត កីឡា និង ជីវភាពវប្បធម៌។<br>• ឱកាសដូចគ្នាក្នុងការទទួលអាហាររូបករណ៍ និង ប្រាក់សម្រាប់ការសិក្សា។<br>• ការទទួលព័ត៌មានពិសេសជាក់លាក់ដើម្បីជួយធានាសុខភាព និង សុខុមាលភាព |

| | | |
|---|---|---|
| -សំយោគចម្លើយឱ្យសិស្សកត់ត្រាចូលសៀវភៅ<br>-ឱ្យសិស្សសាកល្បងទាញសង្ខេបមេរៀនឡើងវិញ<br><br><br><br><br><br><br><br><br><br><br>-សម្រួលឱ្យសិស្សកត់ចូលសៀវភៅ | គ្រួសារ។<br><br><br>**មេរៀនសង្ខេប**<br><br>ស្ត្រី និង បុរសមានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់។ នៅក្នុងវិស័យនយោបាយស្ត្រីចូលរួមបោះឆ្នោង និងឈរឈ្មោះឱ្យគេបោះឆ្នោតចូលរួមក្នុងអង្គការសហគមផ្សេងៗដែលទាក់ទងនឹងជីវភាពរស់នៅ និង នយោបាយរបស់ គិ។ វិស័យអប់រំស្ត្រីទទួលបានការសិក្សាគ្រប់កម្រិតគ្រប់ជំនាញទាំងអស់ ហើយទទួលបានអាហាររូបករណ៍ ឬ ប្រាក់សម្រាប់ការសិក្សា។ | គ្រួសារ។<br>-កត់ត្រាចូលសៀវភៅរៀងៗខ្លួន<br><br>-សាកល្បងសង្ខេបមេរៀន<br><br><br><br><br><br><br><br><br><br><br><br>-កត់ចូលសៀវភៅទាំងអស់គ្នា |
| <br><br>-ឱ្យសិស្សបិទសៀវភៅ<br>-តើខ្លឹមសារនៃអនុសញ្ញាទាមទារលប់បំបាត់ចោលអ្វីខ្លះ?<br><br><br>-តើក្នុងវិស័យអប់រំស្ត្រីមានសមត្ថភាពជាមួយបុរសដូចម្តេចខ្លះ? | **ជំហានទី៤**<br>(ពង្រឹងពុទ្ធិ)<br><br>-ការលប់បំបាត់ការកេងប្រវ័ញ្ចការរើសអើងនារីភេទ<br>ដើម្បីលើកកម្ពស់ស្ថានភាព និងគោរពសិទ្ធិស្ត្រី។<br>-ទទួលបានការសិក្សាគ្រប់កម្រិតគ្រប់ជំនាញទទួលបានអាហាររូបករណ៍ ឬប្រាក់សម្រាប់ការសិក្សា។ | <br><br>-បិទសៀវភៅទាំងអស់គ្នា<br>-អនុសញ្ញាគឺការលប់បំបាត់ការកេងប្រវ័ញ្ច ការរើសអើងនារីភេទ<br>ដើម្បីលើកកម្ពស់ស្ថានភាព និងគោរពសិទ្ធិស្ត្រី។<br>-មានសមត្ថភាព ទទួលបានការសិក្សាគ្រប់កម្រិត គ្រប់ជំនាញទទួលបានអាហាររូបករណ៍ ឬប្រាក់សម្រាប់ការសិក្សា។ |
| <br><br>-ពេលប្អូនទៅផ្ទះវិញត្រូវមើលមេរៀនបន្តទៀតផង មេរៀនយើងមិនទាន់ចប់ទេ ហើយជួយធ្វើការងារឪពុកម្តាយផង។ | **ជំហានទី៥**<br>(បណ្តាំផ្ញើ)<br>- ទំព័រ ១៦៥-១៦៦ | <br><br>-ស្តាប់ដោយយកចិត្តទុកដាក់ និង អនុវត្តតាម ។ |

# កិច្ចតែងការបង្រៀន

- ❖ កាលបរិច្ឆេទ : ថ្ងៃ ទី ខែ ឆ្នាំ
- ❖ មុខវិជ្ជា : សីលធម៌-ពលរដ្ឋវិជ្ជា
- ❖ ថ្នាក់ទី : ៧
- ❖ **ជំពូកទី១** : **យេនឌ័រ និង សិទ្ធិមនុស្ស**
- ❖ **មេរៀនទី៥** : **ការលុបបំបាត់ការរើសអើងចំពោះស្ត្រី**
- ❖ វិធីសាស្ត្រ : គោលវិធីសិស្សមជ្ឈមណ្ឌល (ពិភាក្សាក្រុម)
- ❖ រយៈពេល : ២ ម៉ោងសិក្សា (សម្រាប់ម៉ោងទី២)

## I. វត្ថុបំណង

- ➢ ចំណេះដឹង : ពណ៌នាខ្លឹមសារ ឬវិធីសំខាន់ៗនៃការបំបាត់ចោលរាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ បានត្រឹមត្រូវតាមរយៈការអានខ្លឹមសារមេរៀន និង ការពន្យល់របស់គ្រូ ។
- ➢ បំណិន : កំណត់បានពីសិទ្ធិស្ត្រី និង ការផ្តល់សិទ្ធិឱ្យស្ត្រីនៅតាមជនបទបានត្រឹមត្រូវតាមរយៈការពិភាក្សាក្រុម។
- ➢ ឥរិយាបថ : ព្យាយាមនិងចូលរួមលុបបំបាត់ការរើសអើងចំពោះស្ត្រីក្នុងសង្គមបច្ចុប្បន្ន ។

## II. ខ្លឹមសារមេរៀន

3. **វិស័យការងារ**
4. **ស្ត្រីនៅជនបទ**

## III. សម្ភារឧបទេស

- ▪ សៀវភៅសិក្សាសង្គមថ្នាក់ទី៧ ទំព័រ ១៦៥-១៦៦ បោះពុម្ពឆ្នាំ ២០១១
- ▪ ប័ណ្ណសំណួរ
- ▪ ផ្ទាំងមេរៀនសង្ខេប

IV. **ដំណើរការបង្រៀន**

| **សកម្មភាពគ្រូ** | **ខ្លឹមសារមេរៀន** | **សកម្មភាពសិស្ស** |
|---|---|---|
| -ពិនិត្យលើៈ សណ្តាប់ធ្នាប់ អនាម័យ អវត្តមាន | **ជំហានទី១**<br>(រដ្ឋបាលថ្នាក់)<br>• សណ្តាប់ធ្នាប់<br>• អនាម័យ<br>• អវត្តមាន<br>• ពង្រឹងវិន័យ | -ប្រធានថ្នាក់ឡើងរាយការណ៍ |
| -តើកាលពីថ្ងៃមុនប្អូនបានសិក្សាពីមេរៀនអ្វី?<br><br>-តើខ្លឹមសារនៃអនុសញ្ញាទាមទាការលប់បំបាត់ចោលអ្វីខ្លះ?<br><br>-តើក្នុងវិស័យអប់រំស្ត្រីមានសមត្ថភាពជាមួយបុរសដូចម្តេច ?<br><br>-ក្រៅពីវិស័យនយោបាយ និងវិស័យអប់រំតើស្ត្រីទទួលបានសិទ្ធិក្នុងវិស័យអ្វីខ្លះ? | **ជំហានទី២**<br>(រំលឹកមេរៀនចាស់)<br>**មេរៀនទី៥ៈការលប់បំបាត់ការរើស អើងចំពោះស្ត្រី**<br><br>-ការកេងប្រវ័ញ្ច ការរើសអើងនារីភេទ ដើម្បីលើកកំពស់ស្ថានភាព និង គោរពសិទ្ធិស្ត្រី។<br><br>-ទទួលបានការសិក្សាគ្រប់កម្រិត គ្រប់ជំនាញទទួលបានអាហាររូបករណ៍ ឬប្រាក់សម្រាប់ការសិក្សា។<br><br>ទំនាក់ទំនងមេរៀនថ្មី<br>-វិស័យការងារ ។ | -ឆ្លើយតាមការចងចាំ<br><br>-ទាមទាលប់បំបាត់ចោលនូវការកេងប្រវ័ញ្ច ការរើសអើងនារីភេទ ដើម្បីលើកកំពស់ស្ថានភាព និង គោរពសិទ្ធិស្ត្រី។<br><br>-មានសមត្ថភាព ទទួលបានការសិក្សាគ្រប់កម្រិត គ្រប់ជំនាញ ទទួលបានអាហាររូបករណ៍ ឬ ប្រាក់សម្រាប់ការសិក្សា។<br><br>-ក្នុងវិស័យការងារ ។ |
| -ឱ្យសិស្សបើកសៀវភៅទំព័រ ១៦៥-១៦៦ អានចំណងជើងរួចអានខ្លឹមសារមេរៀនបន្ត | **ជំហានទី៣**<br>(មេរៀនប្រចាំថ្ងៃ)<br>**មេរៀនទី៥ៈការលប់បំបាត់ការរើសអើង ចំពោះស្ត្រី**<br><br>3. **វិស័យការងារ**<br>4. **ស្ត្រីនៅជនបទ** | -អានចំណងជើង និងខ្លឹមសារមេរៀន |

| | | |
|---|---|---|
| –សរសេរពាក្យពិបាកលើក្ដារខៀន រួចឱ្យសិស្សឡើងពន្យល់ | **ពន្យល់ពាក្យ**<br>–វិនិច្ឆ័យ(ន) : ការពិចារណាដោយល្អិតល្អន់។<br>–អភិវឌ្ឍន៍(ន) : ការរីកចម្រើន លូតលាស់។<br>–អក្ខរកម្ម(ន) : ការបង្រៀនឱ្យចេះអក្សរ។ | –ឡើងពន្យល់ន័យ |
| –សម្រួលឱ្យសិស្សកត់ | | –កត់ចូលសៀវភៅ |
| –បែងចែកសិស្សជា៤ក្រុម៖ | **សកម្មភាពក្រុម** | –ចូលតាមក្រុមពិភាក្សា |
| –**ក្រុមទី១**: តើគេត្រូវផ្ដល់សិទ្ធិឱ្យស្ត្រីក្នុងវិស័យអ្វីខ្លះ? | –គេផ្ដល់សិទ្ធិឱ្យស្ត្រីដូចជា៖<br>• វិស័យនយោបាយ<br>• វិស័យអប់រំ<br>• វិស័យការងារ<br>• ជនបទ។ | –គេផ្ដល់សិទ្ធិឱ្យស្ត្រីដូចជា៖<br>• វិស័យនយោបាយ<br>• វិស័យអប់រំ<br>• វិស័យការងារ<br>• ស្ត្រីនៅជនបទ។ |
| –**ក្រុមទី២**: តើក្នុងវិស័យការងារស្ត្រី និងបុរសមានសិទ្ធិដូចគ្នាដូចម្ដេចខ្លះ? | –ស្ត្រី និង បុរស់មានសិទ្ធស្មើគ្នាគឺ សិទ្ធិ មានឱកាសធ្វើការងារទទួលបានប្រាក់បំណាច់ស្មើគ្នា ទទួលបានការតំឡើងស័គ្គ និង ត្រូវទទួលបានប្រាក់ឧបត្ថម្ភនៅពេលគ្មានការងារធ្វើ ពេលមានជំងឺ និងសម្រាកលំហែមាតុភាព។ | –ស្ត្រី និង បុរស់មានសិទ្ធស្មើគ្នាគឺ សិទ្ធិមានឱកាសធ្វើការងារទទួលបានប្រាក់បំណាច់ស្មើគ្នាទទួលបានការតំឡើងស័ក្តិ និងត្រូវទទួលបានប្រាក់ឧបត្ថម្ភនៅពេលគ្មានការងារធ្វើ ពេលមានជំងឺ និងសម្រាកលំហែមាតុភាព។ |
| –**ក្រុមទី៣**: តើរាជរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់ចំពោះស្ត្រីនៅជនបទដោយផ្ដល់ឱ្យគេនៅសិទ្ធិអ្វីខ្លះ? | –ស្ត្រីត្រូវបានចូលរួមក្នុងការអភិវឌ្ឍនៅសហគមន៍ទទួលបានសេវាគ្រប់គ្រាន់ខាងវិស័យសុខាភិបាលព័ត៌មាន និង ដំបូន្មាន មានផ្ទះសម្បែងប្រកបដោយអនាម័យ ទឹក អគ្គីសនីគមនាគមន៍។ | –រាជរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់ចំពោះស្ត្រីដូចជា៖<br>• ស្ត្រីត្រូវបានចូលរួមក្នុងការអភិវឌ្ឍនៅសហគមន៍។<br>• ទទួលបានសេវាគ្រប់គ្រាន់ខាងវិស័យសុខាភិបាលព័ត៌មាន និង ដំបូន្មាន។<br>• ទទួលបានអត្ថប្រយោ- |

| | | |
|---|---|---|
| -**ក្រុមទី៤**:តើសិស្សស្រីត្រូវរកវិធីដូចម្តេចខ្លះដើម្បីឱ្យខ្លួនបានរៀនសូត្រខ្ពង់ខ្ពស់ និង មានលទ្ធភាពរកការងារធ្វើបាន?<br><br>-សម្រួលឱ្យសិស្សកត់ត្រា<br><br>-ឱ្យសិស្សសាកល្បងសង្ខេបមេរៀនឡើងវិញ<br><br>-ឱ្យសិស្សកត់ចូលសៀវភៅ | -សិស្សស្រីត្រូវរកវិធីដូចជា៖<br>• តាំងចិត្តឱ្យក្លាហាន តស៊ូ អំណត់ ព្យាយាមជានិច្ច មិនត្រូវចុះញ៉មនឹងអ្នកដែលមានបុរេនិច្ឆ័យខុសឆ្គង។<br>• ត្រូវចេះស្វែងរកការងារខាងក្រៅធ្វើ។<br>• ត្រូវចេះដកស្រង់នូវបទពិសោធន៍ល្អពីអ្នកដទៃ និង ត្រូវមានគំនិតអភិវឌ្ឍជានិច្ច។<br><br>**មេរៀនសង្ខេប**<br>ស្ត្រីមានសិទ្ធិស្មើបុរសក្នុងគ្រប់វិស័យដូចជាវិស័យនយោបាយ វិស័យអប់រំ និង វិស័យការងារ ។ នៅក្នុងវិស័យការងារស្ត្រីមានសិទ្ធិមានការងារធ្វើ ទទួលបានប្រាក់បំណាច់ស្មើគ្នា ទទួលបានប្រាក់ ដំឡើងស័ក្តិ និង ទទួលបានប្រាក់ឧបត្ថម្ភ ។ ស្ត្រីនៅជនបទ មានសិទ្ធិចូលរួមក្នុងការងារអភិវឌ្ឍសហគមន៍ ទទួលបានគ្រប់សេវា ខាងវិស័យសុខាភិបាល ការអប់រំ អគ្គីសនី និងគមនាគមន៍។ | ជន៍ដោយផ្ទាល់ពីកម្មវិធីសន្តិសុខសង្គម ។<br>• ទទួលបានការអប់រំក្នុង និង ក្រៅប្រព័ន្ធ និង ការអប់រំអក្ខរកម្មបង្កើតមុខរបរផង។<br>-សិស្សស្រីត្រូវរកវិធីដូចជា៖<br>• តាំងចិត្តឱ្យក្លាហាន តស៊ូ អំណត់ ព្យាយាមជានិច្ច មិនត្រូវចុះញ៉មនឹងអ្នកដែលមានបុរេនិច្ឆ័យខុសឆ្គង។<br>• ត្រូវចេះស្វែងរកការងារខាងក្រៅធ្វើ។<br>• ត្រូវចេះដកស្រង់នូវបទពិសោធន៍ល្អពីអ្នកដទៃ និង ត្រូវមានគំនិតអភិវឌ្ឍជានិច្ច។<br>-កត់ចូលសៀវភៅទាំងអស់គ្នា<br><br>-សាកល្បងសង្ខេបមេរៀន<br>ស្ត្រីមានសិទ្ធិស្មើបុរសក្នុងគ្រប់វិស័យដូចជាវិស័យនយោបាយ វិស័យអប់រំ និង វិស័យការងារ។ នៅក្នុងវិស័យការងារស្ត្រីមានសិទ្ធិមានការងារធ្វើទទួលបានប្រាក់បំណាច់ស្មើគ្នា ទទួលបានប្រាក់ដំឡើងស័ក្តិ និង ទទួលបានប្រាក់ឧបត្ថម្ភ។ ស្ត្រីនៅជនបទមានសិទ្ធិចូលរួមក្នុងការងារអភិវឌ្ឍសហគមន៍ទទួលបានគ្រប់សេវាខាងវិស័យសុខាភិបាល ការអប់រំ អគ្គីសនី និង គមនាគមន៍។<br>-កត់ចូលសៀវភៅ |
| | **ជំហានទី៤**<br>(ពង្រឹងពុទ្ធិ) | |

| | | |
|---|---|---|
| –តើរាជរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់ចំពោះស្ត្រីនៅជនបទ ដោយផ្តល់ឱ្យគេនៅសិទ្ធិអ្វីខ្លះ?<br><br>–តើសិស្សស្រីត្រូវរកវិធីដូចម្តេចខ្លះ ដើម្បីឱ្យខ្លួនបានរៀនសូត្របានខ្ពង់ខ្ពស់ និង មានលទ្ធភាពរកការងារធ្វើបាន? | –ចូលរួមក្នុងការអភិវឌ្ឍនៅសហគមន៍ ទទួលបានគ្រប់សេវាខាងវិស័យសុខាភិបាល ព័ត៌មាន ការអប់រំ មានផ្ទះសម្បែង។<br><br>–សិស្សស្រីត្រូវរកវិធីដូចជា៖<br>• តាំងចិត្តឱ្យក្លាហាន<br>• ស្វែងរកការងារខាងក្រៅម៉ោងធ្វើ<br>• ចេះដកស្រង់បទពិសោធន៍ល្អៗពីអ្នកដទៃ<br>• មានគំនិតអភិវឌ្ឍន៍ជានិច្ច។ | –ស្ត្រីត្រូវចូលរួមក្នុងការអភិវឌ្ឍនៅសហគមន៍ ទទួលបានគ្រប់សេវាខាងវិស័យសុខាភិបាលព័ត៌មាន ការអប់រំ មានផ្ទះសម្បែងប្រកបដោយអនាម័យ។<br>–សិស្សស្រីត្រូវរកវិធីដូចជា៖<br>• តាំងចិត្តឱ្យក្លាហាន<br>• ស្វែងរកការងារខាងក្រៅម៉ោងធ្វើ<br>• ចេះដកស្រង់បទពិសោធន៍ល្អៗពីអ្នកដទៃ<br>• មានគំនិតអភិវឌ្ឍន៍ជានិច្ច។ |
| –ពេលប្អូនទៅផ្ទះវិញសូមធ្វើលំហាត់នៅទំព័រ ១៦៧ផង និង ជួយធ្វើការងារផ្ទះផងកុំដើរលេងច្រើនពេក។ | **ជំហានទី៥**<br>(បណ្តាំផ្ញើ) | –សិស្សស្តាប់គ្រូដោយយកចិត្តទុកដាក់ និង អនុវត្តតាម។ |

# កិច្ចតែងការបង្រៀន

- ❖ កាលបរិច្ឆេទ : ថ្ងៃ ទី ខែ ឆ្នាំ
- ❖ មុខវិជ្ជា : សីលធម៌-ពលរដ្ឋវិជ្ជា
- ❖ ថ្នាក់ទី : ៧
- ❖ **ជំពូកទី១** : **យេនឌ័រ និង សិទ្ធិមនុស្ស**
- ❖ **មេរៀនទី៦** : **ឧបាទានការធានាសមភាពយេនឌ័រ**
- ❖ វិធីសាស្ត្របង្រៀន : គោលវិធីសិស្សមជ្ឈមណ្ឌល (វិធីពិភាក្សាក្រុម)
- ❖ រយៈពេល : ២ម៉ោងសិក្សា (សម្រាប់ម៉ោងទី១)

## I. វត្ថុបំណង

- ➢ ចំណេះដឹង : សម្គាល់ពីបញ្ញត្តិយេនឌ័រ បានត្រឹមត្រូវតាមរយៈការពន្យល់ខ្លឹមសារមេរៀនរបស់គ្រូ ។
- ➢ បំណិន : កំណត់ពីច្បាប់ និងគោលនយោបាយលើអនុសញ្ញាអន្តរជាតិសំខាន់ៗដែលគាំទ្រស្ត្រី និងកុមារ បានត្រឹមត្រូវតាមរយៈការពិភាក្សាក្រុម។
- ➢ ឥរិយាបថ : ការពារ និង គោរពសិទ្ធិគ្នាទៅវិញទៅមកដោយមិនប្រកាន់ ភេទ វណ្ណៈក្នុងសង្គមបច្ចុប្បន្ន ។

## II. ខ្លឹមសារមេរៀន

1. **រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា**

## III. សម្ភារឧបទេស

- ▪ សៀវភៅសិក្សាសង្គមថ្នាក់ទី៧ ទំព័រ ១៦៨-១៦៩ បោះពុម្ពឆ្នាំ ២០១១
- ▪ ប័ណ្ណសំណួរ
- ▪ ផ្ទាំងរូបភាព
- ▪ ផ្ទាំងមេរៀនសង្ខេប

IV. **ដំណើរការបង្រៀន**

| **សកម្មភាពគ្រូ** | **ខ្លឹមសារមេរៀន** | **សកម្មភាពសិស្ស** |
|---|---|---|
| -គ្រូគពិនិត្យលើ : សណ្តាប់ធ្នាប់ អនាម័យ វិន័យ អវត្តមាន | **ជំហានទី១**<br>(រដ្ឋបាលថ្នាក់) | -ប្រធានថ្នាក់ឡើងរាយការណ៍។ |
| -តើកាលពីថ្ងៃមុនយើងបានសិក្សាពីមេរៀនអ្វី?<br><br>-តើអនុសញ្ញាស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងនឹងនារីភេទដែលអនុម័តដោយអ.ស.ជ ធ្វើឡើងនៅថ្ងៃខែឆ្នាំណា?<br><br>- តើសិស្សស្រីត្រូវរកវិធីអ្វីខ្លះដើម្បីឱ្យខ្លួនបានរៀនសូត្រខ្ពង់ខ្ពស់និងមានលទ្ធភាពរកការងារធ្វើបាន?<br><br>-ការមិនរើសអើងចំពោះបុរសស្ត្រីហៅថាអ្វី? | **ជំហានទី២**<br>(រំឭកមេរៀនចាស់)<br>មេរៀនទី៥: ការលប់បំបាត់ការរើសអើងស្ត្រីចំពោះស្ត្រី<br><br>-សញ្ញាស្តីពីការលប់បំបាត់ការរើសអើងប្រឆាំងនឹងនារីភេទដែលអនុម័តដោយអ.ស.ជធ្វើឡើងនៅថ្ងៃទី១៨ ធ្នូ ១៩៧៩។<br><br>-សិស្សស្រីត្រូវរកវិធីដូចជា៖<br>• តាំងចិត្តឱ្យក្លាហាន តស៊ូ អំណត់ព្យាយាមជានិច្ច មិនត្រូវចុះញ៉ោមនិងដំណៀលពីសំណាក់អ្នកល្ងង់ ឬអ្នកដែលមានបុរេនិច្ឆ័យ។<br>• ស្វែងរកការងារធ្វើនៅក្រៅ<br>• ដកស្រង់បទពិសោធពីអ្នកដទៃ និងត្រូវមានគំនិតអភិវឌ្ឍជានិច្ច។<br><br><u>**ទំនាក់ទំនងមេរៀនថ្មី**</u><br>-យេនឌ័រ | មេរៀនទី៥: ការលប់បំបាត់ការរើសអើងស្ត្រីចំពោះស្ត្រី<br>-សញ្ញាស្តីពីការលប់បំបាត់ការរើសអើងប្រឆាំងនឹងនារីភេទដែលអនុម័តដោយអ.ស.ជ ធ្វើឡើងនៅថ្ងៃទី១៨ ធ្នូ ១៩៧៩។<br><br>-សិស្សស្រីត្រូវរកវិធីដូចជា៖<br>• តាំងចិត្តឱ្យក្លាហាន តស៊ូ អំណត់ព្យាយាមជានិច្ច មិនត្រូវចុះញ៉ោមនិងដំណៀលពីសំណាក់អ្នកល្ងង់ ឬអ្នកដែលមានបុរេនិច្ឆ័យ។<br>• ស្វែងរកការងារធ្វើនៅក្រៅ<br>• ដកស្រង់បទពិសោធពីអ្នកដទៃ និងត្រូវមានគំនិតអភិវឌ្ឍជានិច្ច។<br><br>-ហៅថាយេនឌ័រ |
| -ឱ្យសិស្សបើកសៀវភៅទំព័រ ១៦៨ អានចំណងជើងមេរៀន | **ជំហានទី៣**<br>(មេរៀនប្រចាំថ្ងៃ)<br>**មេរៀនទី៦**:<br>**ទិដ្ឋភាពការធានាសមភាពយេនឌ័រ** | -ធ្វើតាមការណែនាំរបស់គ្រូ |

| | | |
|---|---|---|
| រួចគ្រូសរសេរដាក់លើក្តារខៀន | | |
| | **សិក្សាចំណាងជើង** | |
| -តើចំណាងជើងមានន័យដូចម្តេច? | -មានន័យថា ការរៀបចំ ឬគម្រោងការការការពារភាពស្មើគ្នារវាងបុរស និងស្ត្រី។ | -មានន័យថា ការរៀបចំ ឬគម្រោងការការការពារភាពស្មើគ្នារវាងបុរស និងស្ត្រី។ |
| | **សិក្សារូបភាព** | |
| -តើប្អូនឃើញអ្វីខ្លះក្នុងរូបភាព? (ទំព័រ ១៦៨-១៦៩) | -ឃើញ អ្នកគ្រូ សិស្ស សៀវភៅ តុ ទូ...។ | -រូបភាពឃើញ អ្នកគ្រូ សិស្ស សៀវភៅ តុ ទូ...។ |
| | **ទំនាក់ទំនងរូបភាពនិងចំណាងជើង** | |
| -តើរូបភាពនិងចំណាងជើងមានន័យដូចម្តេច? | -ភាពស្មើគ្នារវាងបុរស និងស្ត្រី។ | -ភាពស្មើគ្នារវាងបុរស និងស្ត្រី។ |
| -តើរូបភាពនិងចំណាងជើងមានទំនាក់ទំនងគ្នាដែរឬទេ? ព្រោះអ្វី? | -មាន ព្រោះរូបភាពបង្ហាញពីបុរសម្នាក់ នារីម្នាក់។ ចំណោកចំណាងជើងនិយាយពីភាពស្មើគ្នារវាងបុរស និងស្ត្រី។ | -មាន ព្រោះរូបភាពបង្ហាញពីបុរសម្នាក់ នារីម្នាក់។ ចំណោកចំណាងជើងនិយាយពីភាពស្មើគ្នារវាងបុរស និងស្ត្រី។ |
| -ឱ្យសិស្សអានខ្លឹមសារមេរៀន ទំព័រ ១៦៨-១៦៩ | 1. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា | -អាន |
| -គ្រូសរសេរពាក្យពិបាកដាក់លើក្តារខៀនឱ្យសិស្សឡើងពន្យល់ | **ពន្យល់ពាក្យ**<br>-យុទ្ធសាស្ត្រ (ន): ក្បួន ឬវិធីក្នុងការធ្វើអ្វីមួយ។<br>-អនសញ្ញា (ន): កិច្ចព្រមព្រៀង។<br>-រដ្ឋធម្មនុញ្ញ (ន): ច្បាប់កំពូលរបស់ប្រទេសនីមួយៗ ។<br>-សង្គមកិច្ច (ន): កិច្ចការក្នុងសង្គម។ | -សិស្សឡើងពន្យល់ន័យ |
| -គ្រូសំយោគឱ្យសិស្សកត់ | | -សិស្សកត់ចូលសៀវភៅ |
| -គ្រូបែងចែកសិស្សជា៤ក្រុមៈ<br>**-ក្រុមទី១:** តើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ | **ពិភាក្សាក្រុម**<br>- ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានភាព ស្មើគ្នាចំពោះមុខច្បាប់ | -ចូលតាមក្រុមពិភាក្សា<br>-បានកំណត់ថា ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានភាពស្មើគ្នា |

| | | |
|---|---|---|
| មាត្រា៣៥បានកំណត់ដូចម្ដេច?<br><br><br><br><br><br>**-ក្រុមទី២:** តើមាត្រា៣៦ នៃច្បាប់ធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ដូចម្ដេច?<br><br><br><br>**-ក្រុមទី៣:** ដើម្បីលើកស្ទួយសមភាពយេនឌ័រ តើយើងត្រូវធ្វើដូចម្ដេច?<br><br><br><br>**-ក្រុមទី៤:** តើមានច្បាប់អ្វីដើម្បីធានាឱ្យមានសមភាពយេនឌ័រ?<br><br><br><br><br><br><br>-គ្រូសំយោគចម្លើយឱ្យសិស្សកត់<br><br>-គ្រូសាកល្បងឱ្យសិស្សទាញមេរៀនសង្ខេប | -មានសិទ្ធិសេរីភាពចូលរួមយ៉ាងសកម្ម ក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ របស់ប្រទេសជាតិ។<br><br><br>-បានកំណត់ថា ពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិជ្រើសរើសមុខរបរសមស្របតាមសមត្ថភាព ទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា។<br><br>-យើងត្រូវ៖<br>• គោរពសិទ្ធិ<br>• មិនរើសអើងនារីភេទ<br>• មានភាពស្មើគ្នាចំពោះមុខច្បាប់។<br><br>-ច្បាប់មាន៖<br>• ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣<br>• ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ<br>• អនុសញ្ញាស្ដីពីការលុបបំបាត់ចោលរាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ។<br><br><br>**មេរៀនសង្ខេប**<br>មាត្រា៣៥ ៣៦បានចែងថា បុរសស្ត្រីមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិជ្រើសរើសមុខរបរសមស្របតាមសមត្ថភាព និងមានសិទ្ធិចូលរួមអភិវឌ្ឍប្រទេស ដោយមិនប្រកាន់ និងរើសអើង | ចំពោះមុខច្បាប់ មានសិទ្ធិសេរីភាពចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ចវប្បធម៌ របស់ប្រទេសជាតិ។<br><br>-បានកំណត់ថា ពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិជ្រើសរើសមុខរបរសមស្របតាមសមត្ថភាព ទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា។<br><br>-យើងត្រូវ៖<br>• គោរពសិទ្ធិ<br>• មិនរើសអើងនារីភេទ<br>• មានភាពស្មើគ្នាចំពោះមុខច្បាប់។<br><br>-ច្បាប់មាន៖<br>• ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣<br>• ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ<br>• អនុសញ្ញាស្ដីពីការលុបបំបាត់ចោលរាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ។<br>-សិស្សកត់ចូលសៀវភៅ<br><br>-សាកល្បងទាញមេរៀនសង្ខេប |

| | | |
|---|---|---|
| | ភេទឡើយ។ | |
| -ដើម្បីលើកស្ទួយសមភាពយេនឌ័រ តើយើងត្រូវធ្វើដូចម្តេច?<br><br>-តើមានច្បាប់អ្វីខ្លះ ដែលគាំទ្រឱ្យមានសមភាពយេនឌ័រ? | **ជំហានទី៤**<br>(ពង្រឹងពុទ្ធិ)<br>-យើងត្រូវៈ<br>• គោរពសិទ្ធិ<br>• មិនរើសអើងនារីភេទ<br>• មិនប្រកាន់វណ្ណៈ<br>• មានភាពស្មើគ្នាចំពោះមុខច្បាប់។<br><br>-ច្បាប់មានៈ<br>• ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣<br>• ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ<br>• អនុសញ្ញាស្តីពីការលុបបំបាត់ចោលរាល់ទំរងនៃការរើសអើងប្រឆាំងនឹងនារីភេទ។ | -យើងត្រូវៈ<br>• គោរពសិទ្ធិ<br>• មិនរើសអើងនារីភេទ<br>• មិនប្រកាន់វណ្ណៈ<br>• មានភាពស្មើគ្នាចំពោះមុខច្បាប់។<br><br>-ច្បាប់មានៈ<br>• ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣<br>• ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ<br>• អនុសញ្ញាស្តីពីការលុបបំបាត់ចោលរាល់ទំរងនៃការរើសអើងប្រឆាំងនឹងនារីភេទ។ |
| -គ្រូដាក់ពន្យល់ពាក្យឱ្យសិស្សធ្វើនៅផ្ទះៈ | **ជំហានទី៥**<br>(កិច្ចការផ្ទះ)<br><br>-ការរើសអើង<br>-ថ្លៃថ្នូរ<br>-ឧប្បត្តិហេតុ | -សិស្សកត់ពន្យល់ពាក្យទៅធ្វើនៅផ្ទះតាមការណែនាំរបស់គ្រូ។ |

# កិច្ចតែងការបង្រៀន

- ❖ កាលបរិច្ឆេទ : ថ្ងៃ ទី ខែ ឆ្នាំ
- ❖ មុខវិជ្ជា : សីលធម៌-ពលរដ្ឋវិជ្ជា
- ❖ ថ្នាក់ទី : ៧
- ❖ **ជំពូកទី១** : **យេនឌ័រ និង សិទ្ធិមនុស្ស**
- ❖ **មេរៀនទី៦** : **ទង្វើបការរងាទាសមភាពយេនឌ័រ**
- ❖ វិធីសាស្ត្របង្រៀន : គោលវិធីសិស្សមជ្ឈមណ្ឌល (វិធីពិភាក្សាក្រុម)
- ❖ រយៈពេល : ២ម៉ោងសិក្សា (សម្រាប់ម៉ោងទី២)

## I.វត្ថុបំណង

- **ចំណេះដឹង** : សម្គាល់ពីទម្រង់នៃអំពើហិង្សានិងអនុញ្ញាលុបបំបាត់អំពើហិង្សាក្នុងគ្រួសារបាន ត្រឹមតាមរយៈខ្លឹមសារមេរៀន និងសំណួរបំផុសរបស់គ្រូ។
- **បំណិន** : វិភាគពីគោលបំណងនៃការបង្កើតច្បាប់ និងអនុសញ្ញាដើម្បីទប់ស្កាត់អំពើហិង្សា លើស្ត្រីនិងកុមារបានត្រឹមត្រូវតាមរយៈការពវិធីចោទឆ្លើយ ។
- **ឥរិយាបថ** : ការពារ និងគោរពនិងលើកស្ទួយសិទ្ធិស្ត្រីក្នុងសង្គមបច្ចុប្បន្ន ។

## II. ខ្លឹមសារមេរៀន

### ២.ការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ

### ៣.អនុសញ្ញាការបំបាត់ចោលនៃការរើសអើងប្រឆាំងនិងនារីភេទ

## III. សម្ភារឧបទេស

- ផ្ទាំងរូបភាព
- ប័ណ្ណសំណួរ
- ផ្ទាំងមេរៀនសង្ខេប

## V. ដំណឹកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| –ពិនិត្យ:អវត្តមានអនាម័យ សណ្តាប់ធ្នាប់ ពង្រឹងវិន័យ | **ជំហានទី ១**<br>(រដ្ឋបាលថ្នាក់) | –ប្រធានថ្នាក់រាយការណ៍តាមស្ថានភាពជាក់ស្តែង |
| –តើមេរៀនយើងថ្ងៃមុនរៀនដល់ណា?<br><br>–តើមាត្រា36នៃច្បាប់ធម្មបុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ ដូចម្តេច?<br><br>–ដើម្បីលើកស្ទួយសមភាពយេនឌ័រ តើយើងត្រូវធ្វើដូចម្តេច? | **ជំហានទី២**<br>(រំឭកមេរៀនចាស់)<br>**មេរៀនទី៦**:<br>**ធានាការធានាសមភាពយេនឌ័រ**<br>– ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិជ្រើសរើសមុខរបរសមស្របតាមសមត្ថភាពទទួលប្រាក់បៀវត្តន៍ស្មើគ្នាចំពោះការងារដូចគ្នា<br><br>+គោរពសិទ្ធិគ្នា<br>+មិនរើសអើងនារីភេទ<br>+មានភាពស្មើគ្នាចំពោះមុខច្បាប់<br>+ការបង្ខំផ្លូវចិត្ត<br>+ប្រើអំណាចជិះជាន់<br>+ការប្រើពាក្យសម្តីមិនសមរម្យ | –ឆ្លើយតាមការចងចាំមេរៀន<br><br>– ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានទិ្ធជ្រើសរើសមុខរបរសមស្របតាមសមត្ថភាពទទួលប្រាក់បៀវត្តន៍ស្មើគ្នាចំពោះការងារដូចគ្នា។<br>• យើងត្រូវ៖<br>–គោរពសិទ្ធិគ្នា<br>–មិនរើសអើងនារីភេទ<br>–មានភាពស្មើគ្នាចំពោះមុខច្បាប់<br>–ការបង្ខំផ្លូវចិត្ត<br>–ប្រើអំណាចជិះជាន់<br>–ការប្រើពាក្យសម្តីមិនសមរម្យកើតមានចំពោះនារីភេទនិងកុមារ |
| –ឲ្យសិស្សបើកសៀវភៅទំព័រ169 រួចអានចំណងជើងមេរៀន<br><br>–ឲ្យសិស្សសង្កេតរូបភាព<br>–តើប្អូនឃើញអ្វីខ្លះនៅក្នុងរូភាព?<br><br>–តើរូបភាពនេះមានន័យដូចម្តេច? | **<u>ជំហានទី ៣</u>**<br>(មេរៀនប្រចាំថ្ងៃ)<br>**មេរៀនទី ៦ : ធានាការធានាសមភាពយេនឌ័រ**<br><br>**+ សិក្សារូបភាព**<br>–ឃើញមានសមាជិកក្រុមគ្រួសារមួយកំពុងមានភាពសប្បាយរីករាយ<br>–ការនៅក្នុងគ្រួសារប្រកបដោយសុភមង្គលដោយមិនប្រកាន់ភេទ | –ធ្វើតាមការណែនាំរបស់គ្រូ<br><br>–សង្កេតរូបភាព<br>–កុមារា,កុមារី,ឪពុកកំពុងលេងជាមួយកូនក្នុងផ្ទះ<br>-ការរស់នៅប្រកបដោយសុភមង្គល |

| | | |
|---|---|---|
| –ឲ្យសិស្សអានខ្លឹមសារមេរៀន | 2. **ការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ**<br>3. **អនុសញ្ញាការបំបាត់ចោលនៃការរើសអើងប្រឆាំង និងនារីភេទ**<br><u>ពិភាក្សាក្រុម</u> | |
| –តើអំពើហឹង្សាមានទម្រង់ដូចម្តេច? | – អំពើហឹង្សាមានទម្រង់៖<br>– ការវាយតប់<br>– ការបង្ខិតបង្ខំរាងកាយ | – ការវាយតប់<br>– ការបង្ខំលើរូបរាងកាយ |
| -តើអំពើហឹង្សាច្រើនកើតមានចំពោះមនុស្សប្រភេទណា? | -អំពើហឹង្សាច្រើនកើតចំពោះនារីភេទនិងកុមារទន់ខ្សោយ។ | -កើតមានចំពោះនារីភេទនិងកុមារ។ |
| –តើអនុសញ្ញាការបំបាត់ចោលនៃការ<br>រើសអើងប្រឆាំងនិងនារីភេទមានខ្លឹមសារដូចម្តេច? | –អនុសញ្ញានេះមានខ្លឹមសារ៖<br>–ការពារគោរពសិទ្ធិស្ត្រីឲ្យមានសមភាពយេនឌ័រ<br>–បំបាត់ចោលការកេងប្រវ័ញ្ចការរើសអើង និង<br>បង្កើនវិធានការលើកកំពសស្ត្រី | –ការពារគោរពសិទ្ធិស្ត្រីជានាឲ្យមានសមភាពយេនឌ័រ<br>–បំបាត់ចោលការកេងប្រវ័ញ្ចការរើសអើងនិងបង្កើន<br>វិធានការលើកកំពស់ស្ថានភាពស្ត្រី |
| –ឲ្យសិស្សសាកល្បងទាញមេរៀនសង្ខេប<br><br>-បិទផ្ទាំងមេរៀនសង្ខេប | <u>**មេរៀនសង្ខេប**</u><br>ច្បាប់ទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារមានគោលបំណងទប់ស្កាត់ក្នុងគ្រួសារការពារជនរងគ្រោះលើកកម្ពស់តម្លៃគ្រួសារ និង ភាពសុខដុមរមនាក្នុងគ្រួសារ។ | -សិស្សទាញមេរៀនសង្ខេប<br><br>- តក់ត្រា |
| 1. តើអំពើហឹង្សាមានទម្រង់ដូចម្តេច? | **ជំហានទី ៤**<br>(ពង្រឹងពុទ្ធិ)<br>– អំពើហឹង្សាមានទម្រង់៖<br>+ការបង្ខិតបង្ខំផ្លូវចិត្ត<br>+ការបង្ខិតបង្ខំផ្លូវកាយ | – អំពើហឹង្សាមានទម្រង់៖<br>+ការបង្ខិតបង្ខំផ្លូវចិត្ត<br>+ការបង្ខិតបង្ខំផ្លូវកាយ |

| | | |
|---|---|---|
| -តើអំពើហឹង្សាច្រើនកើតមាន ចំពោះបែបណា? | +ការប្រើពាក្យសម្តីមិនសម<br>+ប្រើអំណាចជិះជាន់<br>+ការវាយតប់<br><br>-អំពើហឹង្សាច្រើនកើតមាន ចំពោះ នារីភេទនិងកាមារ ទន់ខ្សោយ | +ការប្រើពាក្យសម្តីមិនសម<br>+ប្រើអំណាចជិះជាន់<br>+ការវាយតប់<br><br>-អំពើហឹង្សាច្រើនកើតមាន ចំពោះ នារីភេទនិងកាមារ ទន់ខ្សោយ |
| -មើលមេរៀនបន្ត<br>-ធ្វើលំហាត់ជំពូក១ | **ជំហានទី ៥**<br>(បណ្តាំផ្ញើ)<br>-ទំព័រ ១៧៣- ១៧៦<br>- ទំព័រ ១៧១- ១៧២ | -ស្តាប់និងធ្វើតាមការផ្តាំផ្ញើ របស់គ្រូ |

# កិច្ចតែងការបង្រៀន

- ❖ កាលបរិច្ឆេទ : ថ្ងៃ ទី ខែ ឆ្នាំ
- ❖ មុខវិជ្ជា : សីលធម៌ ពលរដ្ឋវិជ្ជា
- ❖ **ជំពូក២** : **មិត្តភាព**
- ❖ **មេរៀនទី១** : **លក្ខណៈមិត្តភាពល្អ**
- ❖ ថ្នាក់ : ៧
- ❖ វិធីសាស្ត្រ : គោលវិធីសិស្សមជ្ឈមណ្ឌល
- ❖ រយៈពេល : ២ ម៉ោង(សម្រាប់ម៉ោងទី១)

## I.**វត្ថុបំណង**

- ➢ **ចំណេះដឹង** : សិស្សប្រាប់បានពីលក្ខណៈមិត្តភាពល្អការយល់ចិត្ត សមានចិត្តបានត្រឹមត្រូវ តាមរយៈខ្លឹមសារមេរៀន និងសំណួរបំផុសរបស់គ្រូ ។
- ➢ **បំណិន** : សិស្សបកស្រាយបានពីលក្ខណៈសំខាន់នៃទំនាក់ទំនងមិត្តភាពល្អ បានត្រឹមត្រូវតាមរយៈពិភាក្សាក្រុម ។
- ➢ **ឥរិយាបថ** : បណ្ដុះស្មារតីសិស្សឲ្យចេះស្រឡាញ់និងឲ្យតម្លៃថែរក្សាធំទេមិត្តភាពឲ្យយូរអង្វែង ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ។

## II.**សម្ភារឧបទេស**

- ○ សៀវភៅសិស្សទំព័រ 174- 175 បោះពុម្ពឆ្នាំ 2009
- ○ ប័ណ្ណសំណួរផ្ទាំងរូបភាព

## III.**ខ្លឹមសារមេរៀន**

**១. មិត្តភាព**

**២. ការយល់ចិត្ត**

**៣. សមានចិត្ត**

IV. **ដំណើរការបង្រៀន**

| **សកម្មភាពគ្រូ** | **ខ្លឹមសារមេរៀន** | **សកម្មភាពសិស្ស** |
|---|---|---|
| – គ្រូពិនិត្យ អត្តមាន អនាម័យ សណ្តាប់ធ្នាប់ | **ជំហានទី១**<br>(រដ្ឋបាលថ្នាក់) | – ប្រធានថ្នាក់ឡើងរាយការណ៍ |
| – កែកិច្ចការផ្ទះ | **ជំហានទី២**<br>(រំលឹកមេរៀនចាស់)<br>I . ១. គ<br>២. ក<br>៣. ខ<br>II. ១. គ<br>២. ខ<br>៣. ក<br>៤. ឃ | - ស្តាប់ និងកត់ត្រា |
| – ឲ្យសិស្សបើកសៀវភៅទំព័រ 174-175<br><br>– តើចំនងជើងមេរៀនមានន័យដូចម្តេច ?<br><br>– តើប្អូនឃើញអ្វីខ្លះនៅក្នុងរូបភាព?<br><br>– តើរូបភាពនេះមានន័យដូចម្តេច?<br><br>– តើរូបភាពនិងចំនងជើងមានទំនាក់ទំនងគ្នាដែលឬទេ? | <u>ជំហានទី៣</u><br>(មេរៀនប្រចាំថ្ងៃ)<br>**មេរៀនទី១ : លក្ខណៈមិត្តភាពល្អ**<br><br>– ចំនងជើងមេរៀនមានន័យថា ភាពយោគយល់ភាពចុះសម្រុងគ្នា។<br><br>– ឃើញសាលារៀន ដើមត្នោត ទង់ជាតិ សិស្ស ជាកុមារកុមារី<br><br>– រូបភាពនេះមានន័យថា ការចេះជួយគ្នា យោគយល់ចេះស្រឡាញ់គ្នា។<br><br>**ទំនាក់ទំនមេរៀន**<br><br>– មានទំនាក់ទំនងព្រោះ ចំនងជើងនិយាយពីភាពលក្ខណៈមិត្តភា | – បើកសៀវភៅទំព័រទី 174-175<br><br>– មានន័យថាភាពយោគយល់ចុះសម្រុងគ្នា<br><br>– សាលារៀន ដើមត្នោត ទងជាតិ កុមារាកុមារី។<br><br>– រូបភាពនេះមានន័យថា ការចេះជួយគ្នា យោគយល់ចេះស្រឡាញ់គ្នា។<br><br>– មានទំនាក់ទំនងព្រោះ ចំនងជើងនិយាយពីភាពលក្ខណៈមិត្តភា |

| | | |
|---|---|---|
| | ពល្អងរូបបង្ហាញពីការចេះជួយគ្នាយោគយល់ស្រឡាញគ្នា | ពល្អងរូបបង្ហាញពីការចេះជួយគ្នាយោគយល់ស្រឡាញគ្នា |
| – ឲ្យសិស្សអានមេរៀន | 1.មិត្តភាព<br>2.ការយល់ចិត្ត<br>3.សមានចិត្ត | –អានមេរៀ<br>1.មិត្តភាព<br>2.ការយល់ចិត្ត<br>3.សមានចិត |
| –គ្រូសរសេរពន្យល់ពាក្យដាក់លើក្ដាខៀន | ពន្យល់ពាក្យ<br>–មេត្តភាព(ន) ភាពទំនាក់ទំនង<br>–សមត្ថភាព(ន) ភាពដែលអាចធ្វើបាន<br>–វិនិច្ឆ័យ (ន) ការត្រិះរិះពិចារណាវិភាគ | – សិស្សកត់ត្រា |
| –គ្រូសំយោគរួចឲ្យសិស្សកត់ត្រា | | – សិស្សកត់ត្រា |
| –គ្រូបែងចែកសិស្សជា៣ក្រុម | ពិភាក្សាក្រុម | – សិស្សចូលក្រុមពិភាក្សា |
| + ក្រុមទី១<br>–ដូចម្ដេចដែលហៅថាមិត្តភាព? | - ទំនាក់ទំនងរវាងមនុស្សនិងមនុស្សដែលមានចំណង់ចំណូលចិត្ត ដូចគ្នា<br>- ជាការស្រឡាញ់ ពេញចិត្ត | មិត្តភាពគឺជាការទំនាក់ទំនងរវាងមនុស្ស និងមនុស្សម្នាក់ទៀតដែលពួកគេ ចូលចិត្តនិយាយជាមួយជាដើមប្រឡងប្រជែងជាមួយរួមសុខទុកជាមួយប្រាប់អាថ៌កំបាំងផ្សេងៗដល់គ្នាជាពិសេសការទុតចិត្តលើគ្នា។ |
| + ក្រុមទី២<br>–ដូចម្ដេចដែលហៅថាការយល់ចិត្ត? | –ការស្វែងយល់ សម្ថភាពក្នុងការយល់ចិត្ត | –គឺជាការស្វែងយល់ឬជាសមត្ថភាពក្នុងការយល់ចិត្តគំនិតសេចក្ដីត្រូវការអារម្មណ៍របស់មិត្តភ័ក្ដអ្នកដទៃទោះបីជាគេមិននិយាយប្រាប់ក៏ដោយ។ |
| + ក្រុមទី៣<br>–ដូចម្ដេចដែលហៅថាសមានចិត្ត? | –គឺជាចិត្តស្មោះស្មើចិត្តដែលមានសភាពទោរទន់រកគ្នាដោយសេចក្ដីស្រឡាញ់និងការបង្ហាញការយល់ការជួយសំរាល់ទុក្ខឬបញ្ហារបស់នណា | –គឺជាចិត្តស្មោះស្មើចិត្តដែលមានសភាពទោរទន់រកគ្នាដោយសេចក្ដីស្រឡាញ់និង ជាការបង្ហាញការយល់ការជួយសំរាល់ទុក្ខឬប |

| | | |
|---|---|---|
| | ម្នាក់។ | ញ្ហារបស់នណាម្នាក់។ |
| –ដូចម្តេចដែលហៅថាមិត្តភាព?<br><br>–ដូចម្តេចដែលហៅថាការយល់ចិត្ត? | **<u>ជំហានទី៤</u>**<br>(ពង្រឹងពុទ្ធិ)<br>– ដែលហៅថាមិត្តភាពគឺជាការទំនាក់ទំនងរវាងមនុស្ស និង មនុស្សម្នាក់ទៀត ដែលពួកគេចូលនិយោយជាមួយដើរជាមិត្តភាពប្រឡងប្រជែងជាមួយ រួមសុខទុក្ខជាមួយប្រាប់ អថិកំបាំងផ្សេងៗ ដល់គ្នាជាពិសេការទុកចិត្តលើគ្នា ។<br><br>– គឺជាការស្វែងយល់ឬជាសមត្ថភាពក្នុងការយល់ចិត្តគំនិតសេចក្តីត្រូវការអារម្មណ៍របស់មិត្តភក្តិអ្នកដទៃទោះបីជាតែមិននិយាយប្រាប់ក៏ដោយ។ | – គឺជាការស្វែងយល់ឬជាសមត្ថភាពក្នុងការយល់ចិត្តគំនិតសេចក្តីត្រូវការអារម្មណ៍របស់មិត្តភ័ក្តអ្នកដទៃទោះបីជាគេមិននិយោយប្រាប់ក៏ដោយ។<br><br>– គឺជាចិត្តស្មោះស្មើចិត្តដែលមានសភាពទោរទន់រកគ្នាដោយសេចក្តីស្រឡាញ់និង ជាការបង្ហាញការយល់ការជួយសំរាល់ទុក្ខឬបញ្ហារបស់នណាម្នាក់។ |
| ពេលប្អូនទៅផ្ទះវិញត្រូវមើលមេរៀនបន្តនិងជួយធ្វើការងារឪពុកម្តាយផង។ | **<u>ជំហានទី៥</u>**<br>(បណ្តាំផ្ញើ) | – សិស្សស្តាប់បង្គាប់ដោយយកចិត្តទុកដាក់។ |

# កិច្ចតែងការបង្រៀន

- កាលបរិច្ឆេទ: ថ្ងៃ ទី ខែ ឆ្នាំ
- មុខវិជ្ជា : សីលធម៌ ពលរដ្ឋវិជ្ជា
- ថ្នាក់ទី : ៧
- **ជំពូកទី២** : **មិត្តភាព**
- **មេរៀនទី១** : **លក្ខណៈមិត្តភាពល្អ**
- វិធីសាស្ត្រ : គោលវិធីសិស្សមជ្ឈមណ្ឌល
- រយៈពេល : ២ម៉ោង (សម្រាប់ម៉ោងទី២)

## I. វត្ថុបំណង

- **ចំណេះដឹង** : សិស្សប្រាប់បានពីការការពារ ការទុកចិត្ត និងភាពស្មោះត្រង់បានត្រឹមត្រូវរយៈខ្លឹមសារមេរៀន និងការពន្យល់របស់គ្រូ ។
- **បំណិន** : សិស្សបកស្រាយបានពីលក្ខណៈសំខាន់នៃការការពារការទុកចិត្តភាពស្មោះត្រង់បានត្រឹមត្រូវតាមរយៈពិភាក្សាក្រុម ។
- **ឥរិយាបថ** : បណ្តុះស្មារតីសិស្សមានទឹកចិត្តស្មោះត្រង់ចំពោះគ្នាទៅវិញទៅមកក្នុងការរស់នៅប្រចាំថ្ងៃ។

## II. សម្ភារៈឧបទេស

- សៀវភៅសិស្សទំព័រ១៧៥ - ១៧៦ បោះពុម្ពឆ្នាំ ២០០៩
- ប័ណ្ណសំណួរផ្ទាំងរូបភាព

## III. ខ្លឹមសារមេរៀន

**៤.ការការពារ**

**៥.ការទុកចិត្ត**

**៦.ភាពស្មោះត្រង់**

IV. **ដំណើរការបង្រៀន**

| **សកម្មភាពគ្រូ** | **ខ្លឹមសារមេរៀន** | **សកម្មភាពសិស្ស** |
|---|---|---|
| -ពិនិត្យអវត្តមានអនាម័យ សណ្តាប់ធ្នាប់ | <u>ជំហាន១</u><br>(រដ្ឋបាល)<br>-អនាម័យ សណ្តាប់ធ្នាប់ អវត្តមាន | -ប្រធាន/អនុប្រធានថ្នាក់រាយការណ៍<br>-ប្រមូលអារម្មណ៍រៀនសូត្រ |
| -ដូចម្តេចដែលហៅថាមិត្តភាព?<br><br>- តើប្អូនធ្លាប់មានមិត្តភក្តិដែរឬទេ? | <u>ជំហាន២</u><br>(រំឭកមេរៀនចាស់)<br>-មិត្តភាព គឺជាទំនាក់ទំនងរវាងមនុស្សម្នាក់ និងមនុស្សម្នាក់ទៀត ដែលពួកគេចូលចិត្តនិយាយជាមួយ ដើរជាមួយប្រឡងប្រជែងជាមួយរួមសុខទុក្ខជាមួយប្រាប់អាថ៌កំបាំងផ្សេងៗដល់គ្នាជាពិសេស គឺទុកចិត្តលើគ្នា ។<br><br><u>ទំនាក់ទំនងមេរៀនថ្មី</u><br>-បាទ/ចាស មាន | -មិត្តភាព គឺជាទំនាក់ទំនងរវាងមនុស្សម្នាក់ និងមនុស្សម្នាក់ទៀត ដែលពួកគេចូលចិត្តនិយាយជាមួយ ដើរជាមួយ ប្រឡងប្រជែងជាមួយ រួមសុខទុក្ខជាមួយប្រាប់អាថ៌កំបាំងផ្សេងៗដល់គ្នាពិសេស គឺទុកចិត្តលើគ្នា ។<br><br>-បាទ/ចាស មាន |
| -ឲ្យសិស្សបើកសៀវភៅទំព័រ ១៧៥-១៧៦<br>-ឲ្យសិស្សអានអត្ថបទចំណុច<br><br>-គ្រូសំយោគរួចឲ្យសិស្សកត់ត្រា<br><br>-គ្រូបែងចែកសិស្សជា៤ក្រុម<br><br>**+ក្រុមទី១** | <u>ជំហានទី៣</u><br>(មេរៀនប្រចាំថ្ងៃ)<br>**មេរៀនទី១ លក្ខណៈមិត្តភាពល្អ**<br><br>-៤.ការការពារ<br>-៥.ការទុកចិត្ត<br>-៦.ភាពស្មោះត្រង់<br><br>**<u>ពិភាក្សាក្រុម</u>** | -សិស្សបើកសៀវភៅ<br><br>-៤.ការការពារ<br>-៥.ការទុកចិត្ត<br>-៦.ភាពស្មោះត្រង់<br>-សិស្សកត់ត្រា<br>-សិស្សចូលក្រុមពិភាក្សា<br><br>-ការការពារ គឺជាការរារាំងការ |

| | | |
|---|---|---|
| -ដូចម្ដេចដែលហៅថាការការពារ?<br><br><br><br><br><br>**+ក្រុមទី២**<br>-ដូចម្ដេចដែលហៅថាការទុកចិត្ត?<br><br>**+ក្រុមទី៣**<br>-ដូចម្ដេចដែលហៅថាភាពស្មោះត្រង់?<br><br>**+ក្រុមទី៤**<br>-ដើម្បីឲ្យអ្នកដទៃមានមិត្តភាពល្អជាមួយយើង តើត្រូវធ្វើដូចម្ដេចខ្លះ?<br><br><br><br>-ឲ្យសិស្សសាកល្បងទាញរកមេរៀនសង្ខេប | -ការការពារ គឺជាការរារាំង ការឃាត់ឃាំង ឬបទ់ស្កាត់សកម្មភាព ឬបញ្ចៀសអំពើអ្វីមួយមិនឲ្យកើតមាន គោលបំណងរក្សាសុវត្ថិភាពខ្លួនអ្នកដ៏ទៃរក្សាកិត្តិយស និងភាពថ្លៃថ្នូរ ។<br><br><br>-ការទុកចិត្ត គឺជាការភ្ជាប់ជំនឿ ឬការជឿទៅលើមនុស្សណាម្នាក់ ។<br><br>-ភាពស្មោះត្រង់គឺជាការស្មោះត្រង់អស់ពីចិត្តគ្មានអ្វីលាក់លៀម ។<br><br>-ត្រូវចេះយល់ចិត្តអ្នកដទៃ<br>-មានសមានចិត្តល្អ<br>-ចេះគោរពស្រលាញ់អ្នកដទៃ<br>-ស្មោះត្រង់ ។<br><br>**មេរៀនសង្ខេប**<br>ក្នុងដំណើរការមិត្តភាព មនុស្សម្នាក់ៗមិនត្រឹមតែគិតលើការយល់ចិត្តនិងសមានចិត្តចំពោះគ្នា និងគ្នានោះទេ ពួកគេថែមទាំងចេះការពារថែរក្សាផ្ដល់នូវទំនប់ចិត្ត និងភាពស្មោះត្រង់ចំពោះគ្នាទៅវិញទៅមកថែមទៀតផង ។ | ឃាត់ឃាំង ឬទប់ស្កាត់សកម្មភាព ឬបញ្ចៀសអំពើអ្វីមួយមិនឲ្យកើតមាន គោលបំណងរក្សាសុវត្ថិភាពខ្លួន អ្នកដ៏ទៃរក្សាកិត្តិយស់ និងភាពថ្លៃថ្នូរ ។<br><br><br>-ការទុកចិត្ត គឺជាការភ្ជាប់ជំនឿ ឬការជឿទៅលើមនុស្សណាម្នាក់ ។<br><br>-ភាពស្មោះត្រង់គឺជាការស្មោះត្រង់អស់ពីចិត្តគ្មានអ្វីលាក់លៀម។<br><br>-មានភាពស្មោះត្រង់<br>-ចេះយល់ចិត្តអ្នកដទៃទាំងពួង<br>-គោរពស្រលាញ់ការពារអ្នកដទៃ<br>-គោរពសិទ្ធិអ្នកដទៃ។ |
| <br><br>-ដូចម្ដេចដែលហៅថាការទុកចិត្ត? | **ជំហានទី៤**<br>**(ពង្រឹងពុទ្ធិ)**<br>- គឺជាការភ្ជាប់ជំនឿ ឬការជឿទៅលើមនុស្សណា | <br><br>-គឺជាការភ្ជាប់ជំនឿ ឬការជឿទៅលើមនុស្សណា |

| | | |
|---|---|---|
| -ដូចម្ដេចដែលហៅថាភាពស្មោះត្រង់? | ម្នាក់ ។<br>-គឺជាការស្មោះត្រង់អស់ពីចិត្តគ្មានអ្វីលាក់លៀម ។ | ម្នាក់ ។<br>-គឺជាការស្មោះត្រង់អស់ពីចិត្តគ្មានអ្វីលាក់លៀម ។ |
| -ពេលទៅផ្ទះវិញត្រូវជួយធ្វើការងារឪពុកម្ដាយ និងខិតខំរៀនសូត្រផង ។ | **ជំហានទី៥**<br>(បណ្ដាំផ្ញើ)<br>-ជួយធ្វើការងារឪពុកម្ដាយ<br>-ខិតខំរៀនសូត្រ | -សិស្សស្ដាប់បង្គាប់ដោយយកចិត្តទុកដាក់ ។ |

# កិច្ចតែងការបង្រៀន

- កាលបរិច្ឆេទ: ថ្ងៃ ទី ខែ ឆ្នាំ
- មុខវិជ្ជា : សីលធម៌ ពលរដ្ឋវិជ្ជា
- ថ្នាក់ទី : ៧
- **ជំពូក២ : មិត្តភាព**
- **មេរៀនទី២ : ការរក្សាមិត្តភាព**
- វិធីសាស្ត្រ : ចោទឆ្លើយ ពិភាក្សាក្រុម
- រយៈពេល : ២ម៉ោងសិក្សា (សម្រាប់ម៉ោងទី១)

## I. វត្ថុបំណង

- **ចំណេះដឹង** : បង្ហាញពីមិត្តមិនល្អបួនប្រភេទបានយ៉ាងត្រឹមត្រូវតាមរយៈការអានខ្លឹមសារមេរៀន ។
- **បំណិន** : បកស្រាយពីមិត្តមិនល្អបួនប្រភេទបានយ៉ាងត្រឹមត្រូវតាមរយៈពិភាក្សាក្រុម និងការពន្យល់របស់គ្រូ ។
- **ឥរិយាបថ** : មានស្មារតីប្រុងប្រយ័ត្នខ្ពស់ក្នុងការជ្រើសរើសមិត្ត ។

## II. ខ្លឹមសារមេរៀន

### ១. មិត្តភាពកើតឡើងដោយការជ្រើសរើស

## III. សម្ភារឧបទេស

- សៀវភៅសីលធម៌ ពលរដ្ឋវិជ្ជាថ្នាក់ទី៧បោះពុម្ព បោះពុម្ពឆ្នាំ២០១០ ទំព័រ ១៧៨-១៧៩
- ប័ណ្ណសំណួរ ផ្ទាំងមេរៀនសង្ខេប

## IV. ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ពិនិត្យសណ្ដាប់ធ្នាប់អនាម័យ អវត្តមាន | **ជំហានទី១**<br>(រដ្ឋបាល) | -ប្រធាន/អនុប្រធានថ្នាក់រាយការណ៍ |
| -តើពីថ្ងៃមុនយើងរៀនដល់ណា?<br>-តើលក្ខណៈមិត្តល្អមានអ្វីខ្លះ?<br><br><br><br>-តើប្អូនគួរធ្វើដូចម្ដេចដើម្បីឲ្យមិត្តភាពមានភាពយូរអង្វែង? | **ជំហានទី២**<br>(រំឭកមេរៀនចាស់)<br>-មេរៀនទី១ ″លក្ខណៈមិត្តល្អ″<br>+ លក្ខណៈមិត្តមានៈ<br>-មិត្តភាព ការយល់ចិត្ត សមានចិត្តការការពារ ការទុកចិត្ត ភាពស្មោះត្រង់<br>(ទំនាក់ទំនងមេរៀនថ្មី)<br>-គឺយើងត្រូវចេះថែរក្សា | -សិស្សឆ្លើយតាមការចង់ចាំ<br><br>-មានៈមិត្តភាព,ការយល់ចិត្ត, សមានចិត្ត,ការការពារ,ការទុកចិត្ត, ភាពស្មោះត្រង់។<br><br>-អាស្រ័យលើសិស្ស |
| -ឲ្យសិស្សបើកសៀវភៅទំព័រ ១៧៨រួចអានចំណងជើងមេរៀន<br>-គ្រូសរសេរចំណងជើងដាក់លើក្ដារខៀនរួចធ្វើការពន្យល់ ។<br>-ឲ្យសិស្សអានខ្លឹមសារមេរៀន<br><br><br><br>-គ្រូសរសេរពាក្យដែលត្រូវពន្យល់ដាក់លើក្ដារខៀន<br>-ជោគជ័យ<br>-ស្មោះត្រង់<br>-អែមអប<br><br>-វិនាស | **<u>ជំហានទី៣</u>**<br>(មេរៀនប្រចាំថ្ងៃ)<br>**មេរៀនទី២ ការរក្សាមិត្តភាព**<br><br>-ការរក្សាមិត្តភាពមានន័យថា ធ្វើឲ្យមិត្តភាពមានភាពស្ថិតស្ថេរយូរអង្វែង។<br>-មិត្តភាពជាកត្តាចាំបាច់ គប្បីចៀសវាងឲ្យឆ្ងាយ ។<br><u>ពន្យល់ពាក្យ</u><br>-(ន)សម្រេចបាន,ឈ្នះ ។<br>-(ន)ត្រង់តតល្មៀងមិនវៀចវេរ។<br>-ផ្គាប់ផ្គុនរណប ដើម្បីឲ្យជិតស្និទ្ធស្នាល់។<br>-សេចក្ដីទុក ខ្លោចផ្សាអន្តរាយ។<br>-ចម្លើយត្រឹមត្រូវ | -ស្ដាប់តាមការណែនាំរបស់គ្រូ<br><br>-សិស្សស្ដាប់យ៉ាងយកចិត្តទុកដាក់<br>-សិស្សម្នាក់ ឬពីនាក់អាន<br><br><br><br>-សិស្សឡើងពន្យល់ពាក្យណាដែលចេះ |

| | | |
|---|---|---|
| -គ្រូសរសេរចម្លើយរួចឲ្យ<br>សិស្សកត់ចូលសៀវភៅ | | -សិស្សកត់ចូលសៀវភៅ |
| -គ្រូបែងចែកសិស្សជា៤ក្រុម<br>ពីភាក្សា | **<u>ពិភាក្សាក្រុម</u>** | -ចូលក្រុមតាមការណែនាំរបស់គ្រូ |
| **<u>ក្រុមទី១</u>**<br>-តើអ្វីទៅជាមិត្តភាពកល្យាណ<br>មិត្ត? | -មិត្តជាកត្តាចាំបាច់សម្រាប់<br>បង្កើតទំនាក់ទំនងគ្រប់ប្រភេទប្រកប<br>ដោយជោគជ័យ។<br>-កល្យាណមិត្ត គឺមិត្តមានអាធ្យា<br>ស្រ័យល្អ ចេះជួយមិត្តដែល<br>កំពុងខ្វះខាតតាមលទ្ធភាព ។ | -មិត្តភាពជាកត្តាចាំបាច់សម្រាប់<br>បង្កើតទំនាក់ទំនងល្អគ្រប់ប្រភេទ<br>ប្រកបដោយជោគជ័យ ។<br>-កល្យាណមិត្ត គឺជាមិត្តមានអធ្យា<br>ស្រ័យល្អ និងចេះជួយមិត្ត ។ |
| **<u>ក្រុមទី២</u>**<br>តើតម្លៃផ្ទាល់ខ្លួលរបស់មិត្តល្អជាអ្វី<br>?ហើយមិត្តមិនល្អមានអ្វី<br>ខ្លះ? | -តម្លៃផ្ទាល់ខ្លួនរបស់មិត្តល្អ<br>គឺភាពស្មោះត្រង់ ចិត្តបុណ្យវាចាល្អ<br>សណ្ដាប់ធ្នាប់ល្អ<br>និងមានការតស៊ូព្យាយាមរៀនសូត្រ ។<br>+មិត្តមិនល្អមានបួនប្រភេទ:<br>-មនុស្សគិតតែពីខាងបាន<br>-មនុស្សបានតែនិយាយឥត<br>ប្រយោជន៍<br>-មនុស្សអែបអបប៊ិននិយាយ<br>លើកបញ្ជោរចាក់បណ្ដោយ។<br>-មនុស្សនាំទៅរកតែរឿងវិ<br>នាស។ | -តម្លៃផ្ទាល់ខ្លួនរបស់មិត្តល្អ<br>គឺភាពស្មោះត្រង់ ចិត្តបុណ្យវាចាល្អ<br>សណ្ដាប់ធ្នាប់ល្អ<br>និងមានការតស៊ូព្យាយាមរៀន<br>សូត្រ ។<br>+មិត្តមិនល្អមានបួន:<br>-គិតតែពីខាងបាន<br>-និយាយច្រើនឥតប្រយោជន៍<br>-អែបអប ចាក់បណ្ដោយ<br>-នាំទៅរករឿងវិនាស។ |
| **<u>ក្រុមទី៣</u>**<br>-តើមនុស្សគិតតែពីខាងបាន<br>ជាមនុស្សដូចម្ដេច? | +មនុស្សដែលគិតតែពីខាងបានជាមនុ<br>ស្ស:<br>-គិតតែប្រយោជន៍ផ្ទាល់ខ្លួន<br>-ពេលមានភ័យទើបរត់រក<br>ជំនួយ<br>-សេពគប់មិត្តព្រោះឃើញ<br>ប្រយោជន៍ ។ | +ជាមនុស្សដែល:<br>-គិតតែប្រយោជន៍<br>មានភ័យទើបរកជំនួយ<br>-សេពគប់ព្រោះឃើញប្រយោជន៍។ |
| **<u>ក្រុមទី៤</u>** | | |

| | | |
|---|---|---|
| -តើមនុស្សនាំទៅរកតែរឿងវិនាស់ជាមនុស្សដូចម្តេច?<br><br><br><br><br><br>-គ្រូសំយោគចម្លើយរួចសិស្សកត់ចូលសៀវភៅ<br>-ឲ្យសិស្សសាកល្បងទាញមេរៀនសង្ខេប<br><br><br><br><br><br><br><br>-គ្រូបិទផ្ទាំងមេរៀនសង្ខេបរួចឲ្យសិស្សកត់ចូលសៀវភៅ | +មនុស្សនាំទៅរកតែរឿងវិនាស់ជាមនុស្ស:<br>-តែងនាំមិត្តលេងល្បែង សេពសុរាគ្រឿងញៀនផ្សេងៗ<br>-នាំមិត្តឲ្យបោះបង់ការសិក្សារ<br>-នាំមិត្តដើរលេងពាលា ។<br><br>**ចម្លើយត្រឹមត្រូវ**<br><br>**<u>មេរៀនសង្ខេប</u>**<br>មិត្តភាពជាកត្តាចាំចាច់សម្រាប់បង្កើតទំនាក់ទំនងគ្រប់ប្រភេទប្រកបដោយជោគជ័យ ។ មិត្តមានពីរគឺកល្យាណមិត្ត និងបាបមិត្ត ។ បាបមិត្ត ឬមិត្តមិនល្អមានបួនប្រភេទ:<br>-មនុស្សគិតតែពីបាន<br>-និយាយច្រើន<br>-អែបអប ចាក់បណ្តោយ<br>-នាំទៅរករឿងវិនាស។ | +ជាមនុស្ស:<br>-នាំមិត្តលេងល្បែង សេពសុរាគ្រឿងញៀន<br>-នាំមិត្តឲ្យឈប់រៀន<br>-នាំមិត្តដើរពាលា ។<br><br><br>-កត់ចូលសៀវភៅ<br><br><br><br><br><br><br><br><br><br><br>-សិស្សកត់ចូលសៀវភៅ |
| <br><br>-តើអ្វីជាមិត្តភាព?<br><br><br>-តើមិត្តមិនល្អមានប៉ុន្មានប្រភេទ? អ្វីខ្លះ? | **ជំហានទី៤**<br><u>(ពង្រឹងពុទ្ធិ)</u><br>-មិត្តភាពគឺជាកត្តាចាំបាច់សម្រាប់បង្កើតទំនាក់ទំនងគ្រប់ប្រភេទដោយជោគជ័យ ។<br>+មិត្តមិនល្អមាន៤ប្រភេទដែលគួរចៀសវាង៖<br>-មនុស្សគិតតែពីខាងបាន<br>-មនុស្សបានតែនិយាយ<br>-មនុស្សអែបអបប៉ុននិយាយលើកបញ្ជោរចាក់បណ្តោយ<br>-មនុស្សនាំទៅរកតែរឿងវិនាស។ | <br><br>-សិស្សឆ្លើយតាមការចងចាំ |
| | **ជំហានទី៥**<br><u>(កិច្ចការផ្ទះ)</u> | |

| | | |
|---|---|---|
| -គ្រូដាក់កិច្ចការផ្ទះឲ្យសិស្សធ្វើ | -តើទំនាក់ទំនងល្អរវាងក្មេងស្រី និងក្មេងប្រុសមានលក្ខណៈដូចម្តេច? | -សិស្សកត់ត្រាកិច្ចការផ្ទះចូលសៀវភៅ ។ |

# កិច្ចតែងការបង្រៀន

- ❖ កាលបរិច្ឆេទ : ថ្ងៃ ទី ខែ ឆ្នាំ
- ❖ មុខវិជ្ជា : សីលធម៌-ពលរដ្ឋវិជ្ជា
- ❖ ថ្នាក់ទី : ៧
- ❖ **ជំពូកទី២** : **មិត្តភាព**
- ❖ **មេរៀនទី២** : **ការរក្សាមិត្តភាព**
- ❖ វិធីសាស្ត្រ : គោលវិធីសិស្សមជ្ឈមណ្ឌល (ពិភាក្សាក្រុម)
- ❖ រយៈពេល : ២ម៉ោងសិក្សា (សម្រាប់ម៉ោងទី២)

## I. វត្ថុបំណង

- ➢ ចំណេះដឹង : បង្ហាញពីទំនាក់ទំនងល្អរវាងក្មេងប្រុស និងក្មេងស្រី បានត្រឹមត្រូវតាមរយៈការអានខ្លឹមសារមេរៀន និងការពន្យល់របស់គ្រូ។
- ➢ បំណិន : បកស្រាយពីការពង្រឹងមិត្តភាព ទំនាក់ទំនងល្អរវាងក្មេងប្រុស និងក្មេងស្រី បានត្រឹមត្រូវតាមរយៈការពិភាក្សាក្រុម។
- ➢ ឥរិយបថ : មានបម្រុងប្រយ័ត្នខ្ពស់ក្នុងការរាប់អានមិត្ត និងចេះថែរក្សាមិត្តភាព។

## II. ខ្លឹមសារមេរៀន

2. **ទំនាក់ទំនងល្អរវាងក្មេងស្រី និងក្មេងប្រុស**
3. **ការរក្សា និងការពង្រឹងមិត្តភាព**

## III. សម្ភារឧបទេស

- សៀវភៅពុម្ពថ្នាក់ទី៧ បោះពុម្ពឆ្នាំ ២០១១ ទំព័រ ១៧៩-១៨១
- ប័ណ្ណសំណួរ
- ផ្ទាំងមេរៀនសង្ខេប

## IV. **ដំណើរការបង្រៀន**

| **សកម្មភាពគ្រូ** | **ខ្លឹមសារមេរៀន** | **សកម្មភាពសិស្ស** |
|---|---|---|
| -ពិនិត្យលើ: សណ្តាប់ធ្នាប់ អនាម័យ អវត្តមាន។ | **ជំហានទី១**<br>(រដ្ឋបាលថ្នាក់) | -ប្រធានថ្នាក់ឡើងរាយការណ៍។ |
| -តើថ្ងៃមុនយើងរៀនដល់ណា?<br>- តើមិត្តមិនល្អបួនប្រភេទមានអ្វីខ្លះ?<br><br>-ថ្ងៃនេះយើងនឹងសិក្សាមេរៀននេះបន្តទៀត។ | **ជំហានទី២**<br>(រំឭកមេរៀនចាស់)<br>**មេរៀនទី២:**<br>**ការរក្សាមិត្តភាព**<br>- មិត្តមិនល្អមានបួនប្រភេទគឺ៖<br>• មនុស្សគិតតែពីខាងបាន<br>• មនុស្សបានតែនិយាយឥតប្រយោជន៍<br>• មនុស្សអែបអប<br>• មនុស្សនាំទៅរកតែរឿងវិនាស។<br>**<u>ទំនាក់ទំនងមេរៀនថ្មី</u>** | មេរៀនទី២:<br>ការរក្សាមិត្តភាព<br>- មិត្តមិនល្អមានបួនប្រភេទគឺ៖<br>• មនុស្សគិតតែពីខាងបាន<br>• មនុស្សបានតែនិយាយឥតប្រយោជន៍<br>• មនុស្សអែបអប<br>• មនុស្សនាំទៅរកតែរឿងវិនាស។<br><br>-ស្តាប់ដោយស្ងៀមស្ងាត់ |
| -ឱ្យសិស្សបើកសៀវភៅទំព័រ ១៧៩-១៨០ រួចអានចំណងជើង<br><br>-តើប្អូនឃើញអ្វីខ្លះក្នុងរូបភាពនេះ?<br><br>-តើរូបភាពនេះចង់បង្ហាញពីអ្វី?<br><br>-តើរូបភាពនិងចំណងជើងមានទំនាក់ទំនងគ្នាឬទេ? | **ជំហានទី៣**<br>**(មេរៀនប្រចាំថ្ងៃ)**<br>**មេរៀនទី២: ការរក្សាមិត្តភាព**<br><br>**សិក្សារូបភាព**<br>-ផ្ទះ តុ កៅអី ដើមឈើ ក្មេងប្រុសក្មេងស្រីអង្គុយមើលសៀវភៅ។<br>-បង្ហាញពីមិត្តភាព ឬទំនាក់ទំនងរវាងក្មេងប្រុស-ស្រី។<br>-មាន ព្រោះរូបភាពបង្ហាញពីទំនាក់ទំនងរវាងក្មេងប្រុស-ស្រី ឯចំណងជើងគឺទំនាក់ទំនងល្អ | -ស្តាប់តាមការណែនាំរបស់គ្រូ<br><br>-ឃើញ ផ្ទះ តុ កៅអី ដើមឈើ ក្មេងប្រុសក្មេងស្រីអង្គុយមើលសៀវភៅ។<br>-បង្ហាញពីមិត្តភាព ឬទំនាក់ទំនងរវាងក្មេងប្រុស-ស្រី។<br>-មាន ព្រោះរូបភាពបង្ហាញពីទំនាក់ទំនងរវាងក្មេងប្រុស-ស្រី ឯចំណងជើងគឺទំនាក់ទំនងល្អ |

| | | |
|---|---|---|
| | រវាងក្មេងប្រុស និងក្មេងស្រី។ | រវាងក្មេងប្រុស និងក្មេងស្រី។ |
| -ឱ្យសិស្សអានខ្លឹមសារមេរៀន | 2.**ទំនាក់ទំនងល្អរវាងក្មេងស្រី និង ក្មេងប្រុស**<br>3.**ការរក្សា និងការពង្រឹង មិត្តភាព** | -សិស្សម្នាក់ ឬពីរនាក់អាន |
| -គ្រូសរសេរពាក្យពិបាកដែលត្រូវពន្យល់ដាក់លើក្ដារខៀន | **ពន្យល់ពាក្យ**<br>-ស្ថិតស្ថេរ (គុ): ដែលគង់វង្ស មិនបាត់បង់ ។<br>-ដាស់តឿន (កិ): ក្រើនរំលឹក ឬ ធ្វើឱ្យភ្ញាក់ខ្លួន។<br>-ស្ថាបនា (ន): ការសាងសង់ ឬ ការធ្វើឱ្យចេញជារូបរាង។<br>-ឧបសគ្គ (ន): អ្វីដែលរារាំង របាំង។ | -សិស្សឡើងពន្យល់ន័យ |
| -គ្រូសំយោគឱ្យសិស្សកត់ | | -កត់ចូលសៀវភៅ |
| | **ពិភាក្សាក្រុម** | |
| **-ក្រុមទី១:** តើទំនាក់ទំនងល្អរវាងក្មេងប្រុសក្មេងស្រីមានលក្ខណៈដូចម្ដេច? | -មានលក្ខណៈដូចជា៖<br>• ជាមិត្តភក្តិ<br>• ចេះជួយទុកធុរៈគ្នា<br>• ពិភាក្សាមេរៀនផ្លោះប្ដូរយោបល់គ្នា។ | -មានលក្ខណៈដូចជា៖<br>• ជាមិត្តភក្តិ<br>• ចេះជួយទុកធុរៈគ្នា<br>• ពិភាក្សាមេរៀនផ្លោះប្ដូរយោបល់គ្នា។ |
| **-ក្រុមទី២:** តើមិត្តភាពមានផលប្រយោជន៍អ្វីខ្លះដល់យើង? | -មានប្រយោជន៍ដូចជា៖<br>• ធ្វើឱ្យយើងសប្បាយរីករាយ មិនឯកកា<br>• យល់ច្បាស់ពីសេចក្ដី ស្រឡាញ់<br>• រស់នៅចុះសម្រុងនឹងសង្គម<br>• ចេះស្រឡាញអ្នកដទៃដូចជា ស្រឡាញ់ខ្លួនឯង។ | -មានប្រយោជន៍ដូចជា៖<br>• ធ្វើឱ្យយើងសប្បាយរីករាយ មិនឯកកា<br>• យល់ច្បាស់ពីសេចក្ដី ស្រឡាញ់<br>• រស់នៅចុះសម្រុងនឹងសង្គម<br>• ចេះស្រឡាញអ្នកដទៃដូចជា ស្រឡាញ់ខ្លួនឯង។ |
| **-ក្រុមទី៣:** តើអ្នកគួរធ្វើដូចម្ដេចដើម្បីរក្សាមិត្តភាពឱ្យស្ថិតស្ថេរយូរអង្វែង? | -យើងគប្បី៖<br>• យល់ចិត្តគ្នាទៅវិញទៅមក<br>• មិនភូតកុហកបោកប្រាស់<br>• ចេះសម្របខ្លួនតាមកាលៈ | -យើងគប្បី៖<br>• យល់ចិត្តគ្នាទៅវិញទៅមក<br>• មិនភូតកុហកបោកប្រាស់<br>• ចេះសម្របខ្លួនតាមកាលៈ |

| | | |
|---|---|---|
| <br><br><br><br>**-ក្រុមទី៤:** ចំពោះអ្នក តើរវាងកល្យាណមិត្ត និងបាបមិត្តមួយណាដែលអ្នកគួរសេពគប់? ហេតុអ្វី?<br><br><br><br><br><br><br><br>-សំយោគចម្លើយរួចឱ្យសិស្សកត់ចូលសៀវភៅ<br><br>-ឱ្យសិស្សសាកល្បងទាញមេរៀនសង្ខេប | ទេស:<br>• ជួយទុក្ខធុរៈគ្នាពេលជួបឧបសគ្គ...។<br><br>-ខ្ញុំយល់ថាកល្យាណមិត្តល្អជាងព្រោះ ៖<br>• គេតែងនាំឱ្យធ្វើអំពើល្អ ខិតខំរៀនសូត្រ<br>• ចេះជួយទុកធុរៈគ្នាពេលជួបឧបសគ្គ<br>• បាបមិត្តតែងនាំមិត្តទៅរកតែរឿងវិនាស។<br><br><br><br>**មេរៀនសង្ខេប**<br><br>ទំនាក់ទំនងល្អរវាងក្មេងស្រី និង ក្មេងប្រុសគឺការរក្សាតម្លៃផ្ទាល់ខ្លួនរបស់មិត្តម្នាក់ៗដោយត្រូវកំណត់ឱ្យច្បាស់លាស់ថាមិត្តភាពគឺនៅតែមិត្តភាព។ នៅពេលដែលយើងមានមិត្តល្អហើយគួរចេះថែរក្សា និងការពារកុំឱ្យបាត់បង់ទៅវិញដោយងាយៗនោះទេ។ | ទេស:<br>• ជួយទុក្ខធុរៈគ្នាពេលជួបឧបសគ្គ...។<br><br>-ខ្ញុំយល់ថាកល្យាណមិត្តល្អជាងព្រោះ ៖<br>• គេតែងនាំឱ្យធ្វើអំពើល្អ ខិតខំរៀនសូត្រ<br>• ចេះជួយទុកធុរៈគ្នាពេលជួបឧបសគ្គ<br>• បាបមិត្តតែងនាំមិត្តទៅរកតែរឿងវិនាស។<br>-កត់ចូលសៀវភៅ<br><br>-សិស្សសាកល្បងទាញមេរៀនសង្ខេប |
| <br><br>- តើមិត្តភាពមានផលប្រយោជន៍អ្វីខ្លះដល់យើង? | **ជំហានទី៤**<br>(ពង្រឹងពុទ្ធិ)<br>-មានប្រយោជន៍ដូចជា៖<br>• ធ្វើឱ្យយើងសប្បាយរីករាយមិនឯកកា<br>• យល់ច្បាស់ពីសេចក្តីស្រឡាញ់<br>• រស់នៅចុះសម្រុងនឹងសង្គម<br>• ចេះស្រឡាញអ្នកដទៃដូចជា | <br><br>-មានប្រយោជន៍ដូចជា៖<br>• ធ្វើឱ្យយើងសប្បាយរីករាយមិនឯកកា<br>• យល់ច្បាស់ពីសេចក្តីស្រឡាញ់<br>• រស់នៅចុះសម្រុងនឹងសង្គម<br>• ចេះស្រឡាញអ្នកដទៃដូចជា |

| | | |
|---|---|---|
| -ចំពោះអ្នក តើរវាងមិត្តល្អ និង មិត្តអាក្រក់មួយណាដែលប្រសើរសម្រាប់ប្អូន? | ស្រឡាញ់ខ្លួនឯង។<br>-ខ្ញុំយល់ថាមិត្តល្អប្រសើរជាង ព្រោះ ៖<br>• គេតែងនាំឱ្យធ្វើអំពើល្អ ខិតខំរៀនសូត្រ<br>• ចេះជួយទុកធុរៈគ្នាពេលជួបឧបសគ្គ<br>• បាបមិត្តតែងនាំមិត្តទៅរកតែរឿងវិនាស។ | ស្រឡាញ់ខ្លួនឯង។<br>-ខ្ញុំយល់ថាមិត្តល្អប្រសើរជាង ព្រោះ ៖<br>• គេតែងនាំឱ្យធ្វើអំពើល្អ ខិតខំរៀនសូត្រ<br>• ចេះជួយទុកធុរៈគ្នាពេលជួបឧបសគ្គ<br>• បាបមិត្តតែងនាំមិត្តទៅរកតែរឿងវិនាស។ |
| -គ្រូដាក់កិច្ចការផ្ទះឱ្យសិស្សធ្វើ<br><br>-ទៅផ្ទះវិញកុំភ្លេចធ្វើកិច្ចការផ្ទះ និង មើលមេរៀនបន្តផង។ | **ជំហានទី៥**<br>(កិច្ចការផ្ទះ និងបណ្ដាំផ្ញើ)<br>-ចូរប្អូនពន្យល់ពាក្យ៖<br>• គន្លងធម៌<br>• អាសន្ន<br>• កេរ្តិ៍ឈ្មោះ | -សិស្សកត់កិច្ចការផ្ទះចូលសៀវភៅ។<br><br>-សិស្សស្ដាប់ដោយយកចិត្តទុកដាក់។ |

# កិច្ចតែងការបង្រៀន

- កាលបរិច្ឆេទ : ថ្ងៃ ទី ខែ ឆ្នាំ
- មុខវិជ្ជា : សីលធម៌-ពលរដ្ឋវិជ្ជា
- ថ្នាក់ទី : ៧
- **ជំពូកទី២ : មិត្តភាព**
- **មេរៀនទី៣ : សារៈសំខាន់នៃមិត្តភាពល្អ**
- វិធីសាស្ត្រ : គោលវិធីសិស្សមជ្ឈមណ្ឌល (ពិភាក្សាក្រុម)
- រយៈពេល : ១ម៉ោងសិក្សា

## I. វត្ថុបំណង

- ចំណេះដឹង : រៀបរាប់លក្ខណៈសម្បត្តិនៃមិត្តភាពល្អ បានត្រឹមត្រូវតាមរយៈខ្លឹមសារការសិក្សាមេរៀន។
- បំណិន : វិភាគពីសារៈសំខាន់នៃមិត្តភាពល្អ និងការទំនាក់ទំនងល្អ បានត្រឹមត្រូវតាមរយៈការពិភាក្សាក្រុម ។
- ឥរិយាបថ : បណ្តុះស្មារតីសិស្សឱ្យស្រឡាញ់ និងមានការប្រុងប្រយ័ត្នក្នុងការជ្រើសរើសមិត្តល្អ។

## II. ខ្លឹមសារមេរៀន

### ១. ការជ្រើសរើសមិត្តល្អចិត្ត

### ២. សារៈសំខាន់នៃមិត្តភាពល្អ

## III. សម្ភារឧបទេស

- សៀវភៅសិស្សទំព័រ ១៨២-១៨៣ បោះពុម្ពឆ្នាំ ២០១១
- ប័ណ្ណសំណួរ
- ផ្ទាំងមេរៀនសង្ខេប

IV. **ដំណើរការបង្រៀន**

| **សកម្មភាពគ្រូ** | **ខ្លឹមសារមេរៀន** | **សកម្មភាពសិស្ស** |
|---|---|---|
| -គ្រូពិនិត្យលើ : សណ្តាប់ធ្នាប់ អវត្តមាន អនាម័យ។ | **ជំហានទី១**<br>(រដ្ឋបាលថ្នាក់) | -ប្រធានថ្នាក់ឡើងរាយការណ៍។ |
| -គ្រូសួររំឭកមេរៀនចាស់<br>-តើកាលពីម៉ោងមុនយើងរៀនពីមេរៀនអ្វី?<br>-តើមិត្តភាពកើតឡើងដោយរបៀបណា?<br>-នៅពេលយើងជ្រើសរើស តើយើងជ្រើសរើសយកមិត្តរបៀបណា?<br><br>-ហេតុអ្វីចាំបាច់ត្រូវការមិត្តភាពល្អ? | **ជំហានទី២**<br>(រំឭកមេរៀនចាស់)<br><br>**មេរៀនទី២: ការរក្សាមិត្តភាព**<br><br>-មិត្តភាពកើតឡើងពីការជ្រើសរើស។<br>-យើងជ្រើសរើសមិត្តល្អ គឺកល្យាណមិត្ត។<br><br>**<u>ទំនាក់ទំនងមេរៀនថ្មី</u>**<br>-ព្រោះមិត្តភាពល្អមានសារៈសំខាន់ជាច្រើនដល់យើងដូចជា ធ្វើឱ្យយើងមានទំនាក់ទំនងល្អ ចេះយោគយល់អធ្យាស្រ័យគ្នាទៅវិញទៅមក។ | មេរៀនទី២: ការរក្សាមិត្តភាព<br><br>-មិត្តភាពកើតឡើងដោយការជ្រើសរើស។<br>-យើងជ្រើសរើសមិត្តល្អ គឺកល្យាណមិត្ត។<br><br>-ព្រោះមិត្តភាពល្អមានសារៈសំខាន់ជាច្រើនដល់យើង ដូចជា ធ្វើឱ្យយើងមានទំនាក់ទំនងល្អចេះយោគយល់អធ្យាស្រ័យគ្នាទៅវិញទៅមក។ |
| -ឱ្យសិស្សបើកសៀវភៅទំព័រ ១៨២ អានចំណងជើងមេរៀន រួចគ្រូសរសេរដាក់លើក្តារខៀន<br>-តើចំណងជើងមានន័យយ៉ាងណា?<br><br>-ឱ្យសិស្សអានខ្លឹមសារមេរៀន ទំព័រ ១៨២-១៨៣ | **ជំហានទី៣**<br>(មេរៀនប្រចាំថ្ងៃ)<br>**មេរៀនទី៣:**<br>**សារៈសំខាន់នៃមិត្តភាពល្អ**<br><br>-មានន័យថា មិត្តភាពល្អចំពោះគ្នាទៅវិញទៅមកគឺធ្វើឱ្យយើងមានទំនាក់ទំនងល្អចេះសាមគ្គី និង ចេះជួយគ្នាទៅវិញទៅមក។<br>(ទំនាក់ទំនងមិត្តភាព.................<br>..........យូរអង្វែង។) | - សិស្សបើកសៀវភៅទំព័រ១៨២ អានចំណងជើង<br><br>-មានន័យថា មិត្តភាពល្អចំពោះគ្នាទៅវិញទៅមកគឺធ្វើឱ្យយើងមានទំនាក់ទំនងល្អចេះសាមគ្គី និង ចេះជួយគ្នាទៅវិញទៅមក។<br>- អានខ្លឹមសារមេរៀន |

| | | |
|---|---|---|
| -គ្រូសរសេរពាក្យពិបាកដាក់លើរួចឱ្យសិស្សឡើងពន្យល់ | **ពន្យល់ពាក្យ**<br>-គន្លងធម៌ (ន): ការដើរតាមផ្លូវល្អ<br>-អាសន្ន (ន): គ្រោះភ័យ ឬគ្រោះថ្នាក់នាំឱ្យអន្តរាយ។<br>-មិត្តភាព (ន): ការរាប់អានគ្នាជាមិត្ត។ | -គន្លងធម៌ (ន): ការដើរតាមផ្លូវល្អ។<br>-អាសន្ន (ន): គ្រោះភ័យ ឬគ្រោះថ្នាក់នាំឱ្យអន្តរាយ។<br>-មិត្តភាព (ន): ការរាប់អានគ្នាជាមិត្ត។ |
| -ឱ្យសិស្សកត់ចូលសៀវភៅ | | -សិស្សកត់ចូលសៀវភៅ |
| | **ពិភាក្សាក្រុម** | |
| -គ្រូបែងចែកសិស្សជា៤ក្រុម៖ | | -សិស្សចូលតាមក្រុមពិភាក្សា |
| **-ក្រុមទី១:** តើយើងគួរជ្រើសរើសមិត្តប្រភេទណា? | -យើងគួរជ្រើសរើសមិត្ត គឺកល្យាណមិត្ត មិត្តដែលមានអធ្យាស្រ័យល្អដែលចេះជួយទំនុកបម្រុងមិត្តដែលមានភាពខ្វះខាតតាមលទ្ធភាព មានភាពស្មោះត្រង់។ | -យើងគួរជ្រើសរើសមិត្ត គឺកល្យាណមិត្ត មិត្តដែលមានអធ្យាស្រ័យល្អដែលចេះជួយទំនុកបម្រុងមិត្តដែលមានភាពខ្វះខាតតាមលទ្ធភាព មានភាពស្មោះត្រង់។ |
| **-ក្រុមទី២:** តើមិត្តល្អដែលយើងគួររាប់រកមានប៉ុន្មានប្រភេទ? អ្វីខ្លះ? | -មានបួនប្រភេទគឺ៖<br>• មិត្តមានឧបការៈ<br>• មិត្តមានចិត្តមួយថ្លើមមួយ<br>• មិត្តណែនាំឱ្យធ្វើតែអំពើល្អ<br>• មិត្តមានទឹកចិត្ត។ | -មានបួនប្រភេទគឺ៖<br>• មិត្តមានឧបការៈ<br>• មិត្តមានចិត្តមួយថ្លើមមួយ<br>• មិត្តណែនាំឱ្យធ្វើតែអំពើល្អ<br>មិត្តមានទឹកចិត្ត។ |
| **-ក្រុមទី៣:** តើយើងគួរជៀសវាងរាប់អានមិត្តបែបណា? | -មិត្តគួរជៀសវាងគឺ៖ បាបមិត្តដែលជាមិត្តមិនល្អនាំយើងទៅរកផ្លូវអាក្រក់គ្មានទឹកចិត្ត គិតពីប្រយោជន៍ផ្ទាល់ខ្លួន។ | -មិត្តគួរជៀសវាងគឺ៖ បាបមិត្តដែលជាមិត្តមិនល្អនាំយើងទៅរកផ្លូវអាក្រក់គ្មានទឹកចិត្ត គិតពីប្រយោជន៍ផ្ទាល់ខ្លួន។ |
| **-ក្រុមទី៤:** តើមិត្តល្អមានសារៈសំខាន់អ្វីខ្លះ? | -ផ្តល់សារៈសំខាន់ដូចជា៖<br>• ជួយទុក្ខធុរៈគ្នាពេលមានអាសន្ន<br>• ជាកម្លាំងសាមគ្គីយ៉ាងរឹងមាំ<br>• ជាអ្នកជួយផ្តល់គំនិត ផ្តល់យោបល់ក្នុងការដោះស្រាយបញ្ហាផ្សេងៗ។<br>• ជាអ្នកផ្តល់កម្លាំងចិត្ត។ | -ផ្តល់សារៈសំខាន់ដូចជា៖<br>• ជួយទុក្ខធុរៈគ្នាពេលមានអាសន្ន<br>• ជាកម្លាំងសាមគ្គីយ៉ាងរឹងមាំ<br>• ជាអ្នកជួយផ្តល់គំនិត ផ្តល់យោបល់ក្នុងការដោះស្រាយបញ្ហាផ្សេងៗ។<br>ជាអ្នកផ្តល់កម្លាំងចិត្ត។ |
| -គ្រូសម្របសម្រួលឱ្យសិស្សកត់ | | -សិស្សកត់ចូលសៀវភៅ |

| | | |
|---|---|---|
| ចូលសៀវភៅ<br>-គ្រូសាកល្បងឱ្យសិស្សទាញមេរៀនសង្ខេប | **មេរៀនសង្ខេប**<br>មិត្តមានពីរប្រភេទគឺមិត្តល្អ និងមិត្តមិនល្អ។ មិត្តល្អគឺមិត្តមានឧបការៈ ចិត្តមួយថ្លើមមួយ ណែនាំឱ្យធ្វើអំពើល្អ និងមិត្តមានទឹកចិត្ត។ យើងក៏ត្រូវដឹងពីសារៈសំខាន់នៃមិត្តភាពល្អដែរ។ | -សាកល្បងទាញមេរៀនសង្ខេប |
| -តើមិត្តល្អមានប៉ុន្មានប្រភេទ? អ្វីខ្លះ?<br><br>-តើមិត្តល្អមានសារៈសំខាន់អ្វីខ្លះ? | **ជំហានទី៤**<br>(ពង្រឹងពុទ្ធិ)<br>-មានបួនប្រភេទគឺ៖<br>• មិត្តមានឧបការៈ<br>• មិត្តមានចិត្តមួយថ្លើមមួយ<br>• មិត្តណែនាំឱ្យធ្វើតែអំពើល្អ<br>• មិត្តមានទឹកចិត្ត។<br>-ផ្តល់សារៈសំខាន់ដូចជា៖<br>• ជួយទុក្ខធុរៈគ្នាពេលមានអាសន្ន<br>• ជាកម្លាំងសាមគ្គីយ៉ាងរឹងមាំ<br>• ជាអ្នកជួយផ្តល់គំនិត ផ្តល់<br>• ជាអ្នកផ្តល់កម្លាំងចិត្ត<br>• ជាអ្នកជួយផ្តល់គំនិត ផ្តល់យោបល់ក្នុងការដោះស្រាយបញ្ហាផ្សេងៗ។ | -មានបួនប្រភេទគឺ៖<br>• មិត្តមានឧបការៈ<br>• មិត្តមានចិត្តមួយថ្លើមមួយ<br>• មិត្តណែនាំឱ្យធ្វើតែអំពើល្អ មិត្តមានទឹកចិត្ត។<br>-ផ្តល់សារៈសំខាន់ដូចជា៖<br>• ជួយទុក្ខធុរៈគ្នាពេលមានអាសន្ន<br>• ជាកម្លាំងសាមគ្គីយ៉ាងរឹងមាំ<br>• ជាអ្នកជួយផ្តល់គំនិត ផ្តល់<br>• ជាអ្នកផ្តល់កម្លាំងចិត្ត<br>• ជាអ្នកជួយផ្តល់គំនិត ផ្តល់យោបល់ក្នុងការដោះស្រាយបញ្ហាផ្សេងៗ។ |
| -ពេលប្អូនទៅផ្ទះកុំភ្លេចមើលមេរៀនបន្ថែម ជួយធ្វើការងារម្តាយឪពុក ពេលធ្វើដំណើរត្រូវប្រុងប្រយ័ត្ន។ | **ជំហានទី៥**<br>(បណ្តាំផ្ញើ) | -ស្តាប់តាមការណែនាំរបស់គ្រូដោយយកចិត្តទុកដាក់ និងអនុវត្តតាម។ |

# កិច្ចតែងការបង្រៀន

- ❖ កាលបរិច្ឆេទ : ថ្ងៃ ទី ខែ ឆ្នាំ
- ❖ មុខវិជ្ជា : សីលធម៌-ពលរដ្ឋវិជ្ជា
- ❖ ថ្នាក់ : ៧
- ❖ **ជំពូកទី៣** : **គ្រួសារ**
- ❖ **មេរៀនទី១** : **ប្រភេទគ្រួសារ**
- ❖ វិធីសាស្ត្របង្រៀន : គោលវិធីសិស្សមជ្ឈមណ្ឌល (ពិភាក្សាក្រុម)
- ❖ រយៈពេល : ២ ម៉ោងសិក្សា (សម្រាប់ម៉ោងទី១)

## I. **វត្ថុបំណង**

- ➢ ចំណេះដឹង : ប្រាប់បានពីនិយមន័យគ្រួសារ គ្រួសារតូច គ្រួសារធំ និងសុខុមាលភាពនៃគ្រួសារតូច បានត្រឹមត្រូវតាមរយៈខ្លឹមសារមេរៀន។
- ➢ បំណិន : បង្ហាញពីភាពខុសគ្នានៃសុខុមាលភាពក្នុងការរស់នៅរបស់សមាជិកគ្រួសារតូច និង គ្រួសារធំ បានត្រឹមត្រូវតាមរយៈការពិភាក្សាក្រុម។
- ➢ ឥរិយាបថ : បណ្តុះស្មារតីសិស្សឱ្យចេះគោរពតាមដំបូន្មានម្តាយឪពុក ដើម្បីទទួលបានសុភមង្គលនៅក្នុងគ្រួសារទាំងមូល។

## II. **សម្ភារឧបទេស**

- សៀវភៅសិស្សទំព័រ ១៨៦-១៨៨ បោះពុម្ពឆ្នាំ ២០១០
- ប័ណ្ណសំណួរ
- ផ្ទាំងរូបភាព
- ផ្ទាំងមេរៀនសង្ខេប

## III. **ខ្លឹមសារមេរៀន**

1. **គ្រួសារ**
2. **គ្រួសារតូច**
3. **សុខុមាលភាពនៃគ្រួសារតូច**

## IV. ដំណឹកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ពិនិត្យលើ: សណ្ដាប់ធ្នាប់ អនាម័យ អវត្តមាន។ | **ជំហានទី១**<br>(រដ្ឋបាលថ្នាក់)<br>• សណ្ដាប់ធ្នាប់<br>• អនាម័យ<br>• អវត្តមាន<br>• ពង្រឹងវិន័យ។ | -ប្រធានថ្នាក់ឡើងរាយការណ៍។ |
| -តើកាលពីថ្ងៃមុនយើងបានសិក្សាពីមេរៀនអ្វី?<br>-តើមិត្តមានប៉ុន្មានប្រភេទ?<br><br>-តើមិត្តល្អមានប៉ុន្មានប្រភេទគួររាប់រក?<br><br>-ក្រៅពីទំនាក់ទំនងជាមួយមិត្តភក្តិ តើប្អូនមានទំនាក់ទំនងជាមួយនរណាទៀត? | **ជំហានទី២**<br>(រំលឹកមេរៀនចាស់)<br>**មេរៀនទី៣**:<br>**សារៈសំខាន់នៃមិត្តភាពល្អ**<br>-មានពីរគឺ កល្យាណមិត្ត និង បាបមិត្ត។<br><br>-មានបួនប្រភេទគឺៈ<br>• មិត្តមានឧបការៈ<br>• មិត្តចិត្តមួយថ្លើមមួយ<br>• មិត្តណែនាំឱ្យធ្វើតែអំពើល្អ<br>• មិត្តមានទឹកចិត្ត។<br><br><u>ទំនាក់ទំនងមេរៀនថ្មី</u><br><br>-ជាមួយបងប្អូន និង ម្ដាយឪពុក នៅក្នុងគ្រួសារ។ | -មិត្តល្អមានបួនប្រភេទគឺៈ<br>• មិត្តមានឧបការៈ<br>• មិត្តចិត្តមួយថ្លើមមួយ<br>• មិត្តណែនាំឱ្យធ្វើតែអំពើល្អ<br>• មិត្តមានទឹកចិត្ត។<br><br>-មានទំនាក់ទំនងជាមួយបងប្អូន អ្នកជិតខាង និង ម្ដាយឪពុកនៅក្នុងគ្រួសារ។ |
| -ឱ្យសិស្សបើកសៀវភៅទំព័រ ១៨៥-១៨៦ រួចអានចំណងជើង<br>-សរសេរចំណងជើងមេរៀនដាក់លើក្ដារខៀន | **ជំហានទី៣**<br>(មេរៀនប្រចាំថ្ងៃ)<br><br>**ជំពូកទី៣**: **គ្រួសារ**<br>**មេរៀនទី១**: **ប្រភេទគ្រួសារ**<br>1. គ្រួសារ<br>2. គ្រួសារតូច | -អានចំណងជើងតាមការណែនាំរបស់គ្រូ<br>-សរសេរចំណងជើងចូលសៀវភៅទាំងអស់គ្នា |

| | | |
|---|---|---|
| | **3.** សុខុមាលភាពនៃគ្រួសារតូច | |
| –ឱ្យសិស្សបើកសៀវភៅទំព័រ ១៨៦-១៨៨ រួចអានខ្លឹមសារមេរៀនបណ្ដាក់គ្នា | (ខ្លឹមសារមេរៀនទំព័រ១៨៦-១៨៨) | –អានខ្លឹមសារមេរៀនបណ្ដាក់គ្នា |
| | **ពន្យល់ពាក្យ** | |
| –សរសេរពាក្យពិបាកលើក្ដារខៀន រួចឱ្យសិស្សឡើងពន្យល់ | –សុភមង្គល(ន): ភាពប្រកបដោយសេចក្ដីសុខ។<br>–ករណីកិច្ច(ន): កិច្ចការដែលត្រូវធ្វើ ឬ ត្រូវបំពេញ។<br>–អាពាហ៍ពិពាហ៍(ន): ការរៀបមង្គលការ ឬ រៀបការ។ | –ឡើងពន្យល់ន័យនៃពាក្យ |
| –ឱ្យសិស្សកត់ត្រាចូលសៀវភៅ | | –កត់ត្រាចូលសៀវភៅ |
| | **សកម្មភាពក្រុម** | |
| –បែងចែកសិស្សជាបួនក្រុមពិភាក្សា | | –ចូលតាមក្រុមពិភាក្សា |
| –**ក្រុមទី១:** តើមេគ្រួសារត្រូវធ្វើដូចម្ដេច ដើម្បីតម្រូវការរបស់សមាជិកគ្រួសារ? | –មេគ្រួសារត្រូវខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តដើម្បីគ្រួសារ។ | –មេគ្រួសារត្រូវខិតខំអស់កម្លាំងកាយកម្លាំងចិត្តក្នុងការចិញ្ចឹមផ្គត់ផ្គង់សមាជិកគ្រួសារ។ |
| –**ក្រុមទី២:** តើម្ដាយឪពុកត្រូវធ្វើអ្វី ហើយកូនត្រូវធ្វើអ្វី? | –ចិញ្ចឹម និងអប់រំកូន ឯកូនត្រូវចិញ្ចឹមគាត់វិញនៅពេលគាត់ចាស់ជរា | –ម្ដាយឪពុកមានកាតព្វកិច្ចចិញ្ចឹម និង អប់រំកូន ឯកូនក៏ត្រូវមានករណីកិច្ចចិញ្ចឹមបីបាច់ថែរក្សាម្ដាយឪពុកពេលចាស់ជរា។ |
| –**ក្រុមទី៣:** តើគ្រួសារតូចមានសមាសភាពនរណាខ្លះ? | –មានសមាសភាពៈ<br>• គូស្វាមិភរិយា<br>• ម្ដាយឪពុក កូនប្រុស កូនស្រី<br>• ម្ដាយ កូនប្រុស កូនស្រី<br>• ឪពុក កូនប្រុស កូនស្រី។ | –មានសមាសភាពៈ<br>• គូស្វាមិភរិយា<br>• ម្ដាយឪពុក កូនប្រុស កូនស្រី<br>• ម្ដាយ កូនប្រុស កូនស្រី<br>• ឪពុក កូនប្រុស កូនស្រី។ |
| –**ក្រុមទី៤:** | –មានគុណសម្បត្តិដូចជាៈ | –មានគុណសម្បត្តិដូចជាៈ |

| | | |
|---|---|---|
| តើគ្រួសារតូចមានកូនតិចមានគុណសម្បត្តិអ្វីខ្លះ?<br><br><br><br><br><br><br><br><br><br><br>–កែសម្រួល និង ឱ្យសិស្សរាយការណ៍រួចកត់ត្រា<br><br>–ឱ្យសិស្សទាញមេរៀនសង្ខេប<br><br><br><br><br><br><br><br><br><br>–សំយោគ និងពន្យល់បន្ថែមរួចឱ្យសិស្សកត់ត្រា | • អាចសម្រាកលំហែ និងជួបជុំកំសាន្តផ្សេងៗ<br>• សមាជិកគ្រួសារមានភាពកក់ក្តៅ<br>• កូនបានសិក្សាបានខ្ពស់<br>• មានពេលវេលាគ្រប់គ្រាន់សម្រាប់ថែរក្សាសុខភាព។<br><br><br><br><br><br><br><br><br>**មេរៀនសង្ខេប**<br><br>ក្នុងគ្រួសារនីមួយៗមេគ្រួសារមានតួនាទីយ៉ាងសំខាន់ក្នុងការចិញ្ចឹមផ្គត់ផ្គង់ជីវភាពគ្រួសារ។ គ្រួសារដែលមានសមាជិកតិចធ្វើឱ្យមេគ្រួសារមានភាពងាស្រួលបំផុតក្នុងការគ្រប់គ្រង។ ដូចនេះគ្រួសារដែលមានសមាជិកតិចបានផ្តល់គុណសម្បត្តិយ៉ាងច្រើនសម្រាប់មេគ្រួសារក៏ដូចជគ្រួសារទាំងមូល។ | • មានពេលវេលាអាចសម្រាកលំហែ និងមានលទ្ធភាពក្នុងការបំពេញតម្រូវការរបស់កូន។<br>• អាចផ្តល់ភាពកក់ក្តៅដល់កូន<br>• អាចបញ្ជូនកូនឱ្យទៅសាលារៀនបានល្អ និង ទទួលបានការអប់រំខ្ពស់។<br>• ពួកគេមានពេលវេលាគ្រប់គ្រាន់ក្នុងការថែទាំសុខភាពផ្ទាល់ខ្លួន។<br>–រាយការណ៍ និង កត់ត្រាចូលសៀវភៅ<br><br>–ទាញមេរៀនសង្ខេប<br><br><br><br><br><br><br><br><br><br>–កត់ត្រាចូលសៀវភៅ |
| <br><br>–ឱ្យសិស្សបិទសៀវភៅ<br>–តើមេគ្រួសារត្រូវធ្វើដូចម្តេចដើម្បីបំពេញតម្រូវការរបស់សមាជិកគ្រួសារ?<br><br>–តើគ្រួសារតូចមានសមាសភាព | **ជំហានទី៤**<br>(ពង្រឹងពុទ្ធិ)<br><br>–ត្រូវខិតខំអស់ពីកម្លាំងកាយចិត្តក្នុងការចិញ្ចឹមសមាជិកគ្រួសារ។<br><br><br>–សមាសភាពគ្រួសារតូចគឺ៖ | <br><br>–បិទសៀវភៅទាំងអស់គ្នា<br>–មេគ្រួសារត្រូវខិតខំឱ្យអស់ពីកម្លាំងកាយកម្លាំងចិត្តក្នុងការចិញ្ចឹមផ្គត់ផ្គង់សមាជិកគ្រួសារ។<br><br>–សមាសភាពគ្រួសារតូចគឺ៖ |

| | | |
|---|---|---|
| នរណាខ្លះ? | • គូស្វាមីភរិយា<br>• ម្ដាយឪពុក កូនប្រុស កូនស្រី<br>• ម្ដាយ កូនប្រុស កូនស្រី<br>• ឪពុក កូនប្រុស កូនស្រី។ | • គូស្វាមីភរិយា<br>• ម្ដាយឪពុក កូនប្រុស កូនស្រី<br>• ម្ដាយ កូនប្រុស កូនស្រី<br>• ឪពុក កូនប្រុស កូនស្រី។ |
| -ពេលប្អូនទៅផ្ទះវិញមើលមេរៀន បន្តនូវចំណុចដែលនៅសល់ទំព័រ ១៨៨-១៨៩ | **ជំហានទី៥**<br>(បណ្ដាំផ្ញើ)<br>4. **គ្រួសារធំ**<br>5. **សុខុមាលភាពនៃគ្រួសារធំ** | -ស្ដាប់គ្រូដោយយកចិត្តទុកដាក់ និង ធ្វើតាម |

# កិច្ចតែងការបង្រៀន

- កាលបរិច្ឆេទ : ថ្ងៃ ទី ខែ ឆ្នាំ
- មុខវិជ្ជា : សីលធម៌-ពលរដ្ឋវិជ្ជា
- ថ្នាក់ទី : ៧
- **ជំពូកទី៣** : **គ្រួសារ**
- **មេរៀនទី១** : **ប្រភេទគ្រួសារ (តចប់)**
- វិធីសាស្ត្របង្រៀន : គោលវិធីសិស្សមជ្ឈមណ្ឌល (ចោទឆ្លើយ)
- រយៈពេល : ២ ម៉ោងសិក្សា (សម្រាប់ម៉ោងទី២)

## I. **វត្ថុបំណង**

- ចំណេះដឹង : ប្រាប់បានពីសមាសភាពនៃគ្រួសារធំ បានត្រឹមត្រូវតាមរយៈការសិក្សាអត្ថបទ។
- បំណិន : បង្ហាញពីសុខុមាលភាពនៃគ្រួសារធំ បានត្រឹមត្រូវតាមរយៈការចោទឆ្លើយរបស់គ្រូ។
- ឥរិយាបថ : បណ្តុះស្មារតិសិស្សឱ្យចេះគោរពតាមដំបូន្មានម្តាយឪពុកដើម្បីឱ្យគ្រួសារទាំងមូលមានសុភមង្គល។

## II. **សម្ភារឧបទេស**

- សៀវភៅសិស្សទំព័រ ១៨៨-១៨៩ បោះពុម្ពឆ្នាំ ២០១០
- ប័ណ្ណសំណួរ
- ផ្ទាំងរូបភាព
- ផ្ទាំងមេរៀនសង្ខេប

## III. **ខ្លឹមសារមេរៀន**

6. **គ្រួសារធំ**
7. **សុខុមាលភាពនៃគ្រួសារធំ**

IV. **ដំណើរការបង្រៀន**

| **សកម្មភាពគ្រូ** | **ខ្លឹមសារមេរៀន** | **សកម្មភាពសិស្ស** |
|---|---|---|
| -ពិនិត្យលើ: សណ្តាប់ធ្នាប់ អនាម័យ អវត្តមាន។ | ជំហានទី១<br>(រដ្ឋបាលថ្នាក់)<br>• សណ្តាបធ្នាប់<br>• អនាម័យ<br>• អវត្តមាន<br>• ពង្រឹងវិន័យ។ | -ប្រធានថ្នាក់ឡើងរាយការណ៍។ |
| -តើកាលពីម៉ោងមុនយើងសិក្សាមេរៀនទី១ ដល់ចំណុចណា?<br>-តើគ្រួសារតូចមានសមាសភាពនរណាខ្លះ?<br><br><br><br><br>-តើមេគ្រួសារមានតួនាទីដូចម្តេចខ្លះ?<br><br><br><br>-តើប្អូនរស់នៅក្នុងគ្រួសារតូច ឬ គ្រួសារធំ?<br>-តើគ្រួសារតូច និង គ្រួសារធំខុសគ្នាឬទេ? ហេតុអ្វី? | **ជំហានទី២**<br>(រំលឹកមេរៀនចាស់)<br>3. សុខុមាលភាពនៃគ្រួសារតូច<br><br>• គូស្វាមីភរិយា<br>• ម្តាយឪពុក កូនប្រុស កូនស្រី<br>• ម្តាយ កូនប្រុស កូនស្រី<br>• ឪពុក កូនប្រុស កូនស្រី។<br><br>-ត្រូវខិតខំប្រឹងប្រែងឱ្យអស់ពីកម្លាំងកាយចិត្តដើម្បីគ្រួសារ។<br><br>**ទំនាក់ទំនងមេរៀនថ្មី**<br>-ធំ / តូច<br><br>-ដូច / ខុស ព្រោះគ្រួសារតូចមានសមាជិកតិចហើយមានជីវភាពប្រសើរជាងគ្រួសារធំ។ | <br><br>3. សុខុមាលភាពនៃគ្រួសារតូច<br><br>-មានសមាសដូចជា៖<br>• គូស្វាមីភរិយា<br>• ម្តាយឪពុក កូនប្រុស កូនស្រី<br>• ម្តាយ កូនប្រុស កូនស្រី<br>• ឪពុក កូនប្រុស កូនស្រី។<br>-ត្រូវខិតខំប្រឹងប្រែងឱ្យអស់ពីកម្លាំងកាយ កម្លាំងចិត្តក្នុងការចិញ្ចឹមផ្គតផ្គង់សមាជិកគ្រួសារ។<br><br>-ធំ / តូច<br><br>-ដូច / ខុសព្រោះគ្រួសារតូចមានសមាជិកតិចហើយមានជីវភាពប្រសើរជាងគ្រួសារធំ។ |
| -ឱ្យសិស្សបើកសៀវភៅទំព័រ ១៨៨ អានចំណងជើងមេរៀន<br>-សរសេរចំណងជើងមេរៀនដាក់លើក្តារខៀន | **ជំហានទី៣**<br>(ដំណើរការមេរៀនថ្មី)<br>**មេរៀនទី១:ប្រភេទគ្រួសារ(តចប់)**<br><br>4. **គ្រួសារធំ**<br>5. **សុខុមាលភាពនៃគ្រួសារធំ** | -អានចំណងជើងមេរៀនតាមការណែនាំរបស់គ្រូ<br>4. គ្រួសារធំ<br>5. សុខុមាលភាពនៃគ្រួសារធំ |

| | | |
|---|---|---|
| –ឱ្យសិស្សបើកសៀវភៅទំព័រ ១៨៨-១៨៩ រួចអានខ្លឹមសារមេរៀន | (ខ្លឹមសារមេរៀនទំព័រ១៨៨-១៨៩) | –អានខ្លឹមសារមេរៀនតាមការណែនាំរបស់គ្រូ |
| –សរសេរពាក្យពិបាកលើក្ដារខៀន រួចឱ្យសិស្សឡើងពន្យល់ | **ពន្យល់ពាក្យ**<br>–អាហារូបត្ថម្ភ(ន): ការផ្ដល់ ឬ ផ្គត់ផ្គង់ចំណីអាហារ។<br>–ថវិកា(ន): លុយកាក់ប្រាក់កាស។<br>–លទ្ធភាព(ន): ភាពដែលអាចធ្វើទៅបាន។ | –ឡើងពន្យល់ន័យរបស់ពាក្យ |
| –កែសម្រួល និង ឱ្យសិស្សកត់ត្រាចូលសៀវភៅ | | –កត់ត្រាចូលសៀវភៅ |
| | **សកម្មភាពចោទឆ្លើយ** | |
| –តើគ្រួសារធំជាគ្រួសារដូចម្ដេច? | –ជាគ្រួសារដែលមានសមាជិកលើសពីម្ដាយឪពុក និង កូនៗបង្កើតដែលរស់នៅក្រោមដំបូលផ្ទះតែមួយ។ | –គ្រួសារធំជាគ្រួសារដែលមានសមាជិកលើសពីម្ដាយឪពុក និង កូនៗបង្កើតដែលរស់នៅក្រោមដំបូលផ្ទះតែមួយ។ |
| –ក្រៅពីម្ដាយឪពុក និងកូនៗបង្កើត តើគ្រួសារធំអាចមាននរណាខ្លះទៀត? | –មាន ជីដូនជីតា មីង ពូ ក្មួយប្រុស ក្មួយស្រី...។ | –មាន ជីដូនជីតា ម្ដាយឪពុក កូនប្រុសស្រី បងប្អូនប្រុសស្រី ពូ មីង ក្មួយប្រុស ក្មួយស្រី។ |
| –តើសុខភាព និង សុភមង្គលគ្រួសារអាស្រ័យលើអ្វីខ្លះ? | –ចំនួនសមាជិកដែលគ្រួសារនោះមាន។ | –អាស្រ័យលើចំនួនសមាជិកដែលគ្រួសារនោះមាន។ |
| –ប្រសិនបើរកប្រាក់ចំណូលបានតិច តើគ្រួសារធំមានផលវិបាកដូចម្ដេចខ្លះ? | –មានផលវិបាកដូចជា៖<br>• ចំណីអាហារមិនគ្រប់គ្រាន់<br>• ពុំមានលទ្ធភាពព្យាបាលជំងឺ<br>• កូនរៀនបានតិច<br>• កូនមានសុខភាពមិនល្អ។ | –មានផលវិបាកដូចជា៖<br>• ចំណីអាហារមិនគ្រប់គ្រាន់<br>• ពុំមានលទ្ធភាពក្នុងការព្យាបាលជំងឺ<br>• មិនអាចឱ្យកូនទៅរៀនបានវែងឆ្ងាយ<br>• សមាជិកគ្រួសារមានសុខភាពមិនល្អ។ |

| | | |
|---|---|---|
| -កែសម្រួល រួចឱ្យសិស្សកត់ត្រា<br><br>-ឱសិស្សទាញមេរៀនសង្ខេប<br><br>-សំយោគ រួចឱ្យសិស្សកត់ត្រា | **មេរៀនសង្ខេប**<br><br>គ្រួសារធំជាគ្រួសារដែលមានសមាជិកលើសពីម្ដាយឪពុក និង កូនៗបង្កើត។ គ្រួសារធអាចជួបការលំបាកក្នុងការថែទាំកូន ការព្យាបាលជំងឺ និង ការបញ្ជូនកូនឱ្យទៅរៀនជាដើម។ | -កត់ត្រាចូលសៀវភៅ<br><br>-ទាញមេរៀនសង្ខេប<br><br>-កត់ត្រាចូលសៀវភៅ |
| -ឱ្យសិស្សបិទសៀវភៅ<br>-ក្រៅពីម្ដាយឪពុក និង កូនៗបង្កើត តើមាននរណាខ្លះទៀតក្នុងគ្រួសារធំ?<br>-តើសុភមង្គលគ្រួសារអាស្រ័យលើអ្វី? | **ជំហានទី៤**<br>(ពង្រឹងពុទ្ធិ)<br><br>-ជីដូនជីតា មីង ពូ ក្មួយប្រុស ក្មួយស្រី...។<br><br>-ចំនួនសមាជិកគ្រួសារ។ | -បិទសៀវភៅតាមការណែនាំ<br>-មាន ជីដូនជីតា ម្ដាយឪពុក កូនប្រុសស្រី បងប្អូនប្រុសស្រី ពូ មីង ក្មួយប្រុសក្មួយស្រី។<br>-អាស្រ័យលើចំនួនសមាជិកគ្រួសារដែលគ្រួសារនោះមាន។ |
| -ពេលប្អូនទៅផ្ទះវិញមើលមេរៀនថ្មីផងនៅទំព័រ ១៩០<br>-កិច្ចការផ្ទះ<br>• ចូរប្អូនធ្វើសំណួរទី 6 ទំព័រ ១៨៩។ | **ជំហានទី៥**<br>(បណ្ដាំផ្ញើ ឬ កិច្ចការផ្ទះ)<br>មេរៀនទី២: សុភមង្គលគ្រួសារ<br><br>-សំណួរ: តើប្អូនត្រូវធ្វើដូចម្ដេចដើម្បីឱ្យគ្រួសារមានសុភមង្គល? | -ស្ដាប់ការណែនាំដោយយកចិត្តទុកដាក់ និង អនុវត្តតាម |

# កិច្ចតែងការបង្រៀន

❖ កាលបរិច្ឆេទ : ថ្ងៃ ទី ខែ ឆ្នាំ
❖ មុខវិជ្ជា : សីលធម៌-ពលរដ្ឋវិជ្ជា
❖ ថ្នាក់ទី : ៧
❖ **ជំពូកទី៣** : **គ្រួសារ**
❖ **មេរៀនទី២** : **សុភមង្គលគ្រួសារ**
❖ វិធីសាស្ត្របង្រៀន : គោលវិធីសិស្សមជ្ឈមណ្ឌល (ពិភាក្សាក្រុម)
❖ រយៈពេល : ១ ម៉ោងសិក្សា

## I. **វត្ថុបំណង**

➢ ចំណេះដឹង : ប្រាប់ពីនិយមន័យ"សុភមង្គលគ្រួសារ" បានត្រឹមត្រូវតាមរយៈការអានខ្លឹមសារមេរៀន។
➢ បំណិន : វិភាគពីប្រភពដែលនាំឱ្យមានសុភមង្គលគ្រួសារបានត្រឹមត្រូវតាមរយៈការពិភាក្សាក្រុម។
➢ ឥរិយាបថ : បណ្តុះស្មារតីសិស្សឱ្យស្រឡាញ់ក្រុមគ្រួសារ និង ចូលរួមធ្វើឱ្យគ្រួសារមានសុភមង្គល។

## II. **សម្ភារឧបទេស**

- សៀវភៅសិស្សទំព័រ ១៩០-១៩១ បោះពុម្ពឆ្នាំ ២០១១
- ប័ណ្ណសំណួរ
- ផ្ទាំងមេរៀនសង្ខេប

## III. **ខ្លឹមសារមេរៀន**

1. **និយមន័យ "សុភមង្គលគ្រួសារ"**
2. **ប្រភពនៃសុភមង្គលគ្រួសារ**

## IV. **ដំណើរការនាំមេរៀន**

| **សកម្មភាពគ្រូ** | **ខ្លឹមសារមេរៀន** | **សកម្មភាពសិស្ស** |
|---|---|---|

| | | |
|---|---|---|
| -ពិនិត្យលើ: សណ្តាប់ធ្នាប់ អនាម័យ អវត្តមាន។ | **ជំហានទី១**<br>(រដ្ឋបាលថ្នាក់)<br>• សណ្តាប់ធ្នាប់<br>• អនាម័យ<br>• អវត្តមាន<br>• ពង្រឹងវិន័យ | -ប្រធានថ្នាក់ឡើងរាយការណ៍។ |
| -តើថ្ងៃមុនយើងបានសិក្សាដល់មេរៀនអ្វី?<br>-តើគ្រួសារមានប៉ុន្មានប្រភេទ? អ្វីខ្លះ?<br>-តើគ្រួសារជាអ្វី?<br><br>-គ្រួសារដែលគ្មានអំពើហិង្សា មានទ្រព្យសម្បត្តិ សុខទាំងកាយសប្បាយទាំងចិត្ត តើយើង ចាត់ទុកគ្រួសារនេះជាគ្រួសារដូចម្តេច? | **ជំហានទី២**<br>(រំលឹកមេរៀនចាស់)<br>មេរៀនទី១: ប្រភេទគ្រួសារ<br><br>-មានពីរគឺ គ្រួសារតូច និង គ្រួសារធំ។<br>-ជាក្រុមមនុស្សដែលកើតចេញពីចំណងអាពាហ៍ពិពាហ៍តាមប្រពៃណីរស់នៅផ្ទះជាមួយគ្នា។<br><br>**ទំនាក់ទំនងមេរៀនថ្មី**<br>-គ្រួសារដែលមានសុភមង្គល។ | -គ្រួសារមានពីរប្រភេទគឺ គ្រួសារតូច និង គ្រួសារធំ។<br>-គ្រួសារជាកោសិកានៃសង្គម និង ជាក្រុមមនុស្សដែលកើតចេញពីចំណងអាពាហ៍ពិពាហ៍តាមប្រពៃណីរស់នៅផ្ទះជាមួយគ្នា ហើយបន្តពូជពង្សជាខ្សែស្រឡាយជាញាតិសណ្តានតៗគ្នា។<br><br>-យើងចាត់ទុកគ្រួសារនេះជាគ្រួសារដែលមានសុភមង្គល។ |
| -ឱ្យសិស្សបើកសៀវភៅទំព័រ ១៩០ អានចំណងជើងមេរៀន<br>-សរសេរចំណងជើងមេរៀនដាក់លើក្តារខៀន<br><br>-តើចំណងជើងមេរៀននេះមានន័យដូចម្តេច? | **ជំហានទី៣**<br>(ដំណើរការមេរៀនថ្មី)<br><br>**មេរៀនទី២: សុភមង្គលគ្រួសារ**<br><br>-គ្រួសាររស់នៅប្រកបដោយសេចក្តីសុខចម្រើន។ | -អានចំណងជើងតាមការណែនាំរបស់គ្រូ<br>មេរៀនទី២: សុភមង្គលគ្រួសារ<br><br>-មានន័យថា គ្រួសារដែលរស់នៅប្រកបដោយសេចក្តីសុខចម្រើន សេចក្តីសុខ គ្មានការរំ |

| | | |
|---|---|---|
| –ឱ្យសិស្សអានខ្លឹមសារមេរៀន ទំព័រ ១៩០-១៩១ បណ្ដាក់គ្នា | "បន្ទាប់ពីរៀបមង្គល......គ្រប់ៗ ជាដើម។" | លោភបំពាន មានការគោរពគ្នា ទៅវិញទៅមក។<br>–អានខ្លឹមសារមេរៀនបណ្ដាក់គ្នា |
| | **ពន្យល់ពាក្យ** | |
| –សរសេរពាក្យពិបាកលើក្ដារ ខៀន រួចឱ្យសិស្សឡើងពន្យល់ | –សុខុដុម(ន): ភាពសុខសាន្ត។<br>–អារម្មណ៍(ន): ការដឹង។<br>–និយម(ន): អនុលោមតាម។ | –ឡើងពន្យល់ន័យរបស់ពាក្យ |
| –កែលម្អ រួចឱ្យសិស្សកត់ត្រា | | |
| | **ពិភាក្សាក្រុម** | |
| –បែងចែកសិស្សជាបួនក្រុម ដើម្បីធ្វើការពិភាក្សា | | –ចូលតាមក្រុមពិភាក្សា |
| –**ក្រុមទី១**: តើសុភមង្គលគ្រួសារ មានន័យដូចម្ដេច? | –សមាជិកគ្រួសាររស់នៅប្រកប ដោយសេចក្ដីសុខចម្រើន ទាំងផ្លូវ កាយ និង ផ្លូវចិត្ត។ | –គ្រួសារដែលមានសេចក្ដីសុខ ចម្រើន ការរស់នៅចុះសម្រុងគ្នា គ្មានការឈ្លោះប្រកែកគ្នា និង ចេះយោគយល់អធ្យាស្រ័យគ្នា ទៅវិញទៅមក។ |
| –**ក្រុមទី២**:ចូរប្អូននិយាយពី សេចក្ដីសុខផ្លូវកាយ? | –សុខរាងកាយគ្មានអំពើហិង្សា គ្មានការរំលោភបំពាន...។ | –សុខផ្លូវកាយគឺ សុខរាងកាយ គ្មានអំពើហិង្សា គ្មានការរំលោភ បំពាន លើសពីនេះគឺមានទ្រព្យ សម្បត្តិសម្រាប់បំពេញសេចក្ដី ត្រូវការ និង សម្រួលដល់ការរស់ នៅបានប្រសើរ។ |
| –**ក្រុមទី៣**: ចូរប្អូននិយាយពី សេចក្ដីសុខផ្លូវចិត្ត? | –ចិត្តស្ងប់ អារម្មណ៍ល្អ គ្មានការ គំរាមកំហែង។ | –សុខផ្លូវចិត្តគឺ មានចិត្តស្ងប់ មានអារម្មណ៍ល្អ គ្មានការគំរាម កំហែង ឬ ធ្វើបាបផ្លូវចិត្ត។ |
| –**ក្រុមទី៤**: តើសមាជិកគ្រួសារ ម្នាក់ៗត្រូវមានភារកិច្ចអ្វីខ្លះ ដើម្បីឱ្យគ្រួសារមានភាពសុខសាន្ត ? | –សមាជិកគ្រួសារ<br>• មិនប្រើអំពើហិង្សា<br>• ត្រូវមានទំនួលខុសត្រូវ<br>• មានការអធ្យាស្រ័យ<br>• ចេះរកទ្រព្យសម្បត្តិ | -សមាជិកគ្រួសារម្នាក់ៗគឺ៖<br>• មិនត្រូវប្រើអំពើហិង្សា និង<br>ការរើសអើងចំពោះកូនប្រុសកូនស្រី |

| | | |
|---|---|---|
| –ឱ្យតំណាងសិស្សឡើងបង្ហាញបកស្រាយ<br><br>–គ្រូសំយោគ និង ឱ្យសិស្សកត់ចូលសៀវភៅ<br><br>–ឱ្យសិស្សសាកល្បងសង្ខេបមេរៀន | សម្រាប់គ្រួសារ។<br>• មានពេលវេលាគ្រប់គ្រាន់សម្រាប់គ្រួសារ។<br><br>**មេរៀនសង្ខេប**<br>សុភមង្គលគ្រួសារ គឺសំដៅយកគ្រួសារដែលចេះរួបរួមសាមគ្គីគ្នា មានទ្រព្យសម្បត្តិ និង រស់នៅប្រកបដោយសេចក្តីសុខសេចក្តីចម្រើន។<br>សេចក្តីចម្រើននៅក្នុងគ្រួសារអាស្រ័យលើសមាជិក ម្នាក់ៗស្វែងយល់ច្បាស់ពីសិទ្ធិ តួនាទី និង ការទទួលខុសត្រូវ។ | • ស្វែងយល់ឱ្យច្បាស់ពីសិទ្ធិ តួនាទី និង ភារកិច្ច<br>• ត្រូវមានការទទួលខុសត្រូវរៀងៗខ្លួន<br>• ត្រូវមានការអធ្យាស្រ័យ និង អត់ឱនឱ្យគ្នា<br>• ចេះរកទ្រព្យសម្បត្តិមកផ្គត់ផ្គង់ជីវភាពគ្រួសារ<br>• មានពេលវេលាសម្រាប់គ្រួសារ។<br>–តំណាងក្រុមឡើងរាយការណ៍<br><br>–កត់មេរៀនចូលសៀវភៅ<br><br>–ចូលរួមសង្ខេបមេរៀន |
| –ឱ្យសិស្សបិទសៀវភៅ<br>–តើគ្រួសារមានសុភមង្គល់មានន័យដូចម្តេច? | **ជំហានទី៤**<br>(ពង្រឹងពុទ្ធិ)<br><br>–គ្រួសារដែលមានសេចក្តីសុខសេចក្តីចម្រើន ការនៅចុះសម្រុងគ្នា។<br><br>–សមាជិកគ្រួសារ | –បិទសៀវភៅទាំងអស់គ្នា<br>–គ្រួសារដែលមានសេចក្តីសុខចម្រើន ការរស់នៅចុះសម្រុងគ្នាគ្មានការឈ្លោះប្រកែកគ្នា និង ចេះយោគយល់អធ្យាស្រ័យគ្នាទៅវិញទៅមក។ |

| | | |
|---|---|---|
| –តើសមាជិកគ្រួសារម្នាក់ៗ មានភារកិច្ចអ្វីខ្លះ ដើម្បីឱ្យគ្រួសារមានភាពសុខសាន្ត ? | • មិនប្រើអំពើហិង្សា<br>• ត្រូវមានទំនួលខុសត្រូវ<br>• មានការអធ្យាស្រ័យ<br>• ចេះរកទ្រព្យសម្បត្តិសម្រាប់គ្រួសារ។<br>• មានពេលវេលាគ្រប់គ្រាន់សម្រាប់គ្រួសារ។ | –សមាជិកគ្រួសារត្រូវៈ<br>• មិនប្រើអំពើហិង្សា ការរើសអើងកូនស្រី<br>• ស្វែងយល់ឱ្យបានច្បាស់ពីសិទ្ធិ តួនាទី ភារកិច្ច<br>• មានអធ្យាស្រ័យ ការអត់ឱនគ្នា<br>• ចេះរកទ្រព្យសម្បត្តិដើម្បីផ្គត់ផ្គង់គ្រួសារ<br>• មានពេលវេលាសម្រាប់គ្រួសារ។ |
| –ប្អូនត្រូវចូលរួមថែរក្សាគ្រួសារ ស្រឡាញ់គ្រួសារដើម្បីឱ្យគ្រួសារមានសុភមង្គល<br>–កិច្ចការផ្ទះ<br>• ចូរប្អូនមើលមេរៀនបន្តនៅទំព័រ ១៩២ | **ជំហានទី៥**<br>(បណ្តាំផ្ញើ និងកិច្ចការផ្ទះ)<br><br>មេរៀនទី៣:<br>វិធីកសាងសុភមង្គលគ្រួសារ | –ស្តាប់តាមការណែនាំរបស់គ្រូ ដោយយកចិត្តទុកដាក់ និងត្រៀមអនុវត្តតាម |

# កិច្ចតែងការបង្រៀន

- កាលបរិច្ឆេទ : ថ្ងៃ ទី ខែ ឆ្នាំ
- មុខវិជ្ជា : សីលធម៌-ពលរដ្ឋវិជ្ជា
- ថ្នាក់ : ៧
- **ជំពូកទី៣ : គ្រួសារ**
- **មេរៀនទី៣ : វិធីកសាងសុភមង្គលគ្រួសារ**
- វិធីសាស្ត្របង្រៀន : គោលវិធីសិស្សមជ្ឈមណ្ឌល (ពិភាក្សាក្រុម)
- រយៈពេល : ៣ ម៉ោងសិក្សា (សម្រាប់ម៉ោងទី១)

## I. វត្ថុបំណង

- ចំណេះដឹង : ប្រាប់ពីសុភមង្គលគ្រួសារ និង គុណវិបត្តិនៃគ្រួសារ បានយ៉ាងត្រឹមត្រូវ តាមរយៈ ការអានខ្លឹមសារមេរៀន និង សំណួរបំផុសរបស់គ្រូ។
- បំណិន : បកស្រាយបានពីតួនាទីរបស់ម្ដាយឪពុកចំពោះកូន និង ស្វាមីចំពោះ ភរិយា បានយ៉ាងត្រឹមត្រូវតាមរយៈការពិភាក្សាក្រុម។
- ឥរិយាបថ : បណ្ដុះស្មារតីសិស្សឱ្យចេះពីវិធីកសាងសុភមង្គលនៅក្នុងគ្រួសារ និង មានតួនាទីក្នុងការបំពេញការងារនៅក្នុងសមាជិកគ្រួសារ ព្រមទាំង ចេះស្រឡាញ់គ្រួសារ។

## II. សម្ភារឧបទេស

- សៀវភៅសិស្សទំព័រ ១៩២-១៩៣ បោះពុម្ពឆ្នាំ ២០១១
- ប័ណ្ណសំណួរ
- ផ្ទាំងរូបភាព
- ផ្ទាំងមេរៀនសង្ខេប

## III. ខ្លឹមសារមេរៀន

1. **តួនាទីរបស់ម្ដាយឪពុកចំពោះកូន**
2. **តួនាទីរបស់ស្វាមីចំពោះភរិយា**

IV. **ដំណើរការបង្រៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូត្រួតពិនិត្យលើ: សណ្ដាប់ធ្នាប់ អនាម័យ អវត្តមាន។ | **ជំហានទី១**<br>(រដ្ឋបាលថ្នាក់)<br>• សណ្ដាប់ធ្នាប់<br>• អនាម័យ<br>• អវត្តមាន<br>• ពង្រឹងវិន័យ | -ប្រធាន ឬ អនុប្រធានឡើងរាយការណ៍។ |
| -តើកាលពីថ្ងៃមុនយើងបានសិក្សាអំពីមេរៀនអ្វី?<br>-តើសុភមង្គលគ្រួសារមានអត្ថន័យដូចម្ដេច?<br><br>-តើប្រភពនៃសុភមង្គលគ្រួសារមានអ្វីខ្លះ?<br><br>-ដើម្បីធ្វើឱ្យគ្រួសារមានសុភមង្គល តើប្អូនត្រូវធ្វើដូចម្ដេច?<br><br>-តើកត្តាទាំងអស់នេះអាចជួយប្អូនក្នុងវិធីកសាងសុភមង្គលគ្រួសាររបស់ប្អូនដែរឬទេ? | **ជំហានទី២**<br>(រំលឹកមេរៀនចាស់)<br>មេរៀនទី២: សុភមង្គលគ្រួសារ<br><br>-មានន័យថា គ្រួសារដែលរស់នៅប្រកបដោយសេចក្ដីសុខចម្រើនទាំងផ្លូវកាយ និង ផ្លូវចិត្ត។<br><br>-មានដូចជា៖<br>• ការប្រាស្រ័យទាក់ទងក្នុងក្រុមគ្រួសារ<br>• សុខភាពជាទ្រព្យជាសម្បត្តិ<br>• សេដ្ឋកិច្ច។<br><br>**<u>ទំនាក់ទំនងមេរៀនថ្មី</u>**<br>• ខិតខំរៀនសូត្រ<br>• ជួយធ្វើកិច្ចការផ្ទះ...។<br><br>-ជួយ | -សុភមង្គលគ្រួសារមានន័យថា ជាភាពសុខសាន្ត ភាពសុខដុម និង សេចក្ដីចម្រើនរបស់គ្រួសារ ដោយគ្មានអំពើហិង្សា និង ការរើសអើងក្នុងគ្រួសារ។<br><br>-ប្រភពនៃសុភមង្គលគ្រួសារមានកត្តាសំខាន់ៗមួយចំនួនគឺ៖<br>• ការប្រាស្រ័យទាក់ទងក្នុងក្រុមគ្រួសារ<br>• សុខភាពជាទ្រព្យជាសម្បត្តិ<br>• សេដ្ឋកិច្ច។<br><br>-ដើម្បីធ្វើឱ្យគ្រួសារមានសុភមង្គលត្រូវ៖<br>• ខិតខំរៀនសូត្រ<br>• ជួយធ្វើកិច្ចការផ្ទះ<br>• យោគយល់អធ្យាស្រ័យ<br>-ជួយក្នុងវិធីកសាងសុភមង្គលគ្រួសារ។ |

| | | |
|---|---|---|
| | **ជំហានទី៣**<br>(ដំណើរការមេរៀនថ្មី) | |
| –ឱ្យសិស្សបើកសៀវភៅទំព័រ ១៩២ អានចំណងជើងមេរៀន<br>–សរសេរចំណងជើងមេរៀនដាក់លើក្ដារខៀន | **មេរៀនទី៣**:<br>**វិធីកសាងសុភមង្គលគ្រួសារ** | –អានចំណងជើងមេរៀនតាមការណែនាំរបស់គ្រូ<br>–សរសេរចំណងជើងមេរៀនដាក់សៀវភៅរៀងៗខ្លួន |
| –តើចំណងជើងមេរៀននេះមានន័យដូចម្ដេច? | –វិធីកសាងសេចក្ដីសុខចម្រើននៅក្នុងក្រុមគ្រួសារ។ | –មានន័យថា វិធីកសាងសេចក្ដីសុខ សេចក្ដីសុខចម្រើននៅក្នុងក្រុមគ្រួសារ។ |
| –តើប្អូនឃើញអ្វីខ្លះនៅក្នុងរូបភាពនេះ? | –ឪពុកម្ដាយ កូនប្រុសកូនស្រី កូនង៉ានៅក្នុងអង្រឹង តុ កៅអី ទូរទស្សន៍។ | –ឃើញមាន ឪពុកម្ដាយ កូនប្រុសកូនស្រី កូនង៉ានៅក្នុងអង្រឹង តុ កៅអី ទូរទស្សន៍ រូបភាព...។ |
| –តើរូបភាពនេះចង់បង្ហាញពីអ្វី? | –បង្ហាញពី គ្រួសារមួយដែលមានសុភមង្គល ចេះជួយគ្នា គោរពសិទ្ធិគ្នា...។ | –រូបភាពនេះចង់បង្ហាញពីគ្រួសារមួយដែលមានសុភមង្គល ចេះជួយគ្នា គោរពសិទ្ធិគ្នា និងដឹងពីតួនាទីរៀងៗខ្លួនដើម្បីបំពេញតម្រូវការគ្រួសារ។ |
| –តើរូបភាព និង ចំណងជើងមានទំនាក់ទំនងគ្នាដែរឬទេ?ព្រោះអ្វី?<br>–ឱ្យសិស្សអានខ្លឹមសារមេរៀនទំព័រ ១៩២-១៩៣ | –មាន ព្រោះរូបភាពបង្ហាញពីគ្រួសារមួយដែលមានសុភមង្គល ឯចំណងជើងនិយាយពី ‟វិធីកសាងសុភមង្គលគ្រួសារ″។<br>–អានចាប់ពី″សមាជិកគ្រួសារ...... មានភក្ដីភាពចំពោះភរិយា″។ | –មាន ព្រោះរូបភាពបង្ហាញពីគ្រួសារមួយដែលមានសុភមង្គល ឯចំណងជើងនិយាយពី ‟វិធីកសាងសុភមង្គលគ្រួសារ″។<br>–អានខ្លឹមសារមេរៀនបណ្ដាក់គ្នា |
| –សរសេរពាក្យពិបាកលើក្ដារខៀន រួចឱសិស្សឡើងពន្យល់ | **ពន្យល់ពាក្យ**<br>–សុភមង្គល(ន): សេចក្ដីសុខ សេចក្ដីចម្រើន។<br>–ភារកិច្ច(ន): កិច្ចការដែលត្រូវធ្វើ។<br>–សីលធម៌(ន): ដំបូន្មានដែលនាំចៀសវាងអំពើអាក្រក់។ | –ឡើងពន្យល់ន័យរបស់ពាក្យ |

| | | |
|---|---|---|
| | –ភក្តីភាព(ន): ភាពនៃការរាប់អាន ភាពនៃសេចក្តី ស្រឡាញ់ស្មោះ។<br>–ពលរដ្ឋ(ន): មនុស្សទាំងប្រុស ទាំងស្រីដែលជា កម្លាំង របស់ប្រទេស។ | |
| –កែសម្រួលរួចឱ្យសិស្សកត់ត្រា ចូលសៀវភៅ | | –កត់ត្រាចូលសៀវភៅ |
| | **សកម្មភាពក្រុម** | |
| –បែងចែកសិស្សជាបួនក្រុម ដើម្បីធ្វើការពិភាក្សា | | –ចូលតាមក្រុមពិភាក្សា |
| **–ក្រុមទី១:** ដើម្បីឱ្យគ្រួសារមាន សុភមង្គល តើសមាជិកម្នាក់ៗ ត្រូវធ្វើដូចម្តេច? | –សមាជិកម្នាក់ៗត្រូវ៖<br>• ចេះជួយគ្នា អធ្យាស្រ័យ គ្នាទៅវិញទៅមក<br>• មិនទាស់ទែងគ្នា ដោះ ស្រាយបញ្ហាដោយសន្តិវិធី។<br>• ចេះជួយរំលែកការងារគ្នា ចេះយល់ចិត្តគ្នាទៅវិញទៅមក<br>• សមាជិកទាំងអស់ចេះ ស្រឡាញ់គ្នា។ | –សមាជិកម្នាក់ៗត្រូវ៖<br>• ចេះជួយគ្នា<br>• អធ្យាស្រ័យគ្នាទៅវិញ ទៅមក<br>• មិនទាស់ទែងគ្នា<br>• ចេះដោះស្រាយបញ្ហា ដោយសន្តិវិធី។<br>• ចេះជួយរំលែកការងារគ្នា<br>• ចេះយល់ចិត្តគ្នាទៅវិញ ទៅមក<br>• សមាជិកទាំងអស់ចេះ ស្រឡាញ់គ្នា។ |
| **–ក្រុមទី២:**គ្រួសារដែលគ្មាន សុភមង្គល តើគ្រួសារនោះនឹង ជួបគុណវិបត្តិអ្វីខ្លះ? | –ជួបគុណវិបត្តិដូចជា៖<br>• មានអំពើហិង្សានៅក្នុង គ្រួសារទាស់ទែងគ្នាបែកបាក់ សាមគ្គីកូនៗគ្មានសុភមង្គល (គ្មានភាពកក់ក្តៅ)<br>• ខ្មាស់អ្នកជិតខាង (អ្នកជិតខាងមើលងាយ)<br>• សង្គមមើលងាយ។ | –ជួបគុណវិបត្តិដូចជា៖<br>• មានអំពើហិង្សានៅក្នុង គ្រួសារ<br>• ទាស់ទែងគ្នាបែកបាក់ សាមគ្គី<br>• កូនៗគ្មានសុភមង្គល (គ្មានភាពកក់ក្តៅ)<br>• ខ្មាស់អ្នកជិតខាង (អ្នកជិតខាងមើលងាយ)<br>• សង្គមមើលងាយ។ |

| | | |
|---|---|---|
| –**ក្រុមទី៣**:ចូរនិយាយពីតួនាទីរបស់ម្តាយឪពុកចំពោះកូន។ | –តួនាទីរបស់ម្តាយឪពុកចំពោះកូនមានដូចជា៖<br>• ស្រឡាញ់ថ្នាក់ថ្នមកូនស្មើៗគ្នាពង្រីកការអប់រំខាងស្មារតី សីលធម៌ សាសនា<br>• ពិនិត្យរាល់សកម្មភាពនិង ការកំសាន្ត អប់រំឱ្យឧស្សាហ៍ព្យាយាម និង មានជំនឿលើខ្លួនឯង លើកទឹកចិត្តកិច្ចការផ្ទះ សាលា និង សង្គម។<br>• បង្រៀនពីភារកិច្ចពលរដ្ឋឱ្យស្រឡាញ់ជាតិ ផ្តល់ដំបូន្មានល្អៗចំពោះការអភិវឌ្ឍ ។<br>• ធ្វើជាគំរូល្អដល់ពួកគេទុកដាក់ពួកគេឱ្យមានគូស្រករតាមប្រពៃណី។ | –តួនាទីរបស់ម្តាយឪពុកចំពោះកូនមានដូចជា៖<br>• ស្រឡាញ់ថ្នាក់ថ្នមកូនស្មើៗគ្នា<br>• ពង្រីកការអប់រំខាងស្មារតី សីលធម៌ សាសនា<br>• ពិនិត្យរាល់សកម្មភាពនិង ការកំសាន្ត<br>• អប់រំឱ្យឧស្សាហ៍ព្យាយាម និង មានជំនឿលើខ្លួនឯង<br>• លើកទឹកចិត្តកិច្ចការផ្ទះ សាលា និង សង្គម<br>• បង្រៀនពីភារកិច្ចពលរដ្ឋឱ្យស្រឡាញ់ជាតិ<br>• ផ្តល់ដំបូន្មានល្អៗចំពោះការអភិវឌ្ឍ<br>• ធ្វើជាគំរូល្អដល់ពួកគេ<br>• ទុកដាក់ពួកគេឱ្យមានគូស្រករតាមប្រពៃណី។ |
| –**ក្រុមទី៤**: តើតួនាទីរបស់ស្វាមីចំពោះភរិយាមានអ្វីខ្លះ? | –តួនាទីរបស់ស្វាមីចំពោះភរិយាមានដូចជា៖<br>• លើកតម្កើងស្រឡាញ់ភរិយាមិនមើលងាយភរិយាមិនប្រើអំពើហិង្សា<br>• ដឹកនាំគ្រប់គ្រងគ្រួសារឱ្យបានល្អ និង ទទួលខុសត្រូវលើសុខភាពរបស់សមាជិកគ្រួសារទាំងអស់។<br>• ជួយសម្រួលភារកិច្ចរបស់ភរិយា ចិញ្ចឹមបីបាច់កូន អប់រំកូន ជួយធ្វើកិច្ចការក្នុងផ្ទះ។<br>• ថ្នាក់ថ្នមភរិយា ផ្តល់សេរីភាពគ្រប់បែបយ៉ាងដោះស្រាយដោយឈ្លាសវៃ និង មានមូល | –តួនាទីរបស់ស្វាមីចំពោះភរិយាមានដូចជា៖<br>• លើកតម្កើងស្រឡាញ់ភរិយា<br>• មិនមើលងាយភរិយា មិនប្រើអំពើហិង្សា<br>• ដឹកនាំគ្រប់គ្រងគ្រួសារឱ្យបានល្អ និង ទទួលខុសត្រូវលើសុខភាពរបស់សមាជិកគ្រួសារទាំងអស់។<br>• ជួយសម្រួលភារកិច្ចរបស់ភរិយា ចិញ្ចឹមបីបាច់កូន អប់រំកូន ជួយធ្វើកិច្ចការក្នុងផ្ទះ។<br>• ថ្នាក់ថ្នមភរិយា ផ្តល់សេរីភាពគ្រប់បែបយ៉ាង |

| | | |
|---|---|---|
| <br><br><br><br><br>–សំយោគចម្លើយ រួចឱ្យសិស្ស កត់ត្រាចូលសៀវភៅ<br><br>–ឱ្យសិស្សសាកល្បងទាញ មេរៀនសង្ខេប<br><br><br><br><br><br><br><br><br><br><br>- ឱ្យសិស្សកត់ត្រាចូលសៀវភៅ | ដ្ឋានច្បាស់លាស់។<br>• មានភក្តីភាពចំពោះ ភរិយា។<br><br><br><br><br>**មេរៀនសង្ខេប**<br>គ្រួសារមានសុភមង្គល អាស្រ័យទៅលើសមាជិកចេះជួយ គ្នា យោគយល់គ្នា និងចេះ ចែករំលែកការងារគ្នាឱ្យបានត្រឹម ត្រូវ ប៉ុន្តែនៅក្នុងគ្រួសារដែល ពោរពេញទៅដោយអំពើហិង្សាគឺ ជាគ្រួសារដែលគ្មានសុភមង្គល។ ដូចនេះដើម្បីឱ្យគ្រួសារមានសុភ មង្គល និង រីកចម្រើនសមាជិក ម្នាក់ៗត្រូវគោរពតួនាទីឱ្យបានល្អ រៀងៗខ្លួន។ | • ដោះស្រាយដោយឈ្លាស វៃ និង មានមូលដ្ឋានច្បាស់ លាស់។<br>• មានភក្តីភាពចំពោះ ភរិយា។<br>–កត់ត្រាចូលសៀវភៅរៀងៗខ្លួន<br><br><br>–សាកល្បងទាញមេរៀនសង្ខេប តាមគ្រូ<br><br><br><br><br><br><br><br><br><br><br>–កត់ត្រាចូលសៀវភៅរៀនៗខ្លួន |
| <br><br>–ឱ្យសិស្សបិទសៀវភៅ<br>–តើម្តាយឪពុកមានតួនាទីអ្វីខ្លះ ចំពោះកូន? | **ជំហានទី៤**<br>(ពង្រឹងពុទ្ធិ)<br><br>–តួនាទីរបស់ម្តាយឪពុកចំពោះ កូនមានដូចជា៖<br>• ស្រឡាញ់ថ្នាក់ថ្នមកូន ស្មើៗគ្នា ពង្រីកការអប់រំខាង ស្មារតី សីលធម៌ សាសនា<br>• ពិនិត្យរាល់សកម្មភាពនិង ការកំសាន្ត អប់រំឱ្យឧស្សាហ៍ព្យា- យាម និង មានជំនឿលើខ្លួនឯង លើកទឹកចិត្តកិច្ចការផ្ទះសាលា និង សង្គម។<br>• បង្រៀនពីភារកិច្ចពលរដ្ឋឱ្យ | <br><br>–បិទសៀវភៅទាំងអស់គ្នា<br>–តួនាទីរបស់ម្តាយឪពុកចំពោះ កូនមានដូចជា៖<br>• ស្រឡាញ់ថ្នាក់ថ្នមកូន ស្មើៗគ្នា<br>• ពង្រីកការអប់រំខាងស្មារ តី សីលធម៌ សាសនា<br>• ពិនិត្យរាល់សកម្មភាព និង ការកំសាន្ត<br>• អប់រំឱ្យឧស្សាហ៍ព្យា យាម និង មានជំនឿលើខ្លួនឯង<br>• លើកទឹកចិត្តកិច្ចការផ្ទះ |

| | | |
|---|---|---|
| | ស្រឡាញ់ជាតិ<br>ផ្តល់ដំបូន្មានល្អៗចំពោះការអភិវឌ្ឍ ។<br>• ធ្វើជាគំរូល្អដល់ពួកគេទុកដាក់ពួកគេឱ្យមានគូស្រករតាមប្រពៃណី។ | សាលា និង សង្គម<br>• បង្រៀនពីភារកិច្ចពលរដ្ឋឱ្យស្រឡាញ់ជាតិ<br>• ផ្តល់ដំបូន្មានល្អៗចំពោះការអភិវឌ្ឍ<br>• ធ្វើជាគំរូល្អដល់ពួកគេ<br>• ទុកដាក់ពួកគេឱ្យមានគូស្រករតាមប្រពៃណី។ |
| –ពេលប្អូនត្រឡប់ទៅផ្ទះវិញ ត្រូវខិតខំរៀនសូត្រ និង មើលមេរៀនបន្តនៅទំព័រ ១៩៤-១៩៥ ចំណុចលេខ 3 និង លេខ4 ផង | **ជំហានទី៥**<br>(បណ្តាំផ្ញើ ឬ កិច្ចការផ្ទះ)<br>3. តួនាទីរបស់ភរិយាចំពោះស្វាមី<br>4. តួនាទីរបស់កូនចំពោះឪពុកម្តាយ | –ស្តាប់គ្រូដោយយកចិត្តទុកដាក់ និង ធ្វើតាមការណែនាំ |

# កិច្ចតែងការបង្រៀន

❖ កាលបរិច្ឆេទ : ថ្ងៃ ទី ខែ ឆ្នាំ
❖ មុខវិជ្ជា : សីលធម៌ពលរដ្ឋវិជ្ជា
❖ ថ្នាក់ : ៧
❖ **ជំពូកទី៣** : **គ្រួសារ**
❖ **មេរៀនទី៣** : **ទំនាក់ទំនងក្នុងគ្រួសារ** (ត)
❖ រយៈពេល : ៣ម៉ោងសិក្សា (សម្រាប់ម៉ោងទី២)

## I. **វត្ថុបំណង**

➢ ចំណេះដឹង : រៀបរាប់បានពីតួនាទីរបស់ភរិយាចំពោះស្វាមីនិងតួនាទីរបស់កូនចំពោះម្ដាយឪពុកបានយ៉ាងត្រឹមត្រូវតាមរយៈការអានខ្លឹមសារមេរៀនព្រមទាំងសំណួរបំផុសរបស់គ្រូ។
➢ បំណិន : បកស្រាយបានពីសារៈសំខាន់នៃគ្រួសារបានយ៉ាងត្រឹមត្រូវតាមរយៈការពិភាក្សាក្រុមនិងការពន្យល់ណែនាំរបស់គ្រូ។
➢ ឥរិយាបថ : បណ្ដុះស្មារតីឲសិស្សមានស្មារតីទទួលខុសត្រូវចំពោះតួនាទីរបស់ខ្លួន។

## II. **សម្ភារឧបទេស**

- សៀវភៅសិស្សទំព័រ១៩២-១៩៦បោះពុម្ពឆ្នាំ២០១០
- ប័ណ្ណសំណួរ
- មេរៀនសង្ខេប

## III. **ខ្លឹមសារមេរៀន**

3. **តួនាទីរបស់ភរិយាចំពោះស្វាមី**
4. **តួនាទីរបស់កូនចំពោះម្ដាយឪពុក**

IV. **ដំណើរការបង្រៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| –ពិនិត្យៈ អនាម័យអវត្តមាន សណ្តាប់ធ្នាប់។ | **ជំហានទី១**<br>(រដ្ឋបាលថ្នាក់) | –ប្រធានថ្នាក់ឬអនុប្រធានរាយការណ៍។ |
| –ដើម្បីឲ្យគ្រួសារមានសុភមង្គលតើសមាជិកម្នាក់ៗត្រូវធ្វើដូចម្តេច?<br><br>–តើឪពុកម្តាយមានតួនាទីចំពោះកូនដូចម្តេចខ្លះ?<br><br>–តើប្អូនមកសាលារាល់ថ្ងៃនេះមានតួនាទីធ្វើអ្វី?ចុះប្អូនឃើញម្តាយរបស់ប្អូនជួយអ្វីខ្លះដល់ | **ជំហានទី២**<br>រំលឹកមេរៀនចាស់<br>–ដើម្បីឲ្យគ្រួសារមានសុភមង្គលសមាជិកម្នាក់ៗត្រូវៈ<br>• ចេះជួយគ្នា<br>• អធ្យាស្រ័យគ្នាទៅវិញទៅមក មិនប្រើអំពើហឹង្សា<br>• មិនទាស់ទែងគ្នាដោះស្រាយដោយសន្តិវិធី<br>• ចេះចែករំលែកការងារគ្នា<br>• ប្តីយល់ចិត្តប្រពន្ធប្រពន្ធយល់ចិត្តប្តី សមាជិកទាំងអស់ចេះស្រឡាញ់គ្នា...។<br><br>–ឪពុកម្តាយមានតួនាទីចំពោះកូនដូចជាៈ<br>• ស្រឡាញ់ថ្នាក់ថ្នមកូនស្មើៗគ្នា<br>• ពង្រីកការអប់រំខាងឯស្មារតីសីលធម៌វិន័យសាសនា<br>• ជួយជំរុញលើកទឹកចិត្តធ្វើកិច្ចការផ្ទះកិច្ចការសាលា<br>• ផ្តល់ដំបូន្មានល្អៗចំពោះការអភិវឌ្ឍនិងសុខមាលភាព<br>• ធ្វើជាគំរូល្អដល់ពួកគេ...។<br><br><u>**ទំនាក់ទំនងមេរៀនថ្មី**</u><br>–ខិតខំរៀនសូត្រ...។<br>–ឃើញដូចជាៈចាត់ចែងការងារក្នុងផ្ទះ | –ដើម្បីឲ្យគ្រួសារមានសុភមង្គលសមាជិកម្នាក់ៗត្រូវៈ<br>• ចេះជួយគ្នាអធ្យាស្រ័យគ្នាទៅវិញទៅមក<br>• មិនប្រើអំពើហឹង្សា<br>• សមាជិកទាំងអស់ចេះស្រឡាញ់គ្នា...។<br><br>–ឪពុកមានតួនាទីចំពោះកូនដូចជាៈ<br>• ស្រឡាញ់ថ្នាក់ថ្នមកូនស្មើៗគ្នា<br>• ពង្រីកការអប់រំខាងស្មារតីសីលធម៌វិន័យសាសនា<br>• ផ្តល់ដំន្មានល្អៗ<br>• ធ្វើជាគំរូល្អដល់ពួកគេ...។<br><br>–មាននាទីជាអ្នកខិតខំរៀនសូត្រ...។<br>• ចាត់ចែងការងារផ្ទះបាយ |

| | | |
|---|---|---|
| ឪពុកម្ដាយរបស់ប្អូន?<br><br><br><br><br><br>–អញ្ចឹងថ្ងៃនេះយើងនិងរៀនមេរៀនរបស់យើងបន្តទៀត | • ជួយគោរពស្រឡាញ់និងមានភក្ដីភាពចំពោះគាត់<br>• មើលថៃគ្រួសារ<br>• រក្សាកិត្តិយសគ្រួសារ...។<br>–កត្តាទាំងអស់នេះគឺជាតួនាទីរបស់ភរិយាចំពោះប្តី។ | • មើលថែរក្សាគ្រួសារ<br>• រក្សាកិត្តិយស...។<br>–កត្តាទាំងអស់នេះគឺជាតួនាទីរបស់ភរិយាចំពោះប្តី។ |
| <br><br>–ឲ្យសិស្សបើកសៀវភៅនៅទំព័រ១៩៨អានចំណងជើងរួចគ្រូសរសេរចំណងជើងដាក់លើក្ដារខៀន<br><br>–ឲ្យសិស្សអានខ្លឹមសារមេរៀនទំព័រ ១៩៨<br><br><br><br>–គ្រូសរសេរពាក្យពិបាកដាក់លើក្ដារខៀន<br><br><br><br><br><br><br>–គ្រូសម្រួលឱ្យសិស្សកត់<br><br>គ្រូបែងចែកក្រុមធ្វើការពិភាក្សាក្រុម៖<br><br>**–ក្រុមទី១**:ចូរនិយាយពីតួនាទីរបស់ភរិយាចំពោះស្វាមី។ | **ជំហានទី៣**<br>(មេរៀនប្រចាំថ្ងៃ)<br>**មេរៀនទី៣**:<br>**ទំនាក់ទំនងសុភមង្គលគ្រួសារ**<br><br><br>3. តួនាទីរបស់ភរិយាចំពោះ ស្វាមី<br>4. តួនាទីរបស់កូនចំពោះម្ដាយឪពុក<br>–ភរិយាជាមេផ្ទះ..................<br>ឪពុកចែកឋានទៅ។<br>**ពន្យល់ពាក្យ**<br><br>-សុវត្ថិភាព (ន): ភាពគ្មានគ្រោះថ្នាក់។<br>-កិត្តិយស (ន): កេរ្តិ៍ឈ្មោះដ៏រុងរឿង។<br>-លទ្ធភាព (ន) :ភាពអាចធ្វើទៅបាន។<br><br><br>**សកម្មភាពក្រុម**<br><br><br>–តួនាទីរបស់ភរិយាចំពោះស្វាមី<br>• ចាត់ចែងការងារក្នុងផ្ទះ | <br><br>–អានចំណងជើង និង សរសេរចំណងជើងដាក់សៀវភៅ<br><br><br>–សិស្សអានខ្លឹមសារមេរៀន<br><br><br>–សិស្សឡើងពន្យល់ពាក្យពិបាក<br><br><br><br><br><br><br><br><br>–សិស្សកត់ចូលសៀវភៅ<br><br>–សិស្សចូលតាមក្រុមពិភាក្សា<br><br><br>–តួនាទីរបស់ភរិយាចំពោះស្វាមី<br>• ចាត់ចែងការងារក្នុងផ្ទះ |

| | | |
|---|---|---|
| | • ថែរក្សាទ្រព្យសម្បត្តិឲ្យបាន<br>គង់វង្ស<br>• សង្គ្រោះញាតិខាងស្វាមី<br>ឲ្យបានសមរម្យល្អ<br>• រក្សាខ្លួនតាមច្បាប់សាសនា<br>• គោរពស្រឡាញ់មានភក្តី<br>ភាពចំពោះស្វាមី<br>• មើលថែរក្សាគ្រួសារ<br>• ថែរក្សាកិត្តិយសគ្រួសារ។ | • ថែរក្សាទ្រព្យសម្បត្តិឲ្យបាន<br>គង់វង្ស<br>• សង្គ្រោះញាតិខាងស្វាមី<br>ឲ្យបានសមរម្យល្អ<br>• រក្សាខ្លួនតាមច្បាប់សាសនា<br>• គោរពស្រឡាញ់មានភក្តី<br>ភាពចំពោះស្វាមី<br>• មើលថែរក្សាគ្រួសារ<br>• ថែរក្សាកិត្តិយសគ្រួសារ។ |
| –**ក្រុមទី២**:តើតួនាទីរបស់កូនចំ-<br>ពោះម្តាយឪពុកមានអ្វីខ្លះ? | –តួនាទីរបស់កូនចំពោះឪពុក<br>ម្តាយមាន៖<br>• ស្តាប់ដំបូន្មានរបស់ម្តាយ<br>ឪពុកខិតខំរៀនសូត្រ<br>• ជួយធ្វើកិច្ចការជំនួសម្តាយ<br>ឪពុកនិងចិញ្ចឹមលោកវិញធ្វើជាកូនកត<br>ញ្ញូ<br>• ចេះស្រឡាញ់បងប្អូន<br>• រក្សាវង្សត្រកូលនិង<br>កិត្តិយសកេរ្តិ៍ឈ្មោះឲ្យល្អ<br>• រក្សាទ្រព្យសម្បត្តិម្តាយ<br>ឪពុក<br>• ធ្វើបុណ្យឲ្យគាត់ពេលចែក<br>ឋានទៅ។ | –តួនាទីរបស់កូនចំពោះឪពុក<br>ម្តាយមាន៖<br>• ស្តាប់ដំបូន្មានរបស់ម្តាយ<br>ឪពុកខិតខំរៀនសូត្រ<br>• ជួយធ្វើកិច្ចការជំនួសម្តាយ<br>ឪពុកនិងចិញ្ចឹមលោកវិញធ្វើជាកូន<br>កតញ្ញូ<br>• ចេះស្រឡាញ់បងប្អូន<br>• រក្សាវង្សត្រកូលនិងកិត្តិយស<br>កេរ្តិ៍ឈ្មោះឲ្យល្អ<br>• រក្សាទ្រព្យសម្បត្តិម្តាយ<br>ឪពុក<br>• ធ្វើបុណ្យឲ្យគាត់ពេលចែក<br>ឋានទៅ។ |
| –**ក្រុមទី៣**:តើគ្រួសារមានសារៈ<br>សំខាន់ដូចម្តេចខ្លះចំពោះកូននិ-<br>ងសង្គមជាតិ? | –គ្រួសារមានសារ សំខាន់ណា-<br>ស់ចំពោះកូនៗនិងសង្គមជាតិ<br>ដូចជា៖<br>–ចំពោះកូន<br>• ជាអ្នកចិញ្ចឹមបីបាច់ថែរក្សា<br>កូនជាអ្នកផ្តល់ដំបូន្មាន<br>• ជាអ្នកដឹកនាំ,អ្នកលើកទឹក<br>ចិត្ត ជាអ្នកផ្តល់,អ្នកជួយ<br>–ចំពោះសង្គម<br>• មានធនធានមនុស្សគ្រប់ | –មានសារៈសំខាន់ណាស់ចំ-<br>ពោះកូនៗនិងសង្គមជាតិដូច<br>ជា៖<br>–ចំពោះកូន<br>• ជាអ្នកចិញ្ចឹមបីបាច់ថែរក្សា<br>កូនជាអ្នកផ្តល់ដំបូន្មាន<br>• ជាអ្នកដឹកនាំ,អ្នកលើកទឹក<br>ចិត្ត ជាអ្នកផ្តល់,អ្នកជួយ<br>–ចំពោះសង្គម<br>• មានធនធានមនុស្សគ្រប់ |

| | | |
|---|---|---|
| | គ្រាន់<br>• មានសណ្តាប់ធ្នាប់ល្អមានស្តេភាព,គ្មានអំពើហិង្សា<br>• មានការអភិវឌ្ឍ...។ | គ្រាន់<br>• មានសណ្តាប់ធ្នាប់ល្អមានស្តេភាព,គ្មានអំពើហិង្សា<br>• មានការអភិវឌ្ឍ...។ |
| –**ក្រុមទី៤**:តើនៅក្នុងគ្រួសាររបស់អ្នកតើអ្នកណាទទួលបន្ទុ-កធ្ងនើជាងគេ?ព្រោះអ្វី ?<br><br>–គ្រូសំយោគចម្លើយរបស់សិស្សឱ្យសិស្សកត់ចូលសៀវភៅរៀងៗខ្លួន<br><br>– សិស្សសាកល្បងទាញមេរៀនសង្ខេប<br><br>–គ្រូសំយោគហើយបិទមេរៀនសង្ខេបឱ្យសិស្ស | –នៅក្នុងគ្រួសារអ្នកដែលទទួលបន្ទុកធ្ងន់ជាងគេគឺៈម្តាយឪពុករបស់ខ្ញុំព្រោះគាត់ជាអ្នកទទួលបន្ទុកមើលថែរក្សានិងអប់រំកូនទាំងអស់គ្នា។<br><br>**មេរៀនសង្ខេប**<br>សុភមង្គលនៅក្នុងគ្រួសារអាចកើតមានឡើងអាស្រ័យទៅលើបុគ្គលម្នាក់ៗចេះគោរពស្រឡាញ់និងស្គាល់ពីតួនាទីរបស់ខ្លួនក្នុងគ្រួសារ។ដូចនេះភរិយាត្រូវស្គាល់តួនាទីរបស់ខ្លួនចំពោះស្វាមីឯស្វាមីក៏ដូចគ្នាដែរចំនែកឯកូនវិញត្រូវស្គាល់ពីតួនាទីរបស់ខ្លួនចំពោះឪពុកម្តាយផងដែរនៅក្នុងគ្រួសារដើម្បីគ្រួសារនិងសង្គមមានការអភិវឌ្ឍ។ | –នៅក្នុងគ្រួសារអ្នកដែលទទួ-លបន្ទុកធ្ងន់ជាងគេគឺម្តាយនិងឪពុករបស់ខ្ញុំព្រោះគាត់ជាអ្នក<br><br>-តក់ត្រា<br><br>-កត់ត្រា |
| -តើគ្រួសារមានសារៈសំខាន់ដូចម្តេចខ្លះចំពោះសង្គម? | **ជំហានទី៤**<br>(ពង្រឹងពុទ្ធិ)<br>–គ្រួសារមានសារៈសំខាន់ណាស់ចំពោះសង្គមគឺ មានធនធានមនុស្សគ្រប់គ្រាន់មានសណ្តាប់ធ្នាប់ល្អមានស្ថេរភាពគ្មានអំពើហិង្សាមានការអភិវឌ្ឍ។<br>–អ្នកដែលទទួលបន្ទុកធ្ងន់ជាង | –មានធនធានមនុស្សគ្រប់គ្រាន់មានសណ្តាប់ធ្នាបល្អមានស្ថេរ<br>–អ្នកដែលទទួលបន្ទុកធ្ងន់ជាង<br><br>ភាព,គ្មានអំពើហិង្សាមានការអភិវឌ្ឍ...។ |

| | | |
|---|---|---|
| –នៅក្នុងគ្រួសាររបស់អ្នក តើអ្នកណាទទួលបន្ទុកធ្ងន់ជាងគេ ព្រោះអ្វី ? | គេនៅក្នុងគ្រួសារគឺម្តាយឪពុករបស់ខ្ញុំព្រោះគាត់ជាអ្នកទទួលបន្ទុករកស៊ីនិងមើលថែរក្សាអប់រំកូនៗទាំងអស់គ្នា។ | គេនៅក្នុងគ្រួសារគឺម្តាយឪពុករបស់ខ្ញុំព្រោះគាត់ជាអ្នកទទួលបន្ទុករកស៊ីនិងមើលថែរក្សាអប់រំកូនៗទាំងអស់គ្នា។ |
| -នៅក្នុងគ្រួសាររបស់ប្អូនមានតែឪពុកម្តាយរបស់ប្អូនដែលជាអ្នកកសាងសុភមង្គល?ព្រោះអ្វី? | **ជំហានទី៥**<br>កិច្ចការផ្ទះ | -សិស្សកត់កិច្ចការដាក់ចូលសៀវភៅ |

# **កិច្ចតែងការបង្រៀន**

- កាលបរិច្ឆេទ : ថ្ងៃ ទី ខែ ឆ្នាំ
- មុខវិជ្ជា : សីលធម៌-ពលរដ្ឋវិជ្ជា
- ថ្នាក់ទី : ៧
- **ជំពូកទី៣** : **គ្រួសារ**
- **មេរៀនទី៣** : **ទង្វើកសាងសុភមង្គលគ្រួសារ (តចប់)**
- វិធីសាស្ត្របង្រៀន : គោលវិធីសិស្សមជ្ឈមណ្ឌល (ពិភាក្សាក្រុម)
- រយៈពេល : ៣ ម៉ោងសិក្សា (សម្រាប់ម៉ោងទី៣)

I. **វត្ថុបំណង**

- ចំណេះដឹង : ប្រាប់ពីតួនាទីរបស់កូនចំពោះឪពុកម្ដាយ និង ចំពោះបងប្អូនបានយ៉ាងត្រឹមត្រូវតាមរយៈការអានខ្លឹមសារមេរៀន និង សំណួរបំផុសរបស់គ្រូ។
- បំណិន : កំណត់ពីតួនាទីបងចំពោះប្អូន និង ប្អូនចំពោះបង និង ការបំពេញតួនាទីដែលជាតម្លៃគុណធម៌ បានយ៉ាងត្រឹមត្រូវតាមរយៈការពិភាក្សាក្រុម។
- ឥរិយាបថ : ស្រឡាញ់ គោរពគ្រួសារ ឪពុកម្ដាយ បងប្អូនដើម្បីឱ្យគ្រួសារមានសុភមង្គល

II. **សម្ភារឧបទេស**

- សៀវភៅសិស្សទំព័រ ១៩៥-១៩៦ បោះពុម្ពឆ្នាំ ២០១១
- ប័ណ្ណសំណួរ
- ផ្ទាំងរូបភាព
- ផ្ទាំងមេរៀនសង្ខេប

III. **ខ្លឹមសារមេរៀន**

5. **តួនាទីរបស់បងចំពោះប្អូន**
6. **តួនាទីរបស់ប្អូនចំពោះបង**
7. **ការបំពេញតួនាទីជាតម្លៃគុណធម៌**

IV. **ដំណើរការបង្រៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូតពិនិត្យលើ: សណ្តាប់ធ្នាប់ អនាម័យ អវត្តមាន។ | **ជំហានទី១**<br>(រដ្ឋបាលថ្នាក់)<br>• សណ្តាប់ធ្នាប់<br>• អនាម័យ<br>• អវត្តមាន<br>• ពង្រឹងវិន័យ។ | -ប្រធាន ឬ អនុប្រធានឡើងរាយការណ៍។ |
| -តើភរិយាមានតួនាទីអ្វីខ្លះចំពោះស្វាមី?<br><br><br><br><br><br><br><br>-តើយើងជាកូនៗមានតួនាទីអ្វីខ្លះចំពោះឪពុកម្តាយ?<br><br><br><br><br><br><br><br><br>-ក្រៅពីមានតួនាទីចំពោះម្តាយឪពុក តើកូនមានតួនាទីចំពោះអ្នកណាទៀត? | **ជំហានទី២**<br>(រំលឹកមេរៀនចាស់)<br>-ភរិយាមានតួនាទីចំពោះស្វាមី៖<br>• ចាត់ចែងការងារផ្ទះ<br>• ថែរក្សាទ្រព្យសម្បត្តិ<br>• ស្រឡាញ់គ្រួសារ ស្វាមី និង សាច់ញាតិ<br>• រក្សាខ្លួន និង កិត្តិយស។<br><br>-កូនមានតួនាទីចំពោះឪពុកម្តាយដូចជា៖<br>• ខិតខំរៀនសូត្រ<br>• ស្រឡាញ់ម្តាយឪពុក និង បងប្អូន<br>• ថែរក្សាទ្រព្យសម្បត្តិ និង វង្សត្រកូល<br>• រកប្រាក់ផ្គត់ផ្គង់គ្រួសារ។<br><br>**<u>ទំនាក់ទំនងមេរៀនថ្មី</u>**<br>-មានតួនាទិចំពោះបងប្អូន។ | -ភរិយាមានតួនាទីចំពោះស្វាមី៖<br>• ចាត់ចែងការងារផ្ទះ និង ថែរក្សារទ្រព្យសម្បត្តិ<br>• គោរពស្រឡាញ់ស្វាមី និង សាច់ញាតិ<br>• រក្សាខ្លួនតាមច្បាប់ទម្លាប់ សាសនា ប្រពៃណី<br>• ថែរក្សាគ្រួសារ និង កិត្តិយសស្វាមី។<br>-កូនមានតួនាទីចំពោះឪពុកម្តាយដូចជា៖<br>• ស្តាប់ដំបូន្មាន ជួយធ្វើការងារផ្ទះជំនួសម្តាយឪពុក<br>• ចេះស្រឡាញ់បងប្អូន និង ថែរក្សាម្តាយឪពុក<br>• ថែរក្សាវង្សត្រកូល និង កេរ្តិ៍ឈ្មោះឱ្យបានល្អ។<br>• ធ្វើបុណ្យជូនម្តាយឪពុកនៅពេលគាត់ចែកឋានទៅ។<br><br>-មានតួនាទិចំពោះបងប្អូន។ |
| | **ជំហានទី៣** | |

| | | |
|---|---|---|
| –សរសេរចំណងជើងមេរៀនដាក់លើក្តារខៀន<br><br>–ឱ្យសិស្សបើកសៀវភៅទំព័រ ១៩៤-១៩៦រួចអានខ្លឹមសារមេរៀន<br><br>–សរសេរពាក្យពិបាកលើក្តារខៀន រួចឱ្យសិស្សឡើងពន្យល់<br><br>–កែសម្រួលឱ្យសិស្សកត់<br>–ក្នុងនាមជាបងប្អូន តើយើងត្រូវមានតួនាទីអ្វីខ្លះចំពោះគ្នា?<br><br>–តើបងមានតួនាទីអ្វីខ្លះចំពោះប្អូន? | (មេរៀនប្រចាំថ្ងៃ)<br>**មេរៀនទី៣**:<br>**វិធីកសាងសុភមង្គលគ្រួសារ**<br>5. តួនាទីរបស់បងចំពោះប្អូន<br>6. តួនាទីរបស់ប្អូនចំពោះបង<br>7. ការបំពេញតួនាទីជាតម្លៃគុណធម៌<br><br>**ពន្យល់ពាក្យ**<br><br>–ប្រយោជន៍(ន): ផលដែលបានសម្រេចពីការប្រកបការងារ។<br>–ប្តេជ្ញា(ន): ការតាំងចិត្ត ការសន្យា។<br>សំណួរផ្តើម<br>–ស្រឡាញ់គ្នា មើលថែគ្នា ចេះជួយគ្នា...។<br><br>**សំណួរបញ្ជាក់លើអត្ថបទ**<br>–បងមានតួនាទីចំពោះប្អូនគឺះ<br>• ស្រឡាញ់មើលថែប្អូន<br>• ជួយផ្គត់ផ្គង់ប្អូន<br>• ប្រើសម្តីទន់ភ្លន់ដាក់ប្អូន។ | មេរៀនទី៣:<br>វិធីកសាងសុភមង្គលគ្រួសារ<br>5. តួនាទីរបស់បងចំពោះប្អូន<br>6. តួនាទីរបស់ប្អូនចំពោះបង<br>7. ការបំពេញតួនាទីជាតម្លៃគុណធម៌<br>–អានខ្លឹមសារមេរៀនបណ្តាក់គ្នា<br><br>–ឡើងពន្យល់ន័យរបស់ពាក្យ<br><br>–ប្រយោជន៍(ន): ផលដែលបានសម្រេចពីការប្រកបការងារ។<br>–ប្តេជ្ញា(ន): ការតាំងចិត្ត ការសន្យា។<br><br>–កត់ត្រាចូលសៀវភៅ<br>–ស្រឡាញ់គ្នា មើលថែគ្នា ចេះជួយគ្នា មិនត្រូវប្រកាន់ទោសពៃរ៍។<br><br>–បងមានតួនាទីចំពោះប្អូនគឺះ<br>• ស្រឡាញ់ប្អូន និង ចែករំលែកនូវអ្វីដែលខ្លួនមានឱ្យប្អូន<br>• មើលថែប្អូន ជួយយកអាសាផ្តល់ប្រយោជន៍ឱ្យប្អូន<br>• ប្រើសម្តីទន់ភ្លន់ មិនប្រកាន់ទោសពៃរ៍។ |
| –តើប្អូនត្រូវមានតួនាទីអ្វីខ្លះចំពោះបង? | –ប្អូនមានតួនាទីចំពោះបងគឺះ<br>• ស្រឡាញ់បងស្មោះ<br>• ប្រើសម្តីទន់ភ្លន់<br>• គោរពរាប់អានបង | –ប្អូនមានតួនាទីចំពោះបងគឺះ<br>• ស្រឡាញ់បងស្មោះ មិនច្រណែនបង<br>• ប្រើសម្តីទន់ភ្លន់ សុភាព |

| | | |
|---|---|---|
| | ដោយស្មោះ...។ | ដាក់បង<br>• គោរពរាប់អានបង ដោយស្មោះ<br>• ជួយទុក្ខធុរៈបង។ |
| | **ពិភាក្សាក្រុម** | |
| -បែងចែកសិស្សជាបួនក្រុម៖<br>**-ក្រុមទី១**:<br>តើបងមានតួនាទីអ្វីខ្លះចំពោះប្អូន? | -តួនាទីបងចំពោះប្អូន៖<br>• មើលថែរក្សាប្អូន<br>• កុំប្រើអំណាចសម្លុតប្អូន<br>• ចេះចែករំលែកអ្វីដែលខ្លួនមានឱ្យប្អូន។ | -ចូលតាមក្រុមពិភាក្សា<br>-តួនាទីបងចំពោះប្អូន៖<br>• ស្រឡាញ់ ជួយយកអាសាប្អូន<br>• ថែទាំ និង ផ្គត់ផ្គង់ប្អូន<br>• ផ្តល់ការណែនាំដល់ប្អូន<br>• ធ្វើជាគំរូល្អដល់ប្អូន<br>• ប្រើសម្តីទន់ភ្លន់ មិនយកទោសពៃរ៍។ |
| **-ក្រុមទី២**: តើប្អូនមានតួនាទីអ្វីខ្លះចំពោះបង? | -តួនាទីប្អូនចំពោះបង៖<br>• ពោលពាក្យសម្តីដោយក្តីគោរព និង ជួយបងពេលមានធុរៈ<br>• រាប់អាន និង ជួយទំនុកបម្រុងបងពេលខ្វះខាត<br>• ស្តាប់តាមការណែនាំរបស់បង។ | -តួនាទីប្អូនចំពោះបង៖<br>• ស្រឡាញ់បង មិនច្រណែន<br>• ប្រើសម្តីទន់ភ្លន់ កាយវិការសុភាព<br>• គោរព រាប់អាន និង ចេះជួយធុរៈបង<br>• រាប់អានបងដោយស្មោះស្មើ និង មិនប្រកាន់ខឹង។ |
| **-ក្រុមទី៣**: តើការបំពេញតួនាទីជាតម្លៃគុណធមមានន័យដូចម្តេច ? | -<br>គឺជាការយកចិត្តទុកដាក់ធ្វើយ៉ាងណាឱ្យគ្រួសារមានការជឿទុកចិត្តគ្នា ទើបធ្វើឱ្យគ្រួសារមានសុភមង្គល។ | -គឺជាការទទួលខុសត្រូវលើក្រុមគ្រួសារ ការធ្វើឱ្យគ្រួសារមានសុភមង្គល ផ្តល់ការជឿទុកចិត្ត ការយោគយល់ និង ការបំពេញភារកិច្ចបានល្អរៀងៗខ្លួន។ |
| **-ក្រុមទី៤**: ហេតុអ្វីបានជាយើងចាំបាច់បំពេញតួនាទីចំពោះបងប្អូន? | -ព្រោះមានទំនាក់ទំនងល្អ ចេះសាមគ្គីគ្នា មានភាពរីករាយ ធ្វើឱ្យមានសុភមង្គលនៅក្នុងគ្រួសារ។ | -ពីព្រោះដើម្បីធ្វើឱ្យមានទំនាក់ទំនងល្អ មានភាពជិតស្និទ្ធ មានការសាមគ្គី ជួយធ្វើការងារឪពុកម្តាយដែលជាកត្តាធ្វើឱ្យគ្រួសារមានសុភមង្គល។ |
| -សំយោគចម្លើយឱ្យសិស្សកត់ | | -កត់ត្រាចូលសៀវភៅ |

| | | |
|---|---|---|
| -ឱ្យសិស្សសាកល្បងទាញមេរៀនសង្ខេប<br><br><br><br><br><br><br><br>-ឱ្យសិស្សកត់ត្រាចូលសៀវភៅ | **មេរៀនសង្ខេប**<br><br>នៅក្នុងគ្រួសារនីមួយៗសមាជិកនៅក្នុងគ្រួសារត្រូវមានតួនាទីចំពោះគ្នាទៅវិញទៅមក។ក្នុងនោះផងដែរបងត្រូវមានតួនាទីមើលថែទាំប្អូន ឯប្អូនវិញក៏ត្រូវគោរពស្រឡាញ់បងទើបធ្វើឱ្យគ្រួសារមានតម្លៃគុណធម៌ និងមានសុភមង្គល។ | <br><br><br><br><br><br><br><br><br><br>-កត់ត្រាចូលសៀវភៅ |
| <br><br>-ឱ្យសិស្សបិទសៀវភៅ<br>-ហេតុអ្វីបានជាបងប្អូនចាំបាច់បំពេញតួនាទីចំពោះគ្នា?<br><br><br>-ហេតុអ្វីចាំបាច់បំពេញតួនាទីជាតម្លៃគុណធម៌? | **ជំហានទី៤**<br>(ពង្រឹងពុទ្ធិ)<br><br>-ដើម្បីឱ្យមានទំនាក់ទំនងល្អ បង្កើតភាពស្និទ្ធស្នាល ដើម្បីឱ្យគ្រួសារមានសុភមង្គល។<br><br>-ពីព្រោះដើម្បីឱ្យគ្រួសារមានសុភមង្គល។ | <br><br>-បិទសៀវភៅទាំងអស់គ្នា<br>-ពីព្រោះដើម្បីធ្វើឱ្យមានទំនាក់ទំនងល្អ មានភាពជិតស្និទ្ធ មានការសាមគ្គីគ្នា<br>ដែលជាកត្តាធ្វើឱ្យគ្រួសារមានសុភមង្គល។<br>-ពីព្រោះដើម្បីឱ្យមានការយោគយល់<br>មានទំនាក់ទំនងល្អទើបធ្វើឱ្យគ្រួសារមានសុភមង្គល។ |
| <br><br>-ចូរប្អូនធ្វើសំណួរជំពូកទី៣ នៅទំព័រទី ១៩៧ | **ជំហានទី៥**<br>(កិច្ចការផ្ទះ) | <br><br>-ស្តាប់គ្រូដោយយកចិត្តទុកដាក់ និង ត្រៀមអនុវត្តតាម |

# កិច្ចតែងការបង្រៀន

- ❖ កាលបរិច្ឆេទ : ថ្ងៃ ទី ខែ ឆ្នាំ
- ❖ មុខវិជ្ជា : សីលធម៌ ពលរដ្ឋវិជ្ជា
- ❖ ថ្នាក់ទី : ៧
- ❖ **ជំពូកទី៤** : **ការរស់នៅក្នុងសហគមន៍**
- ❖ **មេរៀនទី១** : **ការបោះឆ្នោត**
- ❖ វិធីសាស្ត្រ : គោលវិធីសិស្សមជ្ឈមណ្ឌល
- ❖ រយៈពេល : ២ ម៉ោងសិក្សា (សម្រាប់ម៉ោងទី១)

## I. វត្ថុបំណង

- ➢ ចំណេះដឹង : ប្រាប់ពីនិយមន័យនៃការបោះឆ្នោត បានយ៉ាងត្រឹមត្រូវតាមរយៈការសិក្សាអត្ថបទ។
- ➢ បំណិន : វែកញែកសារៈសំខាន់នៃការបោះឆ្នោតបានយ៉ាងត្រឹមត្រូវតាមរយៈការពិភាក្សាក្រុម។
- ➢ ឥរិយាបថ : បណ្តុះស្មារតីសិស្សឱ្យយល់ដឹងពីសារៈសំខាន់នៃការចូលរួមបោះឆ្នោតដើម្បីឱ្យប្រទេសជាតិមានការរីកចម្រើន។

## II. ខ្លឹមសារមេរៀន

1. **ការបោះឆ្នោត**

## III. សម្ភារឧបទេស

- សៀវភៅសិស្ស, ប័ណ្ណសំណួរ,ផ្ទាំងរូបភាព, ផ្ទាំងបញ្ញត្តិតម្លៃ

## IV. ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ឱ្យសិស្សក្រោកឈរពង្រឹង វិន័យ អវត្តមាន អនាម័យ សណ្ដាប់ធ្នាប់។ | **ជំហានទី១**<br>(រដ្ឋបាលថ្នាក់)<br>-វិន័យ អនាម័យ អវត្តមាន | -ប្រធានថ្នាក់ឡើងរាយការណ៍ |
| -តើកាលពីថ្ងៃមុនយើងសិក្សាដល់មេរៀនអ្វី?<br><br>-តើកូនមានតួរអ្វីខ្លះចំពោះឪពុកម្ដាយ?<br><br>-នៅពេលដែលភូមិ ឃុំរបស់ប្អូនត្រូវការផ្លាស់ប្ដូរមេភូមិឬ មេឃុំ តើគេជ្រើសរើសដោយវិធីណា? | **ជំហានទី២**<br>(រំលឹកមេរៀនចាស់)<br>**មេរៀនទី៣**:<br>**ខធិកសាខសុភមង្គលគ្រួសារ**<br><br>-កូនមានតួរនាទីចំពោះឪពុកម្ដាយដូចជា៖<br>• ស្ដាប់ដំបូន្មាន ខិតខំរៀន ជួយធ្វើការងារផ្ទះ<br>• ចេះស្រឡាញ់បងប្អូន<br>• រក្សាវង្សត្រកូលឱ្យបានល្អ<br>• រក្សាទ្រព្យសម្បត្តិ និងខិតខំរកប្រាក់ បើខ្លួនមានលទ្ធភាព<br>• គម្បីធ្វើបុណ្យតាមប្រពៃណីពេលម្ដាយឪពុកចែកឋានទៅ។<br><u>ទំនាក់ទំនងមេរៀនថ្មី</u><br>-ដោយការបោះឆ្នោត | -កូនមានតួរនាទីចំពោះឪពុកម្ដាយដូចជា៖<br>• ស្ដាប់ដំបូន្មាន ខិតខំរៀន ជួយធ្វើការងារផ្ទះ<br>• ចេះស្រឡាញ់បងប្អូន<br>• រក្សាវង្សត្រកូលឱ្យបានល្អ<br>• រក្សាទ្រព្យសម្បត្តិ និងខិតខំរកប្រាក់ បើខ្លួនមានលទ្ធភាព<br>• គម្បីធ្វើបុណ្យតាមប្រពៃណីពេលម្ដាយឪពុកចែកឋានទៅ។<br>-ដោយការបោះឆ្នោត |
| -ឱ្យសិស្សបើកសៀវភៅទំព័រ ១៩៩ អានចំណងជើងមេរៀន<br><br>-តើចំណងជើងមានន័យដូចម្ដេច? | **ជំហានទី៣**<br>(មេរៀនប្រចាំថ្ងៃ)<br>**ជំពូកទី៤**:<br>**ការរស់នៅជាមួយសហគមន៍**<br>▪ សិក្សាចំណងជើង<br>-មានន័យថា ការរស់នៅប្រមូលផ្ដុំគ្នាជាពួកឬ ជាក្រុម។<br>▪ សិក្សារូបភាព | -មានន័យថា ការរស់នៅប្រមូលផ្ដុំគ្នាជាពួកឬ ជាក្រុម។ |

| | | |
|---|---|---|
| -តើប្អូនឃើញអ្វីខ្លះ នៅក្នុងរូបភាព?<br><br>-ឱ្យសិស្សអានខ្លឹមសារមេរៀន<br>-ឱ្យសិស្សបើកសៀវភៅទំព័រ ២០០ រួចអានខ្លឹមសារមេរៀន<br>- សសរសេរចំណងជើងដាក់លើក្តាខៀន<br>-តើការបោះឆ្នោតមានន័យដូចម្តេច?<br><br><br><br><br>-ឱ្យសិស្សអានខ្លឹមសារមេរៀន<br><br><br><br><br><br><br><br><br><br>-បែងចែកសិស្សជាបួនក្រុមះ<br>**-ក្រុមទី១:** តើការបោះឆ្នោតជាអ្វី?<br><br><br><br>**-ក្រុមទី២:** តើការបោះឆ្នោតប្រព្រឹត្តទៅដូចម្តេច?<br><br><br><br>**-ក្រុមទី៣:** តើនៅក្នុងសង្គម | -ឃើញមនុស្សកំពុងបោះឆ្នោតដោយមានលក្ខណៈសេរី និងយុត្តិធម៌ មានដើមឈើ...។<br>-ខ្លឹមសារមេរៀនទំព័រ ១៩៩<br><br><br>**មេរៀនទី១: ការបោះឆ្នោត**<br><br>-មានន័យថា ជាពេលវេលា ឬជាឱកាសដែលពលរដ្ឋ ម្នាក់ៗ បានសម្តែងនូវឆន្ទៈរបស់ខ្លួនក្នុងការជ្រើសរើសតំណាងរាស្ត្រ។<br><br><br>**១. ការបោះឆ្នោត**<br><br>ពន្យល់ពាក្យ<br>-ប្រជាធិបតេយ្យ (ន): ការយកមតិប្រជាជនជាធំ ឬ ការយកសម្លេងភាគច្រើនជាធំ។<br>-អចិន្ត្រៃយ៍ (គុ): ដែលរកទីបញ្ចប់គ្មាន។<br>-ឆន្ទៈ(ន): បំណងប្រាថ្នា,ការតាំងចិត្ត សេចក្តីប្រាថ្នា។<br>▪ ការពិភាក្សាក្រុម<br>-ការបោះឆ្នោតគឺជាពេលដែលអ្នកបោះឆ្នោត ចេញទៅបោះឆ្នោតជ្រើសរើស បេក្ខជនឱ្យធ្វើតំណាង ឬជាអ្នកដឹកនាំរបស់ខ្លួន។<br>-ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរីជាសម្ងាត់ ត្រឹមត្រូវយុត្តិធម៌ស្របច្បាប់ និងធ្វើឡើងក្នុងចន្លោះពេលមួយយ៉ាងទៀងទាត់។ | <br>-ឃើញមនុស្សកំពុងបោះឆ្នោតដោយមានលក្ខណៈសេរី និងយុត្តិធម៌ មានដើមឈើ...។<br>-សិស្សអានខ្លឹមសារមេរៀន<br><br><br><br>-មានន័យថា ជាពេលវេលា ឬជាឱកាសដែលពលរដ្ឋ ម្នាក់ៗបានសម្តែងនូវឆន្ទៈរបស់ខ្លួនក្នុងការជ្រើសរើសតំណាងរាស្ត្រ។<br>-សិស្សអានតាមការណែនាំ<br><br><br><br><br><br><br><br><br><br><br><br>-ការបោះឆ្នោតគឺជាពេលដែលអ្នកបោះឆ្នោត ចេញទៅបោះឆ្នោតជ្រើសរើស បេក្ខជនឱ្យធ្វើតំណាង ឬជាអ្នកដឹកនាំរបស់ខ្លួន។<br>-ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរីជាសម្ងាត់ ត្រឹមត្រូវយុត្តិធម៌ស្របច្បាប់ និងធ្វើឡើងក្នុងចន្លោះពេលមួយយ៉ាងទៀងទាត់។ |

| | | |
|---|---|---|
| ប្រជាធិបតេយ្យអំណាចគ្រប់គ្រងស្ថិតស្ថេរ ឬទេ? | -នៅក្នុងសង្គមប្រជាធិបតេយ្យ អំណាចគ្រប់គ្រង ពុំអាចស្ថិតស្ថេរឡើយ ព្រោះអំណាចនេះស្ថិតនៅលើប្រជាពលរដ្ឋ ឬអ្នកបោះឆ្នោតអាចដកសេចក្តីទុកចិត្ត ពីនរណាម្នាក់ ហើយប្រគល់អំណាចឱ្យអ្នកផ្សេងតាមការបោះឆ្នោត។ | -នៅក្នុងសង្គមប្រជាធិបតេយ្យ អំណាចគ្រប់គ្រងពុំអាចស្ថិតស្ថេរឡើយ ព្រោះអំណាចនេះស្ថិតនៅលើប្រជាពលរដ្ឋ ឬអ្នកបោះឆ្នោតឮអាចដកសេចក្តីទុកចិត្ត ពីនរណាម្នាក់ ហើយប្រគល់អំណាចឱ្យអ្នកផ្សេងតាមការបោះឆ្នោត។ |
| -**ក្រុមទី៤:** តើការបោះឆ្នោតមានសារៈសំខាន់ឬទេ? ព្រោះអ្វី? | -ការបោះឆ្នោតមានសារៈសំខាន់ណាស់ព្រោះ៖<br>• ដើម្បីផ្លាស់ប្តូរអ្នកដឹកនាំដែលគ្មានសមត្ថភាពដោយសន្តិវិធី<br>• ដើម្បីជ្រើសរើសអ្នកដែលមានសមត្ថភាព និងមានការគោរព<br>• ផ្តល់សិទ្ធិដល់ប្រជាពលរដ្ឋ<br>• ដើម្បីបង្ហាញឆន្ទៈផ្នែកនយោបាយ<br>• បង្កើនការទទួលខុសត្រូវដល់បេក្ខជនជាប់ឆ្នោត<br>• ចូលរួមក្នុងការអភិវឌ្ឍប្រទេស<br>• មានសិទ្ធិក្នុងការជ្រើសរើសអ្នកតំណាងដើម្បីអនុវត្តតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ។ | -ការបោះឆ្នោតមានសារៈសំខាន់ណាស់ព្រោះ៖<br>• ដើម្បីផ្លាស់ប្តូរអ្នកដឹកនាំដែលគ្មានសមត្ថភាពដោយសន្តិវិធី<br>• ដើម្បីជ្រើសរើសអ្នកដែលមានសមត្ថភាព និងមានការគោរព<br>• ផ្តល់សិទ្ធិដល់ប្រជាពលរដ្ឋ<br>• ដើម្បីបង្ហាញឆន្ទៈផ្នែកនយោបាយ<br>• បង្កើនការទទួលខុសត្រូវដល់បេក្ខជនជាប់ឆ្នោត<br>• ចូលរួមក្នុងការអភិវឌ្ឍប្រទេស<br>• មានសិទ្ធិក្នុងការជ្រើសរើសអ្នកតំណាងដើម្បីអនុវត្តតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ។ |
| -កែសម្រួលឱ្យសិស្សកត់ | **មេរៀនសង្ខេប**<br>ក្នុងលទ្ធិប្រជាធិបតេយ្យ ប្រជារាស្ត្រគឺជាម្ចាស់ទឹកដី លើជោគវាសនារបស់ប្រទេសជាតិ។ ប្រជារាស្ត្រជាអ្នកទទួលខុសត្រូវលើអនាគត របស់ប្រទេស។ ប៉ុន្តែប្រជារាស្ត្រទាំងអស់មិនអាចចា | -សិស្សកត់ |

| | | |
|---|---|---|
| -ឱ្យសិស្សកត់ចូលសៀវភៅ | ត់ថែងកិច្ចការដោយផ្ទាល់ទេ<br>គឺត្រូវជ្រើសរើសបេក្ខជនដែល<br>ខ្លួនពេញចិត្តជាតំណាងរបស់ខ្លួន<br>ហៅថាតំណាងរាស្ត្រដោយការ<br>ជ្រើសរើសនេះត្រូវឆ្លងកាត់ការបោះ<br>ឆ្នោត។ | -សិស្សកត់ |
| -តើការបោះឆ្នោតជាអ្វី?<br><br><br><br><br>-តើការបោះឆ្នោតមានសារៈ<br>សំខាន់ឬទេ? ព្រោះអ្វី? | **ជំហានទី៤**<br>(ពង្រឹងពុទ្ធិ)<br>-ការបោះឆ្នោតគឺជាពេលដែល<br>អ្នកបោះឆ្នោត ចេញទៅបោះ<br>ឆ្នោតជ្រើសរើស បេក្ខជនឱ្យធ្វើ<br>តំណាង ឬជាអ្នកដឹកនាំរបស់<br>ខ្លួន។<br>-ការបោះឆ្នោតមានសារៈសំខាន់<br>ណាស់ព្រោះ៖<br>• ដើម្បីផ្លាស់ប្តូរអ្នកដឹកនាំដែល<br>គ្មានសមត្ថភាពដោយសន្តិវិធី<br>• ដើម្បីជ្រើសរើសអ្នកដែលមាន<br>សមត្ថភាព និងមានការគោរព<br>• ផ្តល់សិទ្ធិដល់ប្រជាពលរដ្ឋ<br>• ដើម្បីបង្ហាញឆន្ទៈផ្នែកនយោ<br>បាយ<br>• បង្កើនការទទួលខុសត្រូវដល់<br>បេក្ខជនជាប់ឆ្នោត<br>• ចូលរួមក្នុងការអភិវឌ្ឍប្រទេស<br>• មានសិទ្ធិក្នុងការជ្រើសរើសអ្នក<br>តំណាងដើម្បីអនុវត្តតាមគោល<br>ការណ៍លទ្ធិប្រជាធិបតេយ្យ។ | -ការបោះឆ្នោតគឺជាពេលដែល<br>អ្នកបោះឆ្នោត ចេញទៅបោះ<br>ឆ្នោតជ្រើសរើស បេក្ខជនឱ្យធ្វើ<br>តំណាង ឬជាអ្នកដឹកនាំរបស់<br>ខ្លួន។<br>-ការបោះឆ្នោតមានសារៈ<br>សំខាន់ណាស់ព្រោះ៖<br>• ដើម្បីផ្លាស់ប្តូរអ្នកដឹកនាំដែល<br>គ្មានសមត្ថភាពដោយសន្តិវិធី<br>• ដើម្បីជ្រើសរើសអ្នកដែល<br>មានសមត្ថភាព និងមាន<br>ការគោរព<br>• ផ្តល់សិទ្ធិដល់ប្រជាពលរដ្ឋ<br>• ដើម្បីបង្ហាញឆន្ទៈផ្នែកនយោ<br>បាយ<br>• បង្កើនការទទួលខុសត្រូវដល់<br>បេក្ខជនជាប់ឆ្នោត<br>• ចូលរួមក្នុងការអភិវឌ្ឍ<br>ប្រទេស<br>• មានសិទ្ធិក្នុងការជ្រើសរើស<br>អ្នកតំណាងដើម្បីអនុវត្តតាមគោល<br>ការណ៍លទ្ធិប្រជាធិប-<br>តេយ្យ។ |
| | **ជំហានទី៥**<br>(បណ្តាំផ្ញើ) | |

| | | |
|---|---|---|
| -ត្រឡប់ទៅផ្ទះវិញមើលមេរៀន និងជួយធ្វើការងារផ្ទះកុំដើរលេងច្រើនពេក | | -សិស្សស្តាប់ដោយយកចិត្តទុកដាក់ |

# កិច្ចតែងការបង្រៀន

- កាលបរិច្ឆេទ : ថ្ងៃ ទី ខែ ឆ្នាំ
- មុខវិជ្ជា : សីលធម៌ ពលរដ្ឋវិជ្ជា
- **ជំពូកទី៤ : ការរស់ក្នុងសហគមន៍**
- **មេរៀនទី១ : ការបោះឆ្នោត**
- បង្រៀនថ្នាក់ទី : ៧
- រយៈពេល : ២ម៉ោងសិក្សា(សម្រាប់ម៉ោងទី២)
- វិធីសាស្ត្រ : គោរវិធីសិស្សមជ្ឈមណ្ឌល

## I. **វត្ថុបំណង**

- ចំណេះដឹង : រៀបរាប់បានពីគោលបំណង និងលក្ខណៈ ការបោះឆ្នោតដោយសេរីបានយ៉ាងត្រឹមត្រូវតាមរយៈ ខ្លឹមសារមេរៀន។
- បំណិន : បង្ហាញពីសិទ្ធិសេរីភាពនៃការបោះឆ្នោតដោយសេរីបានត្រឹមត្រូវតាមរយៈការពិភាក្សា ក្រុម។
- ឥរិយាបថ : បណ្ដុះស្មារតីឱ្យយល់ និងដឹងពីការបោះឆ្នោតដោយសេរី និងចូលរួមបោះឆ្នោតដើម្បីយកទៅអនុវត្តក្នុងជីវភាពរស់ប្រចាំថ្ងៃ។

## II. **ខ្លឹមសារមេរៀន**

2.**គោលបំណងនៃការបោះឆ្នោត**

3.**លក្ខណៈនៃការបោះឆ្នោតដោយសេរី**

## III. **សម្ភារឧបទេស**

-ផ្ទាំងរូបភាព,ប័ណ្ណសំណួរ,ផ្ទាំងបញ្ញត្តិតម្លៃ

-សៀវភៅសិស្សថ្នាក់ទី៧ថ្មីទំព័រទី២០០-២០១ បោះពុម្ពឆ្នាំ២០០៩

IV. **ដំណើរការបង្រៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -គ្រូតពិនិត្យលើ អវត្តមាន អនាម័យ សណ្តាប់ធ្នាប់ វិន័យ | **ជំហានទី១**<br>(រដ្ឋបាលថ្នាក់)<br>-អវត្តមាន អនាម័យ សណ្តាប់ ធ្នាប់ វិន័យ | -ប្រធានថ្នាក់ឡើងរាយការណ៍ |
| -តើកាលពីថ្ងៃមុនយើងសិក្សាដល់មេរៀនអ្វី?<br>- តើការបោះឆ្នោតគឺជាអ្វី?<br><br>-តើការបោះឆ្នោតប្រព្រឹត្តទៅយ៉ាងដូចម្តេច?<br><br>-យើងនឹងសិក្សាមេរៀនបន្ត | **ជំហានទី២**<br>(រំលឹកមេរៀនចាស់)<br>មេរៀនទី១ ការបោះឆ្នោត<br><br>-ការបោះឆ្នោតគឺជាពេលដែលអ្នកបោះឆ្នោតចេញទៅបោះឆ្នោតជ្រើសរើសតំណាងឬអ្នកដឹកនាំរបស់គេ។<br>-ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ជាសម្ងាត់ ត្រឹមត្រូវ យុត្តិធម៌ ស្របច្បាប់និងធ្វើឡើងក្នុងចន្លោះពេលមួយយ៉ាងទៀងទាត់។<br>ទំនាក់ទំនងមេរៀនថ្មី<br>១.គោលបំណងនៃការបោះឆ្នោត<br>២.លក្ខណៈនៃការបោះឆ្នោតដោយសេរី | -ការបោះឆ្នោតគឺជាពេលដែលអ្នកបោះឆ្នោតចេញទៅបោះឆ្នោតជ្រើសរើសតំណាងឬអ្នកដឹកនាំរបស់គេ។<br>-ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ជាសម្ងាត់ ត្រឹមត្រូវ យុត្តិធម៌ស្របច្បាប់និងធ្វើឡើងក្នុងចន្លោះ ពេលមួយយ៉ាងទៀងទាត់។ |
| -ឱ្យសិស្សបើកសៀវភៅទំព័រ ២០១រួចអានចំណងជើងមេរៀន<br>-គ្រូសរសេរចំណងជើងដាក់លើក្តារខៀន<br>-ឱ្យសិស្សអានខ្លឹមសារមេរៀន<br><br>-សរសេរពាក្យពិបាកលើក្តារខៀន ហើយឱ្យសិស្សឡើង ពន្យល់ | **ជំហានទី៣**<br>(មេរៀនប្រចាំថ្ងៃ)<br>**មេរៀនទី១ ការបោះឆ្នោត**(តចប់)<br>2.**គោលបំណងនៃការបោះឆ្នោត**<br>3.**លក្ខណៈនៃការបោះឆ្នោត** ដោយសេរី<br>-ខ្លឹមសារមេរៀន<br>**ពន្យល់ពាក្យ**<br>-សន្តិវិធី(ន) វិធីនៃសេចក្តីសុខសាន្តការស្រុះស្រួល។<br>-ព័ត៌មាន(ន) ដំណឹង ការផ្សព្វ | -សិស្សធ្វើតាមការណែនាំ |

| | | |
|---|---|---|
| -បែងចែកសិស្សជា៤ក្រុមពិភាក្សា៖ | ផ្សាយ។<br>-បេក្ខជន(ន) ជនដែលចង់បានមុខដំណែងឬមុខងារ។<br>**ការពិភាក្សាក្រុម**<br>-សកម្មភាពក្រុម | -ចូលតាមក្រុមពិភាក្សា |
| **-ក្រុមទី១**: តើការបោះឆ្នោតមានគោលបំណងអ្វីខ្លះ? | -គោលបំណងនៃការបោះឆ្នោតគឺ<br>• ផ្លាស់ប្តូរអ្នកដឹកនាំតាមសន្តិវិធី និងផ្តល់អំណាចឱ្យអ្នកដឹកនាំ តាមរយៈសម្លេងភាគច្រើន<br>• ជំរុញឱ្យអ្នកដឹកនាំមានការទទួលខុសត្រូវចំពោះមុខអ្នកម្ចាស់ឆ្នោត<br>• ជ្រើសរើសអ្នកដឹកនាំតាមការពេញចិត្ត និងតាមឆន្ទៈ។ | -គោលបំណងនៃការបោះឆ្នោត គឺ<br>• ផ្លាស់ប្តូរអ្នកដឹកនាំតាមសន្តិវិធី និងផ្តល់អំណាចឱ្យអ្នកដឹកនាំតាម រយៈសម្លេងភាគច្រើន<br>• ជំរុញឱ្យអ្នកដឹកនាំមានការទទួលខុសត្រូវចំពោះមុខអ្នកម្ចាស់ឆ្នោត<br>• ជ្រើសរើសអ្នកដឹកនាំតាមការពេញចិត្ត និងតាមឆន្ទៈ។ |
| **-ក្រុមទី២**: តើការបោះឆ្នោតដោយសេរីជាអ្វី? | -ការបោះឆ្នោតដោយសេរីគឺជាការចូលរួមក្នុងដំណើរការបោះឆ្នោតដោយសេរីរបស់អ្នកបោះឆ្នោត។ | -ការបោះឆ្នោតដោយសេរីគឺជាការចូលរួមក្នុងដំណើរការបោះឆ្នោតដោយសេរីរបស់អ្នកបោះឆ្នោត។ |
| **-ក្រុមទី៣**: តើមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យគឺអ្វី? | -មូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យគឺសិទ្ធិបោះឆ្នោត។ | -មូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យ គឺសិទ្ធិបោះឆ្នោត។ |
| **-ក្រុមទី៤**: តើអ្នកបោះឆ្នោតមានសេរីភាពអ្វីខ្លះ? | -អ្នកបោះឆ្នោតមានសេរីភាពដូចជា៖<br>• អាចទទួលព័ត៌មានពីការបោះឆ្នោតដោយសេរី<br>• ចូលរួមប្រជុំដោយសេរី និងបញ្ចេញមតិដើម្បីពិភាក្សាពីបេក្ខជនបេក្ខនារីឈរឈ្មោះបោះឆ្នោតដោយសេរី<br>• សម្រេចចិត្តបោះឆ្នោតតាមឆន្ទៈ។ | -អ្នកបោះឆ្នោតមានសេរីភាព ដូចជា៖<br>• អាចទទួលព័ត៌មានពីការបោះឆ្នោតដោយសេរី<br>• ចូលរួមប្រជុំដោយសេរី និងបញ្ចេញមតិដើម្បីពិភាក្សាពី បេក្ខជនបេក្ខនារីឈរឈ្មោះបោះឆ្នោតដោយសេរី<br>• សម្រេចចិត្តបោះឆ្នោតតាមឆន្ទៈ។ |
| -សំយោគឡើងវិញហើយឱ្យសិស្សកត់ | | -កត់ចូលសៀវភៅ |

| | | |
|---|---|---|
| -ឱ្យសិស្សសាកល្បងសង្ខេបមេរៀន<br><br>-សំយោគនិងសម្រួលឱ្យសិស្សកត់ | **មេរៀនសង្ខេប**<br>សិទ្ធិបោះឆ្នោតជាមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យ ក្នុងការពង្រឹងគុណភាពនៃការដឹកនាំ។ ការបោះឆ្នោតដោយសេរីដើម្បីជ្រើសរើសតំណាងរបស់ខ្លួនដែលពេញចិត្តដោយគ្មានការបង្ខិតបង្ខំនិងគ្មានការគំរាមកំហែង អ្វីទាំងអស់។ | -កត់ចូលសៀវភៅ |
| -តើការបោះឆ្នោតមានគោលបំណងដូចម្តេច?<br><br>-តើការបោះឆ្នោតដោយសេរីជា អ្វី?<br><br>-តើមូលដ្ឋាននៃលទ្ធិប្រជាធិប-តេយ្យគឺអ្វី? | **ជំហានទី៤**<br>(ពង្រឹងពុទ្ធិ)<br>-គោលបំណងនៃការបោះឆ្នោតគឺ<br>• ផ្លាស់ប្តូរអ្នកដឹកនាំតាមសន្តិវិធី និងផ្តល់អំណាចឱ្យអ្នកដឹកនាំ តាម រយៈសម្លេងភាគច្រើន<br>• ជំរុញឱ្យអ្នកដឹកនាំមានការទទួលខុសត្រូវចំពោះមុខអ្នកម្ចាស់ឆ្នោត<br>• ជ្រើសរើសអ្នកដឹកនាំតាមការពេញចិត្ត និងតាមឆន្ទៈ។<br><br>-ការបោះឆ្នោតដោយសេរីគឺជាការចូលរួមក្នុងដំណើរការបោះឆ្នោតដោយសេរីរបស់អ្នកបោះឆ្នោត។<br>-មូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យគឺសិទ្ធិបោះឆ្នោត។ | -គោលបំណងនៃការបោះឆ្នោត គឺៈ<br>• ផ្លាស់ប្តូរអ្នកដឹកនាំតាមសន្តិវិធី និងផ្តល់អំណាចឱ្យអ្នកដឹកនាំ តាម រយៈសម្លេងភាគច្រើន<br>• ជំរុញឱ្យអ្នកដឹកនាំមានការទទួលខុសត្រូវចំពោះមុខអ្នកម្ចាស់ឆ្នោត<br>• ជ្រើសរើសអ្នកដឹកនាំតាមការពេញចិត្ត និងតាមឆន្ទៈ។<br>-ការបោះឆ្នោតដោយសេរីគឺជាការចូលរួមក្នុងដំណើរការបោះឆ្នោតដោយសេរីរបស់អ្នកបោះឆ្នោត។<br>-មូលដ្ឋាននៃលទ្ធិប្រជាធិប -តេយ្យគឺសិទ្ធិបោះឆ្នោត។ |
| -ពេលត្រលប់ទៅផ្ទះវិញមើលមេរៀន បន្តផង។ជួយធ្វើការឪពុកម្តាយ និងកុំដើរលេងច្រើនពេក។ | **ជំហានទី៥**<br>(បណ្តាំផ្ញើ) | -សិស្សស្តាប់យ៉ាងយកចិត្តទុកដាក់ |

# កិច្ចតែងការបង្រៀន

- កាលបរិច្ឆេទ : ថ្ងៃ ទី ខែ ឆ្នាំ
- មុខវិជ្ជា : សីលធម៌ ពលរដ្ឋវិជ្ជា
- ថ្នាក់ទី : ៧
- **ជំពូកទី៤ : ការរស់នៅជាមួយសហគមន៍**
- **មេរៀនទី២ : តួនាទី និងភារកិច្ចរបស់តំណាងសិស្ស**
- វិធីសាស្ត្រ : គោលវិធីសិស្សមជ្ឈមណ្ឌល
- រយៈពេល : ១ម៉ោងសិក្សា

## I. វត្ថុបំណង

- ចំណេះដឹង : ប្រាប់ពីនិយមន័យ និងភារកិច្ចរបស់តំណាងសិស្សបានត្រឹមត្រូវតាមរយៈការសិក្សាមេរៀន។
- បំណិន : វិភាគពីនិយមន័យ ភារកិច្ចរបស់តំណាងសិស្សបានត្រឹមត្រូវតាមរយៈការពិភាក្សាក្រុម។
- ឥរិយាបថ : បណ្តុះស្មារតីឱ្យចេះសហការ និងចេះទទួលខុសត្រូវលើតួនាទី និងភារកិច្ចរបស់ខ្លួនបានល្អក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

## II. ខ្លឹមសារមេរៀន

1. **តំណាងសិស្ស**
2. **តួនាទីនិងភារកិច្ចតំណាងសិស្សនៅពេលជាប់ឆ្នោត**

## III. សម្ភារឧបទេស

- សៀវភៅសិស្សទំព័រ ២០២, ២០៣ បោះពុម្ពឆ្នាំ២០០៩
- ប័ណ្ណសំណួរ, ផ្ទាំងមេរៀនសង្ខេប

## IV. ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ត្រួតពិនិត្យលើ អវត្តមាន វិន័យ អនាម័យ | **ជំហានទី១**<br>(រដ្ឋបាលថ្នាក់)<br>- អវត្តមាន វិន័យ អនាម័យ | -ប្រធានថ្នាក់ឡើងរាយការណ៍ |
| -តើការបោះឆ្នោតក្នុងសង្គមប្រជាធិបតេយ្យប្រព្រឹត្តទៅដូចម្តេច?<br>-ការបោះឆ្នោតដោយសេរីជាអ្វី?<br>-តើអ្នកណាជាអ្នកគ្រប់គ្រងថ្នាក់បន្ទាប់ពីគ្រូ? | **ជំហានទី២**<br>(រំលឹកមេរៀនចាស់)<br>-ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ជាសម្ងាត់ត្រឹមត្រូវ យុត្តិធមិស្របច្បាប់ និងធ្វើឡើងក្នុងរយៈពេលមួយជាក់លាក់។<br>-ការបោះឆ្នោតដោយសេរីគឺជាការចូលរួមក្នុង ដំណើរការបោះឆ្នោតដោយសេរី របស់អ្នកបោះឆ្នោត។<br><u>ទំនាក់ទំនងមេរៀនថ្មី</u><br>- ប្រធានថ្នាក់,អនុប្រធាន<br>-ដោយការបោះឆ្នោត | -ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ជាសម្ងាត់ត្រឹមត្រូវ យុត្តិធមិស្របច្បាប់ និងធ្វើឡើងក្នុងរយៈពេលមួយជាក់លាក់។<br>-ការបោះឆ្នោតដោយសេរីគឺជាការចូលរួមក្នុង ដំណើរការបោះឆ្នោតដោយសេរី របស់អ្នកបោះឆ្នោត។<br>- ប្រធានថ្នាក់,អនុប្រធាន<br>-ដោយការបោះឆ្នោត |
| -ឱ្យសិស្សបើកសៀវភៅទំព័រទី២០២អានចំណងជើងមេរៀន<br>-តើចំណងជើងមេរៀនមានន័យដូចម្តេច?<br>-ឱ្យសិស្សអានខ្លឹមសារមេរៀនទំព័រ២០២-២០៣ | **ជំហានទី៣**<br>(មេរៀនប្រចាំថ្ងៃ)<br>**មេរៀនទី២**:<br>**តួនាទីនិងភារកិច្ចរបស់តំណាងសិស្ស**<br>-មានន័យថាតួនាទីនិងភារកិច្ចរបស់តំណាងសិស្សដើម្បីឱ្យថ្នាក់រៀនមានដំណើរការល្អ ។<br>-ខ្លឹមសារមេរៀនទំព័រ២០២-២០៣(ការដឹកនាំ...ក្លឹបសិក្សា) | -អានចំណងជើងមេរៀន<br>-មានន័យថាតួនាទីនិងភារកិច្ចរបស់តំណាងសិស្សដើម្បីឱ្យថ្នាក់រៀនមានដំណើរការល្អ ។<br>-អានតាមការណែនាំ |

| | | |
|---|---|---|
| -គ្រូសរសេរពន្យល់ពាក្យលើក្ដារខៀន | **ពន្យល់ពាក្យ**<br>-សមត្ថភាព(ន)<br>ភាពដែលអាចធ្វើបាន។<br>-គុណសម្បត្តិ(ន) លក្ខណៈល្អចំណុចល្អរបស់បុគ្គលម្នាក់ៗ។<br>-បរិស្ថាន(ន) អ្វីៗដែលនៅជុំវិញខ្លួនយើង។ | |
| -បែងចែកសិស្សជា៣ក្រុម | **ពិភាក្សាក្រុម** | |
| **-ក្រុមទី១:** ដូចម្ដេចហៅតំណាងសិស្ស? ហើយជ្រើសរើសដោយនរណា តាមវិធីណា? | -តំណាងសិស្សគឺជាអ្នកតំណាងឱ្យសិស្សទាំងអស់ក្នុងថ្នាក់រៀន និងជួយសម្រួលដល់ការងារក្នុងថ្នាក់។ត្រូវជ្រើសរើសពីនាក់ក្នុងថ្នាក់ទាំងអស់ក្នុងថ្នាក់រៀនតាមរយៈការបោះឆ្នោត។ | -តំណាងសិស្សគឺជាអ្នកតំណាងឱ្យសិស្សទាំងអស់ក្នុងថ្នាក់រៀននិងជួយសម្រួលដល់ការងារក្នុងថ្នាក់។ត្រូវជ្រើសរើសពីនាក់ក្នុងថ្នាក់ទាំងអស់ក្នុងថ្នាក់រៀនតាមរយៈការបោះឆ្នោត។ |
| **-ក្រុមទី២:** តើតំណាងសិស្សត្រូវមានគុណសម្បត្តិ<br>អ្វីខ្លះ? | -គុណសម្បត្តិ របស់តំណាងសិស្សៈ<br>• ព្យាយាមរៀនសូត្រ<br>• ចូលរួមគ្រប់សកម្មភាព<br>• ជាគំរូ ដល់សមាជិក<br>• មានគំនិតផ្ដួចផ្ដើម<br>• រាក់ទាក់ ស្មោះត្រង់<br>• គិតប្រយោជន៍រួមជាធំ។ | -គុណសម្បត្តិ របស់តំណាងសិស្សៈ<br>• ព្យាយាមរៀនសូត្រ<br>• ចូលរួមគ្រប់សកម្មភាព<br>• ជាគំរូ ដល់សមាជិក<br>• មានគំនិតផ្ដួចផ្ដើម<br>• រាក់ទាក់ ស្មោះត្រង់<br>• គិតប្រយោជន៍រួមជាធំ។ |
| **-ក្រុមទី៣:** តើតួនាទី និងភារកិច្ចអ្នកតំណាងសិស្សមានអ្វីខ្លះ? | -តួនាទី និងភារកិច្ចអ្នកតំណាងសិស្សមានៈ<br>• ទំនាក់ទំនងល្អក្នុងងថ្នាក់<br>• ពិនិត្យអវត្តមាន រកមូលហេតុ<br>• លើកទឹកចិត្ត មិត្តឱ្យគោរពវិន័យ<br>• ជំរុញមិត្ត ឱ្យសម្អាតបរិស្ថាន<br>• លើកទឹកចិត្តឱ្យចូលរួមខ្លឹបសិក្សា។ | -តួនាទី និងភារកិច្ចអ្នកតំណាងសិស្សមានៈ<br>• ទំនាក់ទំនងល្អក្នុងងថ្នាក់<br>• ពិនិត្យអវត្តមានរកមូលហេតុ<br>• លើកទឹកចិត្ត មិត្តឱ្យគោរពវិន័យ<br>• ជំរុញមិត្តឱ្យសម្អាតបរិស្ថាន<br>• លើកទឹកចិត្តឱ្យចូលរួមខ្លឹបសិក្សា។ |
| -កែសម្រួឱ្យសិស្សកត់ចូល | | -សិស្សកត់ចូលសៀវភៅ |

| | | |
|---|---|---|
| សៀវភៅ<br><br>-ឱ្យសិស្សកត់ចូលសៀវភៅ | **មេរៀនសង្ខេប**<br>ទីណាក៏ដោយ គឺទាមទារឱ្យមានអ្នកដឹកនាំ ដើម្បីឱ្យមានការផ្លាស់ប្ដូរ និងរីកចម្រើន។ ក្នុងនោះផងដែរទាមទារឱ្យអ្នកនោះដឹង និងស្គាល់ពីតួនាទីនិងភារកិច្ចរបស់ខ្លួន មិនតែប៉ុនោះសមាជិកក៏ចូលរួម ចំណែកលើ ទំនួលខុសត្រូវរបស់ខ្លួន ដើម្បី រួមសហការសម្រេចគោលដៅមួយ។ | -សិស្សកត់ចូលសៀវភៅ |
| -តើតំណាងសិស្សត្រូវមានគុណសម្បត្តិអ្វីខ្លះ?<br><br>-តើតួនាទី និភារកិច្ចអ្នកតំណាងសិស្សមានអ្វីខ្លះ? | **ជំហានទី៤**<br>(ពង្រឹងពុទ្ធិ)<br>-គុណសម្បត្តិ របស់តំណាងសិស្ស៖<br>• ព្យាយាមរៀនសូត្រ<br>• ចូលរួមគ្រប់សកម្មភាព<br>• ជាគំរូ ដល់សមាជិក<br>• មានគំនិតផ្តួចផ្តើម<br>• រាក់ទាក់ ស្មោះត្រង់<br>• គិតប្រយោជន៍រួមជាធំ។<br>-តួនាទី និងភារកិច្ចអ្នកតំណាងសិស្សមាន៖<br>• ទំនាក់ទំនងល្អក្នុងងថ្នាក់<br>• ពិនិត្យអវត្តមាន រកមូលហេតុ<br>• លើកទឹកចិត្ត មិត្តឱ្យគោរពវិន័យ<br>• ជំរុញមិត្ត ឱ្យសម្អាតបរិស្ថាន<br>• លើកទឹកចិត្តឱ្យចូលរួមខ្លឹបសិក្សា។ | -គុណសម្បត្តិ របស់តំណាងសិស្ស៖<br>• ព្យាយាមរៀនសូត្រ<br>• ចូលរួមគ្រប់សកម្មភាព<br>• ជាគំរូ ដល់សមាជិក<br>• មានគំនិតផ្តួចផ្តើម<br>• រាក់ទាក់ ស្មោះត្រង់<br>• គិតប្រយោជន៍រួមជាធំ។<br>-តួនាទី និងភារកិច្ចអ្នកតំណាងសិស្សមាន៖<br>• ទំនាក់ទំនងល្អក្នុងងថ្នាក់<br>• ពិនិត្យអវត្តមាន រកមូលហេតុ<br>• លើកទឹកចិត្ត មិត្តឱ្យគោរពវិន័យ<br>• ជំរុញមិត្ត ឱ្យសម្អាតបរិស្ថាន<br>• លើកទឹកចិត្តឱ្យចូលរួមក្លឹបសិក្សា។ |
| | | |

| | | |
|---|---|---|
| -គ្រូមើលមេរៀនបន្តផង និងជួយការងារផ្ទះផង។ | **ជំហានទី៥**<br>(បណ្តាំផ្ញើ)<br><u>សំណួរ</u><br>១. តើសិស្សម្នាក់ៗត្រូវមានតួនាទីអ្វីខ្លះដើម្បីចូលរួមធ្វើឱ្យថ្នាក់រៀនមានបរិស្ថានស្អាត និងការរីចម្រើនក្នុងការសិក្សា? | -ស្តាប់តាមការណែនាំ |

# កិច្ចតែងការបង្រៀន

❖ កាលបរិច្ឆេទ : ថ្ងៃ ទី ខែ ឆ្នាំ
❖ មុខវិជ្ជា : សីលធម៌-ពលរដ្ឋវិជ្ជា
❖ ថ្នាក់ទី : ៧
❖ **ជំពូកទី៤ : ការរស់នៅជាមួយសហគមន៍**
❖ **មេរៀនទី៣ : ដំណើរការនៃការបោះឆ្នោត**
❖ វិធីសាស្ត្រ : គោលវិធីសិស្សមជ្ឈមណ្ឌល (ពិភាក្សាក្រុម)
❖ រយៈពេល : ១ម៉ោងសិក្សា

## I. **វត្ថុបំណង**

➢ ចំណេះដឹង : ពណ៌នាពីការបោះឆ្នោតជាចំហ និងសម្ងាត់ បានត្រឹមត្រូវតាមរយៈការសិក្សាខ្លឹមសារមេរៀន។
➢ បំណិន : វិភាគពីលក្ខណៈនៃការបោះឆ្នោតជាចំហ និងសម្ងាត់ បានត្រឹមត្រូវតាមរយៈការពិភាក្សាក្រុម។
➢ ឥរិយាបថ : បណ្តុះស្មារតីឱ្យប្រជាពលរដ្ឋចេះអនុវត្តរកវិធីបោះឆ្នោតមួយណាល្អ ដើម្បីជ្រើសរើសអ្នកដឹកនាំ។

## II. **ខ្លឹមសារមេរៀន**

1. **ការបោះឆ្នោតជាសម្ងាត់**
2. **ការបោះឆ្នោតជាចំហ**

## III. **សម្ភារឧបទេស**

- សៀវភៅសិស្សថ្នាក់ទី៧ ទំព័រ ២០៤-២០៥ បោះពុម្ពឆ្នាំ ២០១១
- បណ្តុំសំណួរ
- ផ្ទាំងមេរៀនសង្ខេប

IV. **ដំណើរការបង្រៀន**

| **សកម្មភាពគ្រូ** | **ខ្លឹមសារមេរៀន** | **សកម្មភាពសិស្ស** |
|---|---|---|
| -គ្រូតពិនិត្យលើ អវត្តមាន អនាម័យ សណ្ដាប់ធ្នាប់ | **ជំហានទី១**<br>(រដ្ឋបាលថ្នាក់) | -ប្រធានថ្នាក់ឡើងរាយការណ៍ |
| - តើកាលពីថ្ងៃមុនយើងសិក្សាដល់មេរៀនអ្វី?<br>-តើតំណាងសិស្សជានរណា?<br><br>-តើតំណាងសិស្សត្រូវមានគុណសម្បត្តិអ្វីខ្លះ?<br><br>- ក្នុងភូមិរបស់ប្អូនធ្លាប់ធ្វើការបោះឆ្នោតជ្រើសរើសតំណាងមេឃុំ ឬមេភូមិទេ? | **ជំហានទី២**<br>(រំលឹកមេរៀនចាស់)<br>-មេរៀនទី២ តួនាទី និងភារកិច្ចរបស់តំណាងសិស្ស<br>-តំណាងសិស្សជាអ្នកតំណាងឱ្យសិស្សទាំងអស់ក្នុងថ្នាក់ និងជួយសម្រួលដល់ការងារលោកគ្រូអ្នកគ្រូ។<br>-គុណសម្បត្តិមាន<br>• ខិតខំរៀនសូត្រ ព្យាយាម<br>• ចូលរួមគ្រប់សកម្មភាព<br>• ជាគំរូល្អ រួសរាយរាក់ទាក់<br>• មានគំនិតផ្ដួចផ្ដើម។<br><br><u>ទំនាក់ទំនងមេរៀន</u><br>-មានការបោះឆ្នោត | -តំណាងសិស្សជាអ្នកតំណាងឱ្យសិស្សទាំងអស់ក្នុងថ្នាក់ និងជួយសម្រួលដល់ការងារលោកគ្រូអ្នកគ្រូ។<br>-គុណសម្បត្តិមាន<br>• ខិខំរៀនសូត្រ ព្យាយាម<br>• ចូលរួមគ្រប់សកម្មភាព<br>• ជាគំរូល្អ រសរាយរាក់ទាក់<br>• មានគំនិតផ្ដួចផ្ដើម។<br><br>-មានការបោះឆ្នោត |
| -ឱ្យសិស្សបើកសៀវភៅទំព័រ ២០៤ អានចំណងជើង<br>-តើចំណងជើងមានន័យដូចម្ដេច?<br>-ឱ្យសិស្សអានខ្លឹមសារមេរៀនទំព័រ២០៤ដល់២០៥<br><br>- សរសេរពន្យល់ពាក្យលើក្ដារ | **ជំហានទី៣**<br>(មេរៀនប្រចាំថ្ងៃ)<br>**មេរៀនទី៣**:<br>**ដំណើរនៃការបោះឆ្នោត**<br>- មានន័យថា របៀប ឬជំហាននៃការបោះឆ្នោត។<br>- ខ្លឹមសារមេរៀន<br>1. **ការបោះឆ្នោតជាចំហ**<br>2. **ការបោះឆ្នោតជាសម្ងាត់**<br><br>ពន្យល់ពាក្យ | -អានចំណងជើងមេរៀន<br><br>- មានន័យថា របៀប ឬជំហាននៃការបោះឆ្នោត។<br>-អានខ្លឹមសារមេរៀន<br><br>-ឡើងពន្យល់ |

| | | |
|---|---|---|
| ខៀន | -សិទ្ធិ(ន) អំណាចដែលធម្មជាតិផ្តល់ឱ្យតែក្រោមច្បាប់។<br>-អព្យាក្រឹត(គុ) ដែលកណ្តាល។ | -សិទ្ធិ(ន) អំណាចដែលធម្មជាតិផ្តល់ឱ្យតែក្រោមច្បាប់។<br>-អព្យាក្រឹត(គុ) ដែលកណ្តាល។ |
| -គ្រូបែងចែកជាបួនក្រុម៖<br>**-ក្រុមទី១:** អ្វីទៅជាការបោះឆ្នោត ជាចំហ? | **ពិភាក្សាក្រុម**<br>-ការបោះឆ្នោតជាចំហជាការបោះ ឆ្នោតដោយអ្នកបោះឆ្នោតម្នាក់ៗ សម្តែងការគាំទ្រដល់ការជ្រើស រើសបេក្ខជនតាមការសម្រេចចិត្ត និងតាមការលើកដៃដោយមិនប្រើ សន្លឹកឆ្នោត។ | -ការបោះឆ្នោតជាចំហជាការបោះ ឆ្នោតដោយអ្នកបោះឆ្នោតម្នាក់ៗ សម្តែងការគាំទ្រដល់ការជ្រើស រើសបេក្ខជនតាមការសម្រេចចិត្ត និងតាមការលើកដៃដោយមិនប្រើ សន្លឹកឆ្នោត។ |
| **-ក្រុមទី២:** តើការបោះឆ្នោតជាចំហមានគុណវិបត្តិអ្វីខ្លះ? | -គុណវិបត្តិ<br>• អាចស្គាល់បានចំពោះអ្នកបោះឆ្នោតដែលគាំទ្រ<br>• ការសម្រេចមិនស្របតាម បំណងលើកដៃតាមអ្នកដទៃ<br>• ព្រួយបារម្ភភ័យខ្លាច<br>• ពុំមានសេរីភាពខាងសម្រេច ចិត្ត។ | -គុណវិបត្តិ<br>• អាចស្គាល់បានចំពោះអ្នកបោះឆ្នោតដែលគាំទ្រ<br>• ការសម្រេចមិនស្របតាម បំណងលើកដៃតាមអ្នកដទៃ<br>• ព្រួយបារម្ភភ័យខ្លាច<br>• ពុំមានសេរីភាពខាងសម្រេចចិត្ត។ |
| **-ក្រុមទី៣:** អ្វីទៅជាការបោះឆ្នោតជាសម្ងាត់? | -ជាការបោះឆ្នោតដែលអាចធានាអាថ៌កំបាំងនៃការសម្រេចអ្នកបោះឆ្នោតម្នាក់ៗនៅលើសន្លឹកឆ្នោត។ | -ជាការបោះឆ្នោតដែលអាចធានាអាថ៌កំបាំងនៃការសម្រេចអ្នកបោះឆ្នោតម្នាក់ៗនៅលើសន្លឹកឆ្នោត។ |
| **-ក្រុមទី៤:** គុណសម្បត្តិនៃការបោះឆ្នោតជាសម្ងាត់មានអ្វីខ្លះ? | -គុណសម្បត្តិគឺ៖<br>• មានសេរីភាពក្នុងការសម្រេច ចិត្ត<br>• គ្មានការព្រួយបារម្ភ<br>• គ្មានការបង្ខិតបង្ខំ<br>• គ្មានការគំរាមកំហែង<br>• គ្មានការភ័យខ្លាច | -គុណសម្បត្តិគឺ៖<br>• មានសេរីភាពក្នុងការសម្រេចចិត្ត<br>• គ្មានការព្រួយបារម្ភ<br>• គ្មានការបង្ខិតបង្ខំ<br>• គ្មានការគំរាមកំហែង<br>• គ្មានការភ័យខ្លាច |
| - គ្រូសំយោគចម្លើយ | -សំយោគ | -ស្តាប់ហើយកត់ |

| | | |
|---|---|---|
| -ឱ្យសិស្សទាញបញ្ញត្តិតម្លៃ | **មេរៀនសង្ខេប**<br>ការបោះឆ្នោតមាន២យ៉ាងគឺ ការបោះឆ្នោតជាចំហ និងការបោះឆ្នោតជាសម្ងាត់។វិធី២យ៉ាងនេះ យើងអាចជ្រើសរើសទៅតាមស្ថានភាព។ការបោះឆ្នោតទាំង២នេះសុទ្ធតែមានគុណសម្បត្តិ និងគុណវិបត្តិរបស់វា វាអាស្រ័យលើអ្នកប្រើយកទៅអនុវត្តឱ្យចំទីតាំង ទីកន្លែង ភូមិសាស្ត្រ។ | -សាកល្បង និងកត់ត្រា |
| -អ្វីទៅជាការបោះឆ្នោតជាចំហ?<br><br><br><br><br><br>-អ្វីទៅជាការបោះឆ្នោតជា សម្ងាត់? | **ជំហានទី៤**<br>(ពង្រឹងពុទ្ធិ)<br>-ការបោះឆ្នោតជាចំហជាការបោះ ឆ្នោតដោយអ្នកបោះឆ្នោតម្នាក់ៗ សម្តែងការគាំទ្រដល់ការជ្រើស រើសបេក្ខជនតាមការសម្រេចចិត្ត និងតាមការលើកដៃដោយមិនប្រើ សន្លឹកឆ្នោត។<br>-ជាការបោះឆ្នោតដែលអាចធានាអាថ៌កំបាំងនៃការសម្រេចអ្នកបោះឆ្នោតម្នាក់ៗនៅលើសន្លឹកឆ្នោត។ | -ការបោះឆ្នោតជាចំហជាការបោះ ឆ្នោតដោយអ្នកបោះឆ្នោតម្នាក់ៗ សម្តែងការគាំទ្រដល់ការជ្រើស រើសបេក្ខជនតាមការសម្រេចចិត្ត និងតាមការលើកដៃដោយមិនប្រើសន្លឹកឆ្នោត។<br>-ជាការបោះឆ្នោតដែលអាចធានាអាថ៌កំបាំងនៃការសម្រេចអ្នកបោះឆ្នោតម្នាក់ៗនៅលើសន្លឹកឆ្នោត។ |
| -ពេលត្រឡប់ទៅផ្ទះវិញត្រូវមើលមេរៀនបន្តផង<br>-កុំដើរលេងច្រើនពេក។ | **ជំហានទី៥**<br>(បណ្តាំផ្ញើ)<br>-មេរៀនទី៩: លក្ខខ័ណ្ឌនៃការឈរជាបេក្ខជន<br>-រកពាក្យពិបាក | -ស្តាប់និងអនុវត្តតាម។ |

# កិច្ចតែងការបង្រៀន

- ❖ កាលបរិច្ឆេទ : ថ្ងៃ ទី ខែ ឆ្នាំ
- ❖ មុខវិជ្ជា : សីលធម៌-ពលរដ្ឋវិជ្ជា
- ❖ ថ្នាក់ទី : ឆ្នាំទី១
- ❖ **ជំពូកទី៤** : **ការរស់នៅជាមួយសហគមន៍**
- ❖ **មេរៀនទី៥** : **ការចូលរួមបោះឆ្នោត**
- ❖ វិធីសាស្ត្រ : គោលវិធីសិស្សមជ្ឈមណ្ឌល (ពិភាក្សាក្រុម)
- ❖ រយៈពេល : ២ ម៉ោងសិក្សា (សម្រាប់ម៉ោងទី១)

## I. វត្ថុបំណង

- ➢ ចំណេះដឹង : រៀបរាប់ពីភារកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោត និង ការរៀបចំចាត់ចែងដំណើរការបោះឆ្នោតបានយ៉ាងត្រឹមត្រូវតាមរយៈការអានខ្លឹមសារមេរៀន និង ការពន្យល់របស់គ្រូ។
- ➢ បំណិន : ពន្យល់ពីការរៀបចំទីកន្លែងនៃការបោះឆ្នោតបានយ៉ាងត្រឹមត្រូវតាមរយៈការពិភាក្សាក្រុម។
- ➢ ឥរិយាបថ : បណ្ដុះស្មារតីសិស្សចូលរួមបោះឆ្នោតជ្រើសរើសតំណាងសិស្សនៅក្នុងថ្នាក់របស់ខ្លួន និង ជ្រើសរើសអ្វីមួយនៅក្នុងសង្គម។

## II. សំភារឧបទេស

- ចំពោះគ្រូ : សៀវភៅសិស្ស មេរៀនសង្ខេប ប័ណ្ណសំណួរ ផ្ទាំងរូបភាព
- ចំពោះសិស្ស : សៀវភៅសិស្ស ប៊ិច សៀវភៅសរសេរ...។

## III. ខ្លឹមសារមេរៀន

1. **ការរៀបចំការបោះឆ្នោត**
2. **ការរៀបចំទីកន្លែងបោះឆ្នោត**

IV. **ដំណើរការបង្រៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ពិនិត្យលើ: សណ្ដាប់ធ្នាប់ អនាម័យ អវត្តមាន។ | **ជំហានទី១**<br>(រដ្ឋបាលថ្នាក់)<br>• សណ្ដាប់ធ្នាប់<br>• អនាម័យ<br>• អវត្តមាន<br>• ពង្រឹងវិន័យ | -ក្រោកឈរត្រង់ខ្លួន<br>-ប្រធានថ្នាក់ឡើងរាយការណ៍។ |
| -តើកាលពីថ្ងៃមុនយើងបានសិក្សាអំពីមេរៀនអ្វី?<br><br>-តើបេក្ខជនដែលអាចឈរឈ្មោះឆ្នោតជ្រើសរើសតំណាងសិស្សបានត្រូវបំពេញនូវលក្ខខណ្ឌអ្វីខ្លះ?<br><br>-តើការឃោសនាបោះឆ្នោតមានគោលបំណងអ្វី?<br><br>-តើប្អូនធ្លាប់ចូលរួមបោះឆ្នោតជ្រើសរើសប្រធានថ្នាក់ដែរឬទេ?<br><br>- | **ជំហានទី២**<br>(រំលឹកមេរៀនចាស់)<br>មេរៀនទី៩:<br>លក្ខខណ្ឌនៃការឈរឈ្មោះជាបេក្ខជន<br>-ត្រូវបំពេញនូវលក្ខខណ្ឌ៖<br>• ដាក់ពាក្យសុំឈរឈ្មោះជាជាបេក្ខជន<br>• មានសមត្ថភាព និង សុខភាពល្អ<br>• ចេះអធ្យាស្រ័យចំពោះមិត្តរួមថ្នាក់<br>• ឧស្សាព្យាយាមរៀនសូត្រ<br>• គោរពវិន័យសាលា។<br><br>-មានគោលបំណងឱ្យបេក្ខជនឈរឈ្មោះបោះឆ្នោតផ្សព្វ-ផ្សាយកិច្ចការដែលខ្លួនត្រូវធ្វើក្រោយពេលជាប់ឆ្នោត។<br><br>**<u>ទំនាក់ទំនងមេរៀនថ្មី</u>**<br>-ធ្លាប់ / មិនធ្លាប់<br><br>-ប្រើវិធីដូចជា៖ ការលើកដៃ | -ត្រូវបំពេញនូវលក្ខខណ្ឌ៖<br>• ដាក់ពាក្យសុំឈរឈ្មោះជាជាបេក្ខជនដោយបញ្ជាក់ពីប្រវត្តិរូបឱ្យបានច្បាស់លាស់<br>• មានសមត្ថភាព សីលធម៌ និង សុខភាពល្អ<br>• ចេះអធ្យាស្រ័យចំពោះមិត្តរួមថ្នាក់<br>• ឧស្សាព្យាយាមរៀនសូត្រ<br>• មករៀនទៀងទាត់ និង ស្រឡាញ់ថ្នាក់រៀន។<br>-ការឃោសនាបោះឆ្នោតមានគោលបំណងឱ្យបេក្ខជនឈរឈ្មោះបោះឆ្នោតផ្សព្វ-ផ្សាយកិច្ចការដែលខ្លួនត្រូវធ្វើក្រោយពេលជាប់ឆ្នោត។<br><br>-បាទ / ចាស ធ្លាប់ / មិនធ្លាប់<br><br>-ប្រើវិធីដូចជា៖ ការលើកដៃ |

| | | |
|---|---|---|
| តើក្នុងការបោះឆ្នោតនោះគេប្រើវិធីអ្វីខ្លះ? | ទះដៃយកសំឡេងច្រើន ឬ ការឡើងគូសឈ្មោះ។ | ទះដៃយកសំឡេងច្រើន ឬ ការឡើងគូសឈ្មោះ។ |
| –ឱ្យសិស្សបើកសៀវភៅទំព័រ ២០៨ រួចអានចំណងជើង<br><br>–សរសេរចំណងជើងមេរៀនដាក់លើក្តារខៀន<br><br>–តើចំណងជើងមេរៀននេះមានន័យដូចម្តេច?<br><br>–តើប្អូនឃើញអ្វីខ្លះក្នុងរូបភាពនេះ?<br><br>–តើរូបភាពនិងចំណងជើងមានទំនាក់ទំនងគ្នាដែរឬទេ?<br><br>–ឱ្យសិស្សអានខ្លឹមសារមេរៀនទំព័រ ២០៨-២០៩<br><br>–សរសេរពាក្យពិបាកលើក្តារខៀន រួចឱ្យសិស្សឡើងពន្យល់<br><br>–សម្រួលឱ្យសិស្សកត់ចូលសៀវភៅ<br><br>–បែងចែកសិស្សជា ៦ ក្រុម | **ជំហានទី៣**<br>(មេរៀនប្រចាំថ្ងៃ)<br>**មេរៀនទី៥: ការចូលរួមបោះឆ្នោត**<br><br>**សិក្សាចំណងជើង**<br>–ចង់និយាយពីការចូលរួមជ្រើសរើសអ្នកដឹកនាំណាមួយ។<br><br>**សិក្សារូបភាព**<br>–ឃើញសិស្ស គុ កៅអី ហិប-ឆ្នោត។<br>**ទំនាក់ទំនងរូបភាពនិងចំណងជើង**<br><br>–មាន ព្រោះរូបភាពបង្ហាញពីសកម្មភាពលរួមបោះឆ្នោតជ្រើសរើសតំណាង ឬ អ្នកដឹកនាំ ឯចំណងជើងគឺ "ការចូលរួមបោះឆ្នោត"។<br>(ការចូលរួម......សង្កេតការណ៍។)<br><br>**ពន្យល់ពាក្យ**<br><br>–ព័ត៌មាន (ន): ដំណឹង ផ្សេងៗ។<br><br>–អ្នកសង្កេតការណ៍(ន): អ្នកត្រួតពិនិត្យតាមដាននូវសកម្មភាពផ្សេងៗ ។<br><br>**ពិភាក្សាក្រុម** | –បើកសៀវភៅរួចអានចំណងជើងមេរៀនតាមការណែនាំ<br>–សរសេរចំណងជើងចូលសៀវភៅរៀងៗខ្លួន<br><br>–ចង់បង្ហាញអំពីការចូលរួមការបោះឆ្នោតឬការជ្រើសរើសមេតំណាង។<br><br>–ក្នុងរូបភាពនេះ ឃើញសិស្សប្រុសស្រី គុ កៅអី ហិបឆ្នោត...។<br>–មានទំនាក់ទំគ្នា ព្រោះរូបភាពបង្ហាញពីសកម្មភាពចូលរួមបោះឆ្នោតជ្រើសរើសតំណាង ឬ អ្នកដឹកនាំ ឯចំណងជើងគឺ "ការចូលរួមបោះឆ្នោត"។<br><br>–អានខ្លឹមសារមេរៀនបណ្តាក់គ្នា<br><br>–ឡើងពន្យល់ន័យរបស់ពាក្យ<br><br>–កត់ចូលសៀវភៅទាំងអស់គ្នា<br><br>–ចូលតាមក្រុមពិភាក្សា |

| | | |
|---|---|---|
| ដើម្បីធ្វើការពិភាក្សា៖<br>**-ក្រុមទី១+៤** : តើគណៈកម្មការរៀបចំការបោះឆ្នោតអាចមានសមាសភាគប៉ុន្មានរូប? អ្វីខ្លះ? | -គណៈកម្មការរៀបចំការបោះឆ្នោតមាន ៥រូបគឺ៖<br>• ប្រធាន១រូប<br>• អនុប្រធាន១រូប<br>• លេខាធិការ១រូប<br>• សមាជិក២រូប ។ | -គណៈកម្មការរៀបចំការបោះឆ្នោតមាន ៥រូបគឺ៖<br>• ប្រធាន១រូប<br>• អនុប្រធាន១រូប<br>• លេខាធិការ១រូប<br>• សមាជិក២រូប ។ |
| **-ក្រុមទី២+៥**: តើអ្នកទទួលខុសត្រូវក្នុងការរៀបចំការបោះឆ្នោតមានភារកិច្ចធ្វើអ្វីខ្លះ? | -មានភារកិច្ចដូចជា៖<br>• រៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតនិងធ្វើប័ណ្ណបោះឆ្នោត<br>• រៀបចំបទបញ្ញត្តិនិងសេចក្ដីណែនាំសម្រាប់បោះឆ្នោត<br>• ផ្ដល់ព័ត៌មានអំពីដំណើរការនៃការបោះឆ្នោតនិងកំណត់ពេលវេលានៃការបោះឆ្នោត<br>• ទទួលនិងសម្រេចលើពាក្យសុំឈរឈ្មោះ<br>• រៀបចំដំណើរការបោះឆ្នោតនិងរាប់សន្លឹកឆ្នោត<br>• ដោះស្រាយបណ្ដឹងតវ៉ាក្នុងដំណើរការបោះឆ្នោត។ | -អ្នកទទួលខុសត្រូវក្នុងការៀបចំការបោះឆ្នោតមានភារកិច្ចដូចជា៖<br>• រៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតនិងធ្វើប័ណ្ណបោះឆ្នោត<br>• ធ្វើបទបញ្ញត្តិនិងសេចក្ដីណែនាំសម្រាប់បោះឆ្នោត<br>• ផ្ដល់ព័ត៌មានអំពីដំណើរការនៃការបោះឆ្នោតនិងកំណត់ពេលវេលានៃការបោះឆ្នោត<br>• ទទួលនិងសម្រេចលើពាក្យសុំឈរឈ្មោះ<br>• រៀបចំដំណើរការបោះឆ្នោតនិងរាប់សន្លឹកឆ្នោត<br>• ដោះស្រាយបណ្ដឹងតវ៉ាក្នុងដំណើរការបោះឆ្នោត។ |
| **-ក្រុមទី៣+៦**:<br>តើទីកន្លែងសម្រាប់ការបោះឆ្នោតមាន<br>លក្ខណៈដូចម្ដេច? | -មានលក្ខណៈដូចជា៖<br>• តុ ១សម្រាប់ប្រធានគណៈកម្មការ តុ ១សម្រាប់លេខាធិការនិង អនុប្រធាន<br>• បន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត<br>• សមាជិកម្នាក់ត្រួតពិនិត្យទ្វារបន្ទប់ចេញចូល<br>• តុ ១សម្រាប់អ្នកសង្កេតការណ៍។ | -ទីកន្លែងសម្រាប់ការបោះឆ្នោតមានលក្ខណៈដូចជា៖<br>• តុ ១សម្រាប់ប្រធានគណៈកម្មការ តុ ១សម្រាប់លេខាធិការនិង អនុប្រធាន<br>• បន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត<br>• សមាជិកម្នាក់ត្រួតពិនិត្យទ្វារបន្ទប់ចេញចូល<br>• តុ ១សម្រាប់អ្នកសង្កេតការណ៍។<br>-សិស្សកត់ត្រាចូលសៀវភៅ |

| | | |
|---|---|---|
| -គ្រូសម្រួលចម្លើយឱ្យសិស្សកត់ចូលសៀវភៅ<br>-ឱ្យសិស្សសាកសង្ខេបមេរៀនឡើងវិញ<br><br>-ឱ្យសិស្សកត់ចូលសៀវភៅ | **មេរៀនសង្ខេប**<br>ការរៀបចំការបោះឆ្នោតឱ្យបានសមស្របពិតជាមានសារៈសំខាន់ណាស់ដើម្បីឱ្យការបោះឆ្នោតប្រព្រឹត្តិទៅដោយជោគជ័យ។ គណៈកម្មការរៀបចំការបោះឆ្នោតមានសមាសភាព៥រូប គឺ ប្រធាន១រូប អនុប្រធាន១រូប លេខាធិការ១រូប និងសមាជិក២រូប។ | -សាកសង្ខេបមេរៀន<br><br>-កត់ចូលសៀវភៅ |
| -តើគណៈកម្មការរៀបចំការបោះឆ្នោតមានភារកិច្ចរៀបចំចាត់ចែងដំណើរការបោះឆ្នោតដូចម្តេចខ្លះ? | **ជំហានទី៤**<br>(ពង្រឹងពុទ្ធិ)<br>-មានភារកិច្ចដូចជា៖<br>• ធ្វើបទបញ្ញត្តិនិងសេចក្តីណែនាំ<br>• រៀបចំបញ្ជីឈ្មោះ<br>• ផ្តល់ព័ត៌មានផ្សេងៗ<br>• ទទួលនិងសម្រេចលើពាក្យសុំឈរឈ្មោះ<br>• ពិនិត្យតាមដាននិងរៀបចំដំណើរការបោះឆ្នោត<br>• ប្រកសរុបនិងរាប់សន្លឹកឆ្នោត។ | -មានភារកិច្ចដូចជា៖<br>• ធ្វើបទបញ្ញត្តិនិងសេចក្តីណែនាំ<br>• រៀបចំបញ្ជីឈ្មោះ<br>• ផ្តល់ព័ត៌មានផ្សេងៗ<br>• ទទួលនិងសម្រេចលើពាក្យសុំឈរឈ្មោះ<br>• ពិនិត្យតាមដាននិងរៀបចំដំណើរការបោះឆ្នោត<br>• ប្រកសរុបនិងរាប់សន្លឹកឆ្នោត។ |
| -មេរៀនមិនទាន់ចប់ទេទៅផ្ទះវិញមើលមេរៀននៅចំណុចបន្តនៅទំព័រ ២១០ | **ជំហានទី៥**<br>(បណ្តាំផ្ញើ)<br>3. **ដំណើរការឃោសនារកសំឡេងឆ្នោត**<br>4. **ដំណើរការបោះឆ្នោត** | -សិស្សស្តាប់ដោយយកចិត្តទុកដាក់ |

# កិច្ចតែងការបង្រៀន

- ❖ កាលបរិច្ឆេទ : ថ្ងៃ ទី ខែ ឆ្នាំ
- ❖ មុខវិជ្ជា : សីលធម៌-ពលរដ្ឋវិជ្ជា
- ❖ ថ្នាក់ទី : ៧
- ❖ **ជំពូកទី៤** : **ការរស់នៅជាមួយសហគមន៍**
- ❖ **មេរៀនទី៥** : **ការចូលរួមបោះឆ្នោត** (**តចប់**)
- ❖ វិធីសាស្ត្របង្រៀន : គោលវិធីសិស្សមជ្ឈមណ្ឌល (ពិភាក្សាក្រុម)
- ❖ រយៈពេល : ២ម៉ោងសិក្សា (សម្រាប់ម៉ោងទី២)

I. **វត្ថុបំណង**

- ➢ ចំណេះដឹង : បង្ហាញពីរបៀបនៃការឃោសនារកសំឡេងឆ្នោតបានយ៉ាងត្រឹមត្រូវតាមរយៈការអានខ្លឹមសារមេរៀននិងសំណួរបំផុសរបស់គ្រូ។
- ➢ បំណិន : វិភាគពីរបៀបនៃការឃោសនារកសំឡេងឆ្នោត បានយ៉ាងត្រឹមត្រូវតាមរយៈការពិភាក្សាក្រុម។
- ➢ ឥរិយាបថ : បណ្តុះស្មារតីសិស្សឱ្យមានការចូលរួមក្នុងដំណើរការឃោសនា និងដំណើរការបោះឆ្នោតជ្រើសរើសតំណាងអ្វីមួយនៅក្នុងសហគមន៍ និង ក្នុងសាលារៀន។

II. **ខ្លឹមសារមេរៀន**

3. **ដំណើរការឃោសនារកសំឡេងឆ្នោត**
4. **ដំណើរការបោះឆ្នោត**

III. **សម្ភារឧបទេស**

- សៀវភៅសិស្សទំព័រ ២១០-២១១ បោះពុម្ពឆ្នាំ ២០១០
- ប័ណ្ណសំណួរ
- ផ្ទាំងមេរៀនសង្ខេប

IV. **ដំណើរការបង្រៀន**

| **សកម្មភាពគ្រូ** | **ខ្លឹមសារមេរៀន** | **សកម្មភាពសិស្ស** |
|---|---|---|
| –ពិនិត្យលើ: សណ្ដាប់ធ្នាប់ អនាម័យ អវត្តមាន។ | **ជំហានទី១**<br>(រដ្ឋបាលថ្នាក់)<br>• សណ្ដាប់ធ្នាប់<br>• អនាម័យ<br>• អវត្តមាន<br>• ពង្រឹងវិន័យ។ | –ប្រធានថ្នាក់ឡើងរាយការណ៍។ |
| –តើការពីថ្ងៃមុនយើងបានសិក្សាពីមេរៀនអ្វី?<br><br>–តើគណៈកម្មការរៀបចំការបោះឆ្នោតមានភារកិច្ចរៀបចំចាត់ចែងដំណើរការបោះឆ្នោតយ៉ាងដូចម្ដេចខ្លះ?<br><br>–តើប្អូនធ្លាប់បានឃើញការឃោសនាបោះឆ្នោតដែរឬទេ?<br>–តើអ្វីខ្លះដែលជាការឃោសនារបស់គណៈបក្ស?<br><br>–ដូចនេះយើងបានដឹងខ្លះហើយពីការធ្វើការឃោសនារកសំឡេងឆ្នោត ហើយថ្ងៃនេះយើងនឹងសិក្សាមេរៀនយើងជាបន្ត។ | **ជំហានទី២**<br>(រំឭកមេរៀនចាស់)<br>មេរៀនទី៥:<br>ការចូលរួមបោះឆ្នោត<br>–មានភារកិច្ចដូចជា៖<br>• ធ្វើបទបញ្ញត្តិនិងសេចក្ដីណែនាំផ្សេងៗសម្រាប់ការបោះឆ្នោត<br>• រៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតនិងធ្វើប័ណ្ណបោះឆ្នោត<br>• ត្រួតពិនិត្យភាពមិនប្រក្រតីនៃការបោះឆ្នោត<br>• ពិនិត្យតាមដានការឃោសនាបោះឆ្នោត។<br>**<u>ទំនាក់ទំនងមេរៀនថ្មី</u>**<br>–ធ្លាប / មិនធ្លាប់<br><br>–មានធ្វើក្បួនដង្ហែ ការចែកនិងបិទខិតប័ណ្ណ ការផ្សព្វផ្សាយ ការបិទពាក្យស្លោក...។ | –មានភារកិច្ចដូចជា៖<br>• ធ្វើបទបញ្ញត្តិនិងសេចក្ដីណែនាំផ្សេងៗសម្រាប់ការបោះឆ្នោត<br>• រៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតនិងធ្វើប័ណ្ណបោះឆ្នោត<br>• ត្រួតពិនិត្យភាពមិនប្រក្រតីនៃការបោះឆ្នោត<br>• ពិនិត្យតាមដានការឃោសនាបោះឆ្នោត។<br><br>–ធ្លាប / មិនធ្លាប់<br><br>–មានធ្វើក្បួនដង្ហែ ការចែកនិងបិទខិតប័ណ្ណ ការផ្សព្វផ្សាយ ការបិទពាក្យស្លោកពីគណៈបក្សរបស់គេ ។ |
| | **ជំហានទី៣** | |

| | | |
|---|---|---|
| -គ្រូសរសេរចំណងជើងមេរៀន ដាក់លើក្ដារខៀន<br><br>-ឱ្យសិស្សបើកសៀវភៅទំព័រ ២១០ អានខ្លឹមសារមេរៀន | (មេរៀនប្រចាំថ្ងៃ)<br>**មេរៀនទី៥:**<br>**ការចូលរួមបោះឆ្នោត (តចប់)**<br>3. ដំណើរការឃោសនារកសំឡេងឆ្នោត<br>4. ដំណើរការបោះឆ្នោត | <br><br><br>-សិស្សសរសេរចំណងជើងដាក់ក្នុងសៀវភៅ<br>-សិស្សអានខ្លឹមសារមេរៀនតាមការណែនាំរបស់គ្រូ |
| -គ្រូសរសេរពាក្យពិបាកដាក់លើក្ដារខៀន រួចឱ្យសិស្សឡើងពន្យល់ន័យ | **ពន្យល់ពាក្យ**<br>-ការឃោសនា (ន): ការផ្សព្វផ្សាយជាសាធារណៈដើម្បីឱ្យគេបានដឹងៗ។<br>-ខិតប័ណ្ណ (ន): សំបុត្រដែលគេអាចបោះ ឬចែកផ្សាយដើម្បីឱ្យដឹងដំណឹងអ្វីមួយ។<br>-យុទ្ធនាការ (ន): ការធ្វើសកម្មភាពផ្សេងៗក្នុងគោលបំណងទទួលបាននូវលទ្ធផលមួយជាក់លាក់ពីសាធរណៈជន។ | -សិស្សឡើងពន្យល់ន័យ |
| -គ្រូសម្រួលឱ្យសិស្សកត់ចូលសៀវភៅ | | -សិស្សកត់ចូលសៀវភៅ |
| -គ្រូបែងចែកសិស្សជា៤ក្រុមៈ<br><br>**-ក្រុមទី១**: តើយុទ្ធនាការឃោសនារកសំឡេងឆ្នោតមានគោលបំណងអ្វី?<br><br>**-ក្រុមទី២**: នៅក្នុងយុទ្ធនាការបោះឆ្នោត<br>តើបេក្ខជនឈរឈ្មោះបោះឆ្នោតត្រូវរៀបចំ<br>លក្ខណៈសម្បត្តិអ្វីខ្លះ? | **ពិភាក្សាក្រុម**<br><br>-មានគោលបំណងឱ្យបេក្ខជនឈរឈ្មោះបោះឆ្នោតផ្សព្វផ្សាយកិច្ចការដែលខ្លួនត្រូវធ្វើដល់អ្នកបោះឆ្នោត។<br><br>-មានអធ្យាស្រ័យ អត់ឱន គោរពបទបញ្ញត្តិ មិនគំរាមកំហែងសម្លុតបង្ខិតបង្ខំអ្នកបោះឆ្នោត។ | -សិស្សចូលតាមក្រុមពិភាក្សា<br><br>-យុទ្ធនាការឃោសនារសំឡេងឆ្នោតមានគោលបំណងឱ្យបេក្ខជនឈរឈ្មោះបោះឆ្នោតផ្សព្វផ្សាយកិច្ចការដែលខ្លួនត្រូវធ្វើដល់អ្នកបោះឆ្នោត។<br>-បេក្ខជនឈរឈ្មោះបោះឆ្នោតត្រូវរៀបចំលក្ខណៈសម្បត្តិគឺត្រូវមានអធ្យាស្រ័យ អត់ឱន គោរពបទបញ្ញត្តិ មិនគំរាមកំហែង សម្លុតបង្ខិតបង្ខំអ្នកបោះឆ្នោត។ |

| | | |
|---|---|---|
| -**ក្រុមទី៣**: តើសកម្មភាពឃោសនាបោះឆ្នោតអាចមានអ្វីខ្លះ?<br><br><br><br><br><br><br><br><br><br>-**ក្រុមទី៤**: តើដំណើរការឃោសនាបោះឆ្នោតមានអ្វីខ្លះ?<br><br>-គ្រូសំយោគចម្លើយឱ្យសិស្សកត់ចូលសៀវភៅ<br><br>-គ្រូឱ្យសិស្សទាញមេរៀនសង្ខេប | -សកម្មភាពឃោសនាបោះឆ្នោតអាចមានៈ<br>• ការជួបជុំគ្នាក្រុមតូច ឬធំ<br>• ការបញ្ចុះបញ្ចូលពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត<br>• ការបិទផ្សាយរូបភាព និងពាក្យស្លោក<br>• ការចែកខិតប័ណ្ណ<br>• ការឃោសនាផ្សព្វផ្សាយពីអ្វីដែលខ្លួនត្រូវធ្វើក្រោយពីបានជាប់ឆ្នោត។ល។<br><br>-ដំណើរការឃោសនាបោះឆ្នោតមានការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និតការប្រកាសលទ្ធផលឆ្នោត។<br><br>**មេរៀនសង្ខេប**<br><br>នៅពេលជិតបោះឆ្នោត គណៈបក្សទាំងអស់មានសិទ្ធិធ្វើការឃោសនាបោះឆ្នោត ដើម្បីរកសំឡេងឆ្នោតដែលមានរូបភាពជាច្រើន។<br>ដំណើរការនៃការបោះឆ្នោត មានការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលបោះឆ្នោត។ | -សកម្មភាពឃោសនាបោះឆ្នោតអាចមានៈ<br>• ការជួបជុំគ្នាក្រុមតូច ឬធំ<br>• ការបញ្ចុះបញ្ចូលពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត<br>• ការបិទផ្សាយរូបភាព និងពាក្យស្លោក<br>• ការចែកខិតប័ណ្ណ<br>• ការឃោសនាផ្សព្វផ្សាយពីអ្វីដែលខ្លួនត្រូវធ្វើក្រោយពីបានជាប់ឆ្នោត។ល។<br><br>-ដំណើរការឃោសនាបោះឆ្នោតមាន ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និតការប្រកាសលទ្ធផលឆ្នោត។<br>-សិស្សកត់ចូលសៀវភៅ<br><br>-សិស្សទាញមេរៀនសង្ខេប |
| <br><br>-តើសកម្មភាពឃោសនាបោះឆ្នោតអាចមានអ្វីខ្លះ? | **ជំហានទី៤**<br>(ពង្រឹងពុទ្ធិ)<br>-សកម្មភាពឃោសនាបោះឆ្នោតអាចមាន ៖<br>• ការជួបជុំគ្នាក្រុមតូច ឬធំ | <br><br>សកម្មភាពឃោសនាបោះឆ្នោតអាចមានៈ<br>• ការជួបជុំគ្នាក្រុមតូច ឬធំ |

| | | |
|---|---|---|
| <br><br><br><br><br><br><br><br><br>–តើដំណើរការឃោសនាបោះឆ្នោតមានអ្វីខ្លះ? | • ការបញ្ចុះបញ្ចូលពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត<br>• ការបិទផ្សាយរូបភាព និងពាក្យស្លោក<br>• ការចែកខិតប័ណ្ណ<br>• ការឃោសនាផ្សព្វផ្សាយពីអ្វីដែលខ្លួនត្រូវធ្វើក្រោយពីបានជាប់ឆ្នោត។ល។<br><br>–ដំណើរការឃោសនាបោះឆ្នោតមានការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និតការប្រកាសលទ្ធផលឆ្នោត។ | • ការបញ្ចុះបញ្ចូលពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត<br>• ការបិទផ្សាយរូបភាព និងពាក្យស្លោក<br>• ការចែកខិតប័ណ្ណ<br>• ការឃោសនាផ្សព្វផ្សាយពីអ្វីដែលខ្លួនត្រូវធ្វើក្រោយពីបានជាប់ឆ្នោត។ល។<br><br>–ដំណើរការឃោសនាបោះឆ្នោតមាន ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និតការប្រកាសលទ្ធផលឆ្នោត។ |
| <br><br>–ពេលទៅផ្ទះវិញប្អូនត្រូវមើលមេរៀនឡើងវិញ និងមេរៀនបន្តផង។<br>–កុំភ្លេចជួយធ្វើការងារឪពុកម្តាយផងណា។ | **ជំហានទី៥**<br>(បណ្តាំផ្ញើ)<br>មេរៀនទី៦:<br>លក្ខណៈសម្បត្តិនៃអ្នកជាប់ឆ្នោត | <br><br>–សិស្សស្តាប់តាមការណែនាំរបស់គ្រូដោយយកចិត្តទុកដាក់ និង ត្រៀមអនុវត្តតាម។ |

# កិច្ចតែងការបង្រៀន

- កាលបរិច្ឆេទ : ថ្ងៃ ទី ខែ ឆ្នាំ
- មុខវិជ្ជា : សីលធម៌ ពលរដ្ឋវិជ្ជា
- ថ្នាក់ : ៧
- **មេរៀនទី៦ : លក្ខណៈសម្បត្តិនៃអ្នកជាប់ឆ្នោត**
- វិធីសាស្ត្រ : គោលវិធីសិស្សមជ្ឈមណ្ឌល
- រយៈពេល : ១ម៉ោងសិក្សា

## I. **វត្ថុបំណង**

- ចំណេះដឹង : សិស្សបង្ហាញពីការវាយតម្លៃអំពីរបៀបរៀបរយក្នុងពេល បោះឆ្នោត និងពេលរាប់សន្លឹកឆ្នោត បានត្រឹមត្រូវតាមរយៈ ខ្លឹមសារមេរៀន និង សំណួរបំផុសរបស់គ្រូ ។
- បំណិន : សិស្សបកស្រាយការវាយតម្លៃលក្ខណៈសម្បត្តិរបស់អ្នក ជាប់ឆ្នោត ហេតុអ្វីបានជាបេក្ខជននោះត្រូវបានបោះឆ្នោត ជ្រើសរើស តាមរយៈការពិភាក្សាក្រុម ។
- ឥរិយាបថ : បណ្ដុះស្មារតីសិស្សអោយផ្ដល់ការទុកចិត្តចំពោះអ្នកជាប់ ឆ្នោត ។

## II. **សម្ភារឧបទេស**

- សៀវភៅសិស្សទំព័រ ២១២ -២១៣
- ប័ណ្ណសំណួរ
- ផ្ទាំងមេរៀនសង្ខេប

## III. **ខ្លឹមសារមេរៀន**

1. **ការវាយតម្លៃក្នុងពេលបោះឆ្នោត**
2. **ការវាយតម្លៃក្នុងពេលរាប់សន្លឹកឆ្នោត**
3. **លក្ខណៈសម្បត្តិនៃអ្នកជាប់ឆ្នោត**

IV. **ដំណើរការបង្រៀន**

| **សកម្មភាពគ្រូ** | **ខ្លឹមសារមេរៀន** | **សកម្មភាពសិស្ស** |
|---|---|---|
| - ពិនិត្យអវត្តមាន អនាម័យ សណ្តាប់ធ្នាប់ ។ | **ជំហានទី១**<br>(រដ្ឋបាលថ្នាក់រៀន) | - ប្រធានថ្នាក់ឡើងរាយការណ៍។ |
| - តើថ្ងៃមុនយើងបានរៀន មេរៀនអ្វី?<br>-តើគណកម្មាការរៀបចំការបោះ ឆ្នោតមានភារកិច្ចដូចម្តេចខ្លះ?<br><br><br><br><br><br><br><br><br><br><br><br><br><br>-មុខពេលបោះឆ្នោតតើប្អូនគិតទៅលើអ្វីខ្លះចំពោះបេក្ខជនដែលប្អូនពេញចិត្ត ?<br>-តើប្អូនពេញចិត្តអ្នកដឹកនាំដែលមានលក្ខណៈសម្បត្តិបែបណា ? | **ជំហានទី២**<br>(រំលឹកមេរៀនចាស់)<br>- ការចូលរួមបោះឆ្នោត<br><br>- មានភារកិច្ច<br>+ធ្វើបទបញ្ញាតិ និងសេចក្តីណែនាំ<br>+រៀបចំបញ្ជីឈ្មោះ និងធ្វើបណ្ណបោះឆ្នោត<br>+ផ្តល់ព័ត៌មានផ្សេងៗពីការបោះឆ្នោត<br>+ទទួល និងសម្រេចលើពាក្យសុំឈរឈ្មោះបោះឆ្នោត<br>+ពិនិត្យតាមដានការឃោសនាបោះឆ្នោត<br>+រៀបចំដំណើរការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផល និងការប្រកាសលទ្ធផល<br>+ដោះស្រាយបណ្តឹងតវាទាក់ទងនឹងការបោះឆ្នោត<br>+ត្រួតពិនិត្យសកម្មភាពមិនប្រក្រតីនៃការបោះឆ្នោត។<br><br>**<u>ទំនាក់ទំនងមេរៀនថ្មី</u>**<br>-គិតទៅលើលក្ខណៈសម្បត្តិ<br><br><br>-មានសមត្ថភាព មានចំណេះដឹង មានបទពិសោធន៍ --- ។ | <br><br><br><br>- មានភារកិច្ច<br>+ធ្វើបទបញ្ញាតិ និងសេចក្តីណែនាំ<br>+រៀបចំបញ្ជីឈ្មោះនិងធ្វើបណ្ណបោះឆ្នោត<br>+ផ្តល់ព័ត៌មានផ្សេងៗពីការបោះឆ្នោត<br>+ទទួល និងសម្រេចលើពាក្យសុំឈរឈ្មោះបោះឆ្នោត<br>+ពិនិត្យតាមដានការឃោសនាបោះឆ្នោត<br>+រៀបចំដំណើរការបោះឆ្នោត ការរាប់ សន្លឹកឆ្នោតការបូកសរុបលទ្ធផលនិងការប្រកាសលទ្ធផល<br>+ដោះស្រាយបណ្តឹងតវាទាក់ទងនឹងការបោះឆ្នោត<br>+ត្រួតពិនិត្យសកម្មភាពមិនប្រក្រតីនៃ ការបោះឆ្នោត។<br><br>-គិតទៅលើលក្ខណៈសម្បត្តិ<br><br><br>-មានសមត្ថភាព ចំណេះដឹង មានបទពិសោធន៍ --- ។ |

| | | |
|---|---|---|
| -អោយសិស្សបើកសៀវភៅទំព័រ២១២ហើយអានចំណងជើង<br>-តើចំណងជើងមានន័យដូចម្តេច ?<br><br>-អោយសិស្សអានមេរៀនចាប់ពីទំព័រ២១២ដល់២១៣<br><br><br><br>-សរសេពន្យល់ពាក្យដាក់លើក្តាខៀន<br><br>-ចែកសិស្សជា៣ក្រុម<br>• ក្រុមទី១: តើការបោះឆ្នោតត្រឹមត្រូវមានលក្ខណ:ដូចម្តេច ?<br><br><br><br><br><br><br><br><br><br><br>• ក្រុមទី២: តើការរាប់សន្លឹកឆ្នោតធ្វើឡើងដូចម្តេច? | **ជំហានទី៣**<br>(មេរៀនប្រចាំថ្ងៃ)<br>**មេរៀនទី៦**<br>**លក្ខណៈសម្បត្តិនៃអ្នកជាប់ឆ្នោត**<br><br>-លក្ខណ:សម្បត្តិល្អរបស់អ្នកដឹកនាំ ដែលទទួលបានសម្លេងឆ្នោតច្រើន ។<br>-ខ្លឹមសារមេរៀននៅទំព័រ ២១២ ដល់ ២១៣<br><u>ពន្យល់ពាក្យ</u><br>-ឥទ្ធិពល=អំណាច<br>-ឆន្ទ:    =គោលបំណង<br>-វិនិច្ឆ័យ =ការត្រិះរិះពិចារណា<br><br><br><u>ពិភាក្សាក្រុម</u><br><br>• ការបោះឆ្នោតត្រឹមត្រូវគឺ ៖<br>-អ្នកបោះឆ្នោតម្នាក់មានសិទ្ធិបោះឆ្នោតតែមួយសន្លឹកតែម្តងគត់បោះដោយខ្លួនឯងផ្ទាល់ ហើយសម្ងាត់។<br>-អ្នកបោះឆ្នោតសេរីភាពក្នុងការបង្ខិតបង្ខំ គំរាម លួងលោម ការបន្លំការរារាំង ។<br>-អ្នកបោះឆ្នោតបានគោរពតាមបទបញ្ជានៃការបោះឆ្នោត ដើម្បីរក្សាសណ្តាប់ធ្នាប់ និង របៀបរៀបរយ ។<br>-មានបេក្ខជន ច្រើនចូលរួមក្នុងការប្រកួតប្រជែងឈរឈ្មោះ ។<br><br><br>• ការរាប់សន្លឹកឆ្នោតត្រឹមត្រូវគឺ ៖<br>-រាប់នៅតាមវិធីមួយដែលឮនិងមើលឃើញច្បាស់គំនូសនៃការបោះឆ្នោត | -បើកសៀវភៅហើយអានចំណងជើង<br><br><br>-លក្ខណ:សម្បត្តិរបស់អ្នកដឹកនាំដែលទទួលបានសម្លេងគាំទ្រច្រើន<br><br><br><br><br><br><br><br><br><br>• ការបោះឆ្នោតត្រឹមត្រូវគឺ ៖<br>-អ្នកបោះឆ្នោតម្នាក់មានសិទ្ធិបោះឆ្នោតតែមួយសន្លឹកតែម្តងគត់បោះដោយខ្លួនឯងផ្ទាល់ហើយសម្ងាត់។<br>-អ្នកបោះឆ្នោតសេរីភាពក្នុងការបង្ខិតបង្ខំ គំរាម លួងលោម ការបន្លំការរារាំង ។<br>-អ្នកបោះឆ្នោតបានគោរពតាមបទបញ្ជានៃការបោះឆ្នោត ដើម្បីរក្សាសណ្តាប់ធ្នាប់ និងរបៀបរៀបរយ ។<br>-មានបេក្ខជន ច្រើនចូលរួមក្នុងការប្រកួតប្រជែងឈរឈ្មោះ ។<br>• ការរាប់សន្លឹកឆ្នោតត្រឹមត្រូវគឺ ៖<br>-រាប់នៅតាមវិធីមួយដែលឮនិងមើលឃើញច្បាស់គំនូសនៃការ |

| | | |
|---|---|---|
| • ក្រុមទី៣: តើលក្ខណ:សម្បត្តិនៃអ្នកជាប់ឆ្នោតមានអ្វីខ្លះ ?<br><br>-សំយោគចម្លើយឲ្យសិស្សកត់<br><br>-សាកល្បងទាញមេរៀនសង្ខេប | ទាំងអស់ ដោយអ្នកតាមដាននិង អ្នកសង្កេតការណ៍ ។<br>-ចំនួនសន្លឹកឆ្នោតក្នុងហិបត្រូវមានចំនួនស្មើគ្នា និង ចំនួនអ្នកដែលបានបោះឆ្នោត ដែលរាប់ឃើញក្នុងបញ្ជីបោះឆ្នោត ។<br>-មុននិងរាប់សន្លឹកឆ្នោតត្រូវពិនិត្យហិបឆ្នោត តើមានលួចដូរឬទេ។<br><br>• លក្ខណ:សម្បត្តិនៃអ្នកជាប់ឆ្នោតមានដូចជា ៖<br>-សមត្ថភាព ចំណេះដឹង បទពិសោធន៍ និង សុខភាពល្អ គ្មានជំងឺ មានភាពស្វាហាប់<br>-មានសីលធម៌ សុជីវធម៌មុឺងម៉ាត់ អត្តចរិតស្លូតបូត ក្លាហាន ស្មោះត្រង់ចេះជួយទុកលំបាកអ្នកដទៃ មានគំនិតច្នៃប្រឌិត តស៊ូក្នុងការលំបាក អត់ធ្មត់ ព្យាយាម គិតផលប្រយោជន៍រួមជាធំជាងផលប្រយោជន៍ផ្ទាល់ខ្លួនពិសេសគោរព និង អនុវត្តតាមច្បាប់របស់សង្គម ។<br><br>**<u>មេរៀនសង្ខេប</u>**<br>ការបោះឆ្នោតដែលមានលក្ខណ:សេរី និង ត្រឹមត្រូវគឺ តាមឆន្ទ:របស់ខ្លួន ដោយគ្មានការរារាំង បង្ខិតបង្ខំ និង មានសេរីភាពបញ្ចេញមតិ ដើម្បីពិភាក្សា វិនិច្ឆ័យទៅលើ បេក្ខជនដែលឈរឈ្មោះបោះឆ្នោតការរាប់សន្លឹកឆ្នោតត្រឹមត្រូវ និង អាចជឿទុកចិត្ត គឺរាប់តាមវិធីលឺ និង មើលឃើញគំនូសច្បាស់។ លក្ខណ:សម្បត្តិនៃបេក្ខជន | បោះឆ្នោតទាំងអស់ ដោយអ្នកតាមដាននិង អ្នកសង្កេតការណ៍ ។<br>-ចំនួនសន្លឹកឆ្នោតក្នុងហិបត្រូវមានចំនួនស្មើគ្នា និង ចំនួនអ្នកដែលបានបោះឆ្នោត ដែលរាប់ឃើញក្នុងបញ្ជីបោះឆ្នោត ។<br>-មុននិងរាប់សន្លឹកឆ្នោតត្រូវពិនិត្យហិបឆ្នោត តើមានលួចដូរឬទេ។<br><br>• លក្ខណ:សម្បត្តិនៃអ្នកជាប់ឆ្នោតមានដូចជា ៖<br>-សមត្ថភាព ចំណេះដឹង បទពិសោធន៍ និង សុខភាពល្អ គ្មានជំងឺ មានភាពស្វាហាប់<br>-មានសីលធម៌ សុជីវធម៌មុឺងម៉ាត់ អត្តចរិតស្លូតបូត ក្លាហាន ស្មោះត្រង់ចេះជួយទុកលំបាកអ្នកដទៃ មានគំនិតតច្នៃប្រឌិត តស៊ូក្នុងការលំបាក អត់ធ្មត់ ព្យាយាមគិតផលប្រយោជន៍រួមជាធំជាងផលប្រយោជន៍ផ្ទាល់ខ្លួនពិសេសគោរព និង អនុវត្តតាមច្បាប់របស់ង្គម ។<br>-កត់ត្រាចូលសៀវភៅ<br><br>-សាកល្បងទាញមេរៀនសង្ខេប |

| | | |
|---|---|---|
| | ត្រូវជាប់ឆ្នោតគឺ មានសមត្ថភាព សុខភាពល្អ និង មានគុណធម៌ ។ | |
| • ក្រុមទី៣: តើលក្ខណ:សម្បត្តិនៃអ្នកជាប់ឆ្នោតមានអ្វីខ្លះ ? | **ជំហានទី៤**<br>(ពង្រឹងពុទ្ធិ)<br>-លក្ខណ:សម្បត្តិអ្នកជាប់ឆ្នោតត្រូវមានៈ សមត្ថភាពចំណេះបទពិសោធន៍ សុខភាពល្អ ស្វាហាប់ សីលធម៌ សុជីវធម៌ អត្តចរិកស្លូតបូត ម៉ឹងម៉ាត់ ក្លាហាន ស្មោះត្រង់ ចេះជួយទុក្ខលំបាក អ្នកដទៃមានគំនិតច្នៃប្រឌិត តស៊ូ អត់ធ្មត់ ព្យាយាម គិតផលប្រយោជន៍រួមជាធំ គោរព និង អនុវត្តច្បាប់សង្គម។ | -លក្ខណ:សម្បត្តិអ្នកជាប់ឆ្នោតត្រូវមានៈសមត្ថភាពចំណេះបទពិសោធន៍ សុខភាពល្អ ស្វាហាប់ សីលធម៌ សុជីវធម៌ អត្តចរិកស្លូតបូត ម៉ឹងម៉ាត់ ក្លាហាន ស្មោះត្រង់ចេះជួយទុក្ខលំបាក អ្នកដទៃមានគំនិតច្នៃប្រឌិត តស៊ូ អត់ធ្មត់ ព្យាយាម គិតផលប្រយោជន៍រួមជាធំគោរព និង អនុវត្តច្បាប់សង្គម។ |
| -ពេលទៅផ្ទះវិញប្អូនត្រូវធ្វើសំណួរទាំង៤នៅខាងក្រោមមេរៀននេះផង ហើយកុំភ្លេចជួយធ្វើការងារឪពុកម្តាយផងណា កុំដើរលេងច្រើនពេក ។ | **ជំហានទី៥**<br>(បណ្តាំផ្ញើ និងកិច្ចការផ្ទះ) | -ស្តាប់យ៉ាងយកចិត្តទុកដាក់ និង ធ្វើតាមការណែនាំ |

# កិច្ចតែងការបង្រៀន

- - កាលបរិច្ឆេទ : ថ្ងៃ ទី ខែ ឆ្នាំ
- - មុខវិជ្ជា : សីលធម៌ . ពលរដ្ឋវិជ្ជា
- - ថ្នាក់ទី : ៧
- - **ជំពូកទី៥** : **ការកំណត់គោលដៅសំរាប់ជីវិត**
- - **មេរៀនទី២** : **សារៈសំខាន់នៃការជ្រើសរើសអាជីព**
- - វិធីសាស្រ្តបង្រៀន : គោលវិធីសិស្សមជ្ឈមណ្ឌល
- - រយៈពេលបង្រៀន : ១ម៉ោងសិក្សា

## I. វត្ថុបំណង

- ចំណេះដឹង : រៀបរាប់ពីសារៈសំខាន់នៃការជ្រើសរើសអាជីពបានយ៉ាងត្រឹមត្រូវតាមរយៈខ្លឹមសារមេរៀននិងការពន្យល់របស់គ្រូ ។
- បំណិន : បង្ហាញពីសារៈសំខាន់នៃការកំណត់ជ្រើសរើសអាជីពសំរាប់ខ្លួននាពេលអនាគតបានយ៉ាងត្រឹមត្រូវតាមរយៈការពិភាក្សាក្រុម ។
- -ឥរិយាបថ : បណ្តុះស្មារតីសិស្សឲ្យយកចិត្តទុកដាក់ខិតខំព្យាយាមរៀនសូត្រដើម្បីសំរេចគោលបំណងរបស់ខ្លួន និងទទួលបានជោគជ័យនៅក្នុងជីវិត ។

## II. ខ្លឹមសារមេរៀន

- **សារៈសំខាន់នៃការជ្រើសរើសអាជីព**

## III. សម្ភារឧបទេស

- សៀវភៅសិស្សទំព័រ ២១៦-២១៧ បោះពុម្ពឆ្នាំ ២០១០; រូបភាព

- ប័ណ្ណសំណួរ ; សង្ខេបមេរៀន

## IV. ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| - គ្រូតពិនិត្យ ៖ អនាម័យ<br>អវត្តមាន<br>សណ្ដាប់ធ្នាប់ | **ជំហានទី ១**<br>( រដ្ឋបាលថ្នាក់) | - ប្រធានថ្នាក់ឡើង<br>រាយការណ៍ |
| -តើកាលពីម៉ោងមុនសិក្សាពីមេរៀនអ្វី ?<br>-ដើម្បីជ្រើសរើសអាជីព ឬ មុខរបរឲ្យបានល្អប្រសើរសំរាប់អនាគតរបស់ខ្លួនម្នាក់ៗត្រូវពិចារណាទៅលើចំនុចអ្វីខ្លះ?<br>-តើការជ្រើសរើសអាជីពមានសារៈសំខាន់ដែរឬទេ ? | **ជំហានទី ២**<br>(រំលឹកមេរៀនចាស់)<br>**មេរៀនទី១ៈ**<br>**ការជ្រើសរើសអាជីព**<br>-ពិចារណាលើ ៖<br>១.សមត្ថភាពលើវិជ្ជាជីវៈ<br>២.ចំណង់ចំណូលចិត្ត<br>៣.ប្រភពធនធាន<br>៤.ច្បាប់សង្គម<br>៥.តំរូវការទីផ្សារពលកម្ម<br>ទំនាក់ទំនងមេរៀនថ្មី<br>- មាន ឬ គ្មាន | -ពិចារណាលើ៖<br>១.សមត្ថភាពវិជ្ជាជីវៈ<br>២.ចំណង់ចំណូលចិត្ត<br>៣.ប្រភពធនធាន<br>៤.ច្បាប់សង្គម<br>៥.តំរូវការទីផ្សារពលកម្ម<br>- មាន ឬ គ្មាន |
| -ឲ្យសិស្សបើកសៀវភៅទំព័រ ២២០ អានចំណងជើងមេរៀន<br>-តើចំណងជើងនេះមានន័យដូចម្ដេច?<br>- ឲ្យសិស្សអានខ្លឹមសារមេរៀន<br>- គ្រូកត់ពន្យល់ពាក្យដាក់លើក្ដារខៀនហើយឲ្យសិស្សឡើងពន្យល់<br>-គ្រូសំយោគនិងទុកពេលឲ្យសិស្សកត់ត្រា | **ជំហានទី៣**<br>(មេរៀនប្រចាំថ្ងៃ)<br>**មេរៀនទី២ ៖ សារៈសំខាន់នៃការជ្រើសរើសអាជីព**<br>-អត្ថប្រយោជន៍នៃការជ្រើសរើសការងារ ឬ មុខរបរអ្វីមួយដើម្បីចិញ្ចឹមជីវិត ។<br>ខ្លឹមសារនៅទំព័រ២២០-២២១<br>**ពន្យល់ពាក្យ**<br>-អាជីព (ន) មុខរបរ. ការងារជំនាញ ។<br>-វិចិត្រករ  (ន) ជាងគំនូរ ។ | -អានដោយយកចិត្តទុកដាក់<br>-សិស្សឡើងពន្យល់<br>-ស្ដាប់ហើយកត់ត្រា |

| | | |
|---|---|---|
| - គ្រូចែកសិស្សជា៤ក្រុមពិភាក្សា | <u>**ពិភាក្សាក្រុម**</u> | |
| ១. ដើម្បីកំណត់ទិសដៅនៃជីវិតមួយឲ្យមានភាពត្រចះត្រចង់តើអ្នកត្រូវធ្វើដូចម្តេច? | -ត្រូវចេះសង្កេតពិចារណា<br>អត់ធ្មត់ ពុះពាររាល់ការលំ<br>បាក ដើម្បីឈោងចាប់ឲ្យ<br>បានអ្វីដែលគេប្រាថ្នា ។ | -ចេះសង្កេតពិចារណា<br>អត់ធ្មត់ ពុះពាររាល់ការ<br>លំបាក |
| ២. តើការកំណត់ជ្រើសរើសអាជីពជាមុនសម្រាប់អនាគត់របស់ខ្លួនមានសារៈសំខាន់ដូចម្តេចខ្លះ ? | -មានសារៈសំខាន់ដូចជា ៖<br>+ជម្រុញឲ្យគេខិតខំរៀនសូត្រ<br>+ស្វែងរកព័ត៌មានដែលទាក់<br>ទងនិងអាជីពរបស់ខ្លួនបាន<br>ច្រើន<br>+មានការត្រៀមលក្ខណៈកាន់<br>តែប្រសើរ | -ខិតខំរៀនសូត្រ<br>-ស្វែងរកព័ត៌មានដែល<br>ទាក់ទងនិងអាជីព<br>-មានការត្រៀមលក្ខណៈ<br>ទុកជាមុន |
| ៣.តើការកំណត់ជ្រើសរើសអាជីពបានល្អប្រសើរត្រូវស្របទៅនិងលក្ខខណ្ឌអ្វីខ្លះ ? | -ស្របនិងលក្ខណៈដូចជា ៖<br>ចំណង់ចំណង់ចំណូលចិត្ត<br>សមត្ថភាព និង ធនធាន ។ | -ចំណង់ចំណូលចិត្ត<br>សមត្ថភាព និង ធនធាន |
| ៤.តើការសំរេចចិត្តជ្រើសរើសអាជីពតាមគំនិតអ្នកដទៃផ្តល់នូវគុណវិបត្តិអ្វីខ្លះ ? | -គុណវិបត្តគឺ ៖<br>+គ្មានគោលដៅច្បាស់លាស់<br>+គ្មានភាពប្រាកដនៅក្នុងខ្លួន<br>+គ្មានភាពជឿជាក់<br>+ប្រឈមនិងការបាត់បង់អាជីព | -គុណវិបត្តិ ៖<br>+គ្មានគោលដៅច្បាស់<br>លាស់<br>+គ្មានភាពប្រាកដ<br>+គ្មានភាពជឿជាក់<br>+ប្រឈមនិងការបាត់<br>បង់អាជីព ។ |
| -គ្រូសំយោគនិងឲ្យសិស្សកត់ត្រា | | -ស្តាប់ ហើយ កត់ត្រា |
| -ឲ្យសិស្សទាញមេរៀនសង្ខេប | <u>**មេរៀនសង្ខេប**</u><br>ការកំណត់ជ្រើសរើសអាជីព<br>ជាមុននិងមានភាពប្រាកដប្រជា<br>និងជម្រុញឲ្យគេខិតខំព្យាយាម<br>សិក្សាស្វែងរកព័ត៌មានផ្សេងៗ | -សិស្សសាកល្បងទាញមេរៀន<br>សង្ខេប |

| | | |
|---|---|---|
| -គ្រូសំយោគនិងឲ្យសិស្សកត់ត្រា | ទាក់ទងនិងគោលបំណងអាជីពរបស់គេបានច្រើន និង ត្រៀមលក្ខណៈ កាន់តែប្រសើរដែលជាហេតុធ្វើឲ្យចំណេញពេលវេលាទ្រព្យសម្បត្តិ និងមានអាជីព ។ | -ស្តាប់ និងកត់ត្រា ។ |
| -តើការកំណត់ជ្រើសរើសអាជីពបានល្អប្រសើរត្រូវស្រប និងលក្ខខ័ណ្ឌអ្វីខ្លះ ។<br>-តើការជ្រើសរើសអាជីពតាមគំនិតរបស់អ្នកដ៏ទៃល្អសំរាប់អ្នកដែរឬទេ?ព្រោះអ្វី? | **ជំហានទី៤**<br>(ពង្រឹងពុទ្ធិ)<br>-ស្រប និង ចំណង់ចំណូលចិត្ត សមត្ថភាព និង ធនធានជាដើម<br>-មិនល្អទេព្រោះយើងគ្មានភាពជឿជាក់ ហើយប្រឈមនិងការបាត់បង់អាជីព។ | -ស្របនិងចំណង់ចំណូល ចិត្ត សមត្ថភាព និង ធនធាន<br>-មិនល្អទេព្រោះយើងគ្មានភាពជឿជាក់ ហើយប្រឈម និងការបាត់បង់អាជីព។ |
| - **សំណួរ** | **ជំហានទី៥**<br>(បណ្តាំផ្ញើ ឬ កិច្ចការផ្ទះ)<br>ចូរអ្នកធ្វើការប្រៀបធៀបចំពោះអ្នកដែលបានកំណត់ការជ្រើសរើស អាជីពនិងអ្នកដែលមិនបានកំណត់ជ្រើសរើសអាជីពជាមុននៅពេលសិក្សា ។ | -កត់សំណួរយកទៅស្រាវជ្រាវបន្ថែមនៅផ្ទះ។ |

# កិច្ចតែងការបង្រៀន

- កាលបរិច្ឆេទ : ថ្ងៃ ទី ខែ ឆ្នាំ
- មុខវិជ្ជា : សីលធម៌-ពលរដ្ឋវិជ្ជា
- ថ្នាក់ទី : ៧
- **ជំពូកទី៥** : **ការកំណត់គោលដៅសំរាប់ជីវិត**
- **មេរៀនទី៣** : **ពត៌មានអំពីអាជីព**
- វិធីសាស្ត្របង្រៀន : គោលវិធីសិស្សមជ្ឈមណ្ឌល
- រយៈពេលបង្រៀន : ២ ម៉ោងសិក្សា (សំរាប់ម៉ោងទី ១)

## I. <u>**វត្ថុបំណង**</u>

- ចំណេះដឹង : រៀប់រាប់បានពីប្រភេទ និង អត្ថប្រយោជន៍នៃអាជីពបានយ៉ាងត្រឹមត្រូវតាមរយៈខ្លឹមសារមេរៀន និងការពន្យល់របស់គ្រូ ។
- បំណិន : បង្ហាញបានពីប្រភេទក៏ដូចជាអត្ថប្រយោជន៍នៃអាជីពបានត្រឹមត្រូវតាមរយៈការពិភាក្សាក្រុម។
- ឥរិយាបថ : បណ្តុះស្មារតីសិស្សឲ្យស្គាល់ពីប្រភេទការងារក៏ដូចជាផលប្រយោជន៍នៃការងារដើម្បីងាយស្រួលក្នុងការជ្រើសរើសយកមកអនុវត្តន៍ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ។

## II. **ខ្លឹមសារមេរៀន**

### ១. ប្រភេទអាជីព

### ២. អត្ថប្រយោជន៍នៃអាជីព

## III. **សម្ភារឧបទេស**

- សៀវភៅសិស្សទំព័រ ២២២-២២៣ បោះពុម្ពឆ្នាំ ២០១០
- បណ្ណសំណួរ ; សង្ខេបមេរៀន

## IV. ដំណើរការបង្រៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| - គ្រូតពិនិត្យ ៖ អនាម័យ<br>អវត្តមាន<br>សណ្តាប់ធ្នាប់ | **ជំហានទី ១**<br>( រដ្ឋបាលថ្នាក់) | - ប្រធានថ្នាក់ឡើងរាយការណ៍ |
| -តើកាលពីម៉ោងមុនសិក្សាពីមេរៀនអ្វី ?<br><br>-តើមូលហេតុអ្វីបានជាយើងចាំបាច់ជ្រើសរើសអាជីព ?<br><br>-<br>ដើម្បីជ្រើសរើសអាជីពមួយតើប្អូនត្រូវដឹងពីអ្វីអំពីអាជីពនោះ ? | **ជំហានទី ២**<br>(កែកិច្ចតែងការចាស់ ឬ រំលឹកមេរៀនចាស់)<br>**មេរៀនទី២ សារៈសំខាន់ការជ្រើសរើសអាជីព**<br><br>-ព្រោះដើម្បីស្វែងរកកំរៃផ្គត់ផ្គង់ជីវភាពគ្រួសារដើម្បីភាព ថ្លៃថ្នូរនិង ភាពសុខស្រួល ។<br><br><u>ទំនាក់ទំនងមេរៀនថ្មី</u><br>-ត្រូវដឹងពីពត៌មានផ្សេងៗដែលទាក់ទងនឹងអាជីព ។ | -ព្រោះដើម្បីស្វែងរកកំរៃ ផ្គត់ផ្គង់ជីវភាពគ្រួសារ ដើម្បី ភាពថ្លៃថ្នូរនិងភាពសុខស្រួល ។<br><br>-ត្រូវដឹងពីពត៌មានផ្សេងៗដែលទាក់ទងនិងអាជីព ។ |
| -ឲ្យសិស្សបើកសៀវភៅទំព័រ ២២២ អានចំណងជើងមេរៀន<br><br>-តើចំណងជើងនេះមានន័យដូចម្តេច?<br><br>-តើរូបភាពនិងចំណងជើងមានទំនាក់ទំនងគ្នាឬទេ ? | **ជំហានទី៣**<br>(មេរៀនប្រចាំថ្ងៃ)<br>**មេរៀនទី៣**<br>**ព័ត៌មានអំពីអាជីព**<br>-ព័ត៌មានផ្សេងៗដែលទាក់ទងអាជីពឬក៏ការងារនោះ។<br><br>-អំពីព័ត៌មានឬរបាយការណ៍ផ្សេងៗនៃការងារអ្វីមួយឯរូបភាពបង្ហាញពីប្រភេទឬក៏ទំរង់នៃការងារនីមួយៗ<br><br>-នៅទំព័រ ២២២-២២៣ | -ព័ត៌មានផ្សេងៗដែលទាក់ទងអាជីពឬក៏ការងារនោះ។<br><br>មានព្រោះចំណងជើងនិយាយពីពត៌មានឬរបាយការណ៍ផ្សេងៗនៃការងារអ្វីមួយឯរូបភាពបង្ហាញពីប្រភេទឬក៏ទំរង់នៃការងារនីមួយៗ |

| | | |
|---|---|---|
| -ឲ្យសិស្សអានមេរៀន | | -អានខ្លឹមសារនៅទំព័រ<br>២២២-២២៣ |
| | <u>ពន្យល់ពាក្យ</u> | |
| -គ្រូសរសេរពាក្យពិបាកលើក្តារខៀនហើយឲ្យសិស្សឡើងបកស្រាយឬពន្យល់នៅលើក្តារខៀន។ | -ទេពកោសល្យ (ន) ភាពប៉ិនប្រសប់ដែលមានពីកំណើត ។<br>-គណនេយ្យករ (ន) អ្នកគិតលុយ ។<br>-ក្រឡាបញ្ជី (ន) អ្នកកត់ត្រារឿងក្តីនៅក្នុងតុលាការ ។ | |
| -គ្រូសំយោគនិងឲ្យសិស្សកត់ | | -ស្តាប់ ហើយ កត់ត្រា |
| | <u>ពិភាក្សាក្រុម</u> | |
| -ចែកសិស្សជា៤ក្រុមពិភាក្សា | | -ចូលតាមក្រុម |
| ១.ដើម្បីជ្រើសរើសអាជីពមួយបានត្រឹមត្រូវតើអ្នកត្រូវធ្វើដូចម្តេច? | -ត្រូវសង្កេតពិចារណា ពិគ្រោះយោបល់ជាមួយអ្នកអប់រំមាតាបិតាឬអាណាព្យាបាលរបស់ខ្លួន ។ | -សង្កេត ពិចារណា ពិគ្រោះយោបល់ជាមួយអ្នកអប់រំមាតា បិតាជាដើម។ |
| ២.តើអាជីបឬមុខរបរគ្រប់ប្រភេទសុទ្ធតែល្អមែនឬទេ? ចូររៀប់រាប់ពីមុខរបរសុចរិតឲ្យបានប្រាំ ? | -អាជីពឬមុខរបរគ្រប់ប្រភេទមិនសុទ្ធតែល្អនោះទេ។ មុខរបរសុចរិតគ្រូបង្រៀន គ្រូពេទ្យ ចៅក្រម មេធាវី បសុពេទ្យ។ | -អាជីព ឬ មុខរបរគ្រប់ប្រភេទមិនសុទ្ធតែល្អនោះទេ។គ្រូបង្រៀន គ្រូពេទ្យ ចៅក្រម មេធាវី បសុពេទ្យ |
| -៣.តើអាជីពបានផ្តល់ប្រយោជន៍អ្វីខ្លះដល់មនុស្ស? | -អាជីពផ្តល់ប្រយោជន៍ដល់មនុស្សដូចជា គ្រួសារ សហគមន៍ និងសង្គមទាំងមូល ។ | -អាជីពផ្តល់ប្រយោជន៍ដល់គ្រួសារ សហគមន៍ និងសង្គមទាំងមូល ។ |
| -ចូរប្អូនបកស្រាយពីប្រយោជន៍របស់គ្រូបង្រៀន? | -គ្រូបង្រៀនមានតួនាទីសំខាន់ក្នុងការផ្តល់ចំណេះដឹងចំណេះធ្វើដល់សិស្សគ្រប់កម្រិតនិងអប់រំពួកគេឲ្យក្លាយទៅជាពលរដ្ឋល្អដែលជាអ្នកបន្តវេនដឹកនាំប្រទេសជាតិទៅថ្ងៃក្រោយ។ | -គ្រូបង្រៀនផ្តល់ចំណេះដឹងចំណេះធ្វើអប់រំមនុស្សពួកគេឲ្យក្លាយទៅជាពលរដ្ឋល្អ ដែលជាអ្នកបន្តវេនដឹកនាំប្រទេសជាតិ ។ |
| -គ្រូសំយោគនិងឲ្យសិស្សកត់ត្រានិងឲ្យសិស្សសាក | | -ស្តាប់ និង កត់ត្រា |
| | <u>មេរៀនសង្ខេប</u> | |
| -ល្បងទាញមេរៀនសង្ខេប<br>-គ្រូពន្យល់និងឲ្យសិស្សកត់ត្រា។ | អាជីពមានច្រើនប្រភេទណាស់ដែលទាមទារឲ្យសិស្សគ្រប់រូបស្វែងរកពត៌-មាន អំពីប្រភេទអាជីពនោះឲ្យបាន | -សិស្សទាញយកមេរៀនសង្ខេប |

| | | |
|---|---|---|
| | ច្រើនមុននិងសម្រេចជ្រើសរើសអាជីពណាមួយសំរាប់ខ្លួនទៅអនាគត ។ យ៉ាងណាមិញការជ្រើសរើសអាជីពត្រូវស្របទៅ និង ចំណង់ចំណូលចិត្ត ទេពកោសល្យ សមត្ថភាព ធនធានដែលខ្លួនមាន | -សិស្សស្តាប់និងកត់ត្រា |
| -តើអាជីពបានផ្តល់ប្រយោជន៍អ្វីខ្លះដល់មនុស្ស ?<br><br>**-**ដើម្បីជ្រើសរើសអាជីពមួយបានត្រឹមត្រូវតើអ្នកដឹងអ្វីខ្លះពីអាជីពនោះ? | **ជំហានទី៤**<br>(ពង្រឹងពុទ្ធិ)<br>-អាជីពបានផ្តល់ប្រយោជន៍ដល់មនុស្ស គ្រួសារ សហគមន៍ និង ប្រទេសជាតិទាំងមូល ។<br><br>-ត្រូវសង្កេត ពិចារណា ពិគ្រោះយោបល់ជាមួយអ្នកអប់រំមាតាបិតា ឬ អាណាព្យាបាលរបស់ខ្លួន។ | **-**ផ្តល់ប្រយោជន៍ដល់មនុស្ស គ្រួសារ សហគមន៍ ប្រទេសជាតិទាំងមូល ។<br><br>-ត្រូវអង្កេតពិចារណា ពិគ្រោះយោបល់ជាមួយ អ្នកអប់រំ។ |
| | **ជំហានទី៥**<br>(បណ្តាំផ្ញើ និង កិច្ចការផ្ទះ)<br>តើអាជីពអ្វីដែលប្អូនពេញចិត្តជាងគេទៅអនាគត? ហេតុអ្វី? | -សិស្សកត់ត្រា |

# កិច្ចតែងការបង្រៀន

- កាលបរិច្ឆេទ : ថ្ងៃ ទី ខែ ឆ្នាំ
- មុខវិជ្ជា : សីលធម៌-ពលរដ្ឋវិជ្ជា
- ថ្នាក់ទី : ៧
- **ជំពូកទី៥ : ការកំណត់គោលដៅសម្រាប់ជីវិត**
- **មេរៀនទី៣ : ព័ត៌មានអំពីអាជីព (តចប់)**
- វិធីសាស្ត្របង្រៀន : គោលវិធីសិស្សមជ្ឈមណ្ឌល (ពិភាក្សាក្រុម)
- រយៈពេល : ២ម៉ោងសិក្សា (សម្រាប់ម៉ោងទី២)

## I. វត្ថុបំណង

- ចំណេះដឹង : រៀបរាប់ពីអត្ថប្រយោជន៍នៃការបណ្តុះបណ្តាលវិជ្ជាជីវៈ បានត្រឹមត្រូវ តាមរយៈការសិក្សាខ្លឹមសារមេរៀន និងការពន្យល់របស់គ្រូ។
- បំណិន : វិភាគពីអត្ថប្រយោជន៍នៃការបណ្តុះបណ្តាលវិជ្ជាជីវៈរបស់អាជីព បានត្រឹមត្រូវតាមរយៈការពិភាក្សាក្រុម។
- ឥរិយាបថ : បណ្តុះស្មារតីសិស្សឱ្យខិតខំរៀនសូត្រ ព្យាយាមក្នុងការរៀនសូត្រ និង ក្នុងអាជីព។

## II. ខ្លឹមសារមេរៀន

3. **តម្រូវការនៃការបណ្តុះបណ្តាល**

## III. សម្ភារឧបទេស

- សៀវភៅសិស្សទំព័រ ២២៤ បោះពុម្ពឆ្នាំ ២០១១
- ប័ណ្ណសំណួរ
- ផ្ទាំងមេរៀនសង្ខេប

IV. **ដំណើរការបង្រៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -ពិនិត្យលើ: សណ្តាប់ធ្នាប់ អវត្តមាន អនាម័យ។ | **ជំហានទី១**<br>(រដ្ឋបាលថ្នាក់)<br>• សណ្តាប់ធ្នាប់<br>• អនាម័យ<br>• អវត្តមាន<br>• ពង្រឹងវិន័យ។ | -ប្រធានថ្នាក់ឡើងរាយការណ៍។ |
| -តើកាលពីម៉ោងមុនយើងបានសិក្សាពីមេរៀនអ្វី?<br>-ដើម្បីជ្រើសរើសអាជីពមួយបានត្រឹមត្រូវ តើអ្នកត្រូវធ្វើដូចម្តេច?<br><br>-ដើម្បីទទួលបានការងារល្អតាមការស្រម៉ៃ តើមនុស្សម្នាក់ៗត្រូវទៀមទារអ្វី? | **ជំហានទី២**<br>(រំឭកមេរៀនចាស់)<br>មេរៀនទី៣: ព័ត៌មានអំពីអាជីព<br><br>-ត្រូវគិតពិចារណា ពិគ្រោះយោបល់ជាមួយមាតាបិតា ឬអាណាព្យាបាល។<br><br>**ទំនាក់ទំនងមេរៀនថ្មី**<br>-ទៀមទាការបណ្តុះបណ្តាលជំនាញ។ | មេរៀនទី៣: ព័ត៌មានអំពីអាជីព<br><br>-ត្រូវគិតពិចារណា ពិគ្រោះយោបល់ជាមួយមាតាបិតា ឬអាណាព្យាបាល។<br><br>-ទៀមទាការបណ្តុះបណ្តាលជំនាញ។ |
| -ឱ្យសិស្សបើកសៀវភៅទំព័រ ២២៨អានចំណងជើងមេរៀនរួចគ្រូសរសេរដាក់លើក្តារខៀន<br><br>-តើចំណងជើងមេរៀននេះមានន័យដូចម្តេច?<br><br>-ឱ្យសិស្សអានខ្លឹមសារមេរៀន ទំព័រ ២២៨<br><br>-គ្រូសរសេរពាក្យពិបាកដាក់លើក្តារខៀនរួចឱ្យសិស្សឡើងពន្យល់ន័យ | **ជំហានទី៣**<br>(មេរៀនប្រចាំថ្ងៃ)<br>មេរៀនទី៣:<br>ព័ត៌មានអំពីអាជីព (តចប់)<br>3. តម្រូវការនៃការបណ្តុះបណ្តាល<br>-ចំណងជើងមេរៀននេះមានន័យថាជាការហ្វឹកហាត់ផ្នែកជំនាញនានា។<br>(ខ្លឹមសារមេរៀនទំព័រ ២២៨)<br><br>**ពន្យល់ពាក្យ**<br>-សមត្ថភាព (ន): ភាពដែលអាចធ្វើអ្វីមួយទៅបាន។ | -សិស្សអានចំណងជើងមេរៀនរួចសរសេរដាក់ក្នុងសៀវភៅ<br><br>-ចំណងជើងមេរៀននេះមានន័យថាជាការហ្វឹកហាត់ផ្នែកជំនាញនានា។<br>-សិស្សអានខ្លឹមសារមេរៀន<br><br>-សិស្សឡើងពន្យល់ន័យ<br>-សិស្សកត់ចូលសៀវភៅ |

| | | |
|---|---|---|
| -គ្រូសម្រួលឱ្យសិស្សកត់ | -សញ្ញាប័ត្រ (ន):<br>ក្រដាសបញ្ជាក់នូវការសិក្សា។ | -សិស្សចូលតាមក្រុមពិភាក្សា |
| -គ្រូបែងចែកសិស្សជា៤ក្រុមៈ | **ពិភាក្សាក្រុម** | |
| -**ក្រុមទី១**: ដើម្បីបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ឬមហាវិទ្យាល័យបាន តើគេត្រូវបញ្ចប់ការសិក្សានៅឯណាជាមុន? | -ដើម្បីបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ឬមហាវិទ្យាល័យបាន តើគេត្រូវបញ្ចប់ការសិក្សានៅសាលាមធ្យមចំណេះទូទៅជាមុនសិន។ | -ដើម្បីបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ឬមហាវិទ្យាល័យបាន តើគេត្រូវបញ្ចប់ការសិក្សានៅសាលាមធ្យមចំណេះទូទៅជាមុនសិន។ |
| -**ក្រុមទី២**: មូលហេតុអ្វីបានជាគេ ចាំបាច់បណ្ដុះបណ្ដាលវិជ្ជាជីវៈបន្ថែម? | -បានជាគេចាំបាច់បណ្ដុះបណ្ដាលវិជ្ជាជីវៈបន្ថែមពីព្រោះដើម្បីហ្វឹកហាត់ បំពាក់បំប៉នទៅលើជំនាញរបស់ខ្លួនឱ្យកាន់តែប្រសើរ។ | -បានជាគេចាំបាច់បណ្ដុះបណ្ដាលវិជ្ជាជីវៈបន្ថែមពីព្រោះដើម្បីហ្វឹកហាត់ បំពាក់បំប៉នទៅលើជំនាញរបស់ខ្លួនឱ្យកាន់តែប្រសើរ។ |
| -**ក្រុមទី៣**:ចូររៀបរាប់ពីមុខជំនាញបរិញ្ញាប័ត្រឱ្យបានប្រាំ។ | -ជំនាញបរិញ្ញាប័ត្រមានៈ<br>• អក្សរសាស្ត្រ<br>• គណិតវិទ្យា<br>• វេជ្ជសាស្ត្រ<br>• នីតិសាស្ត្រ<br>• ឱសថសាស្ត្រ។ | -ជំនាញបរិញ្ញាប័ត្រមានៈ<br>• បរិញ្ញាប័ត្រអក្សរសាស្ត្រ<br>• បរិញ្ញាប័ត្រគណិតវិទ្យា<br>• បរិញ្ញាប័ត្រវេជ្ជសាស្ត្រ<br>• បរិញ្ញាប័ត្រនីតិសាស្ត្រ<br>• បរិញ្ញាប័ត្រឱសថសាស្ត្រ។ |
| -**ក្រុមទី៤**:គេថាកាងារជាឃ្លាំងប្រាក់ តើអ្នកយល់ដូចម្ដេច? | -តាមការយល់របស់សិស្ស | -សិស្សឆ្លើយ |
| -គ្រូឱ្យសិស្សសាកល្បងទាញសង្ខេបមេរៀនឡើងវិញ។ | **មេរៀនសង្ខេប**<br>សិស្សដែលរៀនចប់ និងទទួលបានសញ្ញាប័ត្រមធ្យមសិក្សាចំណេះទូទៅអាចបន្តការសិក្សានៅសាលាបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ឬសាកលវិទ្យាល័យណាមួយតាមគោលបំណងនិងតាមការកំណត់របស់គ្រឹះស្ថានសិក្សានោះ។ដើម្បីទទួលបានមុខជំនាញមួយពិតប្រាកដសម្រាប់ខ្លួនព្រោះគ្រប់ការងារទាំងអស់សុទ្ធតែត្រូវការជំនាញពិតប្រាកដ។ | -សិស្សទាញសង្ខេបមេរៀន |
| -គ្រូឱ្យសិស្សកត់ | | |

| | | |
|---|---|---|
| | | –សិស្សកត់ចូលសៀវភៅ |
| –តើមូលហេតុអ្វីបានជាយើងចាំត្រូវបណ្ដុះបណ្ដាលវិជ្ជាជីវៈបន្ថែម? | **ជំហានទី៤**<br>(ពង្រឹងពុទ្ធិ)<br>–បានជាគេចាំបាច់បណ្ដុះបណ្ដាលវិជ្ជាជីវៈបន្ថែមពីព្រោះដើម្បីហ្វឹកហាត់ បំពាក់បំប៉នទៅលើជំនាញរបស់ខ្លួនឱ្យកាន់តែល្អប្រសើរ។ | –បានជាគេចាំបាច់បណ្ដុះបណ្ដាលវិជ្ជាជីវៈបន្ថែមពីព្រោះដើម្បីហ្វឹកហាត់ បំពាក់បំប៉នទៅលើជំនាញរបស់ខ្លួនឱ្យកាន់តែល្អប្រសើរ។ |
| –ទៅផ្ទះវិញចូរប្អូនខិតខំមើលមេរៀនបន្ថែមទៀតផង។ | **ជំហានទី៥**<br>(កិច្ចការផ្ទះ ឬ បណ្ដាំផ្ញើ)<br>–តើអាជីពអ្វីដែលមានទីផ្សារច្រើននៅក្នុងសហគមន៍របស់អ្នក? ពីព្រោះអ្វី?<br>–តើអ្នកត្រូវធ្វើអ្វីខ្លះនៅពេលនេះដើម្បីជួយអ្នកឱ្យសម្រេចបាននូវគោលបំណងអ្នកនៅពេលអនាគត? | –សិស្សស្ដាប់តាមការណែនាំរបស់គ្រូ និងកត់សំណួរយកទៅធ្វើនៅផ្ទះ។ |

# កិច្ចតែងការបង្រៀន

- ❖ កាលបរិច្ឆេទ : ថ្ងៃ ទី ខែ ឆ្នាំ
- ❖ មុខវិជ្ជា : សីលធម៌-ពលរដ្ឋវិជ្ជា
- ❖ ថ្នាក់ទី : ៧
- ❖ **ជំពូកទី៦** : **ជំនឿសាសនា**
- ❖ **មេរៀនទី២** : **ការអប់រំសំខាន់ៗរបស់ព្រះពុទ្ធសាសនា**
- ❖ វិធីសាស្ត្រ : គោលវិធីសិស្សមជ្ឈមណ្ឌល (ពិភាក្សាក្រុម)
- ❖ រយៈពេល : ២ ម៉ោងសិក្សា (សម្រាប់ម៉ោងទី១)

## I. **វត្ថុបំណង**

- ➢ ចំណេះដឹង : ប្រាប់បានពីការអប់រំរបស់ព្រះពុទ្ធក្នុងការជៀសវាងនូវអំពើអាក្រក់ដប់យ៉ាង ស្គាល់នូវសេចក្តីអាក្រក់បីយ៉ាង បានត្រឹមត្រូវតាមរយៈការសិក្សាខ្លឹមសារមេរៀន និង ការសួរសំណួរបំផុសពីគ្រូ។
- ➢ បំណិន : វិភាគបានពីអំពើអាក្រក់ដប់យ៉ាង (អកុសលកម្មបថដប់) កាយទុច្ចរិតបី វចីទុច្ចរិតបួន មនោទុច្ចរិតបី បានត្រឹមត្រូវតាមរយៈការពិភក្សាក្រុម។
- ➢ ឥរិយាបថ : បណ្តុះស្មារតីឱ្យអ្នកកាន់ព្រះពុទ្ធសាសនាអនុវត្តតាមពុទ្ធវចនៈ និង ប្រព្រឹត្តិតែអំពើល្អ។

## II. **សំភារឧបទេស**

- ▪ ចំពោះគ្រូ : សៀវភៅសិស្ស មេរៀនសង្ខេប ប័ណ្ណសំណួរ ផ្ទាំងរូបភាព
- ▪ ចំពោះសិស្ស : សៀវភៅសិស្ស ប៊ិច សៀវភៅសរសេរ...។

## III. **ខ្លឹមសារមេរៀន**

1. **ការអប់រំរបស់ព្រះពុទ្ធសាសនា**

   1.1. **អំពើអាក្រក់ដប់យ៉ាង** (**អកុសលកម្មបថដប់**) **មនុស្សទាំងអស់ត្រូវជៀសវាង**

   - ក. **អំពើអាក្រក់ដោយកាយបីយ៉ាង** (**កាយទុច្ចរិតបី**)
   - ខ. **អំពើអាក្រក់ដោយវាចាបួនយ៉ាង** (**វចីទុច្ចរិតបួន**)
   - គ. **អំពើអាក្រក់ដោយចិត្តបីយ៉ាង** (**មនោទុច្ចរិតបី**)

## IV. ដំណើរកនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| –ពិនិត្យលើ : អនាម័យ អវត្តមាន ផ្លាកឈ្មោះ សម្លៀកបំពាក់។ | **ជំហានទី១**<br>(រដ្ឋបាលថ្នាក់)<br>• សណ្តាប់ធ្នាប់<br>• អនាម័យ<br>• អវត្តមាន<br>• ពង្រឹងវិន័យ។ | –ប្រធានថ្នាក់ឡើងរាយការណ៍។ |
| –តើកាលពីថ្ងៃមុនយើងបានសិក្សាពីមេរៀនអ្វី?<br>–តើព្រះពុទ្ធជានរណា?<br><br>–តើសាសនាព្រះពុទ្ធមានសារៈសំខាន់ចំពោះប្រជាជនខ្មែរដែរឬទេ? ហេតុអ្វី? | **ជំហានទី២**<br>(រំលឹកមេរៀនចាស់)<br>មេរៀនទី១:<br>ដើមកំណើតព្រះពុទ្ធសាសនា<br>–ជាមនុស្សចេះដឹង អាចប្រោសសត្វលោកឱ្យរួចចាក ផុតពីទុក្ខ។<br><br>**<u>ទំនាក់ទំនងមេរៀនថ្មី</u>**<br>–មាន ឬ មិនមាន<br>–មានព្រោះព្រះពុទ្ធបានទូន្មានប្រៀនប្រដៅអប់រំមនុស្សឱ្យប្រព្រឹត្តិតែអំពើល្អ...។ | –ព្រះពុទ្ធជាមនុស្សចេះដឹង អ្នកប្រាជ្ញអាចប្រោសសត្វលោកឱ្យរួចចាកផុតពីទុក្ខ។<br><br>–មាន ឬ មិនមាន<br>–មានព្រោះព្រះពុទ្ធបានទូន្មានប្រៀនប្រដៅអប់រំមនុស្សឱ្យប្រព្រឹត្តិតែអំពើល្អ។ |
| –ឱ្យសិស្សបើកសៀវភៅទំព័រ 232-233 អានចំណងជើង<br>–គ្រូសរសេរចំណងជើងមេរៀនដាក់លើក្តារខៀន<br><br>–តើចំណងជើងមេរៀនមានន័យដូចម្តេច?<br><br>–តើប្អូនឃើញអ្វីខ្លះក្នុងរូបភាពនេះ? | **ជំហានទី៣**<br>(ដំណើរការមេរៀនថ្មី)<br>**មេរៀនទី២**:<br>**ការអប់រំសំខាន់ៗរបស់ព្រះពុទ្ធសាសនា**<br><br>**សិក្សាចំណងជើង**<br>–ការអប់រំប្រៀនប្រដៅរបស់ព្រះពុទ្ធចំពោះពុទ្ធបរិស័ទឱ្យប្រព្រឹត្តិតែអំពើ ល្អ។<br>–រូបភាពឃើញមាន ព្រះពុទ្ធកំពុងទេសនា<br>ទូន្មានប្រៀនប្រដៅដល់មនុស្សលោក និងប្រោសព្រះ<br>សង្ឃប្រាំអង្គឱ្យរួចចាកផុតទុក្ខ។ | –មានន័យថា ការអប់រំប្រៀនប្រដៅរបស់ព្រះពុទ្ធចំពោះពុទ្ធបរិស័ទឱ្យប្រព្រឹត្តិតែអំពើល្អ។<br>–រូបភាពឃើញមាន ព្រះពុទ្ធកំពុងទេសនា ទូន្មានប្រៀនប្រដៅដល់មនុស្សលោកនិងប្រោសព្រះសង្ឃប្រាំអង្គឱ្យរួចចាកទុក្ខ។ |

| | | |
|---|---|---|
| –តើរូបភាពនិងចំណងជើងមានទំនាក់ទំនងគ្នាឬទេ? ព្រោះអ្វី? | –មានទំនាក់ទំនងនឹងគ្នា ព្រោះរូបភាពឃើញរូបព្រះពុទ្ធកំពុងទេសនា ឬផ្តល់ឱវាទ ឯចំណងជើង"ការអប់រំសំខាន់ៗរបស់ព្រះពុទ្ធសាសនា"។ | –មានទំនាក់ទំនងនឹងគ្នា រូបភាពឃើញរូបព្រះពុទ្ធ ឯចំណងជើង "ការអប់រំសំខាន់ៗរបស់ព្រះពុទ្ធសាសនា"។ |
| | **សិក្សាអត្ថបទ**<br>(ក្នុងរយៈពេល......(មិច្ឆាទិដ្ឋិ)។ | |
| –ឱ្យសិស្សអានខ្លឹមសារមេរៀនបណ្តាក់គ្នា | **ពន្យល់ពាក្យ** | –អានខ្លឹមសារមេរៀនបណ្តាក់គ្នា |
| –សរសេរពាក្យពិបាកលើក្តារខៀន រួចឱ្យសិស្សឡើងពន្យល់ | –និព្វាន្ត (ន) : កន្លែងស្ងប់សុខ រកើតឡើងវិញ។<br>–កាយទុច្ចរិត (ន) : អំពើអាក្រក់ដោយកាយបីយ៉ាង។<br>–វចីទុច្ចរិត (ន) : អំពើអាក្រក់ដោយវាចាបួន<br>–មនោទុច្ចរិត (ន) : អំពើអាក្រក់ដោយចិត្តបីយ៉ាង។ | –ឡើងពន្យល់ន័យ<br>យ៉ាង។<br>: អំពើអាក្រក់ដោយចិត្តបីយ៉ាង។<br>–កត់ចូលសៀវភៅ |
| –សំយោគរួចឱ្យសិស្សកត់ | | |
| | **សកម្មភាពក្រុម** | |
| –ឱ្យសិស្សចូលបួនក្រុមពិភាក្សា | | –ចូលតាមក្រុមពិភាក្សា |
| **–ក្រុមទី១:**ពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះពុទ្ធមានច្រើន មែនតែគេអាចបង្រួមមកបានបីយ៉ាង តើមានអ្វីខ្លះ? | –បង្រួមបានបីយ៉ាងគឺៈ<br>• មិនធ្វើអំពើអាក្រក់គ្រប់បែបយ៉ាង<br>• ការញ៉ាំកុសលឱ្យបានសម្រេច គឺធ្វើតែអំពើល្អ<br>• ការញ៉ាំចិត្តរបស់ខ្លួនឱ្យផូរផង់ គឺត្រូវដុសខាត់ចិត្តរបស់ខ្លួនឱ្យស្អាតជានិច្ច។ | –បង្រួមបានបីយ៉ាងគឺៈ<br>• មិនធ្វើអំពើអាក្រក់គ្រប់បែបយ៉ាង(សព្វបាបស្សអកណំ)<br>• ការញ៉ាំកុសលឱ្យបានសម្រេច គឺធ្វើតែអំពើល្អ(កុសលស្សូបសម្បទា)<br>• ការញ៉ាំចិត្តរបស់ខ្លួនឱ្យផូរផង់ គឺត្រូវដុសខាត់ចិត្តរបស់ខ្លួនឱ្យស្អាតជានិច្ច(សចិត្តបរិយោទបនំ)។ |
| **–ក្រុមទី២:**តើអំពើអាក្រក់ដោយកាយបីយ៉ាង(កាយទុច្ចរិតបី)មានអ្វី | –អំពើអាក្រក់ដោយកាយបីគឺៈ<br>• អំពើបៀតបៀនឬសំលាប់ | –អំពើអាក្រក់ដោយកាយបីគឺៈ<br>• អំពើបៀតបៀនឬសំលាប់ |

| | | |
|---|---|---|
| ខ្លះ? | សត្វមានជីវិត<br>• អំពើកេងបន្លំលួចឬប្លន់ទ្រព្យសម្បត្តិអ្នកដទៃ<br>• អំពើខុសឆ្គងក្នុងផ្លូវកាម លួចប្រពន្ធ ប្ដី កូន ចៅអ្នកដទៃ។ | សត្វមានជីវិត(បាណាតិបាត)<br>• អំពើកេងបន្លំលួចឬប្លន់ទ្រព្យសម្បត្តិអ្នកដទៃ(អទិន្នាទាន)<br>• អំពើខុសឆ្គងក្នុងផ្លូវកាម លួចប្រពន្ធ ប្ដី កូន ចៅអ្នកដទៃ(កាមេសុមិច្ឆាចារ)។ |
| **–ក្រុមទី៣:**តើអំពើអាក្រក់ដោយវាចាបួនយ៉ាង(វចីទុច្ចរិតបួន)មានអ្វីខ្លះ? | –អំពើអាក្រក់ដោយវាចាបួនគឺ៖<br>• ពាក្យសំដីភូតភរឬបញ្ឆោត<br>• ពាក្យសំដីញុះញង់បំបែកបំបាក់<br>• ពាក្យសំដីទ្រគោះបោះបោក ជេរប្រទេច<br>• ពាក្យសំដីរោយរាយឥតប្រយោជន៍។ | –អំពើអាក្រក់ដោយវាចាបួនគឺ៖<br>• ពាក្យសំដីភូតភរឬបញ្ឆោត(មុសាវាទ)<br>• ពាក្យសំដីញុះញង់បំបែកបំបាក់(បិសុណាវាទ)<br>• ពាក្យសំដីទ្រគោះបោះបោក ជេរប្រទេច(ផរុសវាទ)<br>• ពាក្យសំដីរោយរាយឥតប្រយោជន៍(សម្ផប្បលាបវាទ)។ |
| **–ក្រុមទី៤:**តើអំពើអាក្រក់ដោយចិត្តបីយ៉ាង(មនោទុច្ចរិតបី)មានអ្វីខ្លះ? | –អំពើអាក្រក់ដោយចិត្តបីគឺ៖<br>• គំនិតសំលឹងរំពៃចង់បានទ្រព្យសម្បត្តិអ្នកដទៃ<br>• គំនិតបៀតបៀន ចង់ឱ្យអ្នកដទៃដល់ក្ដីវិនាស<br>• គំនិតយល់ខុស ហើយប្រកាន់ឡើងថាជាត្រូវ។ | –អំពើអាក្រក់ដោយចិត្តបីគឺ៖<br>• គំនិតសំលឹងរំពៃចង់បានទ្រព្យសម្បត្តិអ្នកដទៃ(អភិជ្ឈា)<br>• គំនិតបៀតបៀន ចង់ឱ្យអ្នកដទៃដល់ក្ដីវិនាស(ព្យាបាទ)<br>• គំនិតយល់ខុស ហើយប្រកាន់ឡើងថាជាត្រូវ(មិច្ឆាទិដ្ឋិ)។ |
| –គ្រូសំយោគចម្លើយឱ្យសិស្សកត់ចូលសៀវភៅ | | –កត់ចូលសៀវភៅ |
| –ឱ្យសិស្សសាកល្បងទាញមេរៀនសង្ខេប | **មេរៀនសង្ខេប**<br>ព្រះសម្មាសម្ពុទ្ធបានបន្សល់ទុកពាក្យទូន្មានប្រៀនប្រដៅ 84000 ធម្មក្ខន្ធ ចែកជាបីផ្នែកគឺ វិន័យបិដក សុត្តន្តបិដក និង អភិធម្មបិដក។<br>ពាក្យទូន្មានទាំងនោះបង្រួមមកបីយ៉ាងគឺ មិនធ្វើ | –ទាញមេរៀនសង្ខេប |

| | | |
|---|---|---|
| –សម្រួលឱ្យសិស្សកត់ | អាក្រក់ ធ្វើតែអំពើល្អ សម្អាតចិត្តឱ្យស្អាតផូរផង់ព្រមទាំងជៀសវាងអកុសលកម្មទាំង ១០យ៉ាង ដើម្បីបានសេចក្ដីសុខចម្រើន។ | –កត់ដោយស្ងៀមស្ងាត់ |
| –តើការប្រដៅបង្រួមបីយ៉ាងមានអ្វីខ្លះ?<br><br>–តើអកុសលកម្មបថដប់យ៉ាងដែលគួរជៀសវាងបីគឺអ្វី? | **ជំហានទី៤**<br>(ពង្រឹងពុទ្ធិ)<br>–បង្រួមបីយ៉ាងមាន៖<br>• មិនធ្វើអំពើអាក្រក់គ្រប់បែបយ៉ាង<br>• ការញុំាកុសលឱ្យបានសម្រេច គឺធ្វើតែអំពើល្អ<br>• ការញុំាចិត្តរបស់ខ្លួនឱ្យផូរផង់ គឺត្រូវជុសខាត់ចិត្តរបស់ខ្លួនឱ្យស្អាតជានិច្ច។<br>–គួរជៀសវាងបីគឺ៖<br>• អំពើអាក្រក់ដោយកាយបី<br>• អំពើអាក្រក់ដោយវាចាបួន<br>• អំពើអាក្រក់ដោយចិត្តបី។ | –បង្រួមបីយ៉ាងមាន៖<br>• មិនធ្វើអំពើអាក្រក់គ្រប់បែបយ៉ាង<br>• ការញុំាកុសលឱ្យបានសម្រេច គឺធ្វើតែអំពើល្អ<br>• ការញុំាចិត្តរបស់ខ្លួនឱ្យផូរផង់ គឺត្រូវជុសខាត់ចិត្តរបស់ខ្លួនឱ្យស្អាតជានិច្ច។<br>–គួរជៀសវាងបីគឺ៖<br>• កាយទុច្ចរិតបី<br>• វចីទុច្ចរិតបួន<br>• មនោទុច្ចរិតបី។ |
| –ទៅផ្ទះវិញត្រូវមើលមេរៀននេះឡើងវិញ រួមទាំងមើលចំណុចបន្តផង។ ពេលទំនេរជួយធ្វើកិច្ចការផ្ទះ កុំដើរលេងច្រើនពេក។ | **ជំហានទី៥**<br>(បណ្ដាំផ្ញើ)<br>1.2. អំពើល្អដប់យ៉ាង(កុសលកម្មបថដប់) មនុស្សទាំងអស់ត្រូវអនុវត្ត<br>1.3. សេចក្ដីពិតបួនយ៉ាង(ចតុរារិយសច្ច) | –សិស្សស្ដាប់តាមការណែនាំរបស់គ្រូដោយយកចិត្តទុកដាក់ និង អនុវត្តតាម។ |

# កិច្ចតែងការបង្រៀន

- កាលបរិច្ឆេទ : ថ្ងៃ ទី ខែ ឆ្នាំ
- មុខវិជ្ជា : សីលធម៌-ពលរដ្ឋវិជ្ជា
- ថ្នាក់ទី : ៧
- **ជំពូកទី៦** : **ជំនឿសាសនា**
- **មេរៀនទី២** : **ការអប់រំសំខាន់ៗរបស់ព្រះពុទ្ធសាសនា (តចប់)**
- វិធីសាស្រ្ត : គោលវិធីសិស្សមជ្ឈមណ្ឌល (ពិភាក្សាក្រុម)
- រយៈពេល : ២ ម៉ោងសិក្សា (សម្រប់ម៉ោងទី២)

## I. វត្ថុបំណង

- ចំណេះដឹង : ប្រាប់បានពីការអប់រំរបស់ព្រះពុទ្ធក្នុងការប្រព្រឹត្តិអំពើល្អដប់យ៉ាង ស្គាល់នូវសេចក្តីពិតបួនយ៉ាង បានត្រឹមត្រូវតាមរយៈការសិក្សាខ្លឹមសារមេរៀន និង ការសួរសំណួរពីគ្រូ។
- បំណិន : វិភាគបានពីអំពើល្អដប់យ៉ាង(កុសលកម្ម) ចតុរារិយសច្ចៈ មគ្គសច្ចៈ បានត្រឹមត្រូវតាមរយៈសំណួរពិភាក្សាក្រុម។
- ឥរិយាបថ : បណ្តុះស្មារតីសិស្សឱ្យគោរពពុទ្ធសាសនា គោរពពុទ្ធឱវាទ និងប្រព្រឹត្តិតែអំពើល្អ។

## II. សំភារៈ

- ចំពោះគ្រូ : សៀវភៅសិស្ស មេរៀនសង្ខេប ប័ណ្ណសំណួរ ផ្ទាំងរូបភាព
- ចំពោះសិស្ស : សៀវភៅសិស្ស ប៊ិច សៀវភៅសរសេរ...។

## III. ខ្លឹមសារមេរៀន

